វិធីប្រែបាលី

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៥៣៧

២២៥.
៧/២
LIBRARY
BUDDHIST INSTITUTE
www.budinst.gov.kh www.elibraryofcambodia.org

ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
ពុទ្ធសាសនបណ្ឌិត្យ និង បណ្ណាល័យអេឡិចត្រូនិចខ្មែរ
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
អង្គការរីស្ស៊ូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ
ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

២២៥.៧២

វិធីប្រែបាលី

អ្នករៀបរៀង

ឃុន សុវត្ថិវេទី យូរ អ៊ុន

អតីតក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

បោះពុម្ពលើកទី ៥ ចំនួន ២០០០ ច្បាប់

LIBRARY
BUDDHIST INSTITUTE

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៣៧ គ.ស ១៩៩៣

១៤១៥/៩៥

06-12

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីបញ្ជាក់

ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " វិធីប្រែបាលី " សម្រាប់សិស្សសាលាពុទ្ធិកបឋមសិក្សា ត្រូវបានថតចម្លង និងបោះពុម្ពឡើងវិញ ដោយមានការឧបត្ថម្ភពីអង្គការជំនួយស្មូតូស្ទិជប៉ុន (JSRC) និងពីអង្គការ វិស្សាកូសី-កែ ។

គោលបំណងនៃការបោះពុម្ពផ្សាយឡើងវិញ គឺសំដៅ :

- ផ្តល់អោយសិស្ស និងគ្រូ មានឧបករណ៍សម្រាប់ស្រាវជ្រាវយ៉ាងល្អប្រសើរ ពោលគឺ មានមធ្យោបាយប្រែបាលីលោតប្រយោគ ដោយខ្លួនឯង បានត្រឹមត្រូវ និងឆាប់រហ័ស,

- រក្សាមតិកវប្បធម៌ អក្សរសាស្ត្រសាសនា អក្សរសាស្ត្រជាតិ អោយគង់វង្សឡើងវិញ និងរីកចំរើន,

- ពង្រីកចំណេះចេះដឹងខាងភាសាបាលី ដែលជាចំណែកមួយ ជួយទ្រទ្រង់ភាសា អក្សរសាស្ត្រ និងការប្រតិបត្តិពុទ្ធសាសនា ក្នុងភាពបរិសុទ្ធ ត្រឹមត្រូវ ក្នុងចំណោមពុទ្ធមាមកជន ទាំងនៅទីក្រុង ទាំងនៅជនបទ ។

សូមឧទ្ទិសសៀវភៅ " វិធីប្រែបាលី " នេះ ចំពោះការរីកចំរើនស្មារតីសិក្សា, ស្មារតីស្រឡាញ់ និងលើកស្ទួយអក្សរសាស្ត្រ និង សីលធម៌ពុទ្ធ-សាសនាក្នុងការរស់នៅ ហើយជាពិសេស ស្មារតីបង្រួបបង្រួមជាតិ ដើម្បីសុខសន្តិភាពដ៏ស្ថិតស្ថេរនៅកម្ពុជា !

សូមពុទ្ធសាសនា បានចំរើនរុងរឿងស្ថិតស្ថេរ ជាស្ថាពរ !

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈកម្មាធិការជំនួយស្មូតូស្ទិជប៉ុន និងអង្គការវិស្សាកូសី-កែ ដែលបានជួយឧបត្ថម្ភយ៉ាងឧត្តុង្គឧត្តមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩៣

ពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org

ごあいさつ

この本は、立正佼成会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committee with the contribution from

RISSHO KOSEI-KAI

We pray that this book would contribute to the friendship with Cambodian people and their cultural preservation.

និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន (JSRC) ដោយមានការឧបត្ថម្ភពី

អង្គការរិស្សូកូសី-កៃ

យើងខ្ញុំអធិដ្ឋាន សូមអោយសៀវភៅនេះ បានជាវិភាគទានរក្សាមិត្តភាព ជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

www.budinst.gov.kh www.elibraryofcambodia.org

អារម្ភកថា

សៀវភៅ **វិធីប្រែបាលី** នេះខ្ញុំបានបោះពុម្ពផ្សាយជាលើកដំបូង តាំងពីឆ្នាំ ១៩៥០ មកម៉្លេះ ។ បន្ទាប់មកខ្ញុំបានបោះពុម្ពលើកទី ២ ឡើងទៀត ក្នុងឆ្នាំ ១៩៦៥; ឥឡូវនេះ សៀវភៅនោះ ផ្សាយចេញអស់ហើយ ទើបខ្ញុំចាត់ការបោះពុម្ព លើកទី ៣ ឡើងទៀតក្នុងឆ្នាំ ១៩៧០ ។ ការណ៍ដែលនាំឲ្យខ្ញុំបោះពុម្ពឡើងនេះ ព្រោះមានសិក្ខាកាមកុលបុត្រជាច្រើនរូប បានសួររកនូវសៀវភៅនេះ ព្រមទាំងបានបង្ខំឲ្យខ្ញុំបោះពុម្ពឡើងជាថ្មី ។

តាមពិត សៀវភៅវិធីប្រែបាលីនេះ ទុកដូចជាគាំជាភាគទី ២ អំពីគាំទី ១ គឺ វេយ្យាករណ៍បាលី ព្រោះថាចំនៀមរៀនភាសាបាលី នៅប្រទេសខ្មែរយើង មុនដំបូងត្រូវរៀនវេយ្យាករណ៍បាលី, លុះសិក្សាវេយ្យាករណ៍បាលីចប់ហើយ គេទៅត្រូវរៀនប្រែនូវគម្ពីរធម្មបទដ្ឋកថា ។ ការណ៍ដែលនឹងប្រែគម្ពីរត្រឹមត្រូវទៅបាន អាស្រ័យមកពីការចេះយាំយល់ នូវវិធីប្រែបាលី ។ ព្រោះហេតុនោះ សៀវភៅវិធី

www.budinst.gov.kh www.elibraryofcambodia.org

ប្រែបាលី នៃខ្ញុំនេះ ទុកដូចជាប្រទីបមួយ សម្រាប់បំភ្លឺផ្លូវនៃអ្នកសិក្សាថ្មី ឲ្យមានសតិបញ្ញាភ្លឺថ្លា ឈ្លាសវៃក្នុងការប្រែបាលី បានត្រឹមត្រូវជាប្រាកដ ។

មួយទៀត សៀវភៅវិធីប្រែបាលីនេះ បានទទួលកិត្តិយស មានគេកោតឈ្មោះថាជាសៀវភៅឯក ខាងពន្យល់របៀបប្រែបាលីគ្មានសល់ចន្លោះវិធីណាសោះទេ ។ ព្រោះថាតាំងពីឆ្នាំ ១៩៥០ ជាឆ្នាំដែលសៀវភៅនេះ ប្រសូតចេញមក រៀងរហូតមកដល់ឆ្នាំនេះ ខ្ញុំតែងបានទទួលញឹកញយ នូវសេចក្តីសរសើរសៀវភៅនេះ អំពីសំណាក់បណ្ឌិតទាំងឡាយ មានព្រះអាចារ្យនៃសាលាពុទ្ធិកបឋមសិក្សាជាដើម ។

មុននឹងបោះពុម្ពលើកទី ៣ នេះ ខ្ញុំបានយកសៀវភៅនេះ ១ ក្បាលមកធ្វើជាច្បាប់សម្រាប់បោះពុម្ព ហើយខ្ញុំពិនិត្យកែតម្រូវត្រង់ដែលបោះពុម្ពលើកទី ២ មានការភ្លាត់ភ្លាំង ព្រមទាំងបានកែសម្រួលពាក្យខ្លះ ឲ្យរឹងរឹតតែពីរោះស្តាប់ ងាយ

យល់ឡើងទៀត ។ មិនតែប៉ុណ្ណោះ ត្រង់ខាងដើម នៃសេចក្តីអធិប្បាយ វិធីមួយ ៗ ខ្ញុំបានកែសម្រួលឲ្យទៅជាមេខ្ទេញ ។ ត្រង់មេខ្ទេញមួយ ៗ មានដឹកបន្ទាត់ព័ទ្ធជុំវិញ ទុកជាសំគាល់ ដើម្បីឲ្យអ្នកសិក្សាថ្នឹកខ្ទេញចាំមាត់ ។

រួមសេចក្តីទៅ **សៀវភៅវិធីប្រែបាលី** ដែលបោះពុម្ពលើកទី ៣ នេះ មានរបៀបរៀបចំ ល្អវិសេស ប្លែកឆ្ងាយជាងកាលបោះពុម្ពលើកទី ២ ។

ភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៧០ ។

ឃុន សុវត្ថិវេទី - យូរអ៊ុន

www.budinst.gov.kh www.elibraryofcambodia.org

សុភាសិតខ្ញុំ

ប្រាប់ឱនទាល់ ជប់ទាល់ កុំឱយទាល់គំនិត

ប្រាប់ប្អូនគិត ជប់គិត កុំគិតមេឃដី

ប្រាប់ប្អូនធ្វើ ជប់ធ្វើ កុំធ្វើការអប្រិយ

ប្រាប់ប្អូនស្ដី ជប់ស្ដី កុំស្ដីពាក្យអសុរោះ ។

កុំធ្វើខ្លួនឲ្យចូលក្នុង សុភាសិតថា :

ដំបូលផ្ទះ ឆ្ងាយជាងដំបូលផ្សារ (១)

គូថភរិយា ជិតជាងធាតុម្ដាយឪពុក (២) ។

១ យកផ្សារជាផ្ទះ ។ ២ គិតតែកូនប្រពន្ធ ម្ដាយឪពុកបំភ្លេច ។

យូរ - អ៊ុន

www.budinst.gov.kh www.elibraryofcambodia.org

កថាមុខ

បុព្វហេតុដែលនាំឲ្យខ្ញុំរៀបរៀងសៀវភៅ «វិធីប្រែបាលី» នេះ ដូចមានសេចក្ដីពណ៌នាតទៅនេះ ៖

កាលនៅថ្ងៃសៅរ៍ ៤ កើត ខែអាសាឍ ឆ្នាំខាល សម្រឹទ្ធិស័ក ព. ស. ២៤៨១ ពួកពុទ្ធបរិស័ទ ធ្វើបុណ្យសម្ពោធបើកសាលាបាលីរង វត្តឧណ្ណាលោម, បន្ទាប់ពីថ្ងៃនោះមក ព្រះតេជព្រះគុណ ព្រះឧត្តមមុនី អ៊ុម-ស៊ូរ បានចាត់ប្រើរូបខ្ញុំ (កាលនៅជាភេទបព្វជិតនោះ) ឲ្យធ្វើជាអាចារ្យបង្រៀនបរិយត្តិនៅសាលាបាលីរង វត្តឧណ្ណាលោម ។ កាលដែលខ្ញុំបង្រៀនសិស្សប្រែគម្ពីរធម្មបទដ្ឋកថា មួយលើក ៗ, ខ្ញុំបានឆ្លៀតពន្យល់បំភ្លឺសិស្ស នូវវិធីប្រែបាលី ដើម្បីឲ្យសិស្សកំណត់គោលសំគាល់របៀបក្នុងការប្រែបាលីបន្តិចៗ បណ្ដើរៗ, រាល់ៗថ្ងៃ. មិនតែប៉ុណ្ណោះ ខ្ញុំបានឲ្យសិស្ស ចម្លងគោលខ្លះ ៗ ដែលខ្ញុំបំប្រួញទុក ៗ ល្មមតែសិស្សទន្ទេញចាំមាត់ស្ទាត់បានហើយ ។ ពួកសិស្សបរិយត្តិ

www.budinst.gov.kh www.elibraryofcambodia.org

ជំនាន់នោះ សព្វាយចិត្តក្នុងការរៀនជាអនេក ដោយហេតុ បានក្តីស្មាន បាត់ស្រពាំង ក្នុងលទ្ធិភាសាបាលី ដោយអន្ទៀ ៗ មានសិស្សខ្លះ ដោយអំណាចចង់ចេះដឹងឲ្យជ្រៅទូលាយទៅទៀត បាននិយាយសុំឲ្យខ្ញុំរៀបរៀងពោះពុម្ពនូវវិធីនោះ ៗ ឡើង ៗ ចំណែកខ្ញុំ ក៏បានផ្គងគំនិតជាយូរមកហើយដែរ ថានឹងរៀបរៀងសៀវភៅនេះ ទុកជាក្បួនប្រែគម្ពីរបាលី ដើម្បីសម្រួលអ្នកស្រេកឃ្លាន ក្នុងការសិក្សាបាលី, មួយទៀត ដោយយល់ឃើញថាបើសៀវភៅនេះកើតឡើង គង់ជាប្រយោជន៍ក្នុងការជួយដំណើរវិជ្ជា នៃអ្នកសិក្សាបាលី ឲ្យមានការចេះដឹងឆាប់រហ័ស ទុកដូចជាមានអាចារ្យតាមពន្យល់ជាប់ជានិច្ចផង ៗ អាស្រ័យហេតុនេះហើយ បានជាកន្លងវេលាមក មិនយូរប៉ុន្មាន ខ្ញុំក៏បានផ្តើមរៀបរៀងឡើង ៗ មុននឹងរៀបរៀង ខ្ញុំយកបែបរបស់លោកណាបណ្ឌិតមកមើលធៀបគ្នា នឹងបែបដែលខ្ញុំបានរៀនចេះតាំង អំពីសំណាក់នៃលោកគ្រូអាចារ្យ ៗ

ក្នុងវគ្គនៃសៀវភៅនេះ ពោលចំពោះតែវិធីប្រែភាសាបាលីដោយច្រើន ជាវិធីធំខ្លះ តូចខ្លះ, បូករួមទាំងអស់ ៦៦ វិធីកប់ទាំងវិធីតែងភាសាបាលី និង វិធីរៀបសព្ទបាលីនិងសំស្រឹតផង ។ តែក្នុងខាងដើមនៃសៀវភៅនេះ ខ្ញុំរៀបរៀងចំណាមតាថារបស់សម្តេចព្រះមហាសុមេធាធិបតី **ជួន-ណាត** សង្ឃនាយកគណៈមហានិកាយ ទ្រង់និពន្ធទុកសម្រាប់សិស្សសាលាបាលីរង តាំងពីកាលនៅជាព្រះសា-សនសោភ័ណ ។ កាលរៀបរៀងចប់ហើយ ខ្ញុំយកទៅថ្វាយសម្តេច ដូចមានព្រះនាមខាងលើនេះសូមឲ្យទ្រង់ជួយពិនិត្យផ្ទៀងផ្ទាត់ ។ ឯសម្តេច ក៏ទ្រង់ព្រះមេត្តាប្រោសពិនិត្យតែ តាមសព្វព្រះហឫទ័យ គ្មានសល់ចន្លោះវិធីណាឡើយ ដោយទ្រង់សព្វព្រះទ័យណាស់នឹងវិធីប្រែបាលីនេះ ។

បុព្វហេតុដែលនាំឲ្យខកខាន មិនបានបោះពុម្ពសៀវភៅនេះ ព្រោះក្នុងពេលដែលរៀបរៀងចប់ហើយ មានវិបត្តិវិបរិតក្នុងព្រះនគរជាខ្លាំង ដោយចំពេជប៉ុនចូលក្នុងប្រទេស

www.budinst.gov.kh www.elibraryofcambodia.org

យើង ម្ល៉ោះហើយសៀវភៅនេះ ក៏ផុតអស់រយៈកាលជាយូរឆ្នាំ ៗ លុះមកដល់ឆ្នាំខាលទោស័ក គ.ស. ១៩៥០ ទើបមានឱកាសល្អ ខ្ញុំក៏ចាត់ការបោះពុម្ពជាគ្រាដំបូងឡើង ។

ក្នុងទីបំផុតនេះ ខ្ញុំសូមឧទ្ទិសកុសល ដែលកើតអំពីកម្លាំងព្យាយាមរៀបរៀងសៀវភៅនេះ ជូនចំពោះបុព្វការីទាំងឡាយនៃខ្ញុំមានមាតាបិតាជាដើម, ដោយអំណាចកុសលកសីនេះ សូមឲ្យបុព្វការីទាំងនោះ បានសម្រេចសម្បត្តិសុខជាទីគាប់ចិត្ត កុំបីឃ្លៀងឃ្លាតឡើយ !

ថ្ងៃពុធ ៨ កើត ខែជេស្ឋ ឆ្នាំខាលទោស័ក ព.ស. ២៤៩៣

ត្រូវនឹងថ្ងៃ ២៤ ខែឧសភា ឆ្នាំ ១៩៥០ ។

ឃុន សុវត្ថិវេទី យូរ-អ៊ុន

www.budinst.gov.kh www.elibraryofcambodia.org

បញ្ជីមាតិកា

វិធីប្រែបាលី

មាតិកានុក្រម	ទំព័រ
បណាមគាថា	១
សុខាភិយាចនគាថា	៤
វិធីលើកសព្ទឡើងប្រែ	៧
វិធីប្រែប្រយោគ	១៥
វិធីដើរប្រយោគ	២៧
វិធីប្រែរូប	៣៤
វិធីវិបល្លាស	៦០
វិធីយោគសព្ទនាម	៧៦
វិធីប្រែការ-សព្ទ	៧៨
វិធីប្រែវិសេសនៈ	៨០
វិធីប្រែវិកតិកត្តា	៨៩

www.budinst.gov.kh www.elibraryofcambodia.org

មាតិកានុក្រម	ទំព័រ
វិធីផ្លាស់ប្រយោគ	១០៨
វិធីរកសព្ទអញ្ញបទ	១៣១
វិធីប្រែប្រយោគឧបមា	១៤១
ប្រយោគបការៈ និង កិរិយាវិសេសនៈ	១៦៦
បកិណ្ណកវិធី	១៧០
លក្ខណៈសព្ទមានឧបសគ្គ	១៩៤
វិធីរកគ្គូកត្ថាក្នុងគម្ពីរនានា	១៩៧
គោលប្រែអដ្ឋកថា	១៩៨
វិធីសង្កេតគោលប្រែអដ្ឋកថា	២០៧
វិធីប្រែអដ្ឋកថាពិសេស	២២៧
វិធីប្រែប្រយោគបុច្ឆា	២៣១
វិធីតែងភាសាបាលី	២៣៦
សព្ទបាលីធៀបសព្ទសំស្រ្កឹត	២៦០

www.budinst.gov.kh www.elibraryofcambodia.org

បណាមគាថា

សម្រាប់សិស្សសាលាពុទ្ធិកបឋមសិក្សាសូត្រមុនរៀន

ពុទ្ធោ មហេសិ អរហំ តថាគតោ

លោកុត្តមោ សព្វគរូហិ ជេដ្ឋកោ

លោកស្ស សត្ថា ជនទម្មកោវិទោ

វន្ទាមហំ តំ នរបូជនេយ្យកំ

ព្រះតថាគត (អង្គឯណា) ទ្រង់ត្រាស់ដឹងនូវចតុរារិយ-សច្ច ទ្រង់ស្វែងរកនូវគុណដ៏ធំមានសីលគុណជាដើម ទ្រង់ឆ្ងាយចាកសឹកសត្រូវ គឺកិលេសព្រមទាំងវាសនាហើយ ទ្រង់ឧត្តមបំផុតជាងសត្វលោក ទ្រង់ជាចម្បងជាងពួកគ្រូទាំង-អស់ ទ្រង់ជាសាស្តានៃសត្វលោក ទ្រង់ឈ្លាសវៃក្នុងការទូន្មាននូវពួកជន, ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះតថាគតអង្គនោះ ទ្រង់គួរដល់ការបូជារបស់ពួកជន ។

ធម្មោ បទីបោ វិយ តស្ស សត្ថុនោ

លោកានមន្ធស្ស វិនាសការកោ

www.budinst.gov.kh www.elibraryofcambodia.org

សព្វញ្ញុពុទ្ធប្បដិត្ថូតិ សញ្ញតោ
វន្ទាមហំ តំ នរបូជនេយ្យំ

ព្រះធម៌ (ឯណា) ដូចជាប្រទីប ជាធម៌របស់ព្រះសា-ស្តាអង្គនោះ ជាធម៌ធ្វើនូវសេចក្ដីងងឹតគឺមោហៈ របស់សត្វលោកទាំងឡាយឲ្យវិនាសបាត់ទៅ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ សំគាល់ទុកថាជាតំណាងអង្គនៃព្រះសព្វញ្ញុពុទ្ធ, ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌នោះ ជាធម៌គួរដល់ការបូជារបស់ពួកជន ។

សង្ឃោ វិសុទ្ធោ សុគតស្ស សាវកោ
សិក្ខាសុ ការោ វរធម្មសិក្ខកោ
និព្វាបសំសារិអនាគរោ វរោ
វន្ទាមហំ តំ នរបូជនេយ្យំ

ព្រះសង្ឃ (ឯណា) បរិសុទ្ធវិសេស ជាសាវ័ករបស់ព្រះសុគត លោកមានសេចក្ដីប្រាថ្នាក្នុងសិក្ខាទាំងឡាយ (មាន

www.budinst.gov.kh www.elibraryofcambodia.org

សីលសិក្ខាជាដើម) លោកសិក្សានូវធម៌ដ៏ប្រសើរ ជាព្រះសង្ឃមិនអើពើចំពោះលោកធម៌ទាំង ៨ មានសេចក្តីខិតខំ សេចក្តីសរសើរជាដើម ជាព្រះសង្ឃប្រសើរ, ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃនោះ ជាព្រះសង្ឃគួរដល់ការបូជា របស់ពួកជន ។

នមក្ការានុភាវេន ចឡ្យតុ ពុទ្ធសាសនំ
សមគ្គោ ហោតុ សង្ឃោ ច សុខីហោន្តុ ច សាធវោ

ដោយអានុភាព នៃកិរិយានមស្ការថ្វាយបង្គំ (នេះ) សូមឲ្យព្រះពុទ្ធសាសនាចម្រើន រុងរឿងផង។ សូមឲ្យព្រះសង្ឃព្រមព្រៀងគ្នាផង ។ សូមឲ្យសប្បុរសទាំងឡាយមានសេចក្តីសុខផង ។

រតនត្តយតេជេន សិក្ខា មេ ឯកុ ចឡ្យនំ
តស្សាបិ អានុភាវេន សហសាយេវ សិជ្ឈតុ

ដោយតេជះនៃព្រះរតនត្រ័យ សូមឲ្យការសិក្សារបស់ខ្ញុំដល់នូវសេចក្តីចម្រើន។ មួយទៀត ដោយអានុភាពនៃព្រះរតនត្រ័យ

www.budinst.gov.kh www.elibraryofcambodia.org

នោះ សូមឲ្យការសិក្សារបស់ខ្ញុំ សម្រេចស្រេចទាន់ពេល !

រោគា ចេទន្តរាយា ច ឧប្បន្នា ចេ ឧបទ្ទវា

ពុទ្ធាទិអានុភាវេន វិនស្សន្តុអសេសតោ

បើរោគទាំងឡាយក្តី អន្តរាយទាំងឡាយក្តី ឧបទ្រពទាំងឡាយក្តី កើតឡើងហើយ ក៏សូមឲ្យវិនាសសាបសូន្យទៅ កុំបីមានសេសសល់ឡើយ ដោយអានុភាពនៃព្រះត្រៃរ័ត្ន មានពុទ្ធរ័ត្នជាដើម !

សុខាភិយាចនគាថា

សម្រាប់សិស្សសាលាពុទ្ធិកបឋមសិក្សាសូត្រក្រោយរៀន

ពុទ្ធំសុមាលី និបទុក្កមោ តមោ

ហន្ត្វាន ពោធេសិធ បទ្ធជំ កជំ

មគ្គគ្គសេលម្ហិ សុខុដ្ឋិតោ ឋិតោ

សោ មំ ចិរំ បាតុ សុខំ សទា សទា

ព្រះពុទ្ធដូចជាព្រះអាទិត្យ ទ្រង់ឧត្តមបំផុតជាងសត្វទ្វេបាទ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់កំចាត់បង់នូវងងឹតគឺមោហៈបានហើយ ទ្រង់ចេញផុតស្រឡះ (ចាកគ្រឿងសៅហ្មងហើយ) ទ្រង់ឋិតនៅលើភ្នំដ៏ប្រសើរ គឺអរហត្តមគ្គ ទ្រង់ដាស់ពួកសត្វដែលកើតអំពីកក់គឺកិលេស ក្នុងលោកនេះឲ្យភ្ញាក់រលឹកហើយ; សូមទ្រង់រក្សានូវខ្ញុំព្រះអង្គ ឲ្យបានសេចក្ដីសុខ សព្វៗកាល ជាយូរអង្វែងទៅ ។

សុភាសិត

បើខ្លាច នឹងស្លាប់

បើចាប់ ចាប់ឱ្យជាប់

បើងាប់ ងាប់ដោយគស្ញ

យូរ អ៊ុន

www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
LIBRARY
BUDDHIST INSTITUTE

វិធីប្រែបាលី

ការប្រែភាសាបាលី ត្រូវប្រកបដោយវិធី ដូចតទៅនេះ

១– វិធីលើកសព្ទឡើងប្រែ

មុននឹងលើកបទឬសព្ទ ក្នុងប្រយោគមួយៗ ឡើងប្រែ អ្នកប្រែគួរពិចារណាឲ្យដឹងមុនថា ជាប្រយោគអ្វី ជាកត្តុ, កម្មឬភាព, លុះស្គាល់ច្បាស់ហើយ តពីនោះទៅ គួរពិនិត្យមើលទៀតថា មានលេខក្នុងឬទេ មានឥតិ-សព្ទ ស្ទះសេចក្ដីលេខក្នុងត្រង់ណា; កាលបើយល់ច្បាស់ថា ជាប្រយោគនោះៗ ឬជាយ៉ាងនេះយ៉ាងនោះហើយ ទើបប្រែបាន ។

> ក្នុងការលើកសព្ទឡើងប្រែ គប្បីប្រកាន់គោលយ៉ាងនេះ គឺបទអាលបនៈ ប្រែទី ១, សព្ទនិបាតផ្ដើមសេចក្ដី ប្រែទី២, បទកាលសត្តមី ប្រែទី ៣, បទប្រធាន ប្រែទី៤; បើក្នុងប្រយោគនោះ មិនមានបទអាលបនៈ ត្រូវប្រែសព្ទនិបាតផ្ដើមសេចក្ដី ជាទី ១, បទកាលសត្តមីជាទី ២, បទប្រធានជាទី ៣, បើមិនមានសព្ទនិបាត ត្រូវប្រែបទកាលសត្តមី

www.budinst.gov.kh www.elibraryofcambodia.org

[library stamp]

ជាទី ១, បទប្រធានជាទី ២; បើមិនមានបទកាលសត្តមី ត្រូវប្រែបទប្រធាន ជាទី ១ ។

អធិប្បាយ

អាលបនៈ "ពាក្យសម្រាប់ហៅ" មាន ២ គឺ អាលបននាម ១ អាលបននិបាត ១ ។ ឯអាលបននាម បានដល់បទនាមដែលសម្រេចមកពីអាលបនវិភត្តិ ដូច បុរិស, ភិក្ខវេ ជាដើម ។ អាលបននិបាត បានដល់សព្ទនិបាតដែលចែកតាមវិភត្តិនាមមិនបាន តែមានសេចក្តីជាអាលបនៈ ដូច ភន្តេ, រេ, អរេ, អាវុសោ ជាដើម ។ អាលបនៈទាំង ២ ប្រភេទនេះ ប្រែសាយកនិបាតថា "បពិត្រ, ម្នាល, នែ, ហៃ" ដូចគ្នា ។ បើអាលបននាម មានក្នុងទីជាមួយគ្នាច្រើនបទ កច់តាំងពីពីរបទឡើងទៅ, កាលនឹងប្រែ ត្រូវប្រើបទមួយជាវិសេសនៈរបស់បទមួយ គឺត្រូវយកបទមួយ ប្រែចេញពាក្យអាលបនៈ បទសល់ពីនេះប្រែត្រឹមតែរូបសព្ទ , តែបទដែលប្រែចេញពាក្យអាលបនៈនោះ ត្រូវជាបទនាមនាម , ឯបទដែល

www.budinst.gov.kh www.elibraryofcambodia.org

ប្រែត្រឹមតែរូបសព្ទនោះ ត្រូវជាបទគុណនាមដូចជា **ឯហិប-ស្ស**(១) **នដបុត្ត ឧគ្គសេន មហព្វល** បណ្តាបទទាំងនេះ បទថា នដបុត្តនិងមហព្វល ជាគុណនាម ឧគ្គសេន ជានាម នាម, ត្រូវប្រែ នដបុត្តនិងមហព្វលឲ្យជាវិសេសនៈរបស់ឧគ្គ-សេនថា ‹‹**ឧគ្គសេន** ម្នាលឧគ្គសេន **នដបុត្ត** ជាកូនអ្នករបាំ **មហព្វល** អ្នកមានកម្លាំងច្រើន **ឯហិ** អញ្ជើញ **បស្ស** សូមមើលចុះ" ។ បើកាលបទនិបាត មានក្នុងទីជាមួយគ្នាច្រើន

---

១ បទនេះជាកិរិយាប្រកបដោយបញ្ចមីវិភត្តិ មជ្ឈិមបុរិសដែលមានសេចក្តីចុះក្នុងអនុត្តកាលពីរយ៉ាង គឺអាណត្តិ ឬ អាសិទ្ធិ: ។ ក្នុងភាសាបាលី លោកមិនរៀងដាក់បទប្រធានមកផងទេ លោករៀងទុកតែបទកិរិយាដូចជា តេនហិ តំ អាបុច្ឆាហិ ‹‹បើដូច្នោះ ចូរលាគេទៅ›› តេនហិ ភន្តេ គច្ឆថ ‹‹បពិត្រលោកដ៏ចំរើន បើដូច្នោះសូមនិមន្តចុះ ‹‹គច្ឆាវុសោ "ម្នាលអាវុសោ ចូរទៅចុះ›› ។ ប្រ-យោគបែបនេះ កាលណាប្រែមិនបាច់ដាក់បទប្រធានថា ត្វំឬតុម្ហេក៏បាន គឺប្រែត្រឹមតែកិរិយាសព្ទ និងកាលរបស់វិភត្តិតែប៉ុណ្ណោះ ដើម្បីសម្រួលសេចក្តីទៅតាមភាសានិយម, តែបើសម្ពន្ធ ត្រូវបញ្ចូលបទប្រធាននោះមក ដូចនេះ: នដបុត្តក្តីមហព្វលក្តី វិសេសនៈរបស់ឧគ្គសេន ។ អ.គារវាលបនៈ, ឯហិ-សព្ទ ឧយ្យោជនត្ថ. ត្វំ សយកត្តាក្នុងបស្ស អាខ្យាតបទ កត្តុវាចក: របស់ត្វំ ។

www.budinst.gov.kh www.elibraryofcambodia.org

បទ តាំងពីពីរបទឡើងទៅត្រូវប្រែឲ្យជាអាលបនៈស្មើគ្នា មិនត្រូវប្រែជាវិសេសនៈរបស់គ្នានិងគ្នាទេ ព្រោះអាលបននិបាតក្នុងវេយ្យាករណ៍ លោកមិនបានចាត់ជានាមជាគុណឡើយ ដូចជា **យគ្ឃេ ភន្តេ សង្ឃោ ជានាតុ** យគ្ឃេ និង ភន្តេ ទាំង២ នេះ ជាអាលបននិបាតដូចគ្នា ត្រូវប្រែថា « **យគ្ឃេ** សូមទានមេត្តាប្រោស **ភន្តេ** បពិត្រព្រះករុណាដ៏ចំរើន **សង្ឃោ** ព្រះសង្ឃ **ជានាតុ** សូមជ្រាបចុះ » ។ តែបើអាលបននាមនិងអាលបននិបាត មាននៅក្នុងទីជាមួយគ្នាវិញ ត្រូវប្រែអាលបននិបាតឲ្យជាវិសេសនៈ របស់អាលបននាមដូចជា **អម្ភោ**(១) **កុមារកា ឯស សាលិកបោតកោ តំ គណ្ហថ** អម្ភោជាអាលបននិបាត, កុមារកាជាអាលបននាម, ត្រូវប្រែអម្ភោ ឲ្យជាវិសេសនៈរបស់កុមារកា ថា « **កុមារកា** នែកុមារទាំងឡាយ **អម្ភោ** ហ៊ុយ **សាលិកបោតកោ** កូនសត្វ សាលិកា **ឯសោ** នុ៎ះ **តុម្ហេ** វែងទ.

១ អម្ភោ-សព្ទ វិសេសនៈរបស់កុមារកា ។ អគារវាលបនៈ ។

គណ្ហាថ ចូរចាប់ **គំ** ខ្ញុំ " ។

និបាត សំដៅយកសព្ទនិបាតដែលប្រើផ្តើមសេចក្តី គឺ ហិ, ច, ចន, តុ, អបិច, អថវា, និបាតប្រាប់សេចក្តីបាទព្ទ, ប្រាប់បរិកប្ប, ប្រាប់សេចក្តីទទួល, ប្រាប់សេចក្តីដាស់តឿន ជាដើមដូចជា **តាត មហាល្លកស្ស ហិ អត្តនោ ហត្ថបា-ទាបិ អនស្សវា ហោន្តិ** (អ៊ុប) ‹‹ **តាត** នែប្អូន **ហិ** ព្រោះថា **ហត្ថបាទាអបិ** សូម្បីដៃនិងជើង **អត្តនោ** នៃខ្លួន **មហាល្លកស្ស** របស់បុគ្គលចាស់ **អនស្សវា ហោន្តិ** ជាអវយវៈមិនស្តាប់បង្គាប់ " ។

កាលេសត្តមី ចាត់ជា ៣ គឺ ជានាមសព្ទប្រាប់ពេល.កាល.វេលា.សម័យ ត្រូវគ្នានឹងសព្ទថា សមយេ, វេលាយំ,កាលេ ជាដើម ដែលប្រើក្នុងអត្ថនៃសត្តមីប្រាប់កាល ១, ជានិបាតប្រាប់កាលដូចអថ ជាដើម១ ជាសព្ទនាមដែលប្រកបដោយ ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ,ជ្ជុ,បច្ច័យ ជាគ្រឿងសំគាល់សត្តមីវិភត្តិចុះក្នុងកាល ដូច យទា, តទា, ឥទានិ, អធុនា

www.budinst.gov.kh www.elibraryofcambodia.org

ជាដើម ១ ។ នាមសព្ទប្រាប់កាល ដូចជា **តស្មឹ សមយេ សត្ថា បរិសមជ្ឈេ ធម្មំ ទេសេតិ** (ប្រែ) "**សមយេ** ក្នុងសម័យ **តស្មឹ** នោះ **សត្ថា** ព្រះសាស្ដា **ទេសេតិ** ទ្រង់សំដែង **ធម្មំ** នូវធម៌ **បរិសមជ្ឈេ** ក្នុងកណ្ដាលនៃបរិសទ្យ" ។ និបាតប្រាប់កាល ដូចជា **អថ នំ ថេរោ បុច្ឆិ កោ ឯសោតិ** (ប្រែ) "**អថ** គ្រានោះ **ថេរោ** ព្រះថេរៈ **បុច្ឆិ** សួរហើយ **នំ សក្កំ** នូវព្រះឥន្ទនោះ **កោ ឯសោ ឥតិ** ជាអ្នកណានុ៎ះ" ។ សព្ទនាម ដែលប្រកបដោយបច្ច័យ ដូច **តទា សាវត្ថិយំ សត្ត មនុស្សកោដិយោ វសន្តិ**(១) (ប្រែ) "**តទា** គ្រានោះ **មនុស្សកោដិយោ** កោដិនៃមនុស្សទ. **សត្ត** ប្រាំពីរ **វសន្តិ** នៅហើយ (១) **សាវត្ថិយំ** ក្នុងក្រុងសាវត្ថី" ។

---

១) កិរិយានេះ ប្រាប់បច្ចុប្បន្នកាល, តែក្នុងប្រយោគនេះ មាន តទា សព្ទ រៀងទុកក្នុងខាងដើម ជាគ្រឿងសំគាល់អតីតកាល ទើបត្រូវប្រែកាច់ជាអតីតកាល ។ សូម្បីបទកិរិយាប្រាប់អនាគតកាល បើមានក្នុងទីដូច្នេះ ក៏ឲ្យប្រែកាច់ជាអតីតកាលដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

បទប្រធាន មាន ៦ យ៉ាង គឺ នាមនាម ១, សព្វនាម ១, សមាសនាម ១, តទ្ធិតនាម ១, កិតកនាម ១, បច្ច័យក្នុងកិតកៈ ខ្លះ ដូច ត, អនីយ, តព្វ, តុំ ១ ។ បទប្រធានទាំង ៦ នេះ, លើកតែ តុំ-បច្ច័យ ១ ចេញ, ត្រូវប្រកបដោយបឋមាវិភត្តិ ទាំង ឯកវចនៈ ទាំងពហុវចនៈ ។ នាមនាម ជាបទប្រធាន ដូច **សត្ថា ធម្មំ ទេសេតិ** (ប្រែ) " **សត្ថា** ព្រះសាស្តា **ទេសេតិ** ទ្រង់សំដែង **ធម្មំ** នូវធម៌ ។ សព្វនាមជាបទប្រធាន បានដល់ ត, តុម្ហ, អម្ហ-សព្ទដែលជាបុរិសសព្វនាម ដូច **សោ យាតិ** " គេ ទៅ " **ត្វំ យាសិ** " ឯងទៅ " **អហំ យាមិ** " ខ្ញុំទៅ " សមាសនាម ជាបទប្រធានដូច **កោលិតុប្បតិស្សា សត្ថារំ ឧបសង្កមិត្វា តមត្ថំ អារោចេសុំ** (ប្រែ) " **កោលិតុប្បតិស្សា** កោលិតៈនិងឧបតិស្សៈ ២. **ឧបសង្កមិត្វា** ចូលទៅគាល់ហើយ **សត្ថារំ** នូវព្រះសាស្តា **អារោចេសុំ** ក្រាបទូលហើយ **អត្ថំ** នូវសេចក្តី **តំ** នោះ " ។ តទ្ធិត-

www.budinst.gov.kh www.elibraryofcambodia.org

នាម ជាបទប្រធាន ដូច **ធម្មស្ស សុធម្មតា** "ភាពៈនៃធម៌ល្អរបស់ធម៌" ។ កិតកនាមជាប្រធាន ដូច **សព្វបាប-ស្ស អករណំ** (ប្រែ) "**អករណំ** កិរិយាមិនធ្វើ **សព្វ-បាបស្ស** នូវសេចក្តីអាក្រក់ទាំងពួង" ។

បច្ច័យក្នុងកិតកៈត្តខ្លះដែលជាបទប្រធាន តៈ **សន្តិ គេសំ គតំ** (១) **ឋិតំ** (ប្រែ) "**គតំ** ការដើរ **ឋិតំ** ការឈរ **គេសំ·សមណានំ** របស់សមណៈទ. ពួកនោះ **សន្តិ** ស្ងប់ហើយ" ។ អនីយ ដូច **អម្ហាកំ គេហេ ខាទនីយំ** (២) **វា ភោជនីយំ វា អត្ថិ** (ប្រែ) "**ខាទនីយំ វា** របស់គួរទំពាស៊ីក្តី **ភោជនីយំ វា** របស់គួរបរិភោគក្តី **អត្ថិ** រមែងមាន **គេហេ** ក្នុងផ្ទះ **អម្ហាកំ** របស់យើងទ." ។ តព្វៈ ដូច **ឯទំ អរិយមគ្គញាណគ្គិនាបិ មហន្តានិ ច ខុទ្ទកានិ ច សញ្ញោជនានិ ឌហន្តេន គន្តព្វំ** (៣)

១–២–៣ កិរិយាប្រកប ត, តព្វ, អនីយ–បច្ច័យដែលប្រើជានាមត្រូវប្រែថា "កិរិយា, ការ, ដំណើរ, សេចក្តី" តាមលំនាំភាវសាធនៈ ។ តែ តព្វ,

www.budinst.gov.kh www.elibraryofcambodia.org

គមិស្សតិ (ប្រែ) “អរិយមគ្គញាណគ្គិនាបិ ម-
ហន្តានិ ច ខុទ្ទកានិ ច សញ្ញោជនានិ ឌហ-
ន្តេន គន្តព្វំ កិរិយាគឺបុគ្គល កាលដុត នូវសំយោជនៈ
ធំផង តូចផង សូម្បីដោយភ្លើងគឺអរិយមគ្គញាណ គប្បី
ទៅ គមិស្សតិ ទីងមាន ឯវំ ដោយពិតយ៉ាងនេះ” ។ គុំ-
ដូច ឯវំ មយា កាតុំ ន វដ្ដតិ (ប្រែ) “មយា កាតុំ
ក៏ការដែលអញធ្វើ ឯវំ យ៉ាងនេះ ន វដ្ដតិ ពុំគួរទេ” ។

២- វិធីប្រែប្រយោគ

របៀបនៃពាក្យ ដែលលោករៀបរៀងប្រកបផ្សំ ឲ្យមានបទនាម, គុណ, កិរិយា និងនិបាតសព្ទ ទុកជាសង្កាត់ៗ ហៅថា ប្រយោគ ។

> ប្រយោគក្នុងភាសាបាលី ដែលជាប្រធាន មាន៦យ៉ាងគឺ ប្រយោគកត្តុ, កម្ម, ភាព, អនាទរៈ, លក្ខណៈ, និទ្ធារណៈ។

អនីយ និងបន្សល់ពាក្យថា “គួរ, គប្បី” ទុកផងក៏បាន មិនបន្សល់ទុកក៏បាន, បើបន្សល់ ត្រូវប្រែថា “កិរិយាគឺ ..គួរ.. ការគឺ.. គប្បី ...។

www.budinst.gov.kh www.elibraryofcambodia.org

១- ប្រយោគកត្តុ បទកិរិយាប្រកបបច្ច័យ សម្រាប់កត្តុវាចកៈ,

២- ប្រយោគកម្ម បទកិរិយាប្រកបបច្ច័យ សម្រាប់កម្មវាចកៈ,

៣- ប្រយោគភាព បទកិរិយាប្រកបបច្ច័យ សម្រាប់ភាវវាចកៈ,

៤- ប្រយោគអនាទរៈ បទនាមនិងបទកិរិយា ប្រកបឆដ្ឋីវិភត្តិ,

៥- ប្រយោគលក្ខណៈ បទនាមនិងបទកិរិយា ប្រកបសត្តមីវិភត្តិ,

៦- ប្រយោគនិទ្ធារណៈ បទនាមប្រកបឆដ្ឋីឬសត្តមីវិភត្តិ តែគ្មានកិរិយាទេ ។

អធិប្បាយ

ក្នុងប្រយោគទាំង៦នេះ,អ្នកសិក្សាកាលប្រែបទកាលបទនៈ, និបាត. និងកាលសត្តមី ដែលជាកិច្ចខាងដើមរួចហើយតទៅ

ដែលមិនត្រូវប្រែប្រយោគនោះៗ ត្រូវសង្កេតមើលបទកិរិយាជាមុនសិន ព្រោះកិរិយាជាធំ ក្នុងការប្រាប់ឲ្យយល់ស្គាល់វាចកៈទាំងប្រាប់ឲ្យស្គាល់បុរិសៈ (បទប្រធាន) ដែលជាម្ចាស់នៃកិរិយាជាសយកត្តា, ហេតុកត្តា ឬ ជាវុត្តកម្ម ប្រចាំប្រយោគនោះៗ; កាលបើដឹងជាក់ហើយ ទើបមិនលំបាកក្នុងការប្រែ ។ ត្រូវសង្កេតដូចសេចក្តីតទៅនេះ ៖

១) ប្រយោគកត្តុ មាន ២ គឺ កត្តុវាចកៈ១, ហេតុកត្តុវាចកៈ១ ។ វាចកៈទាំងពីរនោះ កាលបើបទកិរិយាប្រាប់បុរិសៈ (បទប្រធាន) ណា គប្បីលើកបុរិសៈនោះប្រែមុន ហើយប្រែកិរិយានិងបទដែលជាប់ដោយកិរិយា ។ កត្តុវាចកៈ ដូច **បុរិសោ កុសលរាសឹ ឋបេតិ** (ប្រែ) "**បុរិសោ** បុរស **ឋបេតិ** តម្កល់ទុក **កុសលរាសឹ** នូវគំនរនៃកុសល" ។ ហេតុកត្តុវាចក ដូច **សុនខេហិ នំ ខាទាបេស្សាមិ** (ប្រែ) ៈ **អហំ** អញ **សុនខេហិ** ញុំាងឆ្កែទ. **ខាទាបេស្សាមិ**

www.budinst.gov.kh www.elibraryofcambodia.org

ទឹងឲ្យនាំ នំ-ថេរំ នូវព្រះថេរៈនោះ ” ។ នេះកិរិយាអា-ខ្យាត, បើកិរិយាកិតកៈវិញ លោកសម្រេចរូបតាមនាមសព្ទ ដែលជាបទប្រធាន គ្រប់ ៗ បទ ដូច **ខគ្គ រាជគេហេ** **សមុដ្ឋិតំ** (ប្រែ) “ **ខគ្គ** កើរឿងក៏ **សមុដ្ឋិតំ** តាំងឡើង ហើយ **រាជគេហេ** ក្នុងក្រុងរាជគ្រឹះ ” ។

២) ប្រយោគកម្ម មាន ២ គឺ កម្មវាចកៈ ១, ហេតុកម្មវាចកៈ ១ ។ វាចកៈទាំងពីរនេះ, កាលបើកិរិយាប្រាប់បុរសៈណា គប្បីលើកបុរសៈនោះប្រែមុន ហើយប្រែបទអនភិហិតកត្តា គឺបទប្រកបតតិយាវិភត្តិ ត្រង់ប្រែថា “ គឺ, ដែល, ត្រូវ ” តពីនោះទៅទើបប្រែកិរិយា ។ កម្មវាចកៈ ដូច **គុណវិសេសោ អារទ្ធវីរិយេន អធិគច្ឆិយតេ** (ប្រែ) “ **គុណវិសេសោ** គុណវិសេស **អារទ្ធវីរិយេន** គឺលោកអ្នកមានសេចក្តីព្យាយាមតាំងតែង **អធិគច្ឆិយតេ** រមែងបាន ” ។ ហេតុកម្មវាចកៈ ដូច **គុណ-វិសេសោ អារទ្ធវីរិយេន សិស្សេ អធិគច្ឆាបិយ-**

គេ (ប្រែ) ‹‹ **គុណាធិសេសោ** នូវគុណវិសេស **អារទ្ធវីរិ-យេន** គឺលោកអ្នកមានព្យាយាមតឹងរែង **សិស្សេ** ញ៉ាំងសិស្សទ. **អធិគច្ឆាបិយតេ** ឲ្យបាន ›› ។ នេះកិរិយាអាខ្យាត, បើកិរិយាកិតកៈ លោកសម្រេចរូបតាមនាមសព្ទដែលជាបទប្រធាន គ្រប់ ។ បទ ដូច **គុណាធិសេសោ អារទ្ធ-វីរិយេន អធិគតោ** (ប្រែ) ‹‹ **គុណាធិសេសោ** នូវគុណវិ-សេស **អារទ្ធវីរិយេន** គឺលោកអ្នកមានសេចក្តីព្យាយាមតឹងរែង **អធិគតោ** បានហើយ ›› ។ បុរិសៈនៃប្រយោគកម្មនេះ ប្រែហាលគ្នានឹងប្រយោគកត្តុ មិនបានកំណត់វិភត្តិនិងវចនៈឡើយ ស្រេចហើយតែកិរិយាចង្អុលប្រាប់, បទជាអនភិហិតកត្តាសោត ក៏ដូចគ្នាដែរ រមែងផ្លាស់ប្រែតាមសេច-ក្តីបានទាំង ៦ វចនៈ, តែកិរិយាក្នុងប្រយោគកម្មនេះ បើជាកិរិយាអាខ្យាត ត្រូវប្រើអត្តនោបទ បឋមបុរិសៈ ទាំងឯកវចនៈ ទាំងពហុវចនៈ គឺ តេ, អន្តេ; បើជាកិរិយាកិតកៈ ត្រូវសម្រេចរូបតាមបទប្រធាន ប្រែហាលគ្នានឹងប្រយោគកត្តុ

www.budinst.gov.kh www.elibraryofcambodia.org

ដែរ ប្លែកតែបច្ច័យប៉ុណ្ណោះ ។

៣) **ប្រយោគភាព** ត្រូវលើកបទអនភិហិតកត្តា គឺបទតតិយាវិភត្តិ ត្រង់ដែលប្រែថា «គឺ» ឡើងប្រែមុន ហើយទើបប្រែកិរិយា ដូច **ករំ មយា បដិបជ្ជតេ** (ប្រែ) «**មយា** គឺអញ **បដិបជ្ជតេ** ប្រតិបត្តិ **ករំ** ដោយប្រការដូចម្តេច» ។ បទអនភិហិតកត្តា ក្នុងប្រយោគភាពនេះ ប្រើបានទាំង ២ វចនៈ, តែបទកិរិយានោះ ត្រូវប្រើកិរិយាអកម្មធាតុទើបបាន; ចំណែកវិភត្តិ បើកិរិយាអាខ្យាត ប្រើតែវត្តមានាវិភត្តិ អត្តនោបទ បឋមបុរិស: ឯកវចនៈ គឺ តេ តែប៉ុណ្ណោះ, បើកិរិយាកិតក: ត្រូវសម្រេចរូបជានបុំសកលិង្គ ឯកវចនៈ ។ ជួនណា កិរិយាជាសកម្មធាតុ ក៏ប្រើជាភាវវាចក:បានខ្លះ ប៉ុន្តែកាលណាប្រែមិនបាច់ដាក់បទកម្ម មកទទួលកិរិយានោះទេ ដូច **តយា បចិតព្វំ** (ប្រែ) «**តយា** គឺឯង **បចិតព្វំ** ត្រូវចំ-អិន», **ភី បន ភាគព្វំ** (ប្រែ) «**បន** ចុះ (**អម្ហេហិ** គឺយើង)

www.budinst.gov.kh www.elibraryofcambodia.org

កាតព្វំ ត្រូវធ្វើ **កឹ** ដូចម្តេច? **ភុញ្ជិតព្វំ** (ប្រែ) «(**អម្ហេហិ** គឺយើង) **ភុញ្ជិតព្វំ** ត្រូវគេបរិភោគ» ។

(៤) ប្រយោគអនាទរៈ, ប្រយោគលក្ខណៈ, ប្រយោគនិទ្ធារណៈទាំង ៣ នេះ មិនបានតាំងនៅដោយទំនងរបស់ខ្លួនទេ ព្រោះជាប្រយោគដែលជ្រែកជ្រៀតចូលមក ក្នុងចន្លោះប្រយោគកត្តុ, កម្ម, ភាព, តែសេចក្តីរបស់ប្រយោគដែលទាំង ៣ នេះ ជាកំណាត់មួយដោយឡែក មិនបានទាក់ទងលាយឡំ ចូលនឹងប្រយោគណាៗឡើយ ។

ប្រយោគអនាទរៈនេះ សំដៅយកសព្ទប្រកបដោយឆដ្ឋីវិភត្តិ ដែលប្រែថា «កាល, កាលបើ, កាលដែល» ទោះជាឯកវចនៈ ឬ ពហុវចនៈក៏បាន, តែត្រូវមានកិរិយាកិតកៈដែលប្រកបដោយកិតប្បច្ច័យ (វៀរលែងតែអព្យយប្បច្ច័យចេញ) សម្រេចរូបដោយឆដ្ឋីវិភត្តិ ជាគ្រឿងឃុំគ្រងប្រយោគ ទាំងត្រូវកំណត់ លិង្គ, វចនៈ, វិភត្តិ ឲ្យដូចគ្នានឹងបទនាមនាមផង ហេតុ

www.budinst.gov.kh www.elibraryofcambodia.org

ប្រធាននិងកិរិយាមិនស្មើគ្នា ដូចបានអធិប្បាយមកខាងលើនេះទេ ក៏កប់ថាជាប្រយោគអនាទរៈមិនបាន ។ ឯការរៀងប្រយោគអនាទរៈនេះ មិនបានកំណត់ជាការដាច់ស្រេចថាត្រូវរៀងទុកក្នុងទីដូច្នេះដូច្នោះឡើយ ស្រេចហើយតែសមគួរដល់ដំណើរសេចក្តី ក្នុងប្រយោគធំនោះៗ គឺជួនកាលលោករៀងទុកក្នុងខាងដើមនៃប្រយោគធំ ដូច **ពាលស្ស ទុស្សមានស្ស, នប្បទុស្សន្តិ បណ្ឌិតា** (ប្រែ) "**ពាលស្ស** កាលជនពាល **ទុស្សមានស្ស** កាលប្រទុស្ត, **បណ្ឌិតា** ពួកបណ្ឌិតទាំងឡាយ **នប្បទុស្សន្តិ** មិនប្រទុស្តតបទេ" ។ ជួនកាលលោករៀងទុកក្នុងកណ្តាលនៃប្រយោគធំ ដូច**សោ កិរ, អនុរុទ្ធត្ថេរស្ស អន្តោគាមំ បិណ្ឌាយ បវិដ្ឋស្ស អត្តនោ អាគតំ កដច្ឆុភិក្ខំ ទាបេសិ**, (ប្រែ) "**កិរ** បានឮថា **សោ ឥន្ទកទេវបុត្តោ** ឥន្ទកទេវបុត្រនោះ, **អនុរុទ្ធត្ថេរស្ស** កាលដែលព្រះអនុរុទ្ធត្ថេរ **បវិដ្ឋស្ស** ចូលទៅហើយ **អន្តោគាមំ** កាន់ខាងក្នុងនៃស្រុក **បិណ្ឌាយ**

www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីបិណ្ឌបាត, **ឆាបេសិ** ប្រើបុគ្គលឲ្យប្រគេនហើយ **ភត្តបច្ឆិំ** ទូរបាយមួយវែក **អាគតំ** ដែលគេនាំមក **អត្ត-នោ** ដើម្បីខ្លួន " ។ លោកប្រើនកែរៀនកិរិយានិងនាមទុកព្រមគ្នាតែម្តង: តែជួនណា លោករៀនតែបទកិរិយាមិនមានបទនាមដែលជាតួប្រធាន មកកាន់កាប់ផងទេ, បើទុកជាដូច្នោះ កាលបើនឹងប្រែត្រូវបំពេញនាមសព្ទមក ដោយខ្លួនឯង ដូច **បូជារហេ បូជាយតោ, ន សក្កា** (១) **បុញ្ញំ សង្ខាតុំ** (ប្រែ) "(**សាធុជនស្ស** កាលបើសាធុជន) **បូជ-យតោ** កាលបានបូជា **បូជារហេ** ចំពោះបូជារហបុគ្គល, **បុញ្ញំ** នូវបុណ្យ (**គេន** គឺគេ) **ន សក្កា** មិនអាច **សង្ខាតុំ** ដើម្បីរាប់បានឡើយ,,; ក្នុងទីនេះបំពេញ **សាធុជនស្ស** ។

៥) ប្រយោគលក្ខណៈ សំដៅយកសព្ទប្រកបដោយ

---

១ បទនេះ ហៅបាន ២ យ៉ាងគឺ បើជាកម្មវាចកៈ ហៅថា កិរិយាបទកម្មវាចកៈ បើជាភាវវាចកៈ ហៅថា កិរិយាបទភាវវាចកៈ ។

www.budinst.gov.kh www.elibraryofcambodia.org

សត្តមីវិភត្តិ ដែលប្រែចេញអាយតនិបាតថា “នាកាល, កាលបើ, កាលដែល” ប្រើបានទាំង ២ វចនៈ ហើយត្រូវមានកិរិយាកិតកៈ ដែលប្រកបវិភត្តិស្មើគ្នានឹងនាមនាម ជាគ្រឿងឃុំគ្រងប្រយោគផង ។ ចំណែកវិធីរៀងប្រយោគលក្ខណៈនេះ មិនមានកំណត់ទេ ដូចគ្នានឹងប្រយោគអនាទរៈនោះដែរ ។ ឯវិធីប្រែ, បើប្រយោគនោះគ្មានបទនាមនាមជាប្រធាន មានតែកិរិយាកិតកៈទេ កាលនឹងប្រែ ត្រូវបំពេញនាមនាមជាប្រធាននោះមក, តែលក្ខណៈដែលនឹងបំពេញ ត្រូវប្រកបបទនាមនាមនោះ ឲ្យមានលិង្គ, វចនៈ, វិភត្តិ ស្មើគ្នានឹងកិរិយានោះ ទើបទុកជាត្រឹមត្រូវ តាមរបៀបប្រយោគលក្ខណៈបាន ។ បែបរៀងនៅខាងដើមប្រយោគជំ ដូច **អវិជ្ជន្ធការេ វិគតេ, វិជ្ជាលោកោ ឧប្បជ្ជតិ** (ប្រែ) “**អវិជ្ជន្ធការេ** កាលបើងងឹត គឺអវិជ្ជា **វិគតេ** ទៅបាត់ហើយ, **វិជ្ជាលោកោ** ពន្លឺគឺវិជ្ជា **ឧប្បជ្ជតិ** តែងកើតឡើង” ។ **អតិក្កន្តេសុ កាលេសុ, មច្ចានំ អាយុ ខិយតិ** (ប្រែ)

“**កាលេសុ** *កាលបើកាលទាំងឡាយ* **អតិក្កន្តេសុ** *កន្លងផុតទៅហើយ,* **អាយុ** *គឺអាយុ* **មច្ចានំ** *របស់សត្វទាំងឡាយ* **ខីយតិ** *តែងអស់ទៅដែរ ៗ បែបរៀងនៅកណ្ដាលប្រយោគដ៏ដូច* **អព្ភោកាសេ ឋបិតំ ហិ វិវដមុខចាដិំ, ទេវេ វស្សន្តេ, កិញ្ចាបិ**(១) **ឯកពិន្ទុនាន បូរតិ, បុនប្បុនំ វស្សន្តេ, បន**(១) **បូរតេវ** *(ប្រែ)* “**ហិ** *សេចក្ដីឧបមាថា* **វិវដមុខចាដិំ** *ក្រោជដ៏មានមាត់ប្រហ* **ឋបិតំ** *ដែលគេដាក់ហើយ* **អព្ភោកាសេ** *ក្នុងទីវាលល្វឹង,* **ទេវេ** *កាលបើភ្លៀង* **វស្សន្តេ** *កាលបង្អុរមក,* **ន បូរតិ** *មិនពេញ* **ឯកពិន្ទុនា** *ដោយដំណក់ទឹកមួយដំណក់* **កិញ្ចាបិ** *ក៏ពិតមែន,* **បន** *តែ* (**ទេវេ** *កាលបើភ្លៀង*)

---

១ កិញ្ចាបិ ហៅថា អនុគ្គហត្ថៈ, បន ហៅថា អរុចិសូចនត្ថៈ, និបាត ២ នេះប្រើក្នុងទីជាមួយគ្នា. តែជួនកាលលោកមិនរៀង បន ក៏មាន, កាលបើប្រែ ត្រូវបញ្ចូលមក ។

www.budinst.gov.kh www.elibraryofcambodia.org

វស្សន្តេ កាលបង្អុរមក **បុនប្បុនំ** ញយៗ, **បូរតេវ** គង់ពេញមិនខាន" ។ សេចក្ដីអធិប្បាយក្រៅពីនេះ ដូចន័យដែលពោលហើយ ក្នុងប្រយោគអនាទរៈ ។

៦) ប្រយោគនិទ្ធារណៈ សំគាល់យកនាមសព្ទប្រ-កបឆដ្ឋីនិងសត្តមីវិភត្តិ ដែលប្រែថា "ជំនុំ ឬ បណ្ដា" (សម័យបច្ចុប្បន្ននេះ ខ្មែរយើងច្រើននិយាយថា "ក្នុង",) ដូច **នរានំ ទស្សនិយតរោ រាជា ហោតិ** (ប្រែ) "**នរានំ** បណ្ដានរជនទ. **រាជា** ព្រះរាជា **ទស្សនិយតរោ ហោតិ** ទ្រង់គួរអ្នកផងរមិលមើលជាង(១) ។ **ពាលេសុ បណ្ឌិតោ បសំសនិយតរោ ហោតិ** (ប្រែ) "**ពាលេសុ** ជំនុំជនពាលទាំង បណ្ដាកទ. **បណ្ឌិតោ** បណ្ឌិត **បសំសនិយតរោ ហោតិ** ជាបុគ្គលគួរគេសរសើរជាង" ។

---

១ ប្រយោគបែបនេះបើមិនប្រែជានិទ្ធារណៈទេ ត្រូវប្រែជាអបាទាន-ឆដ្ឋី គឺប្រែកាច់ឆដ្ឋីវិភត្តិ ជាបញ្ចមីវិភត្តិថា "ជាង" វិញក៏បាន ដូចប្រែទុកជាបែបគទោនេះ "ព្រះរាជា ទ្រង់គួរអ្នកផងរមិលមើល ជាងពួកនរជនទ." ។ បាលីគិតថាខ្លួនឯង ។

www.budinst.gov.kh www.elibraryofcambodia.org

៣- វិធីដើរប្រយោគ

ការប្រែភាសាបាលី តាមទម្លាប់ដែលមានជាប់រហូតមកដល់សព្វថ្ងៃនេះ, មិនមែនកាន់បាលីអស់មួយប្រយោគទើបប្រែនោះទេ គឺចាប់ស្រង់យកបាលីមួយបទៗ ឬច្រើនបទ មកប្រែជាភាសាខ្មែរយើង មានទំនងដូចជាលើកជើងឈានដើរទៅមុខ មួយជំហានម្ដង ៗ, ហេតុនោះ លោកទើបសន្មតដំណើរប្រែនោះថា វិធីដើរប្រយោគ ។

> អ្នកសិក្សាកាលលើកបទប្រធាន ដែលជាម្ចាស់នៃប្រយោគឡើងប្រែរួចហើយ ត្រូវដើរទៅរកបទ តុល្យ ដែលមានលិង្គ, វចនៈ, វិភត្តិ ស្មើនឹងបទប្រធាន ឬផ្សេងលិង្គ, វចនៈគ្នាខ្លះក៏បាន ។ បទតុល្យនោះ មាន ២ គឺ វិសេសនៈ១ វិកតិកត្តា១ ។

អធិប្បាយ

១) **វិសេសនៈ** បទគុល្យដែលជាវិសេសនៈនោះបាន ដល់បទគុណ នឹងបទវិសេសនសព្ទនាម ៗ គុណនាម, សំខ្យាគុណ, សមាសគុណ, តទ្ធិតគុណ, កិរិយាកិតកៈប្រើដូចគុណហៅថា បទគុណ ៗ សព្ទនាម ជានិយមៈនិងអនិយមៈ ហៅថាបទវិសេសនសព្ទនាម ៗ បទគុណនិងបទវិសេសន-សព្ទនាមទាំង ២ នេះ ហៅថា បទវិសេសនៈ ៗ

បណ្ដាបទវិសេសនៈទាំងនោះ, បទណាមួយ មិនថានៅខាងមុខ ឬនៅខាងក្រោយរបស់បទប្រធានទេ បើនៅជិតនឹងបទប្រធានហើយ អ្នកប្រែត្រូវដើរទៅចូលបទនោះមុន ឬបទដទៃដែលជាប់ នឹងបទវិសេសនៈនោះ ក៏ត្រូវដើរទៅចូលជាបន្ទាប់គ្នាដែរ; ឯបទវិសេសនៈដែលនៅឆ្ងាយពីបទប្រ-ធាន ត្រូវដើរទៅចូលជាខាងក្រោយ តែមិនកំណត់ជាការដាច់ខាតទេ ដូច **គាថាបរិយោសានេ បញ្ចសតានិ តេ ភិក្ខូ**

www.budinst.gov.kh www.elibraryofcambodia.org

អរហត្តេ បតិដ្ឋហឹសុ (ប្រែ) « គាថាបរិយោសានេ ក្នុងកាលជាទីបំផុតនៃគាថា អបិ ស្រាប់នៃ ភិក្ខុ រីភិក្ខុ. បញ្ចសតា មានប្រមាណប្រាំរយ តេ នោះ បតិដ្ឋហឹសុ តម្កល់ស៊ប់ហើយ អរហត្តេ ក្នុងព្រះអរហត្ត ,, ។

ចំណែកបទវិសេសនៈដែលនៅក្រោយបទប្រធាន, បើមានកិរិយាកិតកៈ នៅកំណត់ក្នុងចន្លោះផង អ្នកប្រែត្រូវដើរទៅចូលកិរិយាកិតកៈ និងបទដែលជាប់ដោយកិរិយាកិតកៈនោះមុនរួចហើយទើបដើរទៅចូលបទវិសេសនៈដែលតាំងនៅខាងចុងក្នុងកាលជាខាងក្រោយ, តពីនោះទៅទៀត ក៏ដើរតាមន័យនេះ; តែបើមិនមានបទវិសេសនៈ ត្រូវដើរតាមរយៈកិរិយាកិតកៈដែលកំណត់ក្នុងចន្លោះៗ និងបទដែលជាប់ដោយកិរិយាកិតកៈនោះ ជាលំដាប់ទៅរហូតទាល់អស់ ហើយទើបចូលទៅរកបទកិរិយាអាខ្យាត និង បទដែលជាប់ដោយកិរិយាអា-ខ្យាតនោះ ក្នុងកាលជាខាងក្រោយ ព្រោះបទកិរិយាអា-ខ្យាត និង កិរិយាកិតកៈ ដែលជាម្ចាស់នៃវាចកៈ ក្នុងប្រ-

www.budinst.gov.kh www.elibraryofcambodia.org

យោគមួយ ៗ ត្រូវប្រែក្រោយបទកិរិយាដទៃដូច **មនុស្សា វត្តសម្បន្នេ ភិក្ខូ ទិស្វា <u>បសន្នចិត្តា</u>។ល។ អាហំសុ** (ប្រែ) "មនុស្សា មនុស្សទាំងឡាយ ទិស្វា ឃើញហើយ ភិក្ខូ នូវភិក្ខុទាំងឡាយ វត្តសម្បន្នេ អ្នកបរិបូណ៌ហើយដោយវត្ត បសន្នចិត្តា មានចិត្តជ្រះថ្លាហើយ ។ល។ អាហំសុ ក្រាបទូលហើយ" ។

២) វិកតិកត្តា នោះ បានដល់បទគុណនាម, បទនាមនាមដែលប្រែដូចគុណ និងបទកិរិយាកិតក: (លើកលែងតែបទប្រកបដោយឥត្យយប្បច្ច័យចេញ) ដែលលោករៀងទុកនៅខាងមុខ ឬ ខាងក្រោយកិរិយាជាធាតុ ភូ, ហុ, អស, ជន ដែលប្រែថា "មាន, កើត, ជា,, (ចូរមើលក្នុងវិធីប្រែវិកតិកត្តាក្នុងខាងមុខ) ។ ឯវិធីដើរទៅចូលបទវិកតិកត្តានេះ មិនខុសអំពីបទវិសេសន: ដែលបានពោលហើយនោះទេ ប្លែកគ្នាតែរៀងទុកប៉ុណ្ណោះ ដូច **គាថាបរិយោសានេ សោ ទិសាវាសិកោ ភិក្ខុ <u>សោតាបន្នោ</u> <u>ជាតោ</u>**

www.budinst.gov.kh www.elibraryofcambodia.org

(ប្រែ)« គាថាបរិយោសានេ ក្នុងកាលជាទីបចប់នៃគាថា ភិក្ខុ វីភិក្ខុ ទិសាវាសិកា អ្នកមានកិរិយានៅក្នុងទិសជាប្រក្រតី សោ នោះ សោតាបន្នា ជាគោ ជាអ្នកដល់នូវសោត: (១) ហើយ» ។

សមនាយ ៣ យ៉ាង

មួយទៀត បើក្នុងប្រយោគនោះ មាននិបាត ២ សព្ទ គឺ សហ ឬ សទ្ធឹ, អ្នកប្រែត្រូវសិក្សាឲ្យស្គាល់លក្ខណៈនិបាតនោះជាមុនសិន ទើបមិនលំបាកក្នុងដំណើរដើរប្រយោគ ។ និបាត ២ សព្ទនេះ ជានិបាតប្រាប់អាការរបស់នាម, គុណ, កិរិយាដែលរួមគ្នាឬជាប់ទាក់ទងគ្នា លោកហៅថា សមនាយ ។

---

១ ពាក្យថា «សោត:» នេះតាមដែលធ្លាប់និយាយមកថា «សោតា». ស្តាប់សំនៀងអាចគួរនឹងចូលចិត្តថា សព្ទនេះជាអាការន្តឥត្ថីលិង្គ តែដែលពិតនោះជាអការន្តបុំលិង្គ គឺជា សោត:, បើប្រកបបឋមាវិភត្តិ ឯកវចន:ជា សោតោ, ដូចក្នុងគម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក: ត្រង់អាកង្ខេយ្យសុត្តវណ្ណនាថា សោតោ ហិទំ សារីបុត្ត វុច្ចតិ កតមោ នុខោ សារីបុត្ត សោតោតិ ។

www.budinst.gov.kh www.elibraryofcambodia.org

សមវាយ មានប្រភេទ ៣ យ៉ាង គឺ

១. **ទព្វសមវាយ** រួមគ្នានឹងទព្វសព្ទ គឺបទប្រធាន,

២ **គុណសមវាយ** រួមគ្នានឹងបទគុណ,

៣. **កិរិយាសមវាយ** រួមគ្នានឹងបទកិរិយា ។

សមវាយ ទាំង ៣ នេះ មានដំណើរដើរប្រយោគផ្សេង គ្នាដូច្នេះ ៖

ទព្វសមវាយ កាលលើកបទប្រធានប្រែរួចហើយ ត្រូវដើរទៅចូល សហ ឬ សទ្ធឹ នឹងបទតតិយាវិភត្តិដែល ត្រូវសម្ពន្ធចូល នឹងនិបាតសព្ទ ២ នោះ, តតិនេះទៅ ដើរតាមរយៈប្រយោគ ដូច **សាមិកោ ភរិយាយ សហ (សទ្ធឹ) វិហារំ បាវិសិ** (ប្រែ) "សាមិកោ ស្វាមី សហ(១) មួយអន្លើ ភរិយាយ ដោយភរិយា បាវិសិ(២) ចូលទៅហើយ វិហារំ កាន់វត្ត" ។

---

១ សហ និង សទ្ធឹ ពីរសព្ទនេះ ប្រែថា „មួយអន្លើ» ជាមួយ ព្រម" ។ បើ

គុណសមវាយ *កាលបើប្រែបទគុណរបស់បទប្រធានរួចហើយ ត្រូវដើរទៅចូល សហ ឬ សទ្ធឹ និងបទប្រកបតតិយាវិភត្តិ, តពីនេះទៅ ដើរតាមរយៈប្រយោគ ដូច* **សទ្ធាសម្បន្នោ សាមិកោ ភរិយាយ សហ** (**សទ្ធឹ**) **វិហារំ បាវិសិ** *(ប្រែ) "សាមិកោ ស្វាមី សទ្ធាសម្បន្នោ អ្នកបរិបូណ៌ហើយដោយសទ្ធា សហ មួយអន្លើ ភរិយាយ ដោយភរិយា បាវិសិ ចូលទៅ*

ប្រែថា« មួយអន្លើ » បទតតិយាវិភត្តិដែលចូលនឹង សហ ឬ សទ្ធឹ នោះត្រូវប្រែថា« ដោយ» បើប្រែថា «ជាមួយ» បទតតិយាវិភត្តិត្រូវប្រែថា«នឹង» ប្រែថា «ព្រម» បទតតិយាវិភត្តិ ត្រូវប្រែថា «ទាំង» ។ សង្កេតផ្ទៀងៈ « មួយអន្លើ គូនឹង ដោយ, ជាមួយ គូនឹង នឹង, ព្រម គូនឹង ទាំង» ។ ២ ធាតុមាន ប ជាបទមុខ, ប នោះប្រើន័យៈជា ៣ ដូច បាវិសិ «ចូលទៅហើយ» (ប+វិស+អ+ឦ) ។ បាយាសិ "ដើរទៅហើយ" (ប+យា+អ+ស+ឦ) ។ បារុបតិ "ដណ្តប់" (ប+ រុប+អ+តិ) ។ បាវទិ "ពោលផ្ទួន, សរសើរ ហើយ" (ប +វទ+អ+ឦ) ។

www.budinst.gov.kh www.elibraryofcambodia.org

ហើយ វិហារំ កាន់វត្ត ” ។

កិរិយាសមវាយ កាលបើប្រែបទកិរិយា រួចហើយ ត្រូវដើរទៅចូល សហ ឬ សទ្ធឹ នឹងបទតតិយាវិភត្តិ ដូច **សទ្ធាសម្បន្នោ សាមិកោ ភរិយាយ សហ (សទ្ធឹ) វិហារំ ធាវិសិ** (ប្រែ) “ សាមិកោ រី ស្វាមី សទ្ធាសម្បន្នោ អ្នកបរិបូណ៌ហើយដោយសទ្ធា ធាវិសិ ចូលទៅហើយ វិហារំ កាន់វត្ត សហ មួយអន្លើ ភរិយាយ ដោយភរិយា ” ។

៤- វិធីប្រែរួប

សេចក្តីជាសង្កាត់ៗ ក្នុងប្រយោគបាលីខ្លះ កាលលើកឡើងប្រែជាបទ ៗ រមែងជំពាក់សាំញ៉ាំ មិនបានសេចក្តីល្អពេញទំនេ, សូម្បីបានសេចក្តីខ្លះ ក៏ពាក្យនោះឯង គេមិនធ្លាប់និយាយសោះ; ព្រោះហេតុដូច្នោះ សេចក្តីក្នុងសង្កាត់នៃប្រ-យោគនោះគួរតាមរួបក្នុងពេលដែលប្រែលោកប្រយោគដើម្បី

www.budinst.gov.kh www.elibraryofcambodia.org

រំលាយសេចក្ដីសង្កត់នោះ ឲ្យរលាយចូលគ្នា ។

លក្ខណៈនៃការកានរូប មានគោល ៨ យ៉ាង គឺ ការ-គន្ថិក, គុំ-បច្ច័យ, និបាត, ប្រយោគមាត្រា, ការសា-ធនៈ, វិកតិកត្ដា, ការ-សព្ទ, បទសមាសដែលមានបទដទៃជាប់ដោយផ្លូវសម្ពន្ធ ។

គោលប្រែរូបទាំង ៨ នេះ មានបទដទៃដែលត្រូវកានរូបចូលទៅនឹងខ្លួន ដូច្នេះ ៖

១- ការគន្ថិក កានរូបបទដែលប្រកបដោយធម្មិកត្តិ:

២- គុំ-បច្ច័យ កានរូបបទអព្យយកិរិយា ឬបទអន-ភិហិតកត្តា;

៣- និបាត កានរូបបទនាម, វិសេសនៈ, កិរិយា;

៤- ប្រយោគមាត្រា កានរូបបទអព្យយកិរិយា ឬបទអនភិហិតកត្តា;

៥- ការសាធនៈ កានរូបបទអព្យយកិរិយាដែលតាំងនៅ

www.budinst.gov.kh www.elibraryofcambodia.org

មុខខ្លួន;

៦. វិភត្តិកត្តា នាមបទវិភត្តិកត្តាឯង រួមចូលក្នុងបទកិរិយា ដែលជាធាតុ ភូ, ហុ, អស, ជន;

៧. ការកសព្ទ នាមរូបបទដែលប្រកបដោយឆដ្ឋីវិភត្តិ;

៨. បទសមាស នាមរូបបទ ដែលចូលនឹងសព្ទមុខ ឬ សព្ទក្រោយ ៗ

អធិប្បាយ

ភាវតទ្ធិត, សព្ទដែលប្រកបបច្ច័យ ក្នុងការកទាំងណាមួយ ហើយដល់វេលានឹងប្រែ ត្រូវនាមរូបបទប្រកបដោយ ឆដ្ឋីវិភត្តិដែលជាប់គ្នានឹងការកទាំងនោះ ព្រមទាំងបទដទៃ ដែលតាក់តែងនឹងសព្ទ ដែលបច្ច័យនៅអាស្រ័យ នោះហូត ដល់បច្ច័យ ដូច **អត្តនោ ធម្មេ បតិដ្ឋិតត្តំ** "ការៈនៃខ្លួន ជាអ្នកតាំងនៅស៊ប់ហើយ ក្នុងធម៌" ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងវិធីនេះ លោកថា « ឲ្យមានបទធ្វើវិកត្តិរួបចូលទៅនឹងការកត្វិក » , ដែលបង្គាប់យ៉ាងនេះ ក៏ព្រោះតែបទធ្វើវិ-កត្តិនោះត្រូវសម្ពន្ធចូលក្នុងបទការកត្វិក ទាំងបទការកត្វិកឯងក៏ត្រូវហៅរកបទ ធ្វើវិកត្តិនោះដែរ, ចំណែកបទដទៃដែលឲ្យមានរួបចូលទៅផង ក៏ព្រោះបទនោះត្រូវសម្ពន្ធចូលក្នុងសត្ទដែលបច្ច័យអាស្រ័យដូចក្នុងឧទាហរណ៍នេះ ត្រូវមានរួបទាំង អត្តនោ ទាំង ធម្មំ ភ្ជាប់ទៅនឹង បតិដ្ឋិតត្តំ, ព្រោះ អត្តនោជាបទធ្វើវិកត្តិត្រូវ សម្ពន្ធចូលក្នុង បតិដ្ឋិតត្តំ ។ ជាបទការកត្វិកដែលត្រូវហៅបទធ្វើវិកត្តិនោះ, ធម្មំ ជាបទត្រូវសម្ពន្ធចូលក្នុង បតិដ្ឋិតត្តំ ។ អ្នករៀនគួរសង្កេតដោយសម្ពន្ធ ដូចតទៅនេះ ៖ អត្តនោ ការកំទិសម្ពន្ធក្នុង បតិដ្ឋិតត្តំ, ធម្មំ អាធារៈក្នុង បតិដ្ឋិតត្តំ ។ លិង្គត្ថបឋមា ។

ចំណែកឯបទធ្វើវិកត្តិ បើមានក្នុងប្រយោគនោះស្រាប់ ក៏ជាការល្អ បើមិនមានទេ ក្នុងពេលដែលលើកបទការកត្វិកនោះប្រែ ត្រូវតែបំពេញមក ដូច **និសិន្នកា** «ការៈ(នៃ...)

www.budinst.gov.kh www.elibraryofcambodia.org

ជាអ្នកអង្គុយហើយ" ។ ពាក្យថា "នៃ..." ក្នុងវង់ក្រចកនេះ ជាពាក្យប្រែបទឆដ្ឋីវិភត្តិ ដែលបទការកខ្ចិតត្រូវហៅមក, អ្នកប្រែត្រូវបញ្ចូលតាមទំនងសេចក្តី ដោយមិនបាច់ជាបាលីផងឡើយ ។

តុំ បច្ច័យ, កិរិយាសព្ទប្រកបដោយ តុំ-បច្ច័យ ដែលជាតុមត្ថកត្តាក្តី តុមត្ថសម្បទានក្តី ខ្លះមានបទដទៃចូលដោយផ្លូវសម្ពន្ធផង ខ្លះក៏មិនមាន, កាលបើមានបទដទៃចូលផងទើបគួរអានរួម ។ ការអានបទដទៃរួមចូលទៅក្នុង តុំ-បច្ច័យនេះ បើពោលឲ្យខ្លីមក គឺអានរួមបទអព្យយកិរិយា(១) ឬ បទអនកហិតកត្តា ទៅចូលនឹងតុំ-បច្ច័យនោះឯង, ព្រោះបទទាំង ២ នោះត្រូវសម្ពន្ធចូលក្នុងកិរិយាសព្ទ ដែលប្រកបដោយ តុំ-បច្ច័យ, បើមានបទដទៃសម្ពន្ធចូលក្នុងអព្យយកិរិយា ឬ ចូល

---

១ កិរិយាដែលប្រកបដោយ ត្វូន, ត្វាន, ត្វា—បច្ច័យ ដូច កត្វា ហៅថាអព្យយកិរិយា ចូរមើលប្រយោគមាត្រា ត្រង់ទំព័រ៤៦ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងបទអនភិហិតកត្តានោះ លោកក៏ឲ្យមានរូបទៅផង ។

កុមត្តកត្តា ដូច **គឺ តយា គតី កត្វាបិ យថាពលំ ទានំ ទាតុំ ន វដ្ដតិ**(១) (ប្រែ) "តយា កតី កត្វាបិ ទាតុំ វិកិរិយា គឺអ្នក សូម្បីធ្វើនូវការឈ្លួលហើយឲ្យ ទានំ នូវទាន យថាពលំ តាមកម្លាំង ន វដ្ដតិ មិនគួរ កី ឬ ?" ។

អំណាច តុំ-បច្ច័យក្នុងទីនេះ ឲ្យមាន តយា, កត្វា រួបចូលក្នុង ទាតុំ; បទ កតី ដែលមានរូបទៅផង ក៏ព្រោះសម្ពន្ធចូលក្នុង កត្វា; ចំណែកបទ យថាពលំ និង ទានំ បានជាមិនមានរូបទៅផងនោះ ព្រោះតុំ-បច្ច័យគ្មានអំណាចដល់, តែបើមានរូបទៅផង ក៏គ្មានទាស់អ្វី ។ គួរសង្កេតដោយសម្ពន្ធតទៅនេះ៖ កី-សត្ថ-បុច្ឆនត្ថៈ, តយា អនភិហិតកត្តាក្នុងទាតុំ, កតី

---

១ បទកិរិយានេះ ប្រាប់កត្តុវាចកៈ តែបើមានកិរិយាប្រកបដោយតុំ-បច្ច័យរៀងទុកនៅខាងមុខ នឹងប្រែជាភាវវាចកៈក៏បាន ហៅថា វាចកវិប-ល្លាស, ដូចក្នុងឧទាហរណ៍នេះ ត្រូវប្រែថាតយា គឺអ្នក ន វដ្ដតិ មិនគួរ កតី កត្វាបិ ទាតុំ ដើម្បីធ្វើ សូម្បីនូវការឈ្លួលហើយឲ្យ ទានំ នូវទាន យថាពលំ តាមកម្លាំង កី ឬ ?

អវុត្តកម្មៈ ក្នុងកត្តា ។ បុព្វកាលកិរិយាក្នុង ឃាតុំ, អញ្ញ សព្ទ អបេក្ខក្កៈក្នុងកត្តា, យថាពល់ កិរិយាវិសេសនៈក្នុង ឃាតុំ, ទានអវុត្តកម្មៈ ក្នុង ឃាតុំ។ គុមត្ថកត្តា ក្នុង វត្តតិ។ គាទ្យាគ បទកត្តុរាចកៈរបស់ឃាតុំ, ន-សព្ទ បដិសេធៈក្នុង វត្តតិ ។

គុមត្ថសម្បទាន ដូច **អញ្ញោ សត្ថោ បុរិសានំ សកលសរីរំ ផរិត្វា ឃាតុំ សមត្ថោ នាម នត្ថិ**

(ប្រែ) “សត្ថោ រឹសរឡឹង អញ្ញោ ដទៃ បុរិសានំ សកល សរីរំ ផរិត្វា ឃាតុំ សមត្ថោ នាម ឈ្មោះថាជាសមត្ថពិបាច ដើម្បីផ្សាយទៅ កាន់សរីរៈទាំងអស់ របស់បុរស. ហើយ ឃាតនៅបាន នត្ថិ មិនមាន” ។

ក៏ តុំ-បច្ច័យ ក្នុងប្រយោគនេះ មានអំណាចឲ្យគាន ចំពោះបទ ផរិត្វា របញ្ចូលទៅក្នុង ឃាតុំ ប៉ុណ្ណោះ, តែដែល បានជាគានរូបទាំងបុរិសានំ, សកលសរីរំ ទៅជាមួយផង ព្រោះបទទាំងនោះជាប់ដោយផ្លូវសម្ពន្ធគ្នា ៗ គ្នា គឺ បុរិសានំ ត្រូវចូលក្នុង សកលសរីរំ ។ ត្រូវចូលក្នុង ផរិត្វា, ចំណែក

www.budinst.gov.kh www.elibraryofcambodia.org

ហ៊ុំ ក្នុងទីនេះ បានជាគានរូបចូលទៅក្នុង សមគ្គោ នាម, ព្រោះហ៊ុំនេះ ជាបទនៅក្នុងអំណាចនាម-និបាតឃុំគ្រង ។ អ្នកសិក្សាគួរសង្កេតតាមសម្ពន្ធដូចតទៅនេះ ៖ អញ្ញា វិ-សេសនៈរបស់ សត្វោ ។ បកតិកត្តាក្នុងនត្ថិ ។ និបាតខ្សាត បទ កត្តុវាចកៈរបស់ សត្វោ, ចុះសាន់ សាមិសម្ពន្ធៈក្នុង សកលសរីរំ ។ សម្បាបុណិយកម្មៈ ក្នុង ផរិត្វា ។ បុព្វកាលកិរិយាក្នុងហ៊ុំ ។ គុមត្តសម្បទានៈក្នុង សមគ្គោ ។ វិកតិកត្តាក្នុង នត្ថិ, នាម–សត្វ សញ្ញាជាកកៈក្នុង សមគ្គោ ។

និបាត បានដល់សព្ទនិបាតដែលបង្គាប់ បទនាម, បទវិសេសនៈ និង បទកិរិយា ឲ្យនៅក្នុងអំណាចខ្លួនប៉ុណ្ណោះមិនមែនបានសារធារណ៍ទូទៅគ្រប់និបាតទេ ។ សព្ទនិបាតដែលប្រើគានរូបដោយច្រើននោះគឺអបិ, នាម, បិ, ឯវ, វិយ, ឥវ, វ,ច,វា.សមុច្ច័យ ជាដើម ។ កាលបើពួកនិបាតសព្ទទាំងនេះ

ណាមួយ តាំងនៅក្រោយបទនាម, វិសេសនៈ, កិរិយាណា

www.budinst.gov.kh www.elibraryofcambodia.org

អ្នកប្រែត្រូវតាមរូបបទនាម, វិសេសនៈ ឬ កិរិយានោះ ព្រមទាំងបទដទៃដែលជាប់នឹងបទនោះ ៗ ទៅរហូតដល់និបាតដែលនៅខាងក្រោយបង្អស់ ហើយសឹមប្រែ ។

អបិ, នាម ដូច **ឥធេវ មេ និបជ្ជិត្វា មរន្តស្សាបិ អបរាបរំ បវត្តេន្តស្សាបិ, តយា សទ្ធិំ(១) គមនំ នាម នត្ថិ** (ប្រែ) "មេ កាលអញ ឥធ ឯវ និបជ្ជិត្វា មរន្តស្ស អបិ ទុកជាកាលដេកស្លាប់ ក្នុងទីនេះក៏ដោយ ឥធ ឯវ និបជ្ជិត្វា អបរាបរំ បវត្តេន្តស្ស អបិ ទុកជាកាលដេកប់រះនទៀល ទៅមក ៗ ក្នុងទីនេះក៏ដោយ តយា សទ្ធិំ គមនំ នាម ឈ្មោះថាកិរិយាទៅ មួយអន្លើ ដោយអ្នក នត្ថិ មិនមាន" ។

បិ ដូច **អាគន្ត្វា ទាតបានឧម្មារេ ឋិតោបិ ន លភិស្សសិ** (ប្រែ) "ត្វំ អ្នក អាគន្ត្វា ទាតបានឧម្មារេ

---

១ កុំច្រឡំៈ សទ្ធិំ ក្នុងទីនេះចូលក្នុង គមនំ ហៅថា ទព្វសមភាយ មិនមែនជាកិរិយាសមភាយទេ ព្រោះ គមនំ ជាកិតកនាម ថែមទាំងជាបទប្រធានទៀតផង ។

www.budinst.gov.kh www.elibraryofcambodia.org

ប៉ះគាថ សូម្បីមកឈរហើយ ត្រង់ធរណីនៃបង្អួច ឧលកិស្ស-ស៍ នឹងមិនបាន (កត្តុំ ខ្លូវកត្ត)" ។

៦៥. ដូច **ឥន្ទ្រិយេសុ គុត្តទ្វារា ភិក្ខូ ខេមានំ បិយា ឯវ (ហោន្តិ)** (ប្រែ) " ភិក្ខូ រីភិក្ខុទ. ឥន្ទ្រិយេសុ គុត្តទ្វារា អ្នកមានទ្វាររក្សាហើយ ក្នុងឥន្ទ្រិយទ. ខេមានំ បិយា ឯវ (ហោន្តិ) រមែងជាទីស្រឡាញ់ នៃខេមាទ. ដោយពិត" ។

ឬ ដូច **សហ គណ្ឋកេន ចោរំ ចូឡាយ គណ្ហន្តី វិយ(១) មំ វិប្បការំ បាបេស្សតិ** (ប្រែ) "(ឧបាសិកា រីឧបាសិកា) មំ ញ៉ាំងអញ បាបេស្សតិ នឹងឲ្យដល់ វិប្បការំ នូវបការៈដ៏ប្លែក សហ គណ្ឋកេន ចោរំ

---

១ ប្រយោគឧបមាក្នុងទីនេះ ប្រែបានតែជាឧបមាលិង្គត្ថៈ នឹងប្រែជាឧបមាវិសេសនៈ មិនបាន ។ សម្ពន្ធៈ សហ កិរិយាសមវាយក្នុង គណ្ហន្តី, គណ្ឋកេនសហត្ថតតិយាក្នុង សហ ចោរំ អវុត្តកម្មៈ ក្នុងគណ្ហន្តី ចូឡាយ ឧបសិលេសិកាធារៈក្នុង គណ្ហន្តី ។ វិសេសនៈរបស់ ឥត្ថី ។ ឧបមាលិង្គត្ថៈ, វិយ–សព្ទ ឧបមាជោតកៈក្នុង ឥត្ថី ។

www.budinst.gov.kh www.elibraryofcambodia.org

ចូឡាយ គណ្ហន្តិ (ឥត្ថី) វិយ ដូចជាស្ត្រី កាលចាប់នូវហោរ ត្រង់ផ្នួងសក់ ព្រមទាំងទ្រព្យ” ។

៤ ដូច **សត្ថា គន្ធកុដិយំ និសិន្នោ ច** (ប្រែ) “សត្ថា ព្រះសាស្ដា គន្ធកុដិយំ និសិន្នោ គង់ហើយ ក្នុង គន្ធកុដិ នោះ” ។

៥ ដូច **ឱកគ្គោគគ្គញ្ញ មេ សាខាភង្គំ ខាទន្តិ អាវិលានិ ច បានិយានិ បិវាមិ** (ប្រែ) “(ហត្ថីវង់ទ.) ទុកគ្គោគគ្គំ មេ សាខាភង្គំ ខាទន្តិ ច រមែងទំពាស៊ី នូវមែកឈើបាក់ ដែលអញបំបាក់ចុះហើយបំបាក់ចុះហើយផង អហំ អញ អាវិលានិ បានិយានិ បិវាមិ ច រមែងផឹកនូវទឹកល្អក់ផង” ។

៦ ដូច **ឥទានិ តុយ្ហំ ខោ មម ឧស្សនំ មយ្ហំ ខោ តវ ឧស្សនំ នត្ថិ** (ប្រែ) “ឥទានិ ឥឡូវនេះ តុយ្ហំ មម ឧស្សនំ ក៏ វិការិយាឃើញ នូវអ្នក របស់ខ្ញុំ ឬ មយ្ហំ តវ ឧស្សនំ ក៏ ឬវិការិយាឃើញនូវខ្ញុំ របស់អ្នក នត្ថិ មិនមាន” ។

www.budinst.gov.kh www.elibraryofcambodia.org

វិធីរួបរាយនិបាតនេះ មិនបាននិយាយជាប់ ដល់ផ្លូវសម្ពន្ធផងទេ ព្រោះសព្ទនិបាតពួកនេះ ជាឥស្សរៈខាងតែរួបរួមបទនាម, គុណ, កិរិយា ឲ្យនៅក្នុងអំណាចខ្លួន ដើម្បីផ្សារតសម្រួលសេចក្ដីឲ្យងាយស្ដាប់ប៉ុណ្ណោះ មិនបានហៅរកបទទាំងនោះ ឲ្យសម្ពន្ធចូលមកនឹងខ្លួនឡើយ, ពួកនិបាតទាំងនោះគឺ ដែលត្រូវសម្ពន្ធចូលទៅនឹងបទនាម, គុណ, កិរិយានោះ ៗ វិញ ។ ដើម្បីបញ្ជាក់ក្នុងរឿងនេះ នឹងលើកឧទាហរណ៍១ ខាងដើមត្រង់និបាត អបិ, នាម មកសម្ពន្ធទុកជាទីសង្កេត ដូចតទៅនេះ៖ ឥធ កាលត្ថសត្តមីក្នុង និបជ្ជិត្វា, ឯវ-សព្ទ អវធារណត្ថៈក្នុង ឥធ, មេអនាទរៈក្នុង មរន្តស្ស បវេដ្ឋន្តស្ស ។ អនាទរៈកិរិយារបស់ មេ, អបិ-សព្ទ គរហត្ថៈក្នុងមរន្តស្ស បវេដ្ឋន្តស្ស, តយា សហត្ថកកិរិយាក្នុង សទ្ធឹ ។ ទត្វាសមវាយ ក្នុង គមនំ ។ សយកត្តាក្នុង ឧត្តិ ។ និបាត-ទ្វាកបទ កត្តាបកៈរបស់ គមនំ, នាម-សព្ទ សញ្ញា-ជោតកៈក្នុង គមនំ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោគមាត្រា , បទកិរិយាកិតកៈណា ប្រកបព្យយ-ប្បច្ច័យ(១) ៧ គួ គឺ អន្ត, មាន, ត, តព្វ, អនីយ (តវន្តុ,តាវី) ដែលជាបឋមាវិភត្តិនៅជាសង្កាត់ៗ ក្នុងរង់នៃអាខ្យាត ហើយមានតាំងបទអនភិហិតកត្តា ឬបទអព្យយកិរិយា(២) ដែលត្រូវសម្ពន្ធចូលផង រៀងទុកក្នុងខាងមុខ នៃបទកិរិយាកិតកៈនោះលោកសន្មតឈ្មោះថា ប្រយោគមាត្រា ។ តែបើបទកិរិយាកិតកៈណា ប្រកបបឋមាវិភត្តិ នៅក្នុងប្រយោគមិនមានកិរិយាអាខ្យាតកាន់កាប់បទប្រធានទេ បទកិរិយាកិតកៈនោះលោកមិនឲ្យឈ្មោះថាប្រយោគមាត្រាឡើយ , ក្នុងប្រយោគដូច្នេះ លោកហាមមិនឲ្យប្រែរួប ព្រោះបទកិរិយាកិតកៈនោះជាម្ចាស់របស់បទប្រធាន ៗ តែឯបទកិរិយាកិតកៈ ប្រកបទុតិ-

---

១ បច្ច័យដែលអាចផ្លាស់រូប តាមអំណាចលិង្គ វចនៈ. វិភត្តិ ទៅតាមបទនាម.នាមបានហៅថា ព្យយប្បច្ច័យ ។ ២ កិរិយាប្រកបអព្យយប្បច្ច័យ (បច្ច័យមិនផ្លាស់រូបទៅតាមអំណាចលិង្គ, វចនៈ វិភត្តិ) ៣ គួ គឺតូន, ត្វាន, ត្វា ហៅថា អព្យយកិរិយា ។

www.budinst.gov.kh www.elibraryofcambodia.org

យា វិកត្តិជាដើមវិញដែលមានបទអនភិហិតកត្តា ឬអព្យយកិរិយាទៀងចុកខាងមុខសឹងបានឈ្មោះថា ប្រយោគមាត្រាទាំងអស់ ។

ឯការប្រែរូបនោះ ត្រូវអាស្រ័យកិរិយាកិតកៈ ជាប្រយោគមាត្រាដែលហៅកបទអនភិហិតកត្តា ឬ បទអព្យយ-កិរិយានោះចូលផង ទើបកាន់រូបបាន ដូច **សត្ថា បន គេន <u>ហត្ថិនា ឧបដ្ឋិយមានោ</u> សុខំ វសិ** (ប្រែ) “បន កិ សត្ថា ព្រះសាស្តា គេន ហត្ថិនា ឧបដ្ឋិយមានោ គឺដំរីនោះកាលបម្រើ វសិ គង់នៅហើយ សុខំ ជាសុខ” ។

បណ្តាបទទាំងឡាយ ក្នុងប្រយោគនេះ, ហត្ថិនា ជាបទអនភិហិតកត្តា សម្ពន្ធចូលក្នុងឧបដ្ឋិយមានោ ១ ជាបទកិរិ-យាកិតកៈ,វសិ ជាបទអាខ្យាតដែលជាម្ចាស់នៃបទប្រធាន គឺសត្ថា ។ ប្រសង្កេតសម្ពន្ធ ដូចតទៅនេះ ៖ បន សត្ថា វាក្យា-រម្ភៈ សត្ថា សយកត្តាក្នុង វសិ ១ អាខ្យាតបទ កត្តុវាចកៈរបស់សត្ថា, គេន វិសេសនរបស់ ហត្ថិនា ១ អនភិហិតកត្តាក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ឧបដ្ឋយមានោ ។ អត្តនូវកិរិយាវិសេសនៈរបស់ សត្ថា, សុទ្ធ
កិរិយាវិសេសនៈ ក្នុង វេសិ ។

សាបិ (ឥត្ថី) ថេរំ វន្ទិត្វា អត្តនា ទិន្នទានំ អាវជ្ជមានា និវត្តិ *(ប្រែ) " អបិ ចំណែកឯ សា ឥត្ថី ស្ត្រីនោះ ថេរំ វន្ទិត្វា អាវជ្ជមានា កាលថ្វាយបង្គំនូវព្រះថេរៈហើយរំពឹង អត្តនា ទិន្នទានំ នូវទានដែលខ្លួនប្រគេនហើយ និវត្តិ ត្រឡប់វិញហើយ" ។*

បណ្តាបទទាំងឡាយ ក្នុងប្រយោគនេះ, វន្ទិត្វា ជាបទកិរិយាប្រកប ត្វាបច្ច័យ ដែលត្រូវសម្ពន្ធចូលក្នុង អាវជ្ជមានា ៗ ជាបទកិរិយាកិតកៈ, និវត្តិ ជាបទអាខ្យាត ដែលជាម្ចាស់នៃបទប្រធាន គឺ ឥត្ថី, ចំណែកបទ អត្តនា ទិន្ន-ទានំ បានជាមិនអានរួបទៅផង ព្រោះបទជាប្រយោគមាត្រា គ្មានអំណាចផល់, តែបើអានរួបទៅផង ក៏គ្មានទាស់អ្វី ៗ ចូរសង្កេតសម្ពន្ធជួបគ្នាទៅនេះ ៖ អបិ សព្ទ បកន្ទនូវត្ថ-បទៈ, សា វិសេសនៈរបស់ ឥត្ថី ៗ សយកត្តាក្នុង និវត្តិ

www.budinst.gov.kh www.elibraryofcambodia.org

ការទ្រាតបទ កត្តុវាចកៈរបស់ ឥត្ថី, ទៅ អវុត្តកម្មៈក្នុង វិ-ទិន្នា ។ បុព្វកាលកិរិយាក្នុង ការផ្ទុចមាមា, ឥត្ថា អនភិហិ-តកត្តាក្នុង ទិន្ន. (២) ទិន្នទាំង អវុត្តកម្មៈ ក្នុង ការផ្ទុចមាមាៗ ឥត្ថូនកិរិយាវិសេសនៈរបស់ ឥត្ថី ។

ឧទាហរណ៍ដែលលើកមកពណ៌នានេះ ជាប្រយោគមាត្រា ប្រកបដោយបឋមាវិភត្តិ, ចំណែកប្រយោគមាត្រាដែលប្រកបវិភត្តិដទៃមានទុតិយាវិភត្តិជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ការវិសោធនៈ សម្គាល់យកសព្ទនាមកិតកៈ ដែលសម្រេចមកពីរូបវិគ្គហៈជាការរូប ។ បទការសោធៈនេះកាលនាំទៅប្រើក្នុងសេចក្ដីទាំងពួង ខ្លះមានកិរិយាខាងមុខ ខ្លះក៏មិនមាន, បើមិនមានកិរិយាខាងមុខទេ ក្នុងវេលាដែលប្រែមិនត្រូវរូប, បើមានទើបរូបបទកិរិយា និងបទដែលជាប់គ្នានោះ ទៅ

១ បទសមាសដែលមានបទដទៃចូលនឹងសព្ទមុខបែបនេះ បើសម្ពន្ធជាបាលីត្រូវបញ្ចូល ឥតិសទ្ទ ផ្ទាប់និងសព្ទនោះ ដូច្នេះ អត្តនាតិ បទំ ទិន្ន_ឥតិសទ្ទ អនភិហិតកត្តា ។

រហូតដល់បទការសាធនៈ, តែបទកិរិយាខាងមុខនោះ ត្រូវជាកិរិយាដែលប្រកបដោយអក្សរបច្ច័យ ទើបកាបការរូបបាន ដូចនេះ: **ភុម្មេសុ ចិត្តំ បសាទេត្វា សគ្គេ និព្វត្តនំ នាម អត្ថិ** (ប្រែ) " ភុម្មេសុ ចិត្តំ បសាទេត្វា សគ្គេ និព្វត្តនំ នាម ឈ្មោះថាកិរិយាញ៉ាំងចិត្តឲ្យជ្រះថ្លា ក្នុងព្រះអគ្គ ហើយកើត ក្នុងឋានសួគ៌ អត្ថិ មាន" ។

បណ្ដាបទទាំងឡាយក្នុងប្រយោគនេះ, បសាទេត្វា ជាបទអក្សរកិរិយា ត្រូវសម្ពន្ធចូលក្នុង និព្វត្តនំ ដែលជាបទការសាធនៈ ។ ក៏បទការសាធនៈ ក្នុងទីនេះ មានអំណាចឲ្យការចំពោះបទ បសាទេត្វា រូបចូលទៅនឹងខ្លួនប៉ុណ្ណោះ មិនមានអំណាចអ្វីឲ្យការបទ ភុម្មេសុ, ចិត្តំ ចូលទៅផងទេ, តែបានជាការរូបទៅផង ក៏ព្រោះភុម្មេសុ, ចិត្តំ ត្រូវសម្ពន្ធចូលក្នុងបទបសាទេត្វា, ចំណែកបទ សគ្គេ ដែលការរូបទៅនោះ ដោយអំណាច នាម-សព្ទ ។ អ្នកសិក្សាត្រូវរៀបមើលដោយ

www.budinst.gov.kh www.elibraryofcambodia.org

សម្ពន្ធដូចតទៅនេះ ៖ តុម្ហេសុ អាធារៈក្នុង បសាទេត្វា, បត្ត ការិតកម្មៈក្នុង បសាទេត្វា ។ បុព្វកាលកិរិយាក្នុង ចិត្តានិ, សគ្គេ វេសយិកាធារៈក្នុង ចិត្តានិ ។ សយកត្តាក្នុង អត្ថិ ។ ចិហាតាខ្យាតបទ កត្តុវាចកៈក្នុង ចិត្តានិ, នាម.សព្ទ សញ្ញាជោតកៈក្នុង ចិត្តានិ ។

បទវិកតិកត្តា, បទគុណនាមក្តី បទនាមនាមដែលប្រើដូចគុណក្តី បទកិរិយាកិតកៈ (លើកលែងតែបទដែលប្រកបដោយអព្យយប្បច្ច័យចេញ) ក្តី ដែលសម្ពន្ធចូលនឹងកិរិយាជាធាតុ ភូ, ហុ, អស ជន, ប្រែថា “ជា” (១) ហៅថា វិកតិកត្តាចូរមើលវិធីប្រែវិកតិកត្តាក្នុងខាងមុខ) ។ បទវិកតិកត្តានេះ ច្រើនបទក្តី តិចបទក្តី, នៅវេលាប្រែ បើទុកជាវៀនទុកនៅក្រោយកិរិយា ក៏ឲ្យលើកមកដាក់ខាងមុខកិរិយាវិញ ហើយអានរួបចូលនឹងកិរិយាដែលប្រែថា “ជា”

---

១ ធាតុ៤នេះ ក្នុងទីដែលមានបទវិកតិកត្តាមិនគួរប្រែថា ‘‘មាន.កើត’’ ទេ បើប្រែ ក៏គ្មានបានន័យជាអ្វីដែរ ដូច Verbe Etre ខាងភាសាបារាំង។

នោះ ដូច **តស្សេកបុត្តកោ អហោសិ បិយោ មនា-**
បោ (ប្រែ) "ឯកបុត្តកោ រីកូនតូចម្នាក់ តស្ស បិយោ មនាបោ អហោសិ បានជា កុមារជាទីស្រឡាញ់ ជាទីពេញចិត្ត របស់គាត់ហើយ" ។ (សម្ពន្ធ) ឯកបុត្តកោ បកតិកត្តា ក្នុងអហោសិ ។ អាខ្យាតបទ កត្តុវាចកៈរបស់ ឯកបុត្តកោ, តស្ស សាមិសម្ពន្ធៈក្នុង បិយោ មនាបោ ។ វិកតិកត្តាក្នុង អហោសិ ។

មួយទៀត បើមានបទដទៃនៅខាងមុខ ដែលជាប់ ដោយផ្លូវសម្ពន្ធចូលនឹងបទវិកតិកត្តានោះ ក៏ត្រូវតែតាមរូប ទៅជាមួយគ្នានឹងបទវិកតិកត្តានោះដែរ ដូច **អយំ មហេ-សក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ** (ប្រែ) "អយំ វនប្បតិ រីឈើជាម្ចាស់នៃព្រៃនេះ(១) មហេសក្ខាយ ទេវតាយ បរិគ្គហិតោ ភវិស្សតិ នឹងជាដើមឈើ គឺទេវតាមាន

១ ឈើជាធំក្នុងព្រៃ

www.budinst.gov.kh www.elibraryofcambodia.org

សក្កាធំ កាន់កាប់ហើយ(១)" ។ (សម្ពន្ធ) អយំ វិសេសនៈរបស់ នេប្បតិ ។ បកតិកត្តាក្នុង ករិស្សតិ ។ អាខ្យាតបទ កត្តុវាចកៈរបស់ នេប្បតិ, មហេសក្ខាយ វិសេសនៈរបស់ ទេវតាយ ។ អនភិហិតកត្តាក្នុងបវត្តិហិតោ ។ វិកតិកត្តាក្នុង ករិស្សតិ ។

ភាវសព្ទ ចាត់ជាសព្ទមួយ ដែលជាហេតុឲ្យរូបបទផ្លាស់-វិភត្តិដែលរៀងនៅខាងមុខខ្លួនបាន ដូចគ្នានឹងការកខ្វិតដែរ តែបើភាវ . សព្ទនោះនៅពោលតែឯកឯង គឺមិនមានអំណាចអ្វីឲ្យកានរូបឡើយ ; ឯភាវ . សព្ទដែលមានអំណាចឲ្យកានបទផ្លាស់វិភត្តិរូបនោះ សំដៅយកភាវ . សព្ទដែលភ្ជាប់ជាបទសមាស រួចហើយប៉ុណ្ណោះ, បើមានបទដែលត្រូវចូលក្នុងសព្ទដែលជាប់នឹងភាវ.សព្ទនេះ ក៏ឲ្យកានរូបទៅដែរ ដូច **ននុ តេ បុត្តេន មដ្ឋកុណ្ឌលិនា មយិ មនំ បសា-ទេត្វា អត្តនោ សគ្គេ និព្វត្តភាវោ កថិតោ** (ប្រែ)

១ ហួងហែងហើយ; រក្សាហើយ ។

«អត្តនោ សត្ថេ និព្វត្តការេ ភាវៈនៃខ្លួនជាបុគ្គលកើតហើយ ក្នុងឋានសួគ៌ មដ្ឋកុណ្ឌលិនា គឺមដ្ឋកុណ្ឌលី បុត្តេន ជាកូន តេ នៃអ្នក មនំ ញ៉ាំងចិត្ត បសាទេត្វា ឲ្យជ្រះថ្លាហើយ មយិ ក្នុងតថាគត កថិតោ ប្រាប់ហើយ ននុ មិនមែនឬ» ។

ការសម្ពន្ធក្នុងទីនេះ ជាភស្សរៈក្នុងការតានរូបបទ អត្ត-នោ ព្រោះអត្តនោ ជាបទឆដ្ឋីវិភត្តិ ត្រូវសម្ពន្ធចូលក្នុង ការេ, ចំណែកបទ សត្ថេ ត្រូវសម្ពន្ធចូលក្នុងនិព្វត្ត-សត្ថ ដែលភ្ជាប់នឹងការេ ។ ចូរសង្កេតសម្ពន្ធបទទៅនេះ ៖ ននុ សត្ថុ បុច្ឆ-នត្ថៈ, អត្តនោ សាមិសម្ពន្ធៈក្នុង និព្វត្តការេ, សត្ថេ វេសយិ-កាធារៈក្នុង និព្វត្ត, និព្វត្តការេ វុត្តកម្មៈក្នុង កថិតោ ។ កិតបទ កម្មវាចក.របស់ និព្វត្តការេ, តេ សាមិសម្ពន្ធៈក្នុង បុត្តេន ។ វិសេសនរបស់មដ្ឋកុណ្ឌលិនា ។ អនភិហិតកត្តាក្នុង កថិ-តោ, មយិ អាធារៈក្នុងបសាទេត្វា ។ បុព្វកាលកិរិយាក្នុង កថិតោ ។

បទសមាស បទខ្លះ មានបទដទៃតាំងនៅមុខខ្លួន ត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

សម្ពន្ធចូលនឹងសព្ទមុខខ្លះ ចូលសព្ទក្រោយខ្លះ ចូលទាំងអស់ខ្លះ, ខ្លះក៏មិនមានបទដទៃចូលផងទេ ។ ឯបទសមាស ដែលមានបទដទៃសម្ពន្ធចូលទាំងអស់ ទាំងគ្មានបទដទៃចូលផងនោះ អ្នកប្រែមិនត្រូវប្រែទេ ។ ចំណែកបទសមាស ដែលមានបទដទៃចូលសព្ទមុខ ឬចូលសព្ទក្រោយ ទើបត្រូវគាន់ប្រែបទនោះទៅនឹងខ្លួនបាន ។

ការណ៍ដែលនឹងនាំឲ្យចូលចិត្តស្គាល់ថា សមាសនេះមានបទដទៃចូលនឹងសព្ទមុខ ឬចូលសព្ទក្រោយ, ចូលទាំងអស់ ឬមិនចូលនោះ ត្រូវអាស្រ័យដល់ការលើកសេចក្ដីនៃបទនោះ មកគិតមើលជាមុនថា សព្ទណាជារបស់សព្ទណា , ឬសព្ទណាមានសេចក្ដីចូលនឹងសព្ទណា, កាលបើលើកសេចក្ដីមកគិតហើយ ក៏នឹងស្គាល់បានដូច **សហាយស្ស មុខវណ្ណោ** "ពណ៌នៃមុខរបស់សំឡាញ់" ត្រូវគិតថា ពណ៌ ។ អ្វី, មុខ ។ អ្នកណា ។ បន្ទាប់ពីនោះនឹងយល់ថា ពណ៌ ។ មុខ មុខ ។ សំឡាញ់, មិនមែនពណ៌របស់សំឡាញ់, មិនមែន

www.budinst.gov.kh www.elibraryofcambodia.org

សំឡាញ់ មានពណ៌ខៀវ ។ កាលបើចូលចិត្តដូច្នេះហើយ ទើបនឹងស្គាល់បានថា សមាសនេះមានបទ សហាយកស្ស ចូលនឹង មុខ-សព្ទ តែប៉ុណ្ណោះ មិនមែនចូលនឹងវណ្ណា ឬ ចូលទាំង ២ សព្ទ ទាំងខាងមុខទាំងខាងក្រោយឡើយ ។ គប្បីសង្កេតឧទាហរណ៍ ដែលបានចែងភាគ ទុកខាងក្រោមនេះ ៖

បទសមាសមានបទដទៃចូលនឹងសព្ទមុខ

សគ្គេ និព្វត្តភាវោ *ភាវៈ (នៃខ្លួន) ជាអ្នកកើតក្នុងឋានសួគ៌,*

អត្តនា ទិន្នទានំ *ទានដែលខ្លួនប្រគេនហើយ,*

អត្តនា សហគាមិនោ *អ្នកទៅមួយអន្លើដោយខ្លួន,*

សត្ថារំ ទដ្ឋុកាមោ *មានបំណងដើម្បីឃើញនូវព្រះសាស្តា ។*

បទសមាសមានបទដទៃចូលនឹងសព្ទក្រោយ

តស្ស អន្តោគេហា *អំពីខាងក្នុងនៃផ្ទះរបស់គាត់,*

www.budinst.gov.kh www.elibraryofcambodia.org

មយិ ចិត្តប្បសាទេន *ដោយការជ្រះថ្លានៃចិត្ត ក្នុងតថាគត,*

វិហារមជ្ឈេ ឧបដ្ឋានសាលា *សាលាបម្រើ ក្នុងកណ្ដាលនៃវត្ត,*

សត្ថុ ធម្មទេសនា *ការសម្ដែងនូវធម៌នៃព្រះសាស្ដា ។*

បទសមាសមានបទដ៏ទៃចូលទាំងសព្ទមុខទាំង
សព្ទក្រោយ មិនត្រូវអានរួប

អត្តនោ ហត្ថបាទា *ដៃនិងជើងទាំងឡាយ នៃខ្លួន,*

មយ្ហំ មាតាបិតរោ *មាតានិងបិតាទាំងឡាយ នៃខ្ញុំ,*

សិស្សានំ អាចរិយុបជ្ឈាយា *អាចារ្យនិងឧបជ្ឈាយ៍ទ. នៃសិស្សទ.*

នគរេ រាជរាជមហាមត្តា *ស្ដេចនិងអាមាត្យធំនៃស្ដេចទ. ក្នុងនគរ ។*

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍

បទសមាសមានបទដទៃចូលនឹងសព្ទមុខ

សក្កោ កោ នុ ខោ មំ ឋានា ចាវេតុកា.
មោតិ ឱលោកេន្តោ ទិព្វេន ចក្ខុនា ថេរំ អទ្ទស

(ប្រែ) "សក្កោ ទេវរាជឈ្មោះសក្កៈ ឱលោកេន្តោ កាលរមិលមើល កោ នុ ខោ មំ ឋានា ចាវេតុកាមោ ឥតិ (ចិត្តគិតដោយកិរិយាគិត) ថាដូច្នេះ អទ្ទស បានឃើញហើយ ថេរំ នូវព្រះថេរៈ ចក្ខុនា ដោយចក្ខុ ទិព្វេន ដ៏ជាទិព្វ; (លេខក្នុង) កោ នុ ខោ អ្នកណាហ្ន៎ មំ ឋានា ចាវេតុកាមោ មានចំណង់ដើម្បីញុំាងអញឲ្យកម្រើកចាកទី" ។ (សម្ពន្ធ) សក្កោ សយកត្តាក្នុង អទ្ទស ៗ អាខ្យាតបទ កត្តុវាចកៈរបស់ សក្កោ, កោ លិង្គត្ថបឋមា, នុ-ខោ និបាតសមុហៈ ជាបុច្ឆនត្ថៈ, មំ ការិតកម្មៈក្នុង ចាវេតុ, ឋានា អបាទានៈក្នុង ចាវេតុ, ចាវេតុកាមោ វិសេសនៈរបស់ កោ, ឥតិ-សព្ទ អាការៈក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ទុលោកេត្តា ។ អត្តន្តក្រិយាវិសេសនៈរបស់ សត្តា. ចំពោះ វិសេសនៈរបស់ ចក្ខុនា ។ ករណៈក្នុង អត្ថស, ឬ អន្ត-កម្មៈក្នុង អត្ថស ។

ឧទាហរណ៍

បទសមាសមានបទផ្សែងចូលនឹងសព្ទក្រោយ

ខីណាសវានំ មរណចេតនា នាម នត្ថិ

ភិក្ខវេ *(ប្រែ)* “ភិក្ខវេ ម្នាលភិក្ខុទ. ខីណាសវានំ មរណចេតនា នាម ឈ្មោះថា ចេតនាជាហេតុញុំាងសត្វឲ្យស្លាប់របស់ព្រះខីណាស្រពទ. នត្ថិ មិនមាន” ។ (សម្ពន្ធ) ភិក្ខវេ អាលបនៈ, ខីណាសវានំ សាមិសម្ពន្ធៈក្នុង មរណ-ចេតនា ។ សយកត្តាក្នុង នត្ថិ ។ និបាតាខ្យាតបទ កត្តុវាចកៈ របស់ មរណចេតនា, នាម. សព្ទ សញ្ញាជោតកៈក្នុង មរណ-ចេតនា ។

៥- វិធីវិបល្លាស

ក្នុងវេយ្យាករណ៍ភាសាបាលី មានការបំប្លែងរបៀបប្រើឲ្យខុសអំពីដំណើរដែលលោកកំណត់ទុកមកហៅថាវិបល្លាស។

វិបល្លាស គឺការបំប្លែងរបៀបប្រើក្នុងភាសាបាលី **មាន ៧ យ៉ាងគឺ**

១ អក្ខរវិបល្លាស	ការបំប្លែងអក្ខរៈ,
២ លិង្គវិបល្លាស	ការបំប្លែងលិង្គ,
៣. វិភត្តិវិបល្លាស	ការបំប្លែងវិភត្តិ,
៤. វចនវិបល្លាស	ការបំប្លែងវចនៈ,
៥. បុរិសវិបល្លាស	ការបំប្លែងបុរិសៈ,
៦. កាលវិបល្លាស	ការបំប្លែងកាល ,
៧. វាចកវិបល្លាស	ការបំប្លែងវាចកៈ ។

www.budinst.gov.kh www.elibraryofcambodia.org

អធិប្បាយ

អក្ខរវិបល្លាស, ក្នុងភាសាបាលី លោកតាក់តែងសន្ធិទុកសម្រាប់តភ្ជាប់តំណអក្ខរៈនិងអក្ខរៈឲ្យជាប់ជិតគ្នាផង សម្រាប់បំប្លែងអក្ខរៈ ឲ្យប្លែកចាកភាពដើមផង ។ ឯអក្ខរវិបល្លាសនេះ សំដៅយកវិធីសន្ធិ ដែលលោកបំប្លែងអក្ខរៈនោះ ៗ ឲ្យខុសពីទំនងដើម ដូច ឥតិ + ឯវ ជា ឥច្ចេវ, ឯកមិធាហំ ជា ឯកមិទាហំ, សាធុ + ទស្សនំ ជា សាហុទស្សនំ, សុគតោ ជា សុគទោ ជាដើម ។

លិង្គវិបល្លាស, តាមសព្ទលោកចែកជាលិង្គ ៣ គឺ បុំលិង្គ ១, ឥត្ថីលិង្គ ១, នបុំសកលិង្គ ១ ។ ក្នុងលិង្គទាំង ៣ នេះនាមនាមខ្លះប្រព្រឹត្តទៅបានតែលិង្គមួយ ដូច បព្វត, ធម្ម នេះជាឯកលិង្គិកៈ ប្រើបានតែជាបុំលិង្គម្យ៉ាង; នាមនាមខ្លះប្រព្រឹត្តទៅបាន ២ លិង្គ ដូច អក្ខរ, អគារ នេះជាទ្វិលិង្គិកៈ ប្រើបានតែបុំលិង្គនិងនបុំសកលិង្គ ប្រើជាឥត្ថីលិង្គមិនបាន; ដែលនិយាយនេះ តាមវិធីដែលលោកកំណត់ទុក ៗ ក៏លិង្គ

www.budinst.gov.kh www.elibraryofcambodia.org

វិបល្លាសនៃ[ពា]ក្យ ដល់ការបំប្លែងលិង្គទាំង ៣ នោះ ឲ្យខុស

អំពីវិធីដែល[ហៅ]ពាក្យខុសទៅវិញ ដូច ធម្មោ, បញ្ចោ ជា

បុំលិង្គ លោ[ក]បំប្លែងជានបុំសកលិង្គ ជា ធម្មានិ, បញ្ចានិ ។

ចូរសង្កេតឧ[ទា]ហរណ៍ ដូចតទៅនេះ ៖

យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា

(វិប្រ) "**យថាបិ** ដូចជា **រហទោ** អន្លង់ទឹក **គម្ភីរោ** ជ្រៅ **វិប្បសន្នោ** ថ្លាថ្លន់ **អនាវិលោ** មិនមានកករល្អក់ **យថា** យ៉ាងណាមិញ, **បណ្ឌិតា** បណ្ឌិតទ. **សុត្វាន** ស្តាប់ហើយ **ធម្មានិ** នូវធម៌ទ. **វិប្បសីទន្តិ** រមែងជ្រះថ្លា **ឯវំ** យ៉ាងនោះឯង"

ពហុំ វេ សរណំ យន្តិ <u>បព្វតានិ</u> វនានិ ច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា

www.budinst.gov.kh www.elibraryofcambodia.org

(ប្រែ) "**មនុស្សា** មែនុស្ស **ពហុំវេ** មានចំនួនច្រើន **គយគន្ធិតា** គឺភ័យគម្រាមហើយ **យន្តិ** តែងដល់ **បព្វតានិ ច** នូវភ្នំ. ទាំង **វនានិ ច** នូវព្រៃ. ទាំង **អារាមរុក្ខចេត្យានិ ច** នូវអារាមនិងឈើជាចេតិយ ទាំង **សរណំ** ជាទីពឹង" ។

វិភត្តិវិបល្លាស, វិភត្តិក្នុងវេយ្យាករណ៍បាលី លោកចាត់ទុកជា ២ ពួក គឺ វិភត្តិប្រកបនឹងនាមសព្ទ១, វិភត្តិប្រកបនឹងកិរិយាសព្ទ១ ។ បណ្ដាវិភត្តិទាំង ២ ពួកនេះ វិភត្តិនាមលោកចែកជា ៧ ពួក, ក្នុងពួកមួយ ៗ មានអត្ថផ្សេង ៗ គ្នាដែលហៅថា តាយតនិបាត សម្រាប់តពាក្យឲ្យកើតជាសេចក្ដីស្ដាប់បាន ។ ប៉ុន្តែប្រយោគក្នុងភាសាបាលី មាននាមសព្ទទាំងដែលលោកប្រកបវិភត្តិណា ៗ ហើយ មិនប្រែតាមអត្ថរបស់វិភត្តិនោះ ៗ ក៏ខុសខ្ចបសេចក្ដី លុះតែប្រែបំប្លែងទៅតាមអត្ថរបស់វិភត្តិដទៃវិញ ទើបបានសេចក្ដីល្អ ។ ការប្រែកាច់អត្ថរបស់វិភត្តិនេះឯង លោកហៅថា វិភត្តិវិបល្លាស ដូចឧទា-

www.budinst.gov.kh www.elibraryofcambodia.org

ហរណ៍តទៅនេះ ៖

ធាបំ នរកោ ផលំ ទេតិ (ប្រែ) "ធាបំ ដែបាប ទេតិ ឲ្យ ផលំ នូវផល នរកោ ដល់សត្វនរក" នេះកាច់បឋមា ជាកត្តា ៗ មនុស្សមំសំ ខាទាមិ រាជ (ប្រែ) "រាជ បពិត្រមហារាជ អហំ ខ្ញុំព្រះអង្គ ខាទាមិ ស៊ី មនុស្សមំសំ នូវសាច់នៃមនុស្ស" នេះកាច់ទុតិយា ជាកម្ម ៗ

វចនវិបល្លាស, វចនៈលោកចែកជា ២ គឺ ឯកវចនៈ១, ពហុវចនៈ១; ឯវចនៈទាំង ២ នេះ ដែលនឹងអាចស្គាល់បាន ដោយការសង្កេតកត្តា ដែលតាំងនៅត្រង់ទីបំផុតនៃនាមសព្ទ និងកិរិយាសព្ទ ៗ ដែលប្រើវចនៈទាំង ២ នោះដូច្នេះ៖ បើសព្ទ មានចំនួនតិច ប្រើឯកវចនៈ, បើសព្ទមានចំនួនច្រើន ប្រើ ពហុវចនៈ; ដែលលោកកំណត់ទុកយ៉ាងនេះ ជាការពិត; តែ ក្នុងភាសាបាលី ចួនកាលនាមសព្ទមានចំនួនតិច លោកត្រ-

www.budinst.gov.kh www.elibraryofcambodia.org

ឡប់ជាប្រើពហុវចនៈវិញក៏បាន , ការប្រកបប្រើវចនៈ មិនត្រូវតាមដំណើរពិតនេះឯង ហៅថា វចនវិបល្លាស ដូច **ឧ. នក្ខត្តា ទិមានំ អនុបរិយាយតិ** (ប្រែ) "**នក្ខត្តា** វិល្វឹង **អនុបរិយាយតិ** ព័ទ្ធ **ទិមានំ** នូវវិមាន" ។ បទថា នក្ខត្តា ជាបឋមាវិភត្តិ ពហុវចនៈ, តែប្រែជាឯកវចនៈ, ព្រោះដើមជានទី + យោ ផ្លាស់ ទី+យោ ជា ត្តា , ក្នុងទីនេះ ប្រើជាបទប្រធានរបស់ អនុបរិយាយតិដែលជាកិរិយាឯកវចនៈ, នក្ខត្តា ហៅថាវចនវិបល្លាស ។

បុរិសវិបល្លាស , បុរិសៈក្នុងអាខ្យាត លោកចាត់ជា ៣ ពួក គឺ បឋមបុរិសៈ ១ មជ្ឈិមបុរិសៈ ១ ឧត្តមបុរិសៈ ១ ។ វិធីប្រើបុរិសៈទាំង ៣ នោះ ដូចខ្មែរ ៖ បើមានបំណងប្រើបុរិសៈណាៗ ត្រូវប្រកបកិរិយាសព្ទឲ្យមានវិភត្តិត្រូវនឹងបុរិសៈនោះៗ; នេះនិយាយតាមគោល ដែលលោកកំណត់ទុក, តែក្នុងភាសាបាលី លោកត្រឡប់ជាបំផ្លែងបុរិសៈ ឲ្យឃ្លាតពីវិធីនេះទៅវិញ

www.budinst.gov.kh www.elibraryofcambodia.org

ក៏បាន គឺជួនកាល បទកិរិយា ជាបឋមបុរិស: លោកប្រើជា មជ្ឈិមបុរិស: ឬបទកិរិយាជាមជ្ឈិមបុរិស: លោកប្រើជាបឋម-បុរិស:វិញ; ការប្រែប្លែងបុរិស:ឲ្យឃ្លាតខុសអំពីច្បាប់ដើមនេះ ហៅថាបុរិសវិបល្លាស ដូចឧទាហរណ៍ថា **អាវុសោ ត្វំ មា ឯវំ ចិន្តយិ** (ប្រែ) "**អាវុសោ** ម្នាលអាវុសោ **ត្វំ** អ្នក **មា ចិន្តយិ** កុំគិតឡើយ **ឯវំ** យ៉ាងនេះ" ; **ខមាបេហិ ភន្តេ, មា ឯវំ ករិ** (ប្រែ) "**ភន្តេ** បពិត្រលោកដ៏ចំរើន, (**ត្វំ** លោក) **ខមាបេហិ** សូមអត់ទោស, (**ត្វំ** លោក) **មា ករិ** កុំធ្វើឡើយ **ឯវំ** យ៉ាងនេះ" ។ បទ ចិន្តយិ មកពី ចិន្ត + ណយ + ឦ អជ្ជត្តនីវិភត្តិ; ករិ មកពី ករ + អ + ឦ អជ្ជត្តនីវិភត្តិ , ឦ វិភត្តិនេះ ជាបឋមបុរិស: ឯក-វចន: តែក្នុងប្រយោគនេះ លោកប្រើជាមជ្ឈិមបុរិស: គឺត្រូវឡើង ត្វំ ជាប្រធាន (តែន័យខ្លះពោលថាផ្ទាល់ ១ ជា ៩) ។ **សា , "សមានជាតិកំ នោ**

កុលន្តិ អធិវាសេត្វា បិតុ សាសនំ បហិណិ "អម្ហាកំ រថំ បេសេន្តូតិ (ព្រ) **"សា·វិសាខា** នាងវិសាខានោះ **អធិវាសេត្វា** ទទួលព្រមហើយ (**វច-នេន** ដោយពាក្យ **សមានជាតិកំ នោ កុលំ ឥតិ** ថា "ត្រកូលមានជាតិស្មើគ្នា នឹងយើង" **បហិណិ** បញ្ជូនទៅហើយ **សាសនំ** នូវសំបុត្រ **បិតុ** ដល់បិតា **អម្ហាកំ រថំ បេសេន្តុ ឥតិ** ថា "សូម (លោក) បញ្ជូនរថដល់ខ្ញុំ" ។ បទ បេសេន្តុ នេះ មកពី បេស+ណេ+អន្តុ បញ្ចមីវិភត្តិ បឋមបុរិសៈ ពហុវចនៈ ៖ ក្នុងប្រយោគនេះ លោកប្រើជាមជ្ឈិមបុរិស ពហុវចនៈ គឺត្រូវទៀងបទប្រធានថា តុម្ហេ វិញ ។ តុ, អន្តុ បញ្ចមីវិភត្តិ មានប្រើជាមជ្ឈិមបុរិសៈ ច្រើនតែត្រង់សេចក្តីសំបុត្រ ដូចក្នុងឧទាហរណ៍នេះឯង ។

កាលវិបល្លាស, កាលក្នុងអាខ្យាតជាប្រធាន មាន៣

www.budinst.gov.kh www.elibraryofcambodia.org

គឺ បច្ចុប្បន្នកាល ១, អតីតកាល ១, អនាគតកាល ១, កាលទាំង ៣ នេះ ដែលមិនស្គាល់បាន ដោយអាស្រ័យការសង្កេតវិភត្តិទាំង ៨ ពួក (មើលក្នុងកច្ចាយនូបត្ថម្ភកៈ ត្រង់អាខ្យាតនិទ្ទេស) ។ ការបំផ្លែងកាលទាំង ៣ នោះ ឲ្យឃ្លាតអំពីវេលាដែលលោកកំណត់ទុក ដូចបច្ចុប្បន្នកាល បំផ្លែងជាអតីតកាលវិញជាដើម ហៅថា កាលវិបល្លាស, ហៅតាមវោហារអ្នករៀនភាសាបាលីថា ប្រែកាច់កាល ។

បច្ចុប្បន្នកាល កាច់ជាអតីតកាល ឧ. **តទា សាវត្ថិយំ សត្ថា មនុស្សភោជនិយោ ចសន្តិ** (ប្រែ) "**តទា** គ្រានោះ **មនុស្សភោជនិយោ** រីករាយនៃមនុស្ស ។ **សត្ថា** ព **ចសន្តិ** នៅហើយ **សាវត្ថិយំ** ក្នុងក្រុងសាវត្ថី" ។ វសន្តិ នេះ មកពី វស+អ+អន្តិ វត្តមានាវិភត្តិ ប្រាប់បច្ចុប្បន្នកាល, តែក្នុងប្រយោគនេះ មាន តទា-សព្ទៈលោករៀបទុកខាងដើម ជាគ្រឿងសំគាល់អតីតកាល ទើបលោកឲ្យប្រែ

www.budinst.gov.kh www.elibraryofcambodia.org

បំប្លែងជាអតីតកាលវិញ ។

អនាគតកាល កាច់ជាអតីតកាល ៤. **អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ គហការំ គវេសន្តោ, ទុក្ខា ជាតិ បុនប្បុនំ** (ប្រែ) "(**អហំ** តថាគត) **គវេសន្តោ** កាលស្វែងរក **គហការំ** នូវជាងផ្ទះគឺតណ្ហា **អនិព្វិសំ** កាលមិនជួប (**ញាណំ** នូវញាណ) **សន្ធាវិស្សំ** អន្ទោលទៅហើយ **អនេកជាតិសំសារំ** អស់សំសារមានជាតិមិនមែនមួយ, **ជាតិ** ការកើត **បុនប្បុនំ** រឿយៗ **ទុក្ខា (ហោតិ)** ដែលជាទុក្ខ" ។ សន្ធាវិស្សំ នេះ មកពី សំ+ធាវុ+អ+ឥ+ស្សំ ភវិស្សន្តិ ឬ កាលាតិបត្តិវិភត្តិ ប្រាប់អនាគតកាល, តែក្នុងគាថានេះ មានបទ អនេកជាតិសំសារំ ដែលប្រែថា "អស់សំសារមានជាតិមិនមែនមួយ" ជាគ្រឿងសំគាល់អតីតកាល ទើបលោកឲ្យប្រែបំប្លែងជាអតីតកាល ។

www.budinst.gov.kh www.elibraryofcambodia.org

វាចកវិបល្លាស, បទកិរិយា លោកចាត់ជាវាចកៈ ៥ គឺ កត្តុវាចកៈ ១, កម្មវាចកៈ ១ ភាវវាចកៈ ១ ហេតុកត្តុវាចកៈ ១ ហេតុកម្មវាចកៈ ១ ៗ វាចកៈទាំង ៥ នេះឯង មានវិភត្តិនិង បច្ច័យជាគ្រឿងសំគាល់ (មើលក្នុងកច្ចាយនរូបត្ថម្ភកៈ ត្រង់អា-ខ្យាតនិទ្ទេសនិងកិតកនិទ្ទេស) ៗ ការប្រែភាសាបាលីក្នុង ប្រយោគមួយ ៗ លោកឲ្យសង្កេតពិនិត្យត្រង់បទកិរិយា, បើបទកិរិយាប្រាប់វាចកៈណា ត្រូវប្រែជាវាចកៈនោះ, នេះ និយាយតាមបែបដែលលោកចាត់ទុកមក ៗ ការប្រែបំប្លែង វាចកៈទាំង ៥ នោះឲ្យខុសពីដំណើរដែលលោកបានចាត់ទុក ដើម្បីធ្វើសេចក្ដីឲ្យងាយស្ដាប់ហៅថា វាចកវិបល្លាស, ហៅ តាមវោហារអ្នករៀនភាសាបាលីថា ប្រែកាច់វាចកៈ ដូច ឧទាហរណ៍ថា ៖

ទិប្បការប្បត្តមេតំ ភាតុំ ខជ្ជតិ

ប្រែជាកត្តុវាចកៈ៖ "**ភាតុំ** រីកិរិយា (គឺអញ) ធ្វើ **ឯតំ-ព្រាហ្មណំ** នូវព្រាហ្មណ៍នុ៎ះ **ទិប្បការប្បត្តំ** ឲ្យជាបុគ្គល

www.budinst.gov.kh www.elibraryofcambodia.org

ផល់ហើយនូវឧបការៈថ្លៃក **វន្ទតិ** ទើបគួរ » ។ ប្រែកាច់កត្តុវាចកៈជាកម្មវាចកៈ ៖ (**មយា** គឺអញ) **វន្ទតិ** គួរ **ភាតុំ** ដើម្បីធ្វើ **ឯតំ.ព្រាហ្មណំ** នូវព្រាហ្មណ៍នុ៎ះ **ចិប្បការប្បត្តំ** ឲ្យជាបុគ្គលផល់ហើយនូវឧបការៈថ្លៃក» ។ វន្ទតិ នេះមកពី វន្ទ+អ+តិ ធាតុមានអាទិកត្តិ ជាកិរិយាប្រាប់កត្តុវាចកៈ តែប្រែកាច់ជាកម្មវាចកៈដូចគួរយ៉ាងដែលប្រែមកនេះក៏បាន ។

ចីវរំ វាតេន ឧក្ខិបិយតិ

ប្រែជាកម្មវាចកៈ ៖ **ចីវរំ** រីចីវរ **វាតេន** គឺខ្យល់ **ឧក្ខិបិយតិ** លើកឡើង» ។ ប្រែកាច់កម្មវាចកៈជាកត្តុវាចកៈ ៖ « **ចីវរំ** រីចីវរ **ឧក្ខិបិយតិ** ប៉ុង **វាតេន** ដោយខ្យល់» ។ ឧក្ខិបិយតិ នេះមកពី ឧ+ខិប+អ+យ+តិ ធាតុមានអាទិកត្តិ ជាកិរិយាប្រាប់កម្មវាចកៈ តែបើតាមរបកពាក្យខ្មែរមកប្រកបប្រែជាកត្តុវាចកៈ បានសេចក្ដីច្បាស់ល្អជាង ក៏ឲ្យប្រែជាកត្តុវាចកចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

៦. វិធីយោគសព្វនាម

ពាក្យថា យោគសព្វនាម នេះ ជាវោហារសម្រាប់ប្រើនិយាយគ្នា នៃអ្នករៀនភាសាបាលី ។

យោគសព្វនាម

វិសេសនសព្វនាម ទាំងនិយមៈ ទាំងអនិយមៈ ត្រូវជាវិសេសនៈរបស់នាមនាម, វៀរលែងតែ គី-សព្វ ត្រង់ប្រែថា «ណា, អ្នកណា» ដែលប្រើជាកត្តាដូចនាមនាមប៉ុណ្ណោះ ។ ក្នុងប្រយោគណា ដែលលោករៀងតែសព្វនាមពួកនេះ មិនបានរៀងនាមនាមទុកផងទេ, ក្នុងប្រយោគនោះ វេលាប្រែត្រូវរកនាមនាម មកប្រកបឱ្យត្រូវតាមលិង្គ, វចនៈ, វិភត្តិរបស់វិសេសនសព្វនាម; តួនាមនាមដែលលើកមកប្រកបផ្សំនឹងវិសេសនសព្វនាមនោះ ហៅថា យោគសព្វនាម ។

អធិប្បាយ

ការយោគសព្វនាមនោះ មិនមែនយោគបានតាមចិត្តរបស់ខ្លួនទេ ស្រេចហើយតែសព្វនាម ក្នុងប្រយោគនោះ សំឡឹង

www.budinst.gov.kh www.elibraryofcambodia.org

នាមនាមបែបណា ដែលបាននិយាយរួចមកហើយក្នុងប្រ-
យោគដើម ៗ មុននឹងយោគ, អ្នកប្រែត្រូវពិចារណា ថា
វិសេសនសព្ទនាមដែលលោករៀងទុក ក្នុងប្រយោគនេះតើ
ដើម្បីសំឡឹងយកនាមនាមប្រភេទណា? កាលបើដឹងច្បាស់
ហើយ ទើបត្រូវយោគនាមនាមប្រភេទនោះ ដូច **សត្ថា
គេសំ កថំ, សុត្វា ឯកសីលំបិ គណ្ហិតុំ អកត្វា
''សញ្ញានេម ទុរក្ខាតិ វត្វា ឥមា គាថា អភា-
សិ** ៗ គេសំ ក្នុងប្រយោគនេះសំឡឹងនាមនាម គឺ ឧបាសក
សព្ទ ក្នុងប្រយោគដើម, សញ្ញានិ សំឡឹងនាមនាម គឺ បញ្ចុ
សិក្ខាបទ.សព្ទ ក្នុងប្រយោគដើមដូចគ្នា, វេលាប្រែត្រូវយោគ
ថា គេសំ-ឧបាសកានំ, សញ្ញានិ ឯ បញ្ចសិក្ខាបទានិ ដូច
ប្រែថា៖ សត្ថា គឺព្រះសាស្តា សុត្វា ទ្រង់ព្រះសណ្តាប់ហើយ
កថំ នូវពាក្យ គេសំ ឧបាសកានំ របស់ឧបាសកទ. ពួក
នោះ អកត្វា មិនទ្រង់ធ្វើហើយ ឯកសីលំបិ សូម្បីនូវសីល
មួយ គណ្ហិតុំ ឲ្យជាសីលពោះឡើយ វត្វា ទ្រង់ត្រាស់ហើយ

www.budinst.gov.kh www.elibraryofcambodia.org

សព្វានិ ឯវ (បញ្ចសិក្ខាបទានិ) ទុរក្ខានិ ឥតិ ថា រីសិក្ខាបទ ១. ប្រាំទាំងពួងនុ៎ះឯង គឺបុគ្គលរក្សាបានដោយលំបាក (ដូចគ្នា) អភាសិ បានត្រាស់ហើយ គាថា នូវគាថា១. ឥមា នេះ ៗ ឧទាហរណ៍នេះ និយាយចំពោះ សព្វ-សព្វ និង ក-សព្វ, ពោះបើវិសេសនសព្វនាមដទៃ ក៏សូមអ្នកសិក្សា ធៀបគ្នា ដោយន័យនេះផងចុះ ៗ

ការយោគសព្វនាមនោះ មានវិធីដូចតទៅនេះ៖ បើសព្វនាមជាលិង្គ, វចនៈ, វិភត្តិណា គួនាមនាមដែលត្រូវយោគចូលមក ក៏ឲ្យមានលិង្គ, វចនៈ, វិភត្តិ ត្រូវនឹងសព្វនាមនោះ, ឯការន្តផ្សេងគ្នាក៏បានត្រូវគ្នាក៏បាន ដូច **សត្ថា បន តេន ហត្ថិនា ឧបដ្ឋិយមានោ សុខំ វសិ ។ សោបិ គណំ បហាយ ផាសុវិហារត្ថាយ តំ វនសណ្ឌំ បាវិសិ** ។ សោបិ ត្រូវយោគ ហត្ថី, សោ និង ហត្ថី មានលិង្គ, វចនៈ, វិភត្តិដូចគ្នាផ្សេងតែការន្ត គឺ សោជា អការន្ត, ហត្ថី ជាឦការន្ត, សោ និង ហត្ថី

យោគចូលគ្នាបានយ៉ាងស្រួល មិនខុសវិធីយោគសព្ទតាមទេ ដូចប្រែថា : «បន ចំណែកខាង សត្ថា ព្រះសាស្តា តេន ហត្ថិនា ឧបដ្ឋិយមានោ កាលដែលដំរីនោះបំរើ វែ ស្តេច គង់នៅហើយ សុខំ សប្បាយ ។ សោបិ-ហត្ថី រីឯដំរីនោះ បហាយ លះហើយ គណំ នូវហ្វូង បាវិសិ ចូលទៅហើយ វនសណ្ឌំ កាន់ដងព្រៃ តំ នោះ ផាសុវិហារត្ថាយ ដើម្បី ប្រយោជន៍ ដល់ការនៅសប្បាយ ។ ឧទាហរណ៍នេះ និយាយចំពោះ បុំ.ប.ឯក. ប៉ុណ្ណោះ, សូម្បីលិង្គ, វចនៈ, វិភត្តិផ្សេង ៗ អ្នកសិក្សាក៏គប្បីរៀបគ្នា ដោយន័យនេះចុះ ។ បើយោគឲ្យខុស លិង្គ, វចនៈ, វិភត្តិ ដូចយោគថា ឥមេ ឥត្ថី, តា បុរិសា, បរ-នារី (ខុសលិង្គ) យ៉ាងនេះក្តី ឥមេ ជនោ, តេ ជនំ (ខុស វចនៈ, វិភត្តិ) យ៉ាងនេះក្តី ប្រើ មិនបានឡើយ ។

វិធីយោគសព្ទតាម ក្រៅពីនេះនៅមានទៀត ជាវិធី ដែលអ្នកសិក្សាគួរសង្កេតឲ្យដឹង ដើម្បីជួយវិជ្ជារបស់ខ្លួនឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

រីកធំទូលាយដូចតទៅនេះ,

គ), ក្នុងប្រយោគដើមមានសំខ្យា ប្រាប់ចំនួនតាមនាម ដល់មកប្រយោគក្រោយ លោកតច្រើនមិនសូវរៀងសំខ្យា ប្រាប់ចំនួននោះទេ រៀងទុកតែវិសេសនសព្ទនាមៗ កាលបើដូច្នេះវេលាប្រែដែលនឹងឲ្យបានសេចក្ដីជាក់លាក់ល្អ គួរបំពេញសំខ្យាចំនួននោះមកប្រែគបផង ទើបសេចក្ដីក្នុងសង្កាត់ក្រោយនោះច្បាស់លាស់ ដូច **សេតព្យនគរវាសិ-សិនោ ហិ ចុល្លកាឡោ មជ្ឈិមកាឡោ មហា-កាឡោ ចាតិ តយោ ភាតរោ កុដុម្ពិកា ។ តេសុ ជេដ្ឋកនិដ្ឋា ទិសាសុ វិចរិត្វា បញ្ចហិ សកដ-សតេហិ ភណ្ឌំ អាហរន្តិ ។**

តេសុ ក្នុងសង្កាត់ក្រោយ ត្រូវយោគយកសំខ្យាក្នុងសង្កាត់ដើមមកផងថា តេសុ តីសុ កុដុម្ពិកេសុ ៗ ប្រែប្រយោគទាំងពីរសង្កាត់នោះ៖ ហិ សេចក្ដីពិស្ដារថា កុដុម្ពិកា រីកុដុម្ពិកៈ១. តយោ ៣ នាក់ ភាតរោ ជាបងប្អូន ឥតិ គឺចុល្លកាឡោ ច

វិចុល្លកាល១ មជ្ឈិមកាលោ ច វិមជ្ឈិមកាល ១ មហាកាលោ ច វិមហាកាល ១ សេតព្យនគរវាសិនោ មានកិរិយានៅក្នុងក្រុងសេតព្យៈជាប្រក្រតី (នេះសង្កាត់ដើម) ។ តេសុ.តីសុ កុដុម្ពិកេសុ បណ្ដាកុដុម្ពិកៈទ. ៣ នាក់នោះ - ជេដ្ឋកនិដ្ឋា វិកុដុម្ពិកៈជាបងបង្អស់ និងកុដុម្ពិកៈជាប្អូនពៅទ. វិចរិត្វា ក្រាប ទៅហើយផ្សេង ៗ ទិសាសុ ក្នុងទិសទ. អាហារត្ថិ ផ្ទុក កណ្ដាំ ខ្ទីរបស់ សកផលគេហា ដោយរយៃខេះទ. បញ្ចហិ ប្រាំ» (នេះសង្កាត់ក្រោយ) ។

ខ) ក្នុងប្រយោគដើម, ប្រយោគខ្លះមាន វា ឬ ច, បិ-សព្ទ ជាសមុច្ច័យ ឬ វិកប្ប ទំណុត្រង់ចន្លោះនៃបទនាម សម្រាប់រួបរួមឬ ញែកបទនាមឱ្យដាច់ចេញពីគ្នា, ដល់មកក្នុងប្រយោគក្រោយ វា, ច, បិ ក្ដី បទនាមនាមនោះ ៗ ក្ដី ក៏បាត់សល់ទៅតែឯសេចក្ដីគន់ះនៅជាប់ទាក់ទងគ្នា ព្រោះហេតុនោះ លោកទើបរៀងវិសេសនសព្ទនាម ទុកសម្រាប់ឱ្យយោគយកបទនាមនាមនោះ ៗ ព្រមទាំង វា, ច, បិ.សព្ទ ក្នុងវេលាដែលប្រែដូច **យេ ខោ កេចិ លោកេ អរហ-**

www.budinst.gov.kh www.elibraryofcambodia.org

ន្តោ ខា អរហត្តមគ្គំ ខា សមាបន្នា , អហំ **គេសំ** អញ្ញតរោ ។ គេសំ ក្រោយបទ អហំ ត្រូវយោគជា គេសំ អរហន្តានំ វា អរហត្តមគ្គំសមា-បន្នានំ វា ។ ប្រែតាំងពីសង្កត់ ៖ "បុគ្គលា រីបុគ្គលទ. យេ ខោ កេចិ ឯណានីមួយ លោកេ ក្នុងលោក អរហន្តោ វា ជាព្រះអរហន្តឬ អរហត្តមគ្គំ សមាបន្នា វា ឬ អ្នកដែលលុះអរហត្តមគ្គ, គេសំ-អរហន្តានំ វា អរហត្តមគ្គំ សមាបន្នានំ វា បណ្តាបុគ្គលទ. ជាព្រះអរហន្ត ឬអ្នកដែល លុះអរហត្តមគ្គនោះ អហំ រីខ្ញុំ អញ្ញតរោ មួយរូបដែរ" ។

៧- វិធីប្រែការ·សព្ទ

ការ·សព្ទ កាលភ្ជាប់ជាបទសមាសនឹងសព្ទដទៃ មានវិធី ប្រែបានច្រើនយ៉ាង តែបើសរុបយកត្រង់វិធីដែលលោកប្រើ ដោយច្រើន មាន ៤ យ៉ាង ។

www.budinst.gov.kh www.elibraryofcambodia.org

វិធីប្រែការ-សព្ទមាន ៤ យ៉ាង គឺ

១– សព្ទជានាមកិតកៈ ការសាធនៈ ប៉េរួមជាបទសមាសនឹងការ-សព្ទ ប្រែថា "ការៈនៃកិរិយា ... " (១) ឧ. **គមនការោ** "ការៈនៃកិរិយាទៅ" ។

២– សព្ទជាគុណនាមក្តី នាមនាមប្រើជាគុណនាមក្តី ប៉េរួមជាបទសមាសនឹងការសព្ទ ប្រែថា "ការៈនៃ ... ជា ..." ឧ. **រញ្ញោ មហន្តការោ** "ការៈនៃព្រះរាជា ជាធំ" **បុរិសស្ស រាជការោ** "ការៈនៃបុរសជាព្រះរាជា" ។

៣– សព្ទជាកិរិយាកិតកៈ ប្រកបត-បច្ច័យ ប៉េរួមជាបទសមាសនឹងការ.សព្ទ ប្រែថា "ការៈនៃ...ជាអ្នក ... " ឧ. **ភិក្ខុនោ និសិន្នការោ** "ការៈនៃភិក្ខុ ជាអ្នកអង្គុយហើយ" ។

(១) លទ្ធិអាចារ្យខ្លះប្រែថា "ការៈគឺកិរិយា ... " គមនការោ "ការៈគឺកិរិយាទៅ" ។

៦- សព្ទជានាមនាមក្តី នាមកិតកៈ កត្តុសាធនៈក្តី បើរួមជាបទសមាសនឹងការ.សព្ទ ប្រែថា "ការៈនៃ..." **ឧ.សហាយការោ** "ការៈនៃសំឡាញ់", **ឃាតក-ការោ** "ការៈនៃបុគ្គលអ្នកសម្លាប់" ។

សម្រាប់បទការកទ្ធិត ដែលប្រកបបច្ច័យ ក្នុងការកតទ្ធិត ទាំងអស់មានកា-បច្ច័យជាដើម ដែលប្រើជំនួសការ.សព្ទ នោះ ក៏មានវិធីប្រែ ៦ យ៉ាង ដូចគ្នានឹងការ.សព្ទ ដែលភ្ជាប់ជាបទសមាសដែរ ។

៨– វិធីប្រែវិសេសនៈ

វិសេសនៈនេះ បានដល់គុណសព្ទ និងវិសេសនសព្វនាម ដែលបានពោលរួចមកហើយ ក្នុងវិធីដើរប្រយោគ ។ គុណ-សព្ទនោះ ជាពាក្យប្រាប់លក្ខណៈរបស់នាមនាម ថាជាបែប

www.budinst.gov.kh www.elibraryofcambodia.org

ណា ៗ មានរូប សណ្ឋាន ពណ៌ យ៉ាងណា ៗ ដូចលើកមក ទុកល្មមជាទីសង្កេត តទៅនេះ ៖

ប្រាប់បែប ដូច អាក្រក់, ល្អ, ក្មេង, ចាស់, កំឡោះ ក្រមុំៗ

ប្រាប់ពណ៌ ដូច ស, ខ្មៅ, ក្រហម, ខៀវ, លឿង ៗ

ប្រាប់រស ដូច សាប, ប្រៃ, ជូ, ចត់, ល្វីង, ផ្អែម ៗ

ប្រាប់សម្ផ័ស្ស ដូច ត្រជាក់, ក្ដៅ, ទន់, រឹង, គ្រើមៗ, គគ្រាត

ប្រាប់ខ្នាត ដូច ធំ, ធាត់, តូច, ឆ្ងាយ, ក្រាស់, ស្ដើង, វែង, ខ្លីៗ

ប្រាប់ភេទឬអាការ; ដូច មានប្រាជ្ញា, ល្ងង់, ខ្លាំ, ស្លូត, កាចៗ

ប្រាប់សណ្ឋាន ដូច មូល, សំប៉ែត, កៀ, ខ្ពស់, ទាប ៗ

ប្រាប់ចំនួនរាប់នាម ដូច ១, ២, ៣, ៤, ៥, ជាដើម ៗ

ប្រាប់ចំនួនរាប់បង្គ្រប់នាម ដូច ទី ១, ទី ២ ជាដើម ៗ

ចំណែកវិសេសនសព្ទនាមនោះ ជាពាក្យសំដែងសេចក្ដីពិតប្រាកដរបស់នាម ដូច នេះ, នុ៎ះ, នោះ, ទាំងពួង, ឯណោះ ដែលហៅថានិយតៈ១ សំដែងសេចក្ដីមិនពិតប្រាកដរបស់នាម ដូច ដទៃ, ដទៃទៀត, ឯណា, អ្វី ជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ដែលហៅថា អទិយក: ១ ។ ពាក្យថា វិសេសន: ។ នេះ សំគាល់សេចក្តីថា ជាសព្ទមានឧបការៈមួយផ្នែក ដល់នាមនាម ទំនុកបម្រុងនាមនាម ឲ្យមានសេចក្តីប្លែកចាកការគតដើម គឺ ទាញនាមនាម ឲ្យឡើងកាន់ជាន់បកតិគុណនាមខ្លះ ឲ្យឡើងកាន់ជាន់វិសេសគុណនាមខ្លះ ឲ្យឡើងកាន់ជាន់អតិវិសេសគុណនាមខ្លះ ។

ការប្រើវិសេសន: ត្រូវអនុវត្តទៅតាមប្រភេទ នៃនាមនាម ដូច្នេះ៖

១. មនុស្សសាមញ្ញ ប្រែថា អ្នក, ជា

២. មនុស្សជាន់ខ្ពស់ ,, ព្រះអង្គ, ទ្រង់, លោកជា

៣. ទេវតា, ទេវបុត្រ ,, អង្គ, អង្គជា

៤. បព្វជិត ,, រូប, លោក, ជា

៥. សត្វ ,, ជា ឬប្រែទទេ ។

៦. វិហារ ,, ដ៏, ដែល, ជា

www.budinst.gov.kh www.elibraryofcambodia.org

៧ - គម្ពីរ ប្រែថា ឿន, ក្បាល

៨ - នាមនាមឆ្អឹងមូល ,, រង់

៩ - នាមនាមមានជំហួល ,, ខ្នង

១០ - នាមនាមសំប៉ែត ,, ផែន

១១ - នាមនាមទ្រវែង ,, ដៃ, ជ្រុង

១២ - នាមនាមមូលវែង ,, ដើម

១៣ - នាមនាមមានស្ទើ ,, ដុង

១៤ - នាមនាមជាសរសៃ ,, កន្ទុយ, បន្ទាយ, សរសៃ

១៥ - ប្រែផ្ទុនគាមនាមដើម ។

ឧទាហរណ៍

១) **វិសេសនៈប្រាប់ប្រភេទ** ចំពោះសេសនៈរបស់មនុស្ស

សាមញ្ញទូទៅ លោកបញ្ញត្តឲ្យប្រែថា « អ្នក, ជា » ឧ.

ឧគ្គោ ជនោ « ជន អ្នកប្រសប់ », **បណ្ឌិតោ ជនោ**

« ជន ជាបណ្ឌិត » ។

www.budinst.gov.kh www.elibraryofcambodia.org

បើវិសេសនៈរបស់មនុស្សថ្នាក់ខ្ពស់ ដូច ព្រះពុទ្ធ, ស្ដេច, ទេវតាជាធំ, ចៅហ្វាយនាយជាន់ខ្ពស់ ប្រែថា "ព្រះអង្គ, ព្រះកជា, ទ្រង់, ទ្រង់ជា, លោក, លោកជា" ឧ. **មហាការុណិកោ ពុទ្ធោ** "ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកបដោយមហាករុណា", **អធិបតិ រាជា** "ស្ដេចទ្រង់ជាធំក្រៃលែង", **មហទ្ធនោ សេដ្ឋី** "សេដ្ឋីលោកមានទ្រព្យច្រើន" ។

បើវិសេសនៈរបស់ទេវតា, ទេវបុត្រ ប្រែថា "អង្គ, អង្គជា" ឬបើបទណា ដែលប្រែចេញពាក្យទាំងនេះទៅ នាំឲ្យឆ្គងសេចក្ដី នោះមិនបាច់ថាក៏បាន ឧ. **ឯកោ ទេវោ** "ទេវតា អង្គមួយ ឬ មួយអង្គ", **ឥទ្ធិកោ ទេវោ** "ទេវតា មានរិទ្ធិ" ។

បើវិសេសនៈរបស់ភិក្ខុ, សាមណេរ, សមណៈប្រព្រឹត្តវត្តផ្សេងៗ ប្រែថា "រូប, រូបជា, លោក, ជា" ឧ. **ទ្វេ**

www.budinst.gov.kh www.elibraryofcambodia.org

តិត្ថ “កំពង់. ពីរលូប” **អារទ្ធវីរិយោ តិត្ថំ** “កំពង់លោកមានសេចក្តីព្យាយាមតឹងតែង”, **ថេរោ តិត្ថំ** “កំពង់ ជាថេរៈ” ។

បើវិសេសនៈ របស់សត្វ ប្រែថា “ជា” ឬក៏ប្រែទទេ ។

ឧ. **ចណ្ឌោ សត្តោ** “សត្វកាច”, **យូថជេដ្ឋកោ សត្តោ** “ សត្វ ជានាយហ្វូង ” ។

បើវិសេសនៈរបស់ទីឋាន, វត្ថុផ្សេងៗ ឬ អំពើល្អ និងអំពើអាក្រក់ ប្រែថា “ដ៏, ដ៏ជា, ជា, ដែល, ដែលជា” ឧ. **សីតំ ឋានំ** “ ទី ដ៏ត្រជាក់”, **វនប្បតិ រុក្ខោ** “ដើមឈើដ៏ជាម្ចាស់នៃព្រៃ”, **សុន្ទរោ ធម្មោ** “ ធម៌ដែលល្អ” , **អប្បមត្តកំ វត្ថុ** “ វត្ថុ ដែលមានប្រមាណតិច ” ។

បើវិសេសនៈ របស់ពាក្យពេចន៍, សេចក្តី និងរឿងការផ្សេងៗ ប្រែថា “រឿង” ឧ. **សុខុមំ អដ្ឋំ** “ក្តីរឿងល្អិត” ។

បើវិសេសនៈរបស់គម្ពីរ, សៀវភៅ, សាស្ត្រាផ្សេងៗ, ម៉ែត្រ ប្រែថា “ក្បាល” ឧ. **ឯកោ ពោត្ថកោ** “សៀវ.

គោ មួយក្បាល» ។

បើវិសេសនសព្វនាម ខាងឯកវចនៈ ប្រែថា «អ្នក, ព្រះអង្គ, អង្គ, រូប, ដ៏, ដ៏ជា, ដែល, ក្បាល» តាមប្រភេទនៃនាមនោះ ៗ ឧ. **អយំ បុរិសោ** «បុរសរូបនេះ» ។ ខាងពហុវចនៈ ប្រែថា «ពួក» ឧ. **តេ ជនា** «ជនទ៎- ពួកនោះ» ។

២) វិសេសនៈប្រាប់សណ្ឋាន, សណ្ឋានរបស់នាម មានច្រើនបែបច្រើនយ៉ាង ប្លែកគ្នាណាស់ មិនអាចនាំមកពណ៌នាឲ្យអស់បានទេ ខ្ញុំនាំមកសំដែងល្មមជាទីសង្កេត ដូចតទៅនេះ ៖

បើវិសេសនៈ របស់នាម ដែលមានសណ្ឋានជាវត្ថុធំមូល ដូចចិញ្ចៀន, កង់ កង, ចំហួរ ប្រែថា «វង់» ឧ. **មហន្តា មុទ្ទិកា** «ចិញ្ចៀនវង់ធំ» ។

បើវិសេសនៈរបស់នាម ដែលមានរូបរាងជាដុំមូល ដូចផ្ទះ, ខ្ទម, កូបដំរី, ផ្ទះរទេះ, បុស្បុក, មុង ។ល។ ប្រែថា «ខ្នង» ឧ. **ឯកំ គេហំ** «ផ្ទះមួយខ្នង» ។

www.budinst.gov.kh www.elibraryofcambodia.org

បើវិសេសនៈរបស់នាម ដែលមានរូបសំប៉ែត ដូច ឥដ្ឋ, ក្បឿង, ក្ដារខៀន, ក្រដាស ជាដើម ប្រែថា «ផែន» ឧ. **តំ ឥដ្ឋំ** «ឥដ្ឋ ផែននោះ» ។

បើវិសេសនៈរបស់នាម ដែលមានរូបសំប៉ែតធំទ្រវែង ដូចសំពត់, ព្រែ, ព្រំ, កន្ទេលជាដើម ប្រែថា «ផ្ទៃ, ផ្ទាំង» ឧ. **ទីឃំ ទុស្សំ** «សំពត់ ផ្ទៃវែង ឬ ផ្ទាំងវែង» ។

បើវិសេសនៈរបស់នាម ដែលមូលវែងរៀវ ដូច សសរ, បន្ទាត់, ខ្មៅដៃ, ខៀន, ធូប ជាដើម ប្រែថា «ដើម» ឧ. **ឯកោ ថម្ភោ** «សសរ មួយដើម», **សា កទលិ** «ចេក ដើមនោះ» ។

បើវិសេសនៈរបស់នាម ដែលមូល ៗ ឬ មានពន្លឺរស្មី ដូច ថ្ងៃ, ខែ, ផ្កាយ, ភ្លើង, ចិត្ត, វិញ្ញាណ ប្រែថា «ដួង» ឧ. **អយំ តារា** «ផ្កាយ ដួងនេះ», **តំ ចិត្តំ** «ចិត្ត ដួងនោះ» ។

បើវិសេសនៈរបស់នាម ដែលជាសរសៃតូចវែង ប្រែថា

www.budinst.gov.kh www.elibraryofcambodia.org

«កន្ទុយ, ចង្កាយ, សរសៃ» ឧ. **ឯកំ សុត្តំ** «អម្បោះមួយសរសៃ», **ឯកា រជ្ជុ** «ខ្សែមួយកន្ទុយ», **ឯកា ទរត្តា** «ព្រ័ត្រមួយចង្កាយ» ៗ

៣) **វិសេសនៈប្រាប់ផ្ទួននឹងនាមដើម**, នាមនាមខ្លះមិនត្រូវការនឹងប្រាប់លក្ខណៈដូចខាងលើនោះទេ, កាលបើប្រែបទវិសេសន ដូច្នោះ ត្រូវយកនាមដើមនោះឯង មកប្រើជាពាក្យវិសេសនៈប្រកបនឹងបទវិសេសនៈនោះ ៗ ឧ. **ទ្វេបទេសា** «ប្រទេសទ. ពីរប្រទេស», **ឯកោ គាមោ** «ស្រុកមួយស្រុក», **ចត្តារោ អាវាសា** «វត្តទ. បួនវត្ត» ៗ

ពាក្យប្រែវិសេសនៈ ដែលបាននាំមកពោលក្នុងទីនេះមិនទាន់អស់ទេ, អ្នកសិក្សា គួរជ្រើសរើសយកពាក្យវិសេសនៈក្រៅពីនេះ ដោយខ្លួនឯង ហើយប្រកបប្រែឲ្យត្រឹមត្រូវនឹងប្រភេទនៃនាមនោះ ៗ ផងចុះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

៩- វិធីប្រែវិកតិកត្តា

សព្ទពួកណា គួរយកជាវិកតិកត្តា ? សព្ទគុណនាមក្តី សព្ទនាមនាមប្រើជាគុណនាមក្តី សព្ទកិរិយាកិតកៈប្រកបព្យ-យប្បច្ច័យក្តី គួរយកជាវិកតិកត្តា ។ ឯសព្ទពួកនោះ កាលប្រកបវិភត្តិហើយ នឹងប្រើជាវិកតិកត្តាបានគ្រប់វិភត្តិក៏មិនមែនទេ ប្រើបានចំពោះតែ ២ វិភត្តិ គឺ បឋមាវិភត្តិ និង តតិយា-វិភត្តិ ។

បទវិកតិកត្តា

សព្ទជាគុណនាម, សព្ទជានាមនាមប្រើជាគុណ, សព្ទជាកិរិយាកិតកៈប្រកបព្យយប្បច្ច័យ ដែលប្រែជាវិកតិកត្តា បានត្រូវប្រកបដោយអង្គ ៣ គឺ សព្ទនោះប្រកបបឋមាវិភត្តិ ឬតតិយាវិភត្តិ នេះជាអង្គ ១, អាស្រ័យកិរិយាសព្ទ សម្រេចមកអំពីធាតុ ៤ តួ គឺ ហុ, ភូ, អស, ជន មានគន្លងប្រយោគនោះ ៗ នេះជាអង្គ ១, សព្ទពួកនោះ លោករៀបទុកនៅខាងមុខ ឬខាងក្រោយ នៃកិរិយាសព្ទ ៤ តួនុ៎ះ តួណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

មិនមានបទដទៃទាក់ទងនឹងបទនោះ នេះជាអង្គ ១, កាលបើព្រមដោយអង្គទាំង ៣ នេះ ទើបឲ្យឈ្មោះសព្ទនោះថាជា បទវិកតិកត្តា ។

វិធីប្រែបទវិកតិកត្តានោះ ត្រូវទាញយកបទបកតិកត្តាជាគោល, ដ្បិតបកតិកត្តាមានច្រើនបែប សូម្បីបែបមួយៗ ក៏មានភេទផ្សេងៗ គ្នា ដែលហៅថាលិង្គ គឺ ជាបុំលិង្គខ្លះ ជាឥត្ថីលិង្គខ្លះជានបុំសកលិង្គខ្លះ ។ បើបទបកតិកត្តាជាបុំលិង្គ ប្រែវិកតិកត្តាដោយខ្សែក, ជាឥត្ថីលិង្គ ប្រែដោយខ្សែក, ជានបុំសកលិង្គប្រែដោយខ្សែក ។ ព្រោះហេតុដូច្នោះ ការប្រែបទវិកតិកត្តាត្រូវតែពិនិត្យបទបកតិកត្តា ដែលជាបទធ្ងុះ បំភ្លឺផ្លូវឲ្យ ទើបអាចប្រែត្រឹមត្រូវបាន ។

ការប្រែបទវិកតិកត្តាត្រូវអនុវត្តតាមលិង្គរបស់បកតិកត្តាដូច្នេះ៖

១– ពួកបុគ្គល បុំលិង្គ ប្រែថា ជាអ្នក, ជាមនុស្ស, ជាបុរស

,, ឥត្ថីលិង្គ ,, ជាអ្នក, ជាស្រី

២– ពួកសត្វ បុំ. ,, ជាសត្វ

,, ឥ. ប្រែថា ជាសត្វ

៣– ពួកកងកាយ ចុំ. ,, ជាខ្លួន, ជាអត្តភាព, ជាអវយវៈ

,, ឥ. ,, ជាធម្មជាតិ

,, ខចុំ. ,, ជាធម្មជាត

៤– ពួកទីឋាន ចុំ. ,, ជាប្រទេស,-ស្រុក,-ក្រុង

,, ឥ. ,, ជាភូមិ

,, ខចុំ. ,, ជាទី, ជាឋាន, ជាភូមិឋាន

៥– ពួករបស់ប្រើ ចុំ. ,, ជារបស់, ជាអាហារ

,, ខចុំ. ,, ជាវត្ថុ ជាអាហារវត្ថុ

៦– ពួកធម៌ល្អ ចុំ. ,, ជាធម៌, សភាវៈគុណ-គុណធម៌

,, ឥ. ,, ជាធម្មជាតិ, ជាគុណជាតិ

,, ខចុំ. ,, ជាធម្មជាត, ជាគុណជាត

៧– ពួកធម៌អាក្រក់ ចុំ. ,, ជាកិលេស, ជាទោស

,, ឥ. ,, ជាកិលេសជាតិ, ជាទោសជាតិ

,, ខចុំ. ,, ជាកិលេសជាត ជាទោសជាត ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍

១) ពួកបុគ្គល, *បកតិកត្តាជាបុំលិង្គ ប្រែកតិកត្តាថា "ជាអ្នក, ជាមនុស្ស, ជារបស់"* ។. **តេ: តណ្ហាវសិកា បុគ្គលា សាតនិស្សិតាៈ សុខនិស្សិតា ច ហុត្វា, សុខេសិនោ: សុខបរិយេសិនោ ហោន្តិ**[១] *(ប្រែ) "បុគ្គលា រីបុគ្គលទ. តេ ពួកនោះ តេ គឺថា តណ្ហាវសិកា ។ អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃតណ្ហា សាតនិស្សិតា: សុខនិស្សិតា ហុត្វា ជាអ្នកអាស្រ័យហើយនូវសេចក្ដីត្រេកអរ គឺថា ជាអ្នកអាស្រ័យហើយនូវសេចក្ដីសុខនុ៎ះឯង, សុខេសិនោ :*

---

១ សម្ពន្ធ: បុគ្គលា បកតិកត្តាក្នុង ករន្តិ ។ អាខ្យាតបទ កត្តុវាចកៈ របស់បុគ្គលា, តេ វិវរណៈក្នុង តណ្ហាវសិកា។ វិវរណីយៈរបស់ តេ, តេ និង តណ្ហាវសិកាវិសេសនៈរបស់ បុគ្គលា. សាតនិស្សិតា វិវរណៈក្នុង សុខនិស្សិតា ។ វិវរណីយៈរបស់ សាតនិស្សិតា សាតនិស្សិតានិងសុខនិស្សិតា វិកតិកត្តាក្នុង ហុត្វា ។ សមានកាលកិរិយាក្នុង ករន្តិ (សុខេសិនោ, សុខបរិយេសិនោ សម្ពន្ធដូច សាតនិស្សិតា. សុខនិស្សិតា. ប្លែកតែបទនេះ ត្រូវចូលក្នុងករន្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

សុខបរិយេសិនោ ភវន្តិ រមែងជាអ្នកស្វែងរកនូវសេចក្តីសុខ បានដល់ជាអ្នកស្វះស្វែងរកនូវសេចក្តីសប្បាយ» ។ **ភិក្ខុនា នាម រាជេន វិយ សុខេន ភវិតព្វំ** (១) *(ប្រែ) “ភិក្ខុនា នាម ដែលឈ្មោះថាភិក្ខុ រាជេន វិយ សុខេន ភវិតព្វំ គប្បីជាអ្នកត្រូវគេប្រដៅងាយ ដូចជារាជភិក្ខុ”* ។ **បុត្តោ ហិ មេ អសន្តាសី វីតតណ្ហោ មហាវីរិយោ មហាបញ្ញោ (ហោតិ)** *(ប្រែ) “ហិ ក៏ បុត្តោ វីបុត្រ មេ របស់តថាគត អសន្តាសី វីតតណ្ហោ មហាវីរិយោ មហាបញ្ញោ ហោតិ រមែងជាមនុស្សមានកិរិយាមិនតក់ស្លុតជាប្រក្រតី ជាមនុស្ស* (២) *មានតណ្ហាទៅប្រាសហើយជាមនុស្ស*(២) *មានវីរិយៈច្រើន ជាមនុស្ស* (២) *មានប្រាជ្ញាច្រើន»* ។

---

១ សម្ពន្ធៈ ភិក្ខុនា បកតិអនភិហិតកត្តាក្នុង ភវិតព្វំ។ ភិតបទ ភាវវាចកៈ, នាម សញ្ញាជោតកៈក្នុងភិក្ខុនា, រាជេន ឧបមាវិសេសន របស់ ភិក្ខុនា, វិយ-សព្ទឧបមាជោតកៈ ក្នុង រាជេន, សុខេន វិកតិអនភិហិតកត្តាក្នុង ភវិតព្វំ ។

២ ពាក្យ វិកតិកត្តាច្រើនបទ ថាតែ១បទខាងដើមក៏បានដែរ ដើម្បីកុំឲ្យសាំ។

www.budinst.gov.kh www.elibraryofcambodia.org

បកតិកត្តាជាឥត្ថីលិង្គ ប្រែថា ជាអ្នក “ជាស្រី” ឧ. **សា វញ្ឈា អហោសិ** (ប្រែ) “សា កុមារិកា ស្រីកុមារិកា នោះ វញ្ឈា អហោសិ បានជាស្រីអារហើយ” ។ **អយំ មេ សហាយិកា ឥទានិ ពហុបការា (ហោតិ)** (ប្រែ) “សហាយិកា ស្រីជាសំឡាញ់ មេ របស់អញ អយំ នេះ ឥទានិ ពហុបការា ហោតិ ជាអ្នកមានឧបការៈច្រើន ក្នុងកាលឥឡូវនេះ” ។

២) ពួកសត្វ, បកតិកត្តាជាបុំលិង្គ និង ឥត្ថីលិង្គប្រែដូចគ្នាថា “ជាសត្វ” ឧ. **ឯតមេត យេ សត្តា រាគរត្តា ទោសទុដ្ឋា មោហមុឡ្ហា (ហោន្តិ)** (ប្រែ) “សត្តា សត្វ១. យេ ពួកណា រាគរត្តា ទោសទុដ្ឋា មោហមុឡ្ហា ហោន្តិ ជាសត្វត្រេកអរហើយដោយអំណាចនៃរាគៈ(១) ប្រទុស្តហើយដោយអំណាចនៃទោសៈ (២)វង្វេងហើយដោយអំណាចនៃមោហៈ” ។

ដដែល១ តែផល់សម្ពន្ធ ត្រូវហៅថា វិកតិកត្តា ។

១-២ បំបាត់ពាក្យថា “ជាសត្វ” ដើម្បីកុំឲ្យសាំទ្ធាន់ ៗ ។

www.budinst.gov.kh www.elibraryofcambodia.org

៣) ពួករាងកាយ, ជាទីប្រជុំនៃចំណែកសរីរៈតូចធំ ដូចកាយ, ជនខ្លួន បកតិកត្តាជាបុំលិង្គ ប្រែថា "ជាខ្លួន ជាអត្តភាព" ឧ. **ឯទំបិ តេន អត្តា បដិជគ្គិតោ ច ហោតិ** (ប្រែ) "ចំ ក៏ ឯ ការណ៍ នោកាលហេតុយ៉ាងនេះ (សម្តេចកាលមាន) អត្តា ខ្លួន តេន បដិជគ្គិតោ ហោតិ ឈ្មោះថា ជាអត្តភាពគឺគេគ្រប់គ្រងហើយពិត" ។ **អបវិទ្ធោ អបគតវិញ្ញាណកាយ តុច្ឆោ (១) ហុត្វា សេស្សតិ** (ប្រែ) "(អយំកាយោ រីកាយនេះ) អបវិទ្ធោ ដែលបុគ្គលចោលហើយ អបគតវិញ្ញាណកាយ តុច្ឆោ ហុត្វា ឈ្មោះថា ជាអត្តភាពទទេ ព្រោះភាពនៃកាយនេះ ជាអត្តភាពមាន

១ បទនេះ លោកលើកយកពីគាថាមក, បើមានបទប្រកបគតិយា ឬ បញ្ចមីវិភត្តិរៀងទុកនៅខាងមុខ ដែលប្រែថា "ព្រោះ, ហេតុ" ហើយ សម្ពន្ធចូលក្នុងបទដែលមានក្នុងគាថានោះ ត្រូវប្រែបទវិកតិកត្តាជាកល់ ហេតុថា "ឈ្មោះថា" ចំណែកសម្ពន្ធ ត្រូវហៅតាមធម្មតា ដូច សម្ពន្ធថា តុច្ឆោវិកតិកត្តាក្នុង ហុត្វា។ សមានកាលកិរិយាក្នុង សេស្សតិ ។

www.budinst.gov.kh www.elibraryofcambodia.org

វិញ្ញាណ ទៅប្រាសហើយ សេសត្រិ ខឹងដេក ។

បើជាអវយវៈធំតូច មានដៃជើងជាដើម ប្រែថា "ជាអវយវៈ" ឧ. **មហល្លកស្ស ហត្ថបាទាបិ អនស្សវា ហោន្តិ** (ប្រែ) "មហល្លកស្ស ហត្ថបាទាបិ សូម្បីដៃនិងជើងទ. នៃបុគ្គលចាស់ អនស្សវា ហោន្តិ រមែងជាអវយវៈមិនស្ដាប់បង្គាប់" ។

បកតិកត្តាជាឥត្ថីលិង្គ ប្រែថា "ជាធម្មជាតិ" ឧ. **អង្គុលិយោ សោភណា (ហោន្តិ)** (ប្រែ) អង្គុលិយោ ម្រាមដៃទ. សោភណា ហោន្តិ ជាធម្មជាតិល្អ" ។

បកតិកត្តាជានបុំសកលិង្គ ប្រែថា "ជាធម្មជាត" ឧ. **គត្តំ បូតិកំ ជាតំ** (ប្រែ) "គត្តំ ខ្លួន បូតិកំ ជាតំ ជាធម្មជាតស្អុយ" ។ **មុខំ សោភណំ (ហោតិ)** (ប្រែ) "មុខំ មុខ សោភណំ ហោតិ ជាធម្មជាតល្អ" ។

(៤) **ពួកទីឋាន** ដូចស្រុក, ក្រុង, ប្រទេស, តំបន់,

www.budinst.gov.kh www.elibraryofcambodia.org

និគម, ជនបទ, ផ្ទះ ជាដើម, បទបកតិកត្តាជាបុំលិង្គ ប្រែថា "ជាប្រទេស" ១. **គាមោ សុន្ទរោ ហោតិ** (ប្រែ) "គាមោ ស្រុក សុន្ទរោ ហោតិ ជាប្រទេសល្អ" ។

បកតិកត្តាជានបុំសកលិង្គ ប្រែថា "ជាទី" ១. **នគរំ នាម ពហិទ្ធា ថិរំ ហោតិ គម្ភីរបរិខំ បាការបរិក្ខិត្តំ ទ្វារដ្ដាលកយុត្តំ** (ប្រែ) "នគរំ នាម ធម្មតា ទីក្រុង គម្ភីរបរិខំ ដែលមានស្នាមភ្លោះ (គូ) ដ៏ជ្រៅ បាការបរិក្ខិត្តំ ដែលបុគ្គលបិទបាំងហើយដោយកំពែង ទ្វារដ្ដាលកយុត្តំ ប្រកបហើយដោយទ្វារនិងប៉ម ពហិទ្ធា ថិរំ ហោតិ ឈ្មោះថា ជាទីមាំមួនខាងក្រៅ„ ។

បទបកតិកត្តាជាឥត្ថីលិង្គ វិធីប្រែបទវិកតិកត្តា មិនមានទេ ។ ចំណែកបទបកតិកត្តាជាបុំលិង្គ និងនបុំសកលិង្គ បើញែកប្រែតាមបកតិកត្តានោះជាលិង្គ ១ មិនពិរោះស្ដាប់ទេ គប្បីយកពាក្យប្រែបកតិកត្តានោះ មកប្រើជាវិកតិកត្តាថា "ជាស្រុក, ជាក្រុង ជាប្រទេស, ជាតំបន់ ជានិគម, ជាជនបទ,

www.budinst.gov.kh www.elibraryofcambodia.org

ជាផ្ទះ" ជាដើម ១. **មនុស្សាវាសោ សបរិបន្ថោ (ហោតិ)** *(ប្រែ) "មនុស្សាវាសោ ប្រទេសជាទីនៅរបស់មនុស្ស សបរិបន្ថោ ហោតិ រមែងជាប្រទេសប្រព្រឹត្តទៅមួយអន្លើដោយអន្តរាយ"* ។ **នគរំ នាម អន្តោសុចិកត្តំ (ហោតិ) វីថិចតុក្កសិង្ឃាដកសម្បន្នំ អន្តរាបណំ** *(ប្រែ) "នគរំ នាម ឈ្មោះនគរ វីថិចតុក្ក-សិង្ឃាដកសម្បន្នំ ដែលសម្បូណ៌ដោយថ្នល់បែកជា ៤ និងថ្នល់បែកជា ៣ អន្តរាបណំ មានរានផ្សារក្នុងចន្លោះ អន្តោសុចិកត្តំ ហោតិ ឈ្មោះថាជានគរគឺបុគ្គលចាក់ថែងល្អហើយក្នុងខាងក្នុង"* ។

មួយទៀត ភូមិភាគ ដូច ចំការ, ស្រែ, សួនច្បារ, ផែនដី ជាដើម ដែលជាបុំលិង្គ ប្រែថា «ជាភូមិភាគ», ដែលជាឥត្ថី-លិង្គ ប្រែថា «ជាភូមិ» ដែលជានបុំសកលិង្គ ប្រែថា "ជាភូមិឋាន " ១. **អសុកគ្គាមតោ អសុកគ្គាមគមន -**

www.budinst.gov.kh www.elibraryofcambodia.org

ដ្ឋានេ(១) **ភូមិភាគំ សមំ . . . ហោតិ** *(ប្រែ) "(ភូមិភាគ ផ្នែកនៃផែនដី) គស្រុកគ្គាមគមនដ្ឋានេ ក្នុងទីជាទីទៅ កាន់ស្រុកឯណោះ សមំ ហោតិ ជាភូមិរាបស្មើ" . . . ។*

៥) ពួករបស់ប្រើផ្សេង ៗ *មានសំពត់ស្លៀក. សំពត់ដណ្ដប់ជាដើម, បកតិកត្តាជាបុំលិង្គ ប្រែថា "ជារបស់" ន.*

ឥមំ សរីរំ និស្សាយ ឯករូបោ បរិសុទ្ធោ សាដកោ បកតី ជហិត្វា កិលិដ្ឋោ ជាតោ *(ប្រែ) "សាដកោ សំពត់សាដក បរិសុទ្ធោ ដ៏បរិសុទ្ធ ឯករូបោ មានសភាពយ៉ាងនេះ ជហិត្វា លះហើយ បកតី នូវប្រក្រតី កិលិដ្ឋោ ជាតោ ទៅជារបស់សៅហ្មងហើយ និស្សាយ ព្រោះតែអាស្រ័យ សរីរំ នូវសរីរៈ ឥមំ នេះ" ។*

---

១ បទនេះ ប្រកបសត្តមីវិភត្តិ បើប្រែកាង់ជាបឋមាវិភត្តិវិញក៏បាន ហៅថា សត្តមីបច្ចត្តបកតិកត្តា ចូលក្នុងហោតិ, បើប្រែកាច់ កុំបញ្ចូល ភូមិភាគំ ។

www.budinst.gov.kh www.elibraryofcambodia.org

បកតិកត្តាជានបុំសកលិង្គ ប្រែថា "ជាវត្ថុ" ឧ. **តស្ស តំ បិលោតិកខណ្ឌំ បរិមជ្ជន្តស្ស កិលិដ្ឋំ អហោសិ**(ប្រែ) "តស្ស-ចូឡបន្ថកស្ស កាលព្រះចូឡបន្ថកៈ នោះ បរិមជ្ជន្តស្ស កាលញ៉ូ បិលោតិកខណ្ឌំ នូវចំណែក នៃកំណាត់សំពត់ តំ នោះ (តំរៀតរុំសំពត់នោះ) កិលិដ្ឋំ អហោសិ បានក្លាយជាវត្ថុសៅហ្មងហើយ" ។

មួយទៀត វត្ថុដែលជាអាហារប្រើបរិភោគបាន, បើ បុំលិង្គប្រែថា "ជាអាហារ", បើនបុំសកលិង្គ ប្រែថា "ជាអាហារវត្ថុ" ឬ "ជាវត្ថុ", ដែលជាទ្រព្យរបស់ បើបុំលិង្គ ប្រែថា "ជាភោគៈ", បើឥត្ថីលិង្គ ប្រែថា "ជាសម្បត្តិ", បើនបុំសកលិង្គ ប្រែថា "ជាទ្រព្យ" ឧ. **សេដ្ឋិនោ ធនំ អឌ្ឍំ ហោតិ** (ប្រែ) "ធនំ ទ្រព្យ សេដ្ឋិនោ នៃសេដ្ឋី អឌ្ឍំ ហោតិ ជាទ្រព្យស្តុកស្តម្ភ" ។

៦– **ពួកធម៌** បកតិកត្តាជាបុំលិង្គ, បើធម៌ចំណែកខាងល្អ

www.budinst.gov.kh www.elibraryofcambodia.org

ប្រែវិកតិកត្តាថា ‹‹ជាធម៌, ជាសភាព, ជាគុណ, ជាគុណធម៌›› ១. **អដ្ឋង្គិកោ មគ្គោ សេដ្ឋោ ឧត្តមោ (ហោតិ)** (ប្រែ) ‹‹មគ្គោ រីមគ្គ អដ្ឋង្គិកោ មានអង្គ ៨ សេដ្ឋោ ឧត្តមោ ហោតិ ជាធម៌ប្រសើរផុត គឺ ជាធម៌ដ៏ខ្ពង់ខ្ពស់›› ។ **ចិត្តស្ស ទមថោ សាធុ (ហោតិ)** (ប្រែ) ‹‹ទមថោ រីការទូន្មាន ចិត្តស្ស នូវចិត្ត សាធុ ហោតិ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច›› ។ បើធម៌ចំណែកខាងអាក្រក់ប្រែថា ‹‹ជាកិលេស, ជាធម៌, ជាទោស›› ឬថាត្រឹមតែ ‹‹ជា›› ក៏បាន ។. **អកុសលា ធម្មា បន ឥធ លោកេ ច បរលោកេ ច មលមេវ (ហោន្តិ)** (ប្រែ) ‹‹បន ក៏ ធម្មា រីធម៌ទ. អកុសលា ជាអកុសល ឥធ លោកេ ច បរលោកេ ច មលំ ឯវ ហោន្តិ រមែងជាគ្រឿងសៅហ្មង ទាំងក្នុងលោកនេះទាំងក្នុងលោកខាងមុខមែនពិត›› ។

បកតិកត្តាជាឥត្ថីលិង្គ, បើធម៌ចំណែកខាងល្អ ប្រែថា ‹‹ជា

ធម្មជាតិ, ជាគុណជាតិ» ឬថាត្រឹមតែ «ជា» ក៏បាន ៖ **ឯតេសុ ចតូសុ យា ឯសា បញ្ញា នាម,សា ច សេដ្ឋា ហោតិ** (ប្រែ) «ចតូសុ ធម្មេសុ បណ្ដាធម៌ ៤ ពួក ឯតេសុ នុ៎ះ យា ឯសា បញ្ញា នាម ឈ្មោះថាបញ្ញា នុ៎ះឯណា សា ៗ បញ្ញា បញ្ញានោះតែម្យ៉ាង សេដ្ឋា ហោតិ ជាគុណជាតិប្រសើរបំផុត » ។ បើពួកធម៌ចំណែកខាងអាក្រក់ ប្រែថា «ជាកិលេសជាតិ, ជាធម្មជាតិ, ជាទោសជាតិ» ឬថាត្រឹមតែ «ជា» ក៏បាន ៖ **អវិជ្ជា បរមំ**(១) **មលំ (ហោតិ)** (ប្រែ) «អវិជ្ជា គឺការមិនដឹងច្បាស់ បរមំ មលំ ហោតិ ជាមន្ទិលយ៉ាងក្រៃលែង » ។

បកតិកត្តាជាឧបុសកលិង្គ, បើធម៌ចំណែកខាងល្អ ប្រែថា «ជាធម្មជាតិ, ជាគុណជាតិ» ឬថាត្រឹមតែ «ជា» ក៏បាន ៖ **សកលស្ស បន ឧដ្ឋកុក្កុស្ស បហានសំខាតំ**

---

១ បរមំ វិសេសនៈរបស់ មលំ ។ វិកតិកត្តាក្នុង ហោតិ ។

អរហត្តមេវ ឥមស្មឹ លោកេ សុខំ នាម (ហោតិ)
(ប្រែ) "បទ កឹ សកលស្ស វដ្តទុក្ខស្ស ឧបហានសំខាតំ អរ-
ហត្តំ ឯវ ព្រះអរហត្តដែលរាប់ថាការលះនូវវដ្តទុក្ខ ទាំងអស់
នុ៎ះឯង ឥមស្មឹ លោកេ សុខំ នាម ហោតិ ឈ្មោះថា ជា
គុណជាតឲ្យកើតសុខ ក្នុងលោកនេះ" ។ បើធម៌ចំណែក
ខាងអាក្រក់ ប្រែថា "ជាធម្មជាត, ជាទោសជាត" ឬថាត្រឹម
តែ "ជា" ក៏បាន ឧ. **មច្ឆេរំ ទទតោ មលំ (ហោតិ)**
(ប្រែ) "មច្ឆេរំ សេចក្តីកំណាញ់ ទទតោ មលំ ហោតិ ជា
មន្ទិល របស់បុគ្គលអ្នកឲ្យ" ។

៣) ពួករប៉ិចរប៉ី បើជាអំពើដូចកុសលកម្ម និង អកុ-
សលកម្ម ជាដើម ប្រែថា "ជាកម្ម", បើជាការប្រតិបត្តិដូច
ឧបជ្ឈាយវត្តជាដើម ប្រែថា "ជាវត្ត", បើជាសង្ខារ ប្រែថា
"ជាសភាព", បើជារុក្ខជាតិមានដងដើម ប្រែថា "ជាដើម
ឈើ", បើជាពួកវល្លិ ប្រែថា "ជាវល្លិ", បើសុខនិង

www.budinst.gov.kh www.elibraryofcambodia.org

ទុក្ខ ដែលជាបុំលិង្គ ប្រែថា "ជាសភាព", ជានបុំសកលិង្គ ប្រែថា "ជាធម្មជាត" ជាដើម ។

មួយទៀត, ប្រយោគអនាទរៈ និងប្រយោគលក្ខណៈ ចាត់ជាប្រយោគមានកិរិយាប្រចាំ ដូចគ្នានឹងប្រយោគ កត្តុ, កម្ម, ភាពដែរ បើមិនមានកិរិយាទេ ក៏ប្រែមិនបាន, តែកិរិយានោះលោកនិយមប្រែកិរិយា កិតកៈ ដែលមិនមែនអព្យយប្បច្ច័យ ព្រោះត្រូវប្រែកបវិភត្តិ, វចនៈ ដូចគ្នានឹងបទនាមដែលជាអនាទរៈ និង លក្ខណៈនោះឯង ។ ឯកិរិយារបស់អនាទរៈនិងលក្ខណៈនេះ ត្រូវជាកិរិយាសុទ្ធ មិនបានរួមជាបទសមាសជាមួយនឹងនាមសព្ទឡើយ ទើបហៅថាជាកិរិយាឃុំគ្រងប្រយោគបាន ។ បើទុកជាដូច្នោះ កិរិយាដែលរួមជាបទសមាសជាមួយនឹងនាមសព្ទហើយ ក៏គង់មានអ្នកប្រែ ប្រើជាកិរិយាអនាទរៈ និងលក្ខណៈដោយច្រើន ដូច **បិតរិ កាលកតេ** (ប្រែ) "បិតរិ កាលបិតា កាលកតេ មានមរណកាលធ្វើហើយ" ។

www.budinst.gov.kh www.elibraryofcambodia.org

អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ (ប្រែ) "បោសស្ស កាលមនុស្ស អត្តទន្តស្ស មានខ្លួនទូន្មានហើយ និច្ចំ សញ្ញតចារិនោ មានការប្រព្រឹត្តដោយភាពជាអ្នកសង្រួមជាប្រក្រតី អស់កាលជានិច្ច" ។ អាចារ្យខ្លះ ប្រកាន់ថា ប្រែយ៉ាងនេះមិនត្រូវទេ ព្រោះមិនមែនជាកិរិយាសុទ្ធ; បើមានកិរិយារួមជាបទសមាសនឹងនាមសព្ទបែបនេះ ត្រូវតែបញ្ចូលបទកិរិយា ដែលប្រព្រឹត្តទៅក្នុងអត្ថថា "មាន, កើត, ជា" ដូច **សន្តេ** ឬ **សតិ** ឬក៏ **ហោន្តស្ស** ណាមួយមកក្នុងប្រយោគ, ចំណែកកិរិយាដើម ដែលជាបទសមាសនោះត្រូវបំបែកទៅជាវិកតិកត្តា ចូលនឹងបទកិរិយាដែលបញ្ចូលនោះមកវិញដូច **បិតរិ កាលកតេ** ត្រូវបញ្ចូល **សន្តេ** ប្រែថា "បិតរិ នាកាលបិតា កាលកតេ សន្តេ(១) ជាអ្នកមានមរណកាលទៅហើយ" ។ **អត្តទន្តស្ស បោសស្ស និច្ចំ**

១– សន្តេ ប្រែថា "ជា", ព្រោះមានបទវិកតិកត្តា ។

www.budinst.gov.kh www.elibraryofcambodia.org

សញ្ញតចារិនោ ត្រូវតែបញ្ចូល **ហោន្តស្ស** ប្រែថា «ហោន្តស្ស កាលមនុស្ស គត្តុំមន្តស្ស មានខ្លួនខ្ជាប់ ហើយ ខិត្តុំ សញ្ញតចារិនោ·ហោន្តស្ស ជាអ្នកមានការប្រព្រឹត្តិដោយភាពជាអ្នកសង្រួមជាប្រក្រតី អស់កាលជានិច្ច» ។ សេចក្តីដែលបានពណ៌នាមកនេះ ឃើញថា មានមតិមិនស្របគ្នា មិនដឹងជាមតិណាខុស មតិណាត្រូវ ព្រោះហេតុនោះអ្នកសិក្សាទាំងឡាយ ចូរលើកគ្រាជួ គឺប្រាជ្ញា ពិចារណាថ្លឹងមើល បើឃើញថាមតិណា មានសេចក្តីត្រឹមត្រូវជាង ក៏ចូរកាន់យកមតិនោះជាបែបចុះ ។

ពាក្យប្រែវិកតិកត្តា ដែលសំដែងមកក្នុងទីនេះ គ្រាន់តែជាផ្លូវគំនិតនៃអ្នកសិក្សាប៉ុណ្ណោះ មិនមែនទាំងអស់ទេ ។ ហេតុនោះ អ្នកសិក្សា បើឃើញពាក្យដទៃក្រៅពីនេះ ល្អជាង ល្មមសមគួរដល់សេចក្តី ក៏ចូរនាំមកប្រើចុះ ដ្បិតពាក្យ

ប្រែវិកតិកត្តាមានច្រើនបែបច្រើនយ៉ាង តាមប្រទេសរបស់បកតិកត្តានោះ ៗ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយវិញទៀត ហុ-ធាតុ, ភូ-ធាតុ, អស-ធាតុ ៣ តួនេះ ប្រព្រឹត្តទៅក្នុងអត្ថថា " មាន " ថា " ជា " ក៏បាន, រួមសេចក្ដីថា ក្នុងធាតុ ៣ តួនោះ, តួមួយ ៗ មានអត្ថ ២ យ៉ាង ៗ បណ្ដាអត្ថ ២ យ៉ាងនោះ, អត្ថថា " មាន " គួរប្រើក្នុងទីដែលមានកត្តាតែមួយ គឺមានតែបកតិកត្តាប៉ុណ្ណោះ ឧ. **ទេសនាវសានេ ចតុន្នំ បាណកោដីនំ ធម្មាភិសមយោ អហោសិ** (ប្រែ) "ទេសនាវសានេ ក្នុងកាលជាទីបំផុតនៃទេសនា ធម្មាភិសមយោ រីការលុះនូវធម៌ អហោសិ បានមានហើយ បាណកោដីនំ ដល់កោដិនៃសត្វ ១. ចតុន្នំ ៤ កោដិ" ។ អត្ថថា "ជា" គួរប្រើក្នុងទីដែលមានកត្តា ២ គឺបកតិកត្តា បានដល់បទប្រធាន ១, វិកតិកត្តា បានដល់បទនាម, បទគុណនាម និងបទកិរិយាកិតកៈប្រើដូចគុណ ដែលចូលទីងធាតុពួកនោះ ។ ឧ. **យោ ហិ ឯទំ**(១)

---

១ ឯទំ-សព្ទ កិរិយាវិសេសនៈក្នុង ករកតិ

ករោតិ សោ លោកវឌ្ឍនោ នាម ហោតិ

(ប្រែ) “ហិ ក៏ យោ-បុគ្គលោ រីបុគ្គលណា ករោតិ តែងធ្វើ ឯវំ យ៉ាងនេះ សោ-បុគ្គលោ រីបុគ្គលនោះ លោកវឌ្ឍនោ នាម ហោតិ ឈ្មោះថា ជាអ្នកចំរើនក្នុងលោក” ។

១០ វិធីផ្លាស់ប្រយោគ(១)

សេចក្ដីក្នុងប្រយោគក្រោយ ប្រើខបង្គាប់ដល់សេចក្ដី ក្នុងប្រយោគមុខ ដែលពោលរួចមកហើយ, ប្រយោគដូច្នោះ បើមានគ្នួសព្ទដែលរៀនទុកស្រេចហើយក៏ជាការល្អ ដល់វេលាទឹងប្រែ ក៏ប្រែតែម្ដង មិនបាច់គិតគូរទៀតទេ ។ តែលំបាកខ្លាំងត្រង់ដែលលោកមិនបានរៀនសព្ទទុក ឬរៀនទុកតែត្រឹមសព្ទនាម, ក្រៅពីនោះ ឲ្យអ្នកប្រែគិតរកសព្ទបញ្ចូលខ្លួន

១ វិធីផ្លាស់ប្រយោគនេះ បំប្រួញឲ្យខ្លីល្មមខន្ធេញចាំមាត់មិនបានទេ ដូច្នេះត្រូវតែមើលសង្កេតផ្ចង់ស្មារតីឲ្យមែនទែន ។

www.budinst.gov.kh www.elibraryofcambodia.org

ឯន ។ កាលបើដូច្នេះ អ្នកសិក្សា ត្រូវតែចេះវិធីផ្លាស់ប្រយោគ ឲ្យច្បាស់លាស់ទើបប្រែគម្ពីរត្រឹមត្រូវទៅបាន, បើមិនដូច្នោះទេ នឹងចេះតែប្រែព្រាវ ៗ ទៅ តាមទំនើងរបស់ខ្លួន សេចក្ដីក៏បាត់ទៅគ្រប់អន្លើមិនមានជាប់គ្នា ។ ឯវិធីផ្លាស់ប្រយោគនោះ ដូច្នេះ ៖

ក) ផ្លាស់កិរិយាអាខ្យាតជានាម

សម្រាប់កត្តុវាចក:

ធាតុប្រព្រឹត្តទៅក្នុងអត្ថ "មាន កើត, ជា" ដូចករតិជាដើម ផ្លាស់ជា ការប្រកបកិត្តនាមជា ភាវេ ប្រែថា "ការកើត, ការមាន" ។ បើមិនប្រើ ភាវេ ប្រើបច្ច័យក្នុងភាវតទ្ធិតតួណាមួយក៏បាន, តែបើបុំលិង្គប្រើ ភាវេ, ឥត្ថីលិង្គប្រើតា-បច្ច័យ, នបុំសកលិង្គ ប្រើបច្ច័យក្រៅពីនេះ មានណ្យបច្ច័យជាដើម ។

ផ្លាស់កត្តាដែលចូលនឹងធាតុពួកនេះ ៖ ក្នុងប្រយោគ

www.budinst.gov.kh www.elibraryofcambodia.org

ដែលជាធាតុពួកនេះ បើមានកត្តា ២ បទ គឺ បកតិកត្តា ១, វិកតិកត្តា ១, សព្ទដែលជាវិកតិកត្តា ត្រូវបញ្ចូលជាបទសមាស ទីឃីការកេ ឬចុះបច្ច័យដែលពោលហើយ ដូចប្រយោគថា **ឥស្សរោ ហោតិ** “(ព្រះរាជា) ទ្រង់ជាឥស្សរៈ” ផ្លាស់ជា នាមបុំ.ជា **ឥស្សរតាយោ**, ឥ.ជា **ឥស្សរតា**, នបុំ. ជា **ឥស្សរត្តំ** “ការៈ(នៃព្រះរាជា) ទ្រង់ជាឥស្សរៈ” ។ ចំណែកសព្ទដែលជាបកតិកត្តា ត្រូវផ្លាស់ជាឆដ្ឋីវិភត្តិ ដូច **រាជា ឥស្សរោ ហោតិ** ផ្លាស់ជា **រញ្ញោ ឥស្សរតាយោ, ឥស្សរតា, ឥស្សរត្តំ** ។

បើមានកត្តាតែមួយបទ, កាលផ្លាស់ជាធាតុពួកនេះជានាម ត្រូវប្រើ អត្ថិ កត្តានឹង ការៈ-សព្ទ ឬបច្ច័យជំនួសការៈ-សព្ទ ដូចនេះ៖ **ធម្មា ហោន្តិ** “ធម៌.មាន” ជា **ធម្មានំ អត្ថិតាយោ**,-**អត្ថិតា** “ការៈនៃធម៌.មាន” ។ ឯកិរិយា អត្ថិ, នត្ថិ ២ បទនេះ លោកក៏បញ្ចូលក្នុងពួកអព្យយសព្ទ ព្រោះផ្លាស់រូបទៅផ្សេងមិនបាន, ប្រើបានទាំងពីរវចនៈ ស្ទើ

www.budinst.gov.kh www.elibraryofcambodia.org

ចូលជាមួយការក-សព្ទ បច្ច័យជំនួសការក សព្ទ ដូចពោលហើយក៏ដោយ; ក្នុងវេលាប្រែ ហាមមិនឲ្យប្រែថា "ជា" នាំមុខដូចសព្ទដទៃទេ ឲ្យប្រែចំពោះពាក្យថា "មាន" ដូច **ធម្មា-នំ អត្ថិតាយ** *ការៈនៃធម៌ទ. មាន"*, **ភិក្ខុនីនមោវា-ទោ បន ឥទានិ តាសំ នត្ថិតាយ នត្ថិ** *(ប្រែ) "ចំណែក ឱវាទោ ក៏ (ការឲ្យ) ឱវាទ ភិក្ខុនីទំ ដល់ភិក្ខុនីទ. នត្ថិ រមែងមិនមាន ឥទានិ ក្នុងកាលឥឡូវនេះ តាសំ នត្ថិតាយ ព្រោះការៈនៃភិក្ខុនីទ. ពួកនោះ មិនមាន" ។*

បើមាននាមកត្តាច្រើនបទ ទុកជាផ្សេងលិង្គគ្នាក៏ដោយ ឲ្យតែមានវិកតិកត្តានិងកិរិយារួមគ្នា ត្រូវផ្លាស់បកតិកត្តានោះរួមដោយច. សព្ទ ឬផ្លាស់រួមជាបទសមាស តាមសមគួរដល់រូបសេចក្ដី ។

ផ្លាស់រួមដោយច-សព្ទៈ <u>**កុមារោ**</u> **ច** <u>**កុមារិកា**</u> **ច សោភាបន្តា អហេសុំ**(១) *"កុមារផង កុមារិកាផង*

---

១ នាមនាមឯកវចនៈច្រើនបទ រួមគ្នាដោយ ច សព្ទ, គុណនាមក្ដី កិរិយាក្ដីរបស់នាមនោះ ត្រូវប្រើជាពហុវចនៈ ។

www.budinst.gov.kh www.elibraryofcambodia.org

បានជាអ្នកដល់នូវសោកៈហើយ» ផ្លាស់ជា **កុមារស្ស ច កុមារិកាយ ច សោកាបន្នតា** "ការៈនៃកុមារផង នៃកុមារិកាផង ជាអ្នកដល់ហើយនូវសោកៈ» , នេះមានច សព្ទមកអំពីដើមស្រាប់ ទាំងមានកែកតិកត្តានិងកិរិយារួមគ្នា ។ **បុត្តា អត្ថិ, ធនំ អត្ថិ** "កូនៗ. មាន, ទ្រព្យមាន» ផ្លាស់ជា **បុត្តានញ្ច ធនស្ស ច អត្ថិតាយ** "ការៈនៃកូនៗ. ផង នៃទ្រព្យផង មាន» , នេះបទដើមមិនមាន ច-សព្ទ ទាំងមិនរួមកិរិយាគ្នា ផ្សេងបទ ផ្សេងកិរិយា តែកិរិយានោះដូចគ្នា ។

ផ្លាស់រួមជាបទសមាស សូម្បីបទដើម ជាឯកវចនៈក៏ដោយ កាលបើរួមចូលជាបទសមាសហើយ ក៏ត្រូវផ្លាស់ជាពហុវចនៈ ដូចនេះ៖ **បុត្តោ អត្ថិ ធនំ អត្ថិ** ផ្លាស់ជា **បុត្តធនានំ អត្ថិតាយ** "ការៈនៃកូននិងទ្រព្យៗ. មាន» ។

ធាតុប្រព្រឹត្តទៅក្នុងអត្ថជនៃ ត្រូវផ្លាស់សម្រេចរូបជា

www.budinst.gov.kh www.elibraryofcambodia.org

ការសាធនៈ ដូច ករោតិ ផ្លាស់ជា ករណំ “កិរិយាធ្វើ” , គច្ឆតិ ផ្លាស់ជា គមនំ “ដំណើរទៅ” ជាដើម ។ កាលផ្លាស់ជានាម ចុះក្នុងការសាធនៈហើយ, តួកត្តាដើមដែលជាបឋមាវិភត្តិត្រូវផ្លាស់ជាឆដ្ឋីវិភត្តិថែមមុខទៀត ដូច **បុញ្ញត្ថិកា បុញ្ញំ ករោន្តិ** (ប្រែ) “ជនា រីជនទ. បុញ្ញត្ថិកា អ្នកមានសេចក្តីត្រូវការដោយបុណ្យ ករោន្តិ រមែងធ្វើ បុញ្ញំ នូវបុណ្យ”; ផ្លាស់ជា **បុញ្ញត្ថិកានំ បុញ្ញករណំ** (ប្រែ) បុញ្ញត្ថិកានំ បុញ្ញករណំ រីការធ្វើនូវបុណ្យ នៃជនទ. អ្នកមានសេចក្តីត្រូវការដោយបុណ្យ” ។ បើជាពាក្យកណ្តាល ។ (មជ្ឈិមបុរិសៈ)មិនត្រូវយកកត្តាមកទេ ដូច**តិបិដកំ ឧគ្គហេត្វា ធារេហិ**, តំ-(**តិបិដកំ ឧគ្គហេត្វា ធារណំ**) **គន្ថធុរំនាម** (ប្រែ) “ត្វំ អ្នក តិបិដកំ ឧគ្គហេត្វា ធារេហិ ចូររៀននូវព្រះត្រៃបិដក ហើយទ្រទ្រង់ទុក, តំ (តិបិដកំ ឧគ្គហេត្វា ធារណំ រីការរៀននូវព្រះត្រៃបិដកហើយទ្រទ្រង់ទុក) នោះ

www.budinst.gov.kh www.elibraryofcambodia.org

គន្ធធុរំ នាម ឈ្មោះថា គន្ធធុរៈ ” ។ ក្នុងទីនេះ ធុរំ ជាកត្តាក្នុងប្រយោគមុខ, តែ នាំសេចក្ដីមុខមកនិយាយទៀតទើបផ្លាស់កិរិយាខាងមុខជានាម ដូចសរសេរទុកក្នុងវង់ក្រចកដើម្បីឲ្យយោគចូលនឹង តែ, តែមិនត្រូវយក ធុរំ ផ្លាស់មកជាឆដ្ឋីវិភត្តិទេ ព្រោះជាពាក្យកណ្ដាល (មជ្ឈិមបុរិសៈ) ។

កាលផ្លាស់កិរិយា មកជានាមដូច្នោះហើយ សព្ទដែលចាក់ចងនឹងកិរិយាដើមមានប៉ុន្មានបទ គប្បីនាំមកពោលផង ឬមិនយកមកពោលនោះ ស្រេចហើយតែសេចក្ដី របស់ប្រ-យោគក្រោយនឹងឲ្យគម្រូយ, សូម្បីការផ្លាស់បទនាម ដែលជាម្ចាស់ប្រយោគក្នុងសំនួនដើម ឲ្យមកជាឆដ្ឋីវិភត្តិក្នុងប្រ-យោគក្រោយវិញក្ដី ក៏មិនបង្គាប់គ្រប់ន័យទេ ដូចសំនួនដើមថា **ពុទ្ធោ សត្តានំ នាថោ** (១) (ប្រែ) “ពុទ្ធោ ព្រះពុទ្ធនាថោ ជាទីពឹង សត្តានំ របស់សត្វទាំងឡាយ”, សំនួន

---

១ គុណនាម ត្រូវរៀងមុខនាម, បើរៀងក្រោយនាមច្រើនជាវិកតិកត្តា។

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយថា **សោ តំ សទ្ធាយ លោកនាថោតិ**(១) **វុច្ចតិ** (ប្រែ) "សោ-ពុទ្ធោ រីព្រះពុទ្ធអង្គនោះ (វិញ្ញូហិ គឺវិញ្ញូជនទ.) សទ្ធាយ សំដៅយក តំ. (សត្តានំ នាថត្តំ នូវភាវៈនៃព្រះអង្គ ទ្រង់ជាទីពឹង របស់សត្វទ.) នោះវុច្ចតិ ទើបលោកហៅ លោកនាថោ ឥតិ ថាព្រះលោកនាថ", ត្រូវផ្លាស់ត្រឹមតែ សត្តានំ នាថោ ជា សត្តានំ នាថត្តំ ឬ សត្តានំ នាថភាវំ មកចូលនឹង តំ ក៏ចុះជាស្រេច, តែមិនត្រូវផ្លាស់បទពុទ្ធោ មកជា ពុទ្ធស្ស ទេ ព្រោះ សោ ក្នុងសំនួនក្រោយហួច សេចក្តីផល់ហើយ ។ បើសំនួនក្រោយថា **តំ សទ្ធាយ**

---

១ លោកនាថោ សរុបៈក្នុងឥតិ ។ សព្ទ សញ្ញាជោតកៈក្នុងសោ–ពុទ្ធោ ។ ឥតិ សព្ទក្នុងទីនេះចាត់ជាសញ្ញាជោតកៈប្រែថា "ថា, ឈ្មោះថា" ឲ្យឈ្មោះថា " ។ ប្រយោគបែបនេះ ប្រែបានជា ២ បែប បែបទី១ ដូចប្រែរួចហើយ, បែបទី ២ លើកបទប្រធានប្រែ រួចត្រូវប្រែបទអនភិហិ–តកត្តា រួចប្រែលោកនាថោ ឥតិ "ឲ្យឈ្មោះថាព្រះលោកនាថ", តទៅត្រូវប្រែបទកិរិយា ។ ត្រូវរកក្អែកមើលឧទាហរណ៍ខាងលើហើយប្រែល្បងមើលទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

លោកនាថោតិ[១] **វចនំ វិញ្ញូហិ វុច្ចតិ** *(ប្រែ)*

“វចនំ ពាក្យ លោកនាថោ ឥតិ ថាព្រះលោកនាថ វិញ្ញូហិ គឺវិញ្ញូជនទ. វុច្ចតិ តែងពោល សព្វាយ សំដៅយក គំ-(ពុទ្ធស្ស សត្ថានំ នាថត្តំ នូវភាវៈនៃព្រះពុទ្ធ ទ្រង់ជាទីពឹងរបស់សត្វទ.) នោះ” ។ សំនួនបែបនេះ បើយក ពុទ្ធោ ជា ពុទ្ធស្ស បាន, ព្រោះប្រធានក្នុងសំនួនក្រោយ ផ្សេងអំពីប្រធានក្នុងសំនួនដើម សេចក្តីលើសខ្វះគ្នា មានបន្តិចបន្តួច, គំ នៅមុខ សព្វាយ ត្រូវយោគបញ្ចូលថា **គំ-ពុទ្ធស្ស សត្ថានំ នាថត្តំ ឬ ពុទ្ធស្ស សត្ថានំ នាថភាវំ** *យ៉ាងនេះទើបត្រូវល្អ ព្រោះ ពុទ្ធស្ស នោះឯង នៅចុះបំពេញ*

---

១ លោកនាថោ សរូបៈក្នុង ឥតិ ។ សព្ទ សរូបៈក្នុង វចនំ ។ ឥតិ-សព្ទនេះបើចូលនឹងនាមហៅថា សរូបៈខ្លះ, អាខ្យាតៈខ្លះ, សញ្ញាជោតកៈខ្លះ ។ បើចូលនឹងកិរិយា ហៅថា អាការៈ ។ អាខ្យាតៈ “ដូច្នេះជាដើម” ឧ. មនោបុព្វង្គមាតិ ទុតិយគាថាយបិ ។ សញ្ញាជោតកៈ “ឈ្មោះថា, ឲ្យឈ្មោះថា” ឧ. បមាទោតិបមជ្ជនភាវោ ។

www.budinst.gov.kh www.elibraryofcambodia.org

គ្រប់បន្ទោះដែលខ្វះនោះ ៗ

ផ្លាស់កិរិយាអាខ្យាតមានបដិសេធ

កិរិយាសព្ទដូចពោលមកនេះ មិនមានបដិសេធ, បើមាន បដិសេធ គឺ ន-សព្ទ ឬ នោ សព្ទ មានវិធីផ្លាស់ ដូច្នេះ ៖

ធាតុប្រព្រឹត្តទៅក្នុងអត្ថ "មាន, កើត, ជា" ដែលមានកត្តាតែមួយ ត្រូវផ្លាស់ ន-បដិសេធ ជា អ ចូលនឹង ការ ជា អការក៏បាន, បើ នត្ថិ នាំមុខ ការ ជា នត្ថិការក៏បាន ដូច **សង្ខារា សស្សតា នត្ថិ** សង្ខារទ. ជាសភាពទៀង មិនមាន". ផ្លាស់ជា **សង្ខារានំ សស្សតានំ នត្ថិតាយ** "ការៈនៃសង្ខារទ. ជាសភាពទៀង មិនមាន; ឬ កាត់ឲ្យខ្លីថា **តាទិសានំ អភាវោ** "ការៈមិនមាន នៃសង្ខារទ. ប្រាកដដូច្នោះ" ៗ **សព្វេ សង្ខារា អនិច្ចា, តេ ហុត្វា ន ហោន្តិ** "(ប្រែ) សង្ខារា-សង្ខារទ សព្វេ ទាំងពួង អនិច្ចា មិនទៀង, តេ-សព្វេ

www.budinst.gov.kh www.elibraryofcambodia.org

សង្ខារា រឺសង្ខារទ. ទាំងពួងនោះ ហុត្វា ហុត្វា មានហើយៗ ន ហោន្តិ រមែងមិនមានវិញ" ផ្លាស់ជា **តេសំ ហុត្វា ហុត្វា នត្ថិតា** "ភាវៈនៃសង្ខារទ. ពួកនោះមានហើយៗ មិនមានវិញ" ។ ដែលមានកត្តា ២ ត្រូវផ្លាស់ ន. បដិសេធ ជា អ ឬ អន តាមវិធីសមាស ហើយយកបទបដិសេធនោះ ចូលនឹងវិកតិកត្តា ដូច **អយំ ជនោ ន អរិយោ ហោតិ** "ជននេះ មិនមែនជាអរិយៈ", ផ្លាស់ជា **ឥមស្ស អនរិយ-ភាវោ** "ភាវៈនៃជននេះ ជាអ្នកមិនមែនជាអរិយៈ ។

ធាតុប្រព្រឹត្តទៅក្នុងអត្ថដទៃ បើធាតុដែលមានអក្សរដើម ជាព្យញ្ជនៈ, ផ្លាស់ ន បដិសេធជា អ ដូចជា **ន ករោ-តិ** "មិនធ្វើ", ផ្លាស់ជា **អករណំ** "ការមិនធ្វើ" ។ បើធាតុដែលមានអក្សរដើមជាស្រៈ ផ្លាស់ ន បដិសេធ ជា អន ដូចជា **ន អាគច្ឆតិ** "មិនមក", ផ្លាស់ជា **អនាគមនំ** "ការមិនមក" ។

www.budinst.gov.kh www.elibraryofcambodia.org

បកតិកត្តាផ្លាស់ជាឆដ្ឋីវិភត្តិក៏ កិរិយាផ្លាស់ជានាមកិត្ត ដែលបានផ្លាស់មកហើយនោះ ដើម្បីឲ្យឃើញជាបែបប៉ុណ្ណោះទេ ។ ចំណែកការប្រែ ទឹងប្រើតែសព្ទនាម ឬត្រូវមានរូបបទដែលផ្លាស់ផងនោះ ស្រេចហើយតែសេចក្ដីត្រូវរូប ឬមិនត្រូវរូប ។

ផ្លាស់កិរិយាអាខ្យាតជាកិរិយាកិតកៈសិន

សម្រាប់កម្មវាចកៈ

វិធីផ្លាស់កិរិយាអាខ្យាតជានាម ដូចសំដែងមកហើយនោះសម្រាប់កត្តុវាចកៈប៉ុណ្ណោះ; បើកម្មវាចកៈ ត្រូវផ្លាស់ជាកិរិយាកិតកៈ ចុះបច្ច័យសម្រាប់កម្មវាចកៈ តាមលំនាំកិរិយាដើមរួចហើយទើបយកសព្ទនោះទៅចូលទឹង ការ ឬ បច្ច័យកន្តការកត្ថិត, បើមានបដិសេធ ចូរធ្វើឲ្យត្រូវរបៀបបដិសេធដូចន័យដែលសំដែងទុកខ្លះ ដូច្នេះ ៖

លព្ភតិ ផ្លាស់ជា **លព្ភមាន – តាខោ, – តា**

ន លព្ភតិ ផ្លាស់ជា **អលព្ភមាន–តាខោ,–តា**

www.budinst.gov.kh www.elibraryofcambodia.org

ទិស្សតិ ផ្លាស់ជា ទិស្សមាន -តាតោ, តា

ន ទិស្សតិ ,, អទិស្សមាន -តាតោ, តា

ទេសិយតេ ,, ទេសិយមាន -តាតោ,-តា

ន ទេសិយតេ ,, អទេសិយមាន -តាតោ,-តា

ន អាបុច្ឆិយតេ ,, អនាបុច្ឆិយមាន-តាតោ,-តា

សុយិត្ថ ,, សុត -តាតោ, តា

កិរិយាអាខ្យាត កាលផ្លាស់ជាកិរិយាកិតកៈរួចហើយ ត្រូវចូលនឹង តា បច្ច័យតាមគន្លង ជា លព្ភមានតាតោ, លព្ភមានតា; អទេសិយមានតាតោ, អទេសិយមានតា, អនាបុច្ឆិយមានតាតោ, អនាបុច្ឆិយមានតា, សុតតាតោ, សុតតា ជាដើម ដូចឧទាហរណ៍ខាងលើនោះឯង ។

ផ្លាស់កិរិយាអាខ្យាតជាគុណសិន

កិរិយាអាខ្យាត ផ្លាស់ជាកិរិយាកិតកៈក៏បាន ជានាមក៏បាន ដូចសំដែងមកហើយ, មិនតែប៉ុណ្ណោះទេ អាចផ្លាស់ជាគុណ

www.budinst.gov.kh www.elibraryofcambodia.org

បានទៀត ។ ឯការផ្លាស់កិរិយាសព្ទជាគុណនេះ ក៏ត្រូវផ្លាស់ជាកិតកៈដូចផ្លាស់ជានាមដែរ ផ្សេងគ្នាតែសាធនៈគឺបើផ្លាស់ជានាម ត្រូវសម្រេចរូបជាភាវសាធនៈ, ចំណែកផ្លាស់ជាគុណត្រូវសម្រេចរូបជាសាធនៈដទៃ មានកត្តុសាធនៈជាដើម ស្រេចហើយតែត្រូវការ ។ លុះផ្លាស់មកជាបទគុណហើយ ទើបយកសព្ទនោះ ទៅប្រកបនឹងការ-សព្ទ ឬបច្ច័យក្នុងការតទ្ធិត ដូច **សក្កោ មយិ សិនេហំ ករោតិ** “ព្រះឥន្ទ្រ ធ្វើនូវសេចក្តីស្នេហា ចំពោះតថាគត», ផ្លាស់ជា **សក្កស្ស មយិ សិនេហស្ស ការកត្តំ** “ការៈនៃព្រះឥន្ទ្រ អ្នកធ្វើ នូវសេចក្តីស្នេហា ចំពោះតថាគត» ។

ខ) ផ្លាស់គុណជានាម

ការផ្លាស់គុណជានាមនេះ រមែងសម្រេចបាន ដោយអំណាចការ-សព្ទ ឬបច្ច័យចំនួនការ សព្ទនោះដែរ, ចំណែកឯនាមនាមដែលជាម្ចាស់ប្រយោគ ត្រូវផ្លាស់ជាឆដ្ឋីវិភត្តិ ដូច

www.budinst.gov.kh www.elibraryofcambodia.org

សុន្ទរោ ធម្មោ «ព្រះធម៌ល្អ», ផ្លាស់ជា ធម្មស្ស សុន្ទរតា ខោ «ការៈនៃព្រះធម៌ជាគុណល្អ» ។ កុសលោ អាចរិយោ «អាចារ្យអ្នកឈ្លាស», ផ្លាស់ជា អាចរិយស្ស កុសលតា ឬ អាចរិយស្ស កោសល្លំ ការៈនៃអាចារ្យអ្នកឈ្លាស» ។

គ) ផ្លាស់កិរិយាកិតកៈជានាម

កិរិយាកិតកៈដែលផ្លាស់មកជានាម ក៏ត្រូវអាស្រ័យការ-សព្ទបច្ច័យនោះឯង ដូច ពុទ្ធោ លោកេ ឧប្បន្នោ «ព្រះពុទ្ធកើតហើយក្នុងលោក», ផ្លាស់ជា ពុទ្ធស្ស លោកេ ឧប្បន្នត្តំ «ការៈនៃព្រះពុទ្ធ ព្រះអង្គកើតហើយក្នុងលោក» ។ រាជា ចនេហិ ហនិតោ «ព្រះរាជា គឺជនទ. កាប់គាប់ហើយ», ផ្លាស់ជា រញ្ញោ ចនេហិ ហនិតត្តំ «ការៈនៃព្រះរាជា ជាកម្មត្រូវគឺជនទ. កាប់គាប់ហើយ» ។ អរហន្តោ បរមាយ វិសុទ្ធិយា វិសុទ្ធា

www.budinst.gov.kh www.elibraryofcambodia.org

"ព្រះអរហន្ត. បរិសុទ្ធហើយ ដោយសេចក្ដីបរិសុទ្ធដ៏វិសេស ហ៊ានក្រៃលែង" , ផ្លាស់ជា **អរហតំ បរមាយ វិសុទ្ធិយា វិសុទ្ធត្តំ** "ភាវៈនៃព្រះអរហន្ត. ជាអ្នកបរិសុទ្ធហើយ ដោយសេចក្ដីបរិសុទ្ធដ៏វិសេស ហ៊ានក្រៃលែង" ។

ផ្លាស់ប្រយោគត្រូវបង្អោនតាមសព្វនាម

ការយល់ក្នុងវិធីផ្លាស់កិរិយាអាខ្យាត ជានាម ជាកិរិយា. កិតកៈ ជាគុណត្ថ ផ្លាស់គុណជានាមត្ថ ផ្លាស់កិរិយាកិតកៈ ជានាមត្ថ ដូចពណ៌នាមកនេះ មានប្រយោជន៍ក្នុងការប្រែគម្ពីរ ជាទីបំផុត ។ ព្រោះភាសាបាលី ច្រើននិយាយកំបុក ៗ ទុំ ៗ គឺសំនួនដើមដែលបាននិយាយរួចហើយ ដល់មកសំនួនក្រោយសូម្បីសេចក្ដីបន្ទាប់ដល់ ក៏មិននាំយកសេចក្ដីនោះ មកនិយាយឲ្យអស់ទេ ។ កាលបើយ៉ាងនេះ សេចក្ដីក្នុងសំនួនក្រោយនោះកាលនឹងប្រែជាភាសាខ្មែរត្រូវតែបញ្ចូលមក ។ តែការបញ្ចូលនេះបើមិនបានចេះវិធីផ្លាស់ទុកជាមុនទេ រមែង

www.budinst.gov.kh www.elibraryofcambodia.org

ជាទោស នាំឲ្យបញ្ច្រុលខុសខ្លះ ត្រូវខ្វះឲ្យខូចដំរៀបនៃសេចក្តី ក្នុងប្រយោគក្រោយដោយអន្ទេ ១ ៗ

ក្នុងភាសាបាលី មានសេចក្តីខ្លះ បង្គាប់ដល់សេចក្តីក្នុងប្រយោគមុខទាំងអស់ក៏មាន បង្គាប់ដល់ពាក្យខ្លះ សព្ទខ្លះក៏មាន ៗ ដែលបង្គាប់ដល់សេចក្តី ក្នុងប្រយោគទាំងមូល ត្រូវតែផ្លាស់ប្រយោគជាថ្មី ដើម្បីយកទៅចុះបំពេញត្រង់ចន្លោះដែលខ្វះខាត ក្នុងសំនួនក្រោយនោះ ៗ តាមដែលពិតសំនួនក្រោយលោកច្រើនរៀងសព្ទនាមទុក សម្រាប់សំឡឹងយកសេចក្តីខាងមុខ ៗ បើសំឡឹងយកទាំងមូល ក្នុងវេលាប្រែ ក៏ត្រូវផ្លាស់អស់មួយប្រយោគ ហើយប្រើសព្ទនាមយោគ, បើសំឡឹងយកចំពោះតែពាក្យខ្លះ សព្ទខ្លះ, សំឡឹងដល់ពាក្យណា ឬ សព្ទណាក្នុងវេលាប្រែ ត្រូវប្រើសព្ទនាមយោគយកពាក្យនោះ ឬសព្ទនោះតែម្តង, តែសព្ទនាមដែលលោករៀងទុកនោះ ជាបុំលិង្គក៏មានជាឥត្ថីលិង្គក៏មាន ជានបុំសកលិង្គក៏មាន ៗ ព្រោះហេតុ

www.budinst.gov.kh www.elibraryofcambodia.org

នោះការផ្លាស់សព្ទនោះ ៗ រមែងបង្អោនទៅតាមសព្ទនាម ដែលជាលិង្គនោះៗ ដូចមានឧទាហរណ៍ តទៅនេះ៖

សព្ទនាមជាបុំលិង្គ, កាលបានផ្លាស់សព្ទនោះៗ រួចហើយ ត្រូវយកទៅភ្ជាប់ជាបទសមាសនឹងការ-សព្ទ ដើម្បីឲ្យត្រូវលិង្គគ្នានឹងសព្ទនាមដែលលោករៀងទុកហើយ ដូចប្រយោគថា

ធម្មោ សុចិណ្ណោ <u>សុខមាវហាតិ</u>, <u>ឯសានិសំសោ</u>

ធម្មោ សុចិណ្ណោ (ប្រែ) "ធម្មោ គឺព្រះធម៌ សុចិណ្ណោ គឺបុគ្គលប្រព្រឹត្តល្អហើយ ការហាតិ រមែងនាំមក សុខំ នូវសេចក្តីសុខ, ឯសោ (សុខស្ស ការហនភាវោ គឺភាវៈនៃកិរិយានាំមកនូវសេចក្តីសុខ)នុ៎ះ អានិសំសោ ជាអានិសង្ស ធម្មេ ក្នុងធម៌ សុចិណ្ណេ ដែលបុគ្គលប្រព្រឹត្តល្អហើយ" ។ នេះ ឯសោ សំឡឹងយកចំពោះ សុខមាវហាតិ មិនសំឡឹងយកអស់ទាំងប្រយោគទេ បើត្រូវផ្លាស់ សុខមាវហាតិ ជា សុខស្សការហន ភ្ជាប់នឹងភាវោជាសុខស្សការហនភាវោ(ធ.ក.១ទំព័រ១៤១)។

www.budinst.gov.kh www.elibraryofcambodia.org

សព្វនាមជាឥត្ថីលិង្គ ប្រើតា-បច្ច័យក្នុងការតែង ចុះក្នុងសព្ទដែលផ្លាស់ហើយនោះ ដូចប្រយោគថា **ធម្មតា តិ-រេសោ, យំ ធម្មោ ធម្មចារិនំ រក្ខតិ** (ប្រែ) "គឺបានឮថា ធម្មោ ព្រះធម៌ រក្ខតិ រមែងរក្សា ធម្មចារិនំ នូវបុគ្គលអ្នកប្រព្រឹត្តនូវធម៌ដោយប្រក្រតី យំ(១) ឯណា, ឯសា (ធម្មេន ធម្មចារិនោ រក្ខិតតា ភាវៈនៃបុគ្គលអ្នកប្រព្រឹត្តនូវធម៌ដោយប្រក្រតី ជាអ្នកគឺធម៌រក្សាហើយ)ចុះ ធម្មតា ជាធម្មតា។ ។ នេះ ឯសា សំឡឹងយកតែសម្ពួយប្រយោគ ត្រូវផ្លាស់ ធម្មោ ធម្មចារិនំ រក្ខតិ ជា ធម្មេន ធម្មចារិនោ រក្ខិត ភ្ជាប់នឹងតា-បច្ច័យ (ធ.ភ. ៨ ទំព័រ ១០១) ។

សព្វនាមជានបុំសកលិង្គ បើផ្លាស់ជានាម មិនត្រូវចុះ

១ យំប្រែក្រោយកិរិយាសំគាល់ប្រយោគហៅថាកិរិយាវិសេសនៈឬហៅថាកិរិយាបរាមាសៈក៏បានចូលនឹងកិរិយានោះៗ, ក្នុងទីនេះត្រូវចូលក្នុងរក្ខតិ។

www.budinst.gov.kh www.elibraryofcambodia.org

បច្ច័យក្នុងការតទ្ធិតទេ, បើផ្លាស់ជាគុណ ទើបចុះបច្ច័យក្នុងការតទ្ធិតក្រៅពីកា-បច្ច័យនោះ ដូចប្រយោគថា **អនច្ឆរិយំ ភិក្ខវេ ឯតំ, យំ សក្កោ ទេវានមិន្ទោ មយិ សិនេហំ ករោតិ** (ប្រែ)" ភិក្ខវេ ម្នាលភិក្ខុទ. ទេវានជា ទេវានមិន្ទ សក្កោ នាម ជាសក្កៈ ករោតិ រមែងធ្វើ សិនេហំ នូវសេចក្ដីស្រឡាញ់ មយិ ក្នុងតថាគត យំ ឯណា, ឯតំ-(សក្កស្ស ទេវានមិន្ទស្ស មយិ សិនេហស្ស ករណំ កិរិយាធ្វើ នូវសេចក្ដីស្រឡាញ់ ក្នុងតថាគត របស់ទេវានមិន្ទ នាមជាសក្កៈ)នុ៎ះ អនច្ឆរិយំ មិនចាត់ជាអស្ចារ្យទេ" ។ នេះផ្លាស់ ករោតិ ជានាម ។ ឯតំ-(សក្កស្ស ទេវានមិន្ទស្ស មយិ សិនេហស្ស ការកត្តំ កិរិយានៃទេវានមិន្ទនាមជាសក្កៈ ជាអ្នកធ្វើ នូវសេចក្ដីស្រឡាញ់ ក្នុងតថាគត)នុ៎ះ អនច្ឆរិយំ មិនចាត់ជាអស្ចារ្យទេ" ។ នេះផ្លាស់ ករោតិ ជាគុណនាម (ធ.ក.៦ ទំព័រ ១៩៧) ។

និយាយនេះ ចំពោះធាតុប្រព្រឹត្តទៅក្នុងកត្តុវាច្យ, ចំណែក

www.budinst.gov.kh www.elibraryofcambodia.org

ធាតុប្រព្រឹត្តទៅក្នុងអត្ថថា "មាន, កើត, ជា", បើសព្ទនាម ជាបុំលិង្គ ត្រូវផ្លាស់ជា ការ ហើយយកទៅប្រកបចូលនឹងបទ វិសេសនៈឬវិកតិកត្តា, បើសព្ទនាមជាឥត្ថីលិង្គ ឬនបុំសកលិង្គ ត្រូវចុះបច្ច័យក្នុងការកេទ្ធិត ក្រៅពីតា បច្ច័យ ត្រង់បទវិ-សេសនៈឬវិកតិកត្តានោះ ដូចប្រយោគថា **អនច្ឆរិយំ ខោ បនេតំ កិច្ចំ, យំ ត្វំ មាទិសំ អាចរិយំ លភិត្វា អព្យិត្តោ អហោសិ** (ប្រែ) "កិច្ចំ មួលកិច្ច បន ក៏ តុំ អ្នក លភិត្វា បានហើយ អាចរិយំ នូវអាចារ្យ មាទិសំ ប្រាកដដូចតថាគត អព្យត្តោ អហោសិ បានជាអ្នកមានសេចក្តីប្រាជ្ញាតិចហើយ យ៉ាងណា, ឯក–(ករ មាទិសំ អាចរិយំ លភិត្វា អព្យត្តភាវៈនៃអ្នកជាអ្នកបាន នូវអាចារ្យ ប្រាកដដូចតថាគត ហើយ មានសេចក្តីប្រាជ្ញាតិច)នុ៎ះ អនច្ឆរិយំ ទោ មិនគួរអស្ចារ្យ ទៀយ" (ជ ក.២ ទំព័រ ១៩១) ។ **ឥធ ខោ តំ កិច្ចំ**

www.budinst.gov.kh www.elibraryofcambodia.org

សោភេថ, យំ តុម្ហេ ឯវំ(១) ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ខមា ច ភវេយ្យាថ សោរតា ច

(ប្រែ) "ភិក្ខវេ ម្នាលភិក្ខុទ. តុម្ហេ អ្នកទ. ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា ជាអ្នកបួសហើយ ក្នុងធម្មវិន័យដែលតថាគតពោលល្អហើយ យ៉ាងនេះ ខមា ច សោរតា ច ភវេយ្យាថ គប្បីជាអ្នកអត់ធន់ផង ជាអ្នកត្រេកអរក្នុងធម៌ដ៏ល្អផង យំ ឯណា, តំ–(តុម្ហាកំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតានំ ខមសោរច្ចំ ភាវៈនៃអ្នកទ. បួសហើយ ក្នុងធម្មវិន័យដែលតថាគតពោលល្អហើយ យ៉ាងនេះ ជាអ្នកអត់ធន់ និងជាអ្នកត្រេកអរក្នុងធម៌ដ៏ល្អ) នោះ សោភេថ គប្បីល្អផង ទោ ធម្មវិនយេ ក្នុងធម្មវិន័យនេះឯង" ។ នេះ គឺសំឡឹងយកតសម្ពន្ធប្រយោគ (ធ.ក. ១ ទំព័រ ៨០) ។

ឧទាហរណ៍ដែលបានសំដែងមកនេះ សុទ្ធតែផ្លាស់កិរិយា

១ ឯវំ– សព្ទ កិរិយាវិសេសនៈក្នុង ស្វាក្ខាតេ ។

www.budinst.gov.kh www.elibraryofcambodia.org

អាខ្យាត ជានាម, ជាគុណ, ជាកិរិយាគតិកៈ ៗ ចំណែកការផ្លាស់គុណជានាមឬផ្លាស់កិរិយាគតិកៈជានាម គេឧទាហរណ៍ក្នុងគម្ពីរធម្មបទដ្ឋកថាមិនមានទេ ទើបមិនលើកមកសំដែង, អ្នកសិក្សា បើបានជួបត្រង់ណា ក៏ចូរគៀបនឹងឧទាហរណ៍ដែលពោលហើយនេះចុះ ។

សំដែងមកនេះ ចំពោះដែលមានរៀងសព្ទនាមទុក, ត្រង់លោកមិនរៀងទុកនោះ អ្នកសិក្សាចូរបញ្ចូលសព្ទនាមណាមួយដោយខ្លួនឯង ហើយប្រើយោគយកសេចក្តីដែលចំណាំនឹងនិយាយដល់នោះ ៗ មក ដូចប្រយោគថា **អាម ន ជានាមិ** (ខាងមុខ) ។ **ហោតាវុសោ** (ខាងក្រោយ) ។ ប្រែថា "អាមតើ អហំ រីខ្ញុំ ន ជានាមិ មិនដឹង" ។ "អាវុសោ ម្នាលអាវុសោ (ឯតំ អជាននំ រីការមិនដឹងនុ៎ះ) ហោតុ ចូរលើកទុក" ។ មួយទៀត ប្រយោគដែលត្រូវបញ្ចូលនោះដូច **អាវុសោ តយា ឧទកំ ឋបិតំ** (ប្រែ) "អាវុសោ ម្នាលអាវុសោ ឧទកំ រីទឹក តយា គឺអ្នក ឋបិតំ តាំងទុកហើយឬ ?"

www.budinst.gov.kh www.elibraryofcambodia.org

នេះសំនួនមុខ; **អាម អាវុសោ** នេះសំនួនក្រោយ, វេលាមិនប្រែសំនួនក្រោយ ត្រូវបញ្ចូល **អាម អាវុសោ (មយា ឧទកំ ឋបិតំ)** "អាម អើ អាវុសោ ម្នាលអាវុសោ ឧទកំ ទឹក មយា គឺខ្ញុំ ឋបិតំ តាំងទុកហើយ" (ធ.ក. ១ ទំព័រ ៧៦) ។ សូម្បីក្នុងទីដទៃ គប្បីនាំមកផ្ទៀបមើលដោយន័យនេះចុះ, កាលបើប្រែឲ្យត្រឹមត្រូវ តាមដំណើរសេចក្ដីដែលបង្គាប់ដល់ មិនទៅជាប្រយោគប្រកបដោយពាក្យពេចន៍ដ៏ល្អ ។

១១- វិធីរកសព្ទអញ្ញបទ

គុណសព្ទ គឺ សមាសគុណ, តទ្ធិតគុណ, សំខ្យាគុណ, គុណនាម រមែងមិនប្រែដោយចំនេនខ្លួនឯង មិនបានសេចក្ដីជាដាច់ទេ, ទុកជាបានសេចក្ដីខ្លះ ក៏មិនច្បាស់លាស់ ឬ មិនជិតស្និទ្ធល្អ លុះតែការប្រើយនាមនាមចូលជួយប្រកបផង ទើបសេចក្ដីនឹងអណ្ដែតច្បាស់ឡើង ឲ្យអ្នកស្ដាប់ចូល

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តបានយ៉ាងឆាយ ៗ ព្រោះហេតុនោះ អ្នកប្រែត្រូវសិក្សាឲ្យចេះចាំសព្ទអញ្ញបទ ដើម្បីនឹងនាំយកទៅប្រកបផ្សំ នឹងគុណសព្ទនោះ ៗ ឯវិធីនឹងរកអញ្ញបទ គឺនាមដទៃអំពីគុណសព្ទនោះ ត្រូវមើលគុណសព្ទឲ្យដឹងជាមុនសិន ថាតើជាលិង្គណា សំឡឹងយកសព្ទអញ្ញបទប្រភេទណា, កាលបើយល់ច្បាស់ហើយ ទើបនាំសព្ទអញ្ញបទប្រភេទនោះ លិង្គនោះមកប្រើ ៗ ឯសព្ទអញ្ញបទ ដែលប្រើជាញឹកញាប់ ដូច្នេះ ៖

នាមសព្ទប្រើជាអញ្ញបទនៃបទគុណ

បុំលិង្គ	ឥត្ថីលិង្គ	នបុំសកលិង្គ
កម្មន្តោ	ធម្មជាតិ, កិរិយា	កម្មំ, កិច្ចំ, ធុរំ
សភាវោ, ធម្មោ	ធម្មជាតិ	ធម្មជាតំ
គុណោ	គុណជាតិ	គុណជាតំ

www.budinst.gov.kh www.elibraryofcambodia.org

បុំលិង្គ	ឥត្ថីលិង្គ	នបុំសកលិង្គ
ទោសោ	ទោសជាតិ	ទោសជាតំ
បទេសោ, ភូមិភាគោ,	ភូមិ, បថវី	ភូមិតលំ, ឋានំ
វាទោ	វាចា, កថា	វចនំ
ចេតនាធម្មោ	ចេតនា	ចេតនាកម្មំ
ឱវាទោ	អនុសាសនី, ទេសនា	សាសនំ
កាលោ	វេលា	អទ្ធានំ
មគ្គោ, បថោ	វត្តនី, វីថិ	អទ្ធានំ
ភោគោ	សម្បត្តិ	វត្ថុ

អធិប្បាយ

ពាក្យដែលពោលក្នុងខាងលើថា “វិធីនឹងរកសព្ទអញ្ញបទ នោះត្រូវមើលគុណសព្ទឲ្យដឹងជាមុន ថាតើជាលិង្គណា, សំ-ឲ្យនឹងយកសព្ទអញ្ញបទ ប្រភេទណា” ។ ពាក្យនេះឯង បាន សេចក្តីថា “គុណសព្ទមានអំណាច ចាំបែនាមសព្ទដើមដែល

www.budinst.gov.kh www.elibraryofcambodia.org

ជាបុំលិង្គ ឥត្ថីលិង្គ និង នបុំសកលិង្គ ឲ្យប្រែក្លាយទៅជាលិង្គដទៃ ៗ ផ្សេងអំពីលិង្គដើមបាន ។ តែតាមដែលពិតនោះ មិនមែនដូច្នោះទេ ព្រោះក្នុងបាលីវេយ្យាករណ៍ថា "គុណសព្ទប្រព្រឹត្តទៅបាន ៣ លិង្គ" ការដែលគុណសព្ទប្រព្រឹត្តទៅបាន ៣ លិង្គ ក៏ដោយអំណាចនាមសព្ទមានលិង្គផ្សេងៗគ្នា គឺនាមសព្ទណា ជាបុំលិង្គ, ឥត្ថីលិង្គឬនបុំសកលិង្គ គុណសព្ទ ក៏ត្រូវក្លាយលិង្គទៅតាមនាមសព្ទនោះៗ ត្រង់ពាក្យដែលថា "ត្រូវសំឡឹងរកមើលគុណសព្ទ" នោះ ក៏ព្រោះគុណសព្ទលោកច្រើនតែសរសេរទុកក្នុងគម្ពីរស្រាប់, តែដែលលោកសរសេរទុកនោះ ក៏លោកតែងលិង្គតាមអញ្ញបទដែលត្រូវយោគបញ្ចូលមក ៗ

មែនពិត វិធីតែងគម្ពីរជាភាសាបាលី កន្លែងខ្លះលោករៀងទុកតែគុណសព្ទ, កន្លែងខ្លះរៀងទុកទាំងគុណសព្ទ ទាំងនាម-សព្ទ(អញ្ញបទ)ឲ្យអ្នកប្រែចូលចិត្តបានងាយ ទាំងមិនបាច់ព្រួយនឹករកអញ្ញបទមកប្រកបចូលទៀត ។ ចំណែកត្រង់កន្លែង

www.budinst.gov.kh www.elibraryofcambodia.org

ដែលលោករៀនទុកតែគុណសព្ទនោះ អ្នកប្រែនឹងចូលចិត្ត បានក៏ដោយអាស្រ័យគុណសព្ទ ដែលលោករៀនទុក ប្រកបលិង្គ, វចនៈ, វិភត្តិ ក្នុងទីនោះ ៗ ស្រាប់, បើគុណសព្ទនោះសំឡឹងដល់នាមសព្ទប្រភេទណា ក៏ត្រូវនាំយកនាមសព្ទប្រភេទនោះ មកប្រកបចូលជាអញ្ញបទ ដូចបទគុណសព្ទថា ៖

កាយិកោ បទនេះ ជាតទ្ធិតគុណ បុំលិង្គ សំឡឹងដល់សព្ទអញ្ញបទ ប្រភេទដែលជាប់ដោយកាយ ត្រូវយក **កម្មន្តោ** ជា អញ្ញបទ ប្រែថា « (កម្មន្តោ ការងារ) កាយិកោ គឺបុគ្គលធ្វើហើយ ដោយកាយ » ៗ **កាយិកា** បទនេះ ជាឥត្ថីលិង្គ ត្រូវយក **កិរិយា** ជាអញ្ញបទ **កាយិកំ** បទនេះ ជានបុំសកលិង្គត្រូវយក **កម្មំ** ជាអញ្ញបទ ៗ

អាទិកល្យាណោ បទនេះ ជាសមាសគុណ បុំលិង្គ សំឡឹងដល់សព្ទអញ្ញបទប្រភេទធម៌ ត្រូវយក **ធម្មោ** មកជាអញ្ញបទ ប្រែថា «(ធម្មោ ធម៌) អាទិកល្យាណោ មាន

www.budinst.gov.kh www.elibraryofcambodia.org

លំអក្នុងខាងដើម» ។ **អាទិកល្យាណំ** បទនេះ ជានបុំសកលិង្គ ត្រូវយក **ធម្មជាតំ** ជាអញ្ញបទ ។

មនុស្សាវាសោ សបរិបន្ថោ, បទថា **មនុស្សាវាសោ** ជាបុំលិង្គ សំឡឹងដល់ទីឋាន ត្រូវយក **បទេសោ** មកជាអញ្ញបទ ប្រែថា «(បទេសោ ប្រែទេស) មនុស្សាវាសោ ជាទីនៅនៃមនុស្ស សបរិបន្ថោ ប្រព្រឹត្តទៅមួយអន្លើ ដោយសេចក្តីអន្តរាយ» ។

ឥតោ បដ្ឋាយ តវ អភូមិ, បទថា **អភូមិ** នេះជាឥត្ថីលិង្គ ត្រូវយក **អយំ ភូមិ** មកជាអញ្ញបទ ប្រែថា «បដ្ឋាយ តាំងដើម ឥតោ ហាំនគោ អំពីទីនោះ (អយំភូមិ ភូមិនេះ) អភូមិ មិនមែនជាភូមិ **តវ** របស់អ្នក» ។

អសមំ បទនេះ ជានបុំសកលិង្គ ត្រូវយក **ឋានំ** មកជាអញ្ញបទ ប្រែថា «(ឋានំ ទី) អសមំ ដែលមិនស្មើ» ។

បើបទគុណសព្ទសំឡឹងដល់នាមសព្ទ ដែលជាសាធារណ-

www.budinst.gov.kh www.elibraryofcambodia.org

នាម ឬសាធារណនាម ក៏ត្រូវយកនាមសព្ទនោះមកប្រកបឲ្យត្រូវតាមសេចក្ដី ដែលបទគុណសព្ទសំឡឹងដល់ ៗ ក្រៅពីនេះក្នុងទីដែលជានបុំសកលិង្គ ត្រូវប្រើវត្ថុជាពាក្យកណ្ដាល ៗ ជាអញ្ញបទបានខ្លះទៅ ។ បើក្នុងទីដែលត្រូវការលិង្គដទៃត្រូវរើសសព្ទប្រើឲ្យសមគួរដល់សេចក្ដី ដូចយ៉ាងសេចក្ដីជាប់ដោយទ្រព្យសម្បត្តិ បើបុំលិង្គ ប្រើ **ភោគោ**, ឥត្ថីលិង្គ ប្រើ **សម្បត្តិ** ជាអញ្ញបទ ៗ សព្ទដែលជាប់ដោយអវយវៈកងកាយ ឬជាប់ដោយទព្វសម្ភារៈ ដែលប្រកបជាកងរថ ឬរទេះ បើបុំលិង្គប្រើ **អវយោ**, ឥត្ថីលិង្គ ប្រើ **ធម្មជាតិ** ជាអញ្ញបទ ៗ តែរឿងដែលជាប់ដោយកងកាយនេះ បើនឹងប្រើ **អង្គំ** ជាអញ្ញបទវិញសម្រាប់ក្នុងទីដែលជានបុំសកលិង្គក៏បាន ។

មួយទៀតបទសមាសដែលមាន តទ-សព្ទ ជាសមាសមួយ ដែលលំបាកក្នុងការរកសព្ទអញ្ញបទ, បើទុកជាយ៉ាងនោះក៏គង់មានគោលទុកឲ្យអ្នកសិក្សាល្មមសង្កេតបាន គឺឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

មើលបទនាម ដែលតាំងនៅក្នុងបទសមាសនោះ តើជាប់ដោយអ្វី ? បើជាប់ដោយអាការៈ ក៏យកអាការៈមកជាអញ្ញបទ ដូច **កេសាទិ** (**អាការោ** អាការ.) មានសក់ជាដើម ៗ បើជាប់ដោយវត្ថុ ក៏យកវត្ថុអញ្ញបទ ដូច **គុឡមធុផាណិតាទីនិ** (**វត្ថូនិ** វត្ថុ.) មានប្រេងនិងទឹកឃ្មុំនិងទឹកអំពៅជាដើមៗបើជាប់ដោយកិច្ច ក៏យកកិច្ចជាអញ្ញបទ ដូច **ន្ហានសម្ពាហនាទីនិ** (**កិច្ចានិ** កិច្ច.) មានការច្របាច់ខ្លួនជើងជាដើម ៗ បើជាប់ដោយវត្ត ក៏យកវត្តជាអញ្ញបទ ដូច **អាចរិយុបជ្ឈាយវត្តាទីនិ** (**វត្តានិ** វត្ត.) មានអាចារ្យវត្តនិងឧបជ្ឈាយវត្តជាដើមៗ បើជាប់ដោយទុក្ខក៏យកទុក្ខជាអញ្ញបទ ដូច **ជាតិអាទីនិ**(**ទុក្ខានិ** ទុក្ខ.)មានជាតិទុក្ខជាដើម ៗ បើជាប់ដោយសត្វ ក៏យកសត្វជាអញ្ញបទ ដូច **អស្សាទយោ** (**សត្តា** សត្វ.) មានសេះជាដើម ៗ បើជាប់ដោយបុគ្គល ក៏យកបុគ្គល ឬជនជាអញ្ញបទ ដូច

www.budinst.gov.kh www.elibraryofcambodia.org

អនាថបិណ្ឌិកាទយោ (ជនា *រ៉ែដខ១.*) មាសេដ្ឋីឈ្មោះអនាថបិណ្ឌិកជាដើម ។ បើបទសមាស មាននាមផ្សេងបែបគ្នា ដូច **គោមហិសទាសីទាសខេត្តវត្ថុគាមនិគមជនបទាទីនិ** ក៏ចូរយកសព្ទអញ្ញបទនោះ ៗ រួមចូលជាសមាស ប្រែថា “(សត្តបរិវារកង្ខានាទិ រសត្វនិងមនុស្សអ្នកបំរើនិងទីទ.) គោមហិស ..ជនបទាទីនិ មានគោនិងក្របី និងខ្ញុំស្រី និងខ្ញុំប្រុស និងស្រែ និងចំការ និងស្រុក និងនិគម និងជនបទ ជាដើម ” ។

មួយវិញទៀត នាមនាមណា ប្រព្រឹត្តទៅបានតែលិង្គមួយ គឺ បើបុំលិង្គ បានតែជាបុំលិង្គ, ឥត្ថីលិង្គ បានតែជាឥត្ថីលិង្គនឹង ប្រែជាលិង្គដទៃមិនបាន; បើបទគុណសព្ទឬសព្វនាម លោករៀនទុកដើម្បីសំឡឹងដល់នាមនាមនោះ តែលោកមិនបានតែងលិង្គទុកឲ្យត្រូវគ្នានឹងនាមនាមនោះទេ, កាលបើដូច្នេះ ត្រូវយកសព្ទ គឺ **ជាត , គត, ជាតិ** ទៅប្រកបចូលនឹងនាមនាមដើម្បីស្គាល់លិង្គដើមរបស់នាមនាមនោះ ឲ្យប្រក្លាយ

www.budinst.gov.kh www.elibraryofcambodia.org

លិង្គត្រូវគ្នានឹងបទគុណសព្ទឬសព្ទនាម ក្នុងទីនោះ ៗ មែនពិត សព្ទញាតិ **ជាត, គត, ជាតិ** នេះ ហៅថា សព្ទស្កាត់លិង្គ ឬហៅថាសព្ទសម្រាប់តែងលិង្គ នៃនាមនាម ដើម្បីនឹងយកទៅប្រកបចូលជាមួយសព្ទនាមមាន ឯក, ឥម ជាដើម ឬបទគុណសព្ទខ្លះក៏បាន គឺនាមនាមដែលជាបុំលិង្គ តែងឲ្យជានបុំសកលិង្គនិងឥត្ថីលិង្គបាន ឬនាមនាមជាឥត្ថីលិង្គ តែងឲ្យជាបុំលិង្គ និងនបុំសកលិង្គវិញ ដូច **វិត្តោ** ជា **វិត្តជាតំ, រោគោ** ជា **រោគជាតំ, និធិ** ជា **និធិគតំ និធិគតោ, ធម្មោ** ជា **ធម្មជាតំ ធម្មជាតិ, សទ្ទោ** ជា **សទ្ទជាតំ សទ្ទជាតិ** ៗ ចំណែកការប្រែសព្ទដែលមាន **ជាត, គត, ជាតិ** នៅខាងចុង ត្រូវប្រែចំពោះតែនាមសព្ទខាងដើម ដូច **វិត្តជាតំ** (ប្រែថា) សម្បត្តិ, **និធិគតោ** វត្ថុ **ធម្មជាតិ** ធម៌ (ឬធម្មជាតិ) ៗ ត្រង់ **ជាត គត, ជាតិ** មិនបាច់ប្រែ, បើទុកជាប្រែ ក៏មិនបានសេចក្ដីជាយ៉ាងម៉េច មានតែនាំឲ្យខូចតែឲ្យសេចក្ដីទៅវិញព្រោះ **ជាត, គត , ជាតិ** នោះ ដែល

www.budinst.gov.kh www.elibraryofcambodia.org

ប្រកបមក ដើម្បីតែសួរលិង្គដើមរបស់នាមនាមប៉ុណ្ណោះ ។

១២. វិធីប្រែប្រយោគឧបមា

សេចក្តីដែលនាំមកប្រៀបធៀប ជាសេចក្តីដែលមានមកអំពីដើម បើល្អក៏ល្អមែន បើអាក្រក់ក៏អាក្រក់មែន ជារឿងពិតប្រាកដដែលលោកត្រូវនាំយកមកផ្ទួរធៀបគ្នា នឹងសេចក្តីនៃសង្កាត់ដទៃ ដើម្បីបំភ្លឺសេចក្តីឲ្យឃើញច្បាស់តាមពិត ឈ្មោះថា ប្រយោគឧបមា ។ កាលបើប្រយោគឧបមាមានហើយ ប្រយោគឧបមេយ្យក៏ត្រូវមានដែរ ព្រោះសេចក្តីក្នុងប្រយោគទាំង ២ នេះ ទាក់ទងគ្នាដូចកូនសោនិងមេសោ ។ សេចក្តីគួរនាំទៅប្រៀបធៀបនឹងសេចក្តីឧបមានោះ ឈ្មោះថា ប្រយោគឧបមេយ្យ ។ សេចក្តីទាំងពីរនេះ អាស្រ័យអ្វីជាគោលឲ្យស្គាល់បាន ថាជាសេចក្តីសង្កាត់នេះជាឧបមា ឬសង្កាត់នោះជាឧបមេយ្យ ? រឿងនេះនឹងស្គាល់បាន ដោយសារនិបាត ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោគឧបមា កំណត់ដោយនិបាត ៤ សព្ទគឺ **សេយ្យថាបិ, យថា** ប្រែថា «ដូចជា, យ៉ាងណា, យ៉ាងណាមិញ, មានឧបមាយ៉ាងណា», **វិយ, ឥវ** ប្រែថា «បីដូច, ដូចជា, ហាក់ដូច, ហាក់ដូចជា, ប្រហែលដូច, ប្រហែលដូចជា, ប្រដូច, មានឧបមាដូចជា, មានឧត្តរមាដូចជា.» ។ ប្រយោគឧបមេយ្យ កំណត់ដោយនិបាត ២ សព្ទគឺ **តថា, ឯវំ** ប្រែថា «យ៉ាងនោះ, ដូច្នោះ, យ៉ាងនេះ, យ៉ាងនោះ, មានឧបមេយ្យយ៉ាងនោះ» ។ និបាតក្នុងប្រយោគទាំងពីរនេះប្លែកគ្នាដូច្នេះគឺ សេយ្យថាបិ, យថា និងតថា, ឯវំ លោកច្រើននិយមចុះក្នុងប្រយោគ ដែលជាពាក្យពេញទី គឺប្រយោគដែលមានកិរិយារបស់ប្រធាន; វិយ, ឥវ ច្រើននិយមចុះក្នុងប្រយោគជាវាក្យាង្គ(១) ខ្លះ ជាគុណ-

១ វាក្យ+អង្គ «ចំណែកពាក្យ», គឺចំណែកប្រយោគ ដែលជាសង្កាត់ពាក្យមានសេចក្ដីមិនទាន់គ្រប់គ្រាន់ ដូចពាក្យថា «ផ្ទះ របស់ខ្ញុំ, ឈើ ធំ, គោ កាច» ។

www.budinst.gov.kh www.elibraryofcambodia.org

ក្បាច់ស្រូវ ហើយស្រែកគ្រៀតនៅក្នុងចន្លោះកណ្ដាល នៃ ប្រយោគឧបមេយ្យ ។

ប្រយោគឧបមាដែលជាពាក្យពេញទី

វិធីប្រែប្រយោគឧបមា ឧបមេយ្យ ដែលជាពាក្យពេញទី បើនឹងពោលតាមដំណើរ ដែលលោកធ្លាប់ប្រើជាញឹកញាប់ មានវិធីប្រែ ៣ យ៉ាង ។

ការប្រែប្រយោគឧបមា ឧបមេយ្យ ដែលជាពាក្យពេញទី មានវិធីប្រែ ៣ យ៉ាង គឺ ប្រែទទួល ១, មិនប្រែទទួល១, ប្រែទទួលក៏បាន មិនទទួលក៏បាន១ ។

អធិប្បាយ

១) ប្រែទទួល, ការប្រែទទួលនេះ មុនបន្តិចអ្នកប្រែត្រូវពិនិត្យឲ្យស្គាល់ជាមុនថា កាលបើប្រយោគឧបមា-ឧបមេយ្យនោះជាពាក្យទី ៗ បើទុកជាប្រែទទួល ក៏មិនធ្វើសេចក្ដីបន្តិចបន្តួចសូម្បីតែមួយបទ ឬ សព្ទមួយឲ្យបាត់ទៅក្ដី ប្រយោគ

www.budinst.gov.kh www.elibraryofcambodia.org

ឧបមាមិនមាននិបាត គឺ វ, ឥវ, នាមណាមួយជាប់នឹងឧបមា នេះ ឬមិនមាន ហិ, ច, ចន ដែលជានិបាតដើមពាក្យក្តី ប្រយោគឧបមាតាំងនៅក្នុងចន្លោះ ឬស្រែកចុះក្នុងកណ្តាល នៃប្រយោគឧបមេយ្យក្តី យ៉ាងនេះ គួរប្រែទទួល ៗ ការប្រែទទួលនេះត្រូវប្រែខាងប្រយោគឧបមេយ្យជាមុន ប្រែឲ្យទាល់តែអស់សព្ទទុកឲ្យសល់នៅតែ ឯវំ, កាលនឹងប្រែ ឯវំ គប្បីអានតាំងពីយថា ទាំងប្រយោគ មកត្រួមនឹង ឯវំ ប្រែចូលគ្នាតែម្តងថា "ដូចជា...ដូច្នោះ" ឧ. **យថា សោ រហទោ អនាកុលតាយ វិប្បសន្នោ អចលតាយ អនាវិលោ (ហោតិ) ឯវំ មម ទេសនាធម្មំ សុត្វា សោតាបត្តិមគ្គាធិគមេន និរុបក្កិលេសចិត្តំ អាបជ្ជន្តា វិប្បសីទន្តិ** (ប្រែ) "បណ្ឌិតា រឺបណ្ឌិតទ.) មម ទេសនាធម្មំ សុត្វា អាបជ្ជន្តា កាលស្តាប់នូវធម៌ទេសនារបស់តថាគត ហើយដល់ និរុបក្កិលេសចិត្ត នូវចិត្តមានឧបក្កិលេស

www.budinst.gov.kh www.elibraryofcambodia.org

មិនមាន សោតាបត្តិមគ្គាទិវសេន ដោយអំណាចនៃមគ្គមាន សោតាបត្តិមគ្គជាដើម វិប្បសីទតិ ឈ្មោះថា(១) រមែងជ្រះថ្លា យថា សោ រហទោ អនាកុលតាយ វិប្បសន្នោ អបលតាយ អនាវិលោ (ហោតិ) ឯវំ ដូចជាអន្លង់ទឹកនោះ ដែលឈ្មោះថាជាទឹកថ្លាច្នួនហើយ (២) ព្រោះភាវៈនៃអន្លង់ទឹកនោះជានូវទឹកជាតមិនកករ ដែលឈ្មោះថាជាទឹកមិនល្អក់(៣) ព្រោះ

---

១ "ឈ្មោះថា" នេះ ហៅថា ប្រែផកហេតុ ។ សង្កេតគោលប្រែផកហេតុដូច្នេះ អដ្ឋកថាដែលមានកិរិយា២គឺ កិរិយាខាងមុខប្រកបអន្ត-មានបច្ច័យ, កិរិយាខាងចុង ជាបទកិរិយាអាខ្យាតដែលមានក្នុងគាថា យ៉ាងនេះ ត្រូវប្រែផកហេតុ ។

២, ៣ កុំច្រឡំ, បទនេះមិនមែនជាសញ្ញាវិសេសនៈទេ, ពាក្យថា "ឈ្មោះថាៗ" ក្នុងទីនេះហៅថា ប្រែកល់ហេតុ ព្រោះបទវិប្បសន្នោ, អនាវិលោ នេះលោកលើកពីក្នុងគាថាមកកែ ដោយបទខាងដើមប្រកបតតិយា ឬ បញ្ចមីវិភត្តិ ដែលប្រែថាព្រោះឬហេតុ ។ ឯវិធីប្រែកល់ហេតុនេះ គ្មានពាក្យសម្ពន្ធទេ,ត្រូវហៅទៅតាមវិធីសម្ពន្ធធម្មតាថា វិប្បសន្នោ,អនាវិលោ វិកតិកត្តាក្នុង ហោតិ ។

www.budinst.gov.kh www.elibraryofcambodia.org

ការៈនៃទឹកនោះជាឧទកជាគម៌នរលកផន្គំដូច្នោះ» (ផ.ក ៤
ទំព័រ ៦៨) ។ **សោ កិរ, យថា គេណិយោ ជដិ-
លោ បព្វជិតវេសេន, ឯវំ គោបាលកត្តេន
រាជបីឡំ បរិហរន្តោ អត្តនោ កុដុម្ពំ វឌ្ឍេតិ**
*(ប្រែ) «គេ បានឮថា សោ.នន្ទគោបាលកោ រីឯយនន្ទ-
គោបាលនោះ បរិហរន្តោ គាលវៀសវាង កជបីឡំ នូវ
សេចក្ដីបៀតបៀនអំពីស្ដេច វឌ្ឍេតិ រក្សា កុដុម្ពំ នូវទ្រព្យ
អត្តនោ របស់ខ្លួន គោលបាលកវេសេន ដោយភាវៈនៃខ្លួនជាអ្នក
ឃ្វាលនូវគោ យថា គេណិយោ ជដិលោ បព្វជិតវេសេន
(រាជបីឡំ បរិហរន្តោ អត្តនោ កុដុម្ពំ វឌ្ឍេតិ) ឯវំ ដូច
ជាវីគេណិយជដិល (គាលវៀសវាង នូវសេចក្ដីបៀតបៀន
អំពីស្ដេច រក្សានូវទ្រព្យ របស់ខ្លួន) ដោយភេទរបស់បព្វជិត
ដូច្នោះ (ផ.ក. ២ ទំព័រ ២៤៩)* ។

២) មិនប្រែឲទួល *រីឯនេះ គប្បីកំណត់យ៉ាងនេះ គឺ*

ប្រយោគទាំងពីរនោះ ជាពាក្យវែង ៗ មានសេចក្ដីដដែលច្រឡូកច្រឡំ ជ្រែកជ្រៀតមកក្នុងកណ្ដាល ជាប្រយោគអនាទរៈ ឬប្រយោគលក្ខណៈជាដើមខ្លះ មិនមានខ្លះ កាលបើប្រែរួចហើយធ្វើសេចក្ដីឲ្យឃ្លាតមិនជិតល្អ ឬក៏ប្រយោគឧបមាមាននិបាត ដូចពោលហើយនោះ បើប្រែចង្អូល សេចក្ដីរបស់និបាតនឹងបាត់ទៅ, ប្រយោគទាំងនេះ មិនគួរប្រែចង្អូលទេ ។

> វិធីប្រែមិនចង្អូល មានពីរយ៉ាង គឺ ប្រែឧបមារួចប្រែឧបមេយ្យ ១, ប្រែឧបមារួចប្រែ ដាក់បន្ទាប់បទប្រធាននៃឧបមេយ្យ ១ ។

ក) ប្រែឧបមារួចប្រែឧបមេយ្យ

វិធីនេះ ត្រូវប្រែប្រយោគឧបមាមុន លុះប្រែអស់សេចក្ដីខាងឧបមាហើយ ទើបប្រែយថា ថា "យ៉ាងណា ..." ទុកត្រង់ទីបំផុតដើមប្រយោគតែម្ដង រួចទៅប្រែប្រយោគឧប-

www.budinst.gov.kh www.elibraryofcambodia.org

មេយ្យ, កាលប្រែអស់សេចក្ដីខាងប្រយោគឧបមេយ្យហើយ ទើបប្រែ ឯវំថា "យ៉ាងនោះ..." ទុកត្រង់ទីបំផុតដើមប្រយោគ ដូចគ្នាដែរ ។. **យថា ឯកេន បុរិសេន បដិវាតេ ឋិតំ បហារិតុកាមតាយ ខិត្តោ សុខុមោ រជោ តមេវ បុរិសំ បច្ចេតិ : តស្សេវ ឧបរិ បតតិ, ឯវមេវ យោ បុគ្គលោ អប្បទុដ្ឋស្ស បុរិសស្ស បាណិប្បហារាទីនិ ទទន្តោ បទុស្សតិ តមេវ ពាលំ ទិដ្ឋេវ ធម្មេ សម្បរាយេ វា និរយាទីសុ វិបច្ចមានំ តំ បាបំ វិបាកទុក្ខវសេន បច្ចេតិ** (ប្រែ) "រជោ ធូលី សុខុមោ ដ៏ល្អិត ឯកេន បុរិសេន ខិត្តោ ដែលបុរសម្នាក់ បាចទៅហើយ បដិវាតេ ឋិតំ បហារិតុកាមតាយ ដោយភាពនៃខ្លួនជាអ្នកប្រាថ្នាដើម្បីប្រហារ នូវបុគ្គលអ្នកឈរក្នុងទីច្រាសនៃខ្យល់ បតិ ឯតិ រមែងត្រឡប់ដល់ បុរិសំ នូវបុរស តំ ឯវ នោះវិញ តមេវ បុរិសំ បច្ចេតិ គឺថា តស្សេវ ឧបរិ

បតតិ, បតតិ រមែងធ្លាក់ទៅ ឧបរិ ពីខាងលើ តស្ស ឯវ-បុរិសស្ស នៃបុរសនោះវិញ យថា យ៉ាងណា, បុគ្គលេក វិបុ-គ្គល យោ ឯណា ទទត្តោ កាលឲ្យ បាណិប្បហារកំ នូវការប្រហារ១, មានការប្រហារដោយដៃជាដើម បុរិសស្ស ដល់បុរស អប្បទុដ្ឋស្ស អ្នកមិនប្រទុស្តកហើយ បទុស្សតិ ឈ្មោះជាប្រទុស្ត, បាបំ វិបាក តំនោះ វិបច្ចមានំ កាលឲ្យផល ទំនួរ ផល្លេ ក៏ ក្នុងបច្ចុប្បន្នឬ សម្បរាយេ និរយាទិសុ ក៏ ឬក្នុងអបាយ១. មាននរកជាដើម ក្នុងសម្បរាយភព តំ ឯវ ពាលវិបាកទុក្ខរសេន បតិ ឯតិ ឈ្មោះថាតាមស្ទង់ នូវបុគ្គលពាលនោះឯង ដោយអំណាចនៃវិបាកទុក្ខ ឯវំ ឯវ យ៉ាងនោះឯង»

(ធ.ក ៤ ទំព័រ ៦៩) ។

ខ)ប្រែឧបមារូបប្រែងវបន្ទាប់បទប្រធាននៃឧបមេយ្យ

វិធីនេះ ក៏ត្រូវប្រែប្រយោគឧបមាមុន កាលប្រែអស់សេចក្តីខាងប្រយោគឧបមាហើយ ទើបប្រែ យថា ថា «ដូចម្តេចមិញ»

ទុកក្នុងទីបំផុតនៃពីរប្រយោគដូចគ្នា, រួចទៅប្រែបទប្រធាន ក្នុងប្រយោគឧបមេយ្យ ព្រមទាំងបទវិសេសនៈរបស់បទប្រធាន ទើបប្រែ ឯវំ, ទីនេះប្រែ ឯវំ ថា "គឺដូច្នោះឯង" តពី ឯវំ ទៅ ត្រូវប្រែសព្ទដទៃ ៗ ក្នុងប្រយោគឧបមេយ្យនោះ រហូតដល់ចប់ ឧទាហរណ៍ដូច្នេះ ៖ **យថា តំ បុប្ផំ ធារេន្តស្ស សរីរេ គន្ធោ ផរតិ ឯវំ តេបិដកពុទ្ធវចនសង្ខាតា សុភាសិតា វាចាបិ សុកុព្វតោ : យោ សក្កច្ចំ សវនាទីហិ តត្ថ កត្តព្វំ ករោតិ សា អស្ស បុគ្គលស្ស សផលា ហោតិ : សុតគន្ធធារណ-គន្ធប្បដិបត្តិគន្ធានំ អាវហនតោ មហប្ផលា ហោតិ មហានិសំសា** *(ប្រែ) "គន្ធោ ក្លិននៃផ្កា ផរតិ រមែងផ្សាយទៅ សរីរេ ក្នុងសរីរៈ (បុគ្គលស្សនៃបុគ្គល) ធារេន្តស្ស កាលទ្រទ្រង់ បុប្ផំ នូវផ្កា តំ នោះ យថា ដូចម្តេចមិញ តេបិដកពុទ្ធវចនសង្ខាតា សុភាសិតា វាចាបិ សូម្បីវាចាជា*

www.budinst.gov.kh www.elibraryofcambodia.org

សុភាសិត ដែលបណ្ឌិតកប់ជាពុទ្ធវចនៈ គឺព្រះត្រៃបិដក ឯវំ ក៏ដូច្នោះឯង សា-សុភាសិតា វាចា . . . នោះ សផលា ហោតិ ជាគុណជាតប្រព្រឹត្តទៅមួយអន្លើដោយផល សផលា ហោតិ គឺថា សុគន្ធ . . . ហោតិ មហានិសំសា, មហប្ផលា មហា-និសំសា ហោតិ ឈ្មោះថាជាធម្មជាតិមានផលច្រើន មានអា-និសង្សច្រើន ករោតោ ព្រោះកិរិយានាំមកសុគន្ធការណ-គន្ធប្បដិបត្តិគន្ធានំ នូវគុណគឺការស្តាប់និងគុណគឺការចងចាំនិងគុណ គឺការប្រព្រឹត្តទាំងឡាយ សុកុព្វតោ ដល់បុគ្គលកាលធ្វើល្អ សុកុព្វតោ គឺថា យោ សក្កច្ចំ . . . តស្ស បុគ្គលស្ស, យោ-បុគ្គលោ សក្កច្ចំ សវនាទីហិ តត្ថ ពុទ្ធវចនេ កត្តព្វំ ករោតិ តស្ស បុគ្គលស្ស ដល់ រីបុគ្គលណា ធ្វើនូវកិច្ចដែលខ្លួនគប្បី ធ្វើក្នុងពុទ្ធវចនៈនោះ ដោយកិច្ច. មានការស្តាប់ដោយគោរព ជាដើម បុគ្គលនោះ» (ធ.ក. ៣ ទំព័រ ៧៤) ។

៣) ប្រែទទួលក៏បាន មិនទទួលក៏បាន, វិធេះ

www.budinst.gov.kh www.elibraryofcambodia.org

គប្បីសង្កេតយ៉ាងនេះ៖ សេចក្ដីក្នុងប្រយោគទាំងពីរនោះ ជាពាក្យខ្លីៗ ក៏ដោយ ជាពាក្យវែងៗ ទាំងមានសេចក្ដីប្រឡូកប្រឡំគ្នាក៏ដោយ នឹងប្រែខ្ចួល ឬមិនខ្ចួល ក៏បានសេចក្ដីច្បាស់ល្អទាំង២ យ៉ាង, យ៉ាងនេះ នឹងប្រែខ្ចួលក៏បាន មិនខ្ចួលក៏បាន, តែបើប្រយោគឧបមា មាននិបាតដូចសំដែងមកហើយនោះ នៅប្រចាំផង មិនគួរប្រែខ្ចួលទេ, ព្រោះថា កាលបើប្រែខ្ចួល សេចក្ដីរបស់និបាតនឹងបាត់ទៅ. ក្រៅពីនេះ មិនហាមទេ ។ ឧទាហរណ៍ដូច្នេះ៖

យថា ទណ្ឌេន គោបាលោ គាវោ បាចេតិ គោចរំ
ឯវំ ជរា ច មច្ចុ ច អាយុំ បាចេន្តិ បាណិនំ

(ប្រែ) "គោបាលោ អ្នកចិញ្ចឹមនូវគោ បាចេតិ រមែងដេញទៅ គាវោ នូវគោទ. គោចរំ កាន់ទីគោចរ ទណ្ឌេន ដោយដំបង យថា យ៉ាងណា, ជរា ច ជរាផង មច្ចុ ច មច្ចុផង បាចេន្តិ រមែងដេញទៅ អាយុំ នូវអាយុ បាណីនំ

www.budinst.gov.kh www.elibraryofcambodia.org

របស់សត្វ. ឯវំ ដូច្នោះ" (នេះមិនប្រែទទួល) ។ "ជរា ច ជរាផង មច្ចុ ច មច្ចុផង បាចេន្តិ រមែងដេញទៅ អាយុំ នូវអាយុ បាណីនំ របស់សត្វ. យថា ទណ្ឌេន គោបាលោ គាវោ បាចេតិ គោចរំ ឯវំ ដូចជាអ្នកចិញ្ចឹមនូវគោ ដេញនូវគោទ. ទៅកាន់ទីគោចរដោយដំបងដូច្នោះ" (នេះប្រែទទួល) ធ.ក. ៥ ទំព័រ៨៥ ។

ប្រយោគឧបមាជាវាក្យាង្គ

ប្រយោគឧបមា ជានាមវាក្យាង្គនិងគុណវាក្យាង្គ លោកប្រកបដោយនិបាត ២ សព្ទ គឺ **និយនិងឥវ** ។ ប្រយោគនេះតែងតែបនែបច្រៀកជ្រែកនៅក្នុងចន្លោះ នៃប្រយោគឧបមេយ្យមិនតាំងនៅកណ្តាលបកណ្តាលតែឯង ដូចប្រយោគឧបមាដែលជាពាក្យពេញទីទេ តែសេចក្តីជាសង្កាត់មួយផ្សេងដោយឡែកៗ

នាមវាក្យាង្គដូចឧទាហរណ៍ថា **មច្ឆានំ ខីណគាគោ** **និយ ឥមេសំ គោគានំ អគាគោ** (ប្រែ) "អគាគោ

វិការមិនមាន គោគានំ នៃគោគ។. ជមេសំ-ពាលានំ របស់ជនពាល។. នេះ មជ្ឈានំ ទំណកាលេ វិយ ដូចជាគាពនៃត្រែង-អស់ហើយ" (ធ.ក. ៥ ទំព័រ ១៨៦) ។ + +

គុណវាក្យាង្គ ដូចឧទាហរណ៍ថា **ឥទំ និន្ទនំ វា បសំសនំ វា អជ្ជតនំ(១): អធុនា ឧប្បន្នំ វិយ ន ហោតិ**(ប្រែ) "និន្ទនំ ក៏ វិការតិះដៀលក្តី បសំសនំ ក៏ វិការសរសើរក្តី ឥទំ នេះ អជ្ជតនំ : អធុនា ឧប្បន្នំ វិយ ន ហោតិ មិនមែនដូចជាទើបនឹងកើតឡើងក្នុងកាលមានក្នុងថ្ងៃ នេះ គឺ ក្នុងកាលឥឡូវនេះទេ" (ធ.ក.៦ទំព័រ៤៣៥) ។

---

១. ជាបទតទ្ធិត ចុះ តន បច្ច័យ វិគ្គហៈថា អជ្ជ ភវោ › អជ្ជតនោ (ការលោ)។ដែលជា អជ្ជតនំ នោះ គឺផ្លាស់ ស្ទើជា អំ ។ សព្ទគឺ សនន្តនោ "ធម៌មានក្នុងកាលមុន" ស្វាតនំ "កត្តមានក្នុងថ្ងៃស្អែក" អជ្ជតនី "វិភត្តិមានក្នុងថ្ងៃនេះ", ទាំងបីនេះ ក៏ជាបទតទ្ធិត ចុះតន-បច្ច័យដែរ វិគ្គហៈថា សនំ ភវោ›សនន្តនោ(ធម្មោ), ស្វេ ភវោ›ស្វាតនំ(កត្តំ), អជ្ជ ភវា > អជ្ជតនី (វិភត្តិ)

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោគឧបមាជាវាក្យាង្គនេះ កាលនឹងប្រែ ត្រូវប្រែប្រយោគឧបមេយ្យ ហេតុតែសេចក្តីខាងឧបមេយ្យជាមុន ទើបប្រែប្រយោគឧបមាបាន ។ តាមន័យនេះបានសេចក្តីថា ប្រែបានតែដោយវិធីប្រែទទួលប៉ុណ្ណោះ ។ មួយទៀត គតិនៃ **វិយ, ឥវ** នេះ ប្រព្រឹត្តទៅក្នុងនាមនិងគុណ, នាមនៅជានាមដដែលក៏បាន ក្លាយជាវិសេសនៈក៏បាន ក្លាយជាវិកតិ-កត្តាក៏បាន, សព្វគុណនៅជាគុណដដែលក៏បាន ក្លាយជាវិកតិកត្តាក៏បាន ស្រេចតែសេចក្តីដែលបង្គាប់ក្នុងទីនោះ ៗ ។

ឧបមាជាវាក្យាង្គ

ប្រយោគឧបមា ដែលជានាមវាក្យាង្គ និងគុណវាក្យាង្គ លោកកំណត់ដោយនិបាត ២ សព្ទគឺ វិយ និង ឥវ, មានវិធីប្រែ ៣ យ៉ាង គឺ ប្រែជាឧបមាលិង្គត្ថៈ១, ប្រែជាឧបមា-វិសេសនៈ១, ប្រែជាឧបមាវិកតិកត្តា ១ ។

www.budinst.gov.kh www.elibraryofcambodia.org

អធិប្បាយ

១) **ឧបមាលិង្គត្ថៈ** វិធីនេះ ប្រែក្រោយកិរិយាអាខ្យាតឬ កិរិយាសំគាល់ពាក្យ នៃប្រយោគឧបមេយ្យ បានសេចក្តីថា ក្នុងប្រយោគឧបមេយ្យមានប៉ុន្មានបទ ប៉ុន្មានសព្ទ ក៏ប្រែមុនហូតដល់កិរិយាសំគាល់ពាក្យ ហើយទើបប្រែប្រយោគឧប-មាជាខាងក្រោយ ។ ក៏វិធីប្រែជាឧបមាលិង្គត្ថៈនេះ ត្រូវប្រែបទកត្តាថា «វ៏» ហើយប្រែសព្ទឧបមាភ្ជាប់ខាងមុខថា «ដូចវ៏..., ដូចជាវ៏ . . .» ព្រោះបទកត្តាដែលជាលិង្គត្ថៈ ក្នុងប្រយោគឧបមានេះលោកប្រើបឋមាវិភត្តិ ឯកវចនៈ ឬពហុវចនៈប៉ុណ្ណោះ ប្រើវិភត្តិដទៃមិនបាន ។ មួយទៀត ប្រយោគឧប-មាលិង្គត្ថៈនេះ បើសេចក្តីបង្អាប់ដល់កិរិយា ក៏ត្រូវបន្ថែមកិរិ-យាចូលមក តែកិរិយានោះនិយមកិរិយាសព្ទប្រកប អត្ថមាន-បច្ច័យ ឧទាហរណ៍ដូច្នេះ ៖

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ

www.budinst.gov.kh www.elibraryofcambodia.org

ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។
វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ

(ប្រែ) "មេធាវី រីបុគ្គលមានប្រាជ្ញា ករោតិ រមែងធ្វើ ចិត្តំ នូវចិត្ត ផន្ទនំ ដែលញាប់ញ័រ ចបលំ ដែលឃ្លេងឃ្លោង ទុរក្ខំ ដែលបុគ្គលរក្សាបានដោយលំបាក ទុន្និវារយំ ដែលបុគ្គលហាមបានដោយលំបាក ឧជុំ ឲ្យត្រង់បាន ឧសុការោ ឥវ ដូចជារីជាងកូនសរ (ករោន្តោ កាលធ្វើ) តេជនំ នូវកូនសរ (ឧជុំ ឲ្យត្រង់) ។ ចិត្តំ រីចិត្ត ឥទំ នេះ (ឧក្ខិត្តំ ដែលបុគ្គលលើកឡើងហើយ បញ្ចកាមគុណាលយា ចាកអាល័យគឺបញ្ចកាមគុណ) បហាតវេ ដើម្បីលះបង់ មារធេយ្យំ នូវវត្ថុៈជាទីតាំងនៅនៃមារ បរិផន្ទតិ រមែងញាប់ញ័រ, វារិជោ ឥវ ដូចជារីសត្វកើតក្នុងទឹក (ត្រី) ឧព្ភតោ ដែលបុគ្គលលើកឡើងហើយ ឱកមោកតោ ចាកអាល័យគឺទឹក ខិត្តោ

ពោះទៅហើយ ថលេ លើគោក (បរិវត្តនេត្តា កាលញាប់ញ័រ)

ធ.ក ២ទំព័រ ១៩៦ ។

ប្រយោគឧបមាលង្កត្តៈនេះ មានប្រើជ្រែកជ្រៀតនៅក្នុង ចន្លោះនៃកិរិយាកិតកៈ ដែលមិនមែនជាពាក្យពេញទី ។ ប្រ-យោគបែបនេះ ក៏ត្រូវប្រែកិរិយាសង្កាត់ឧបមេយ្យនោះជាមុន ដែរដូច " **ឯវញ្ហិ ភវិស្សតិ, ឯវំ ករិស្សាមីតិ វា "ឥមស្មឹ កម្មេ ឯវំ កតេ ឥទន្នាម ភវិស្សតីតិ វា ឯវំ និធានំ សល្លក្ខេត្វា ពេតតិកិច្ចនំ វិយ សព្វកម្មានិ និសាមេត្វា ឧបធារេត្វា ករោន្តស្ស** (ប្រែ) សព្វកម្មានិ និសាមេត្វាៈ ឧបធារេត្វា ករោន្តស្ស កាល ពិនិត្យហើយ គឺថាពិចារណាហើយ ទើបធ្វើនូវការងារទាំង ពួង។. ឯវញ្ហិ ភវិស្សតិ . . . សល្លក្ខេត្វា ពេតតិកិច្ចនំ វិយ ដូចជាការកំណត់នូវដើមហេតុ យ៉ាងនេះថា " ប្រសិនបើ ផលនឹងមានយ៉ាងនេះ អញនឹងធ្វើនូវហេតុយ៉ាងនេះ" ដូច្នេះ ឬ ឬថា " កាលបើកម្មនេះ គឺអញធ្វើហើយយ៉ាងនេះ

www.budinst.gov.kh www.elibraryofcambodia.org

ផលឈ្មោះនេះ នឹងមាន"ដូច្នេះ(មុន) ហើយទើបក្រោខ្លួនកេត
(ផ.ក ២ ទំព័រ ១២៧) ។

២) ឧបមាវិសេសនៈ វិធីនេះ ប្រែមុនកិរិយា បើបទឧបមានៅជិតបទប្រធាន, គឺកាលប្រែបទប្រធាននិងបទវិសេ-សនៈ ឬបទដែលមាននៅជិតបទប្រធានរួចហើយ ទើបប្រែបទឧបមា, តែបើនៅជិតមែនហើយ ប៉ុន្តែមានបទវិសេសនៈ ឬបទដទៃកាំងក្នុងចន្លោះ ត្រូវប្រែបទវិសេសនៈ ឬបទដទៃនោះជាមុនសិន លុះដើរមកដល់ហើយ ទើបឲ្យប្រែបទឧបមាថា "ដូចជា..., ហាក់ដូចជា..." ឧទាហរណ៍ថា **រុក្ខោ និក-ន្តោ ខានុមត្ថកោ ហុត្វា និច្ចាវច្ឆិន្នោ វាតេ បហ-រន្តេ អាកោដិតោ វិយ សទ្ធំ និច្ឆារេន្តោ អដ្ឋាសិ**

(ប្រែ) "រុក្ខោ គឺដើមឈើ និកន្តោ បាក់ចុះហើយ ខានុមត្ថកោ និច្ចាវច្ឆិន្នោ ហុត្វា ថែរជានៅត្រឹមតែដង្គត់ មានប្រមាណតូច និងប្រមាណធំ វាតេ កាលខ្យល់ បហរន្តេ កាលបក់ត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

អាកោដិតោ វិយ(១) ដូចជាគឺមនុស្សគោះហើយ និច្ឆារេត្វា កាលបញ្ចេញ សទ្ទំ នូវសំឡេង អដ្ឋាសិ បានឋិតនៅហើយ» (ជ ក.២ ទំព័រ ១៩២) ។

បើបទឧបមា ជាវិភត្តិដទៃក្រៅអំពីបឋមាវិភត្តិ ឬជាកិរិយាវិសេសនៈ, ប្រែបទឧបមាក្រោយកិរិយាវិញក៏បាន ។ តាមន័យនេះ ឧបមាវិសេសនៈ ចែកចេញជា ២ យ៉ាង គឺ ឧបមាវិសេសនៈ១ ឧបមាកិរិយាវិសេសនៈ១ ។

ឧបមាវិសេសនៈ ដូចឧទាហរណ៍ថា

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ និគ្គយ្ហវាទី មេធាវី តាទិសំ បណ្ឌិតំ ភជេ តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ (ប្រែ) «បុគ្គលោ រីបុគ្គល បស្សេ គប្បីឃើញ យំ · បណ្ឌិតំ នូវបណ្ឌិតណា មេធាវី អ្នកមានប្រាជ្ញា

១ អាកោដិតោ ឧបមាវិសេសនៈរបស់ រុក្ខោ, វិយ-សព្ទ ឧបមាជោតកៈក្នុងអាកោដិតោ ។

www.budinst.gov.kh www.elibraryofcambodia.org

និគ្គយ្ហវាទី អ្នកពោលសង្កត់សង្កិន វជ្ជទស្សិនំ អ្នកចង្អុលប្រាប់នូវទោស និធីនំ បវត្តារំ គឺ ដូចបុគ្គលអ្នកប្រាប់នូវកំណប់ប្រាជ្ញ. បុគ្គលោ រីបុគ្គល ភជេ គប្បីគប់ បណ្ឌិតំ នូវបណ្ឌិត តាទិសំ ប្រាកដដូច្នោះ (ហិ ព្រោះថា) បុគ្គលស្ស កាលបុគ្គល ភជមានស្ស កាលគប់រក តាទិសំ-បណ្ឌិតំ នូវបណ្ឌិតប្រាកដដូច្នោះ សេយ្យោ រីគុណដ៏ប្រសើរ ហោតិ រមែងមាន បាបិយោ រីទោសដ៏លាមក ន ហោតិ និងមិនមាន" (ធ.ក. ៤ ទំព័រ៥) ។

ឧបមាកិរិយាវិសេសនៈ ដូចមានឧទាហរណ៍ថា **ឥតិ នំ សោ មធុំ ឥវ មញ្ញតិ** (ប្រែ) "សោ-ពាលោ រីមនុស្សពាលនោះ មញ្ញតិ រមែងសំគាល់ នំ បាបំ នូវបាបនោះ មធុំ(១) គឺ ដូចទឹកឃ្មុំ ឥតិ ដោយប្រការដូច្នេះ"

១- មធុំ ឧបមាកិរិយាវិសេសនៈក្នុង មញ្ញតិ។ បទដែលជាកិរិយាវិសេស-នៈនេះ ប្រែមិនថាឥវនិបាតទេ សូម្បីពាក្យ"ជា" មិនថាក៏បាន បទនេះ ចាត់ជាឧបមាវិសេសនៈរបស់ បាបំ ក៏បាន

www.budinst.gov.kh www.elibraryofcambodia.org

(ឥ.ក. ៣ ទំព័រ ២៣៦) ។

៣) ឧបមាវិកតិកត្ថា , វិធីនេះ ប្រែមុនកិរិយាសំគាល់ពាក្យក៏បាន ប្រែក្រោយក៏បាន, បើកិរិយាសំគាល់ពាក្យ ជាធាតុប្រព្រឹត្តទៅក្នុងអត្ថថា " មាន, កើត, ជា " ប្រែព្រមគ្នាក៏បាន ។ ចំណែកវិធីប្រែឧបមា ដែលជាវិកតិកត្ថានេះ មិនប្រែខុស ៗ ទេ គឺ ប្រែបន្ថែមពាក្យតាមប្រភេទ របស់បកតិកត្ថាដូចបានអធិប្បាយទុក ក្នុងវិធីប្រែវិកតិកត្ថារួចមកហើយ ។

ឧបមាវិកតិកត្ថា មានវិធីប្រែ ៣ យ៉ាង គឺ ប្រែមុនកិរិយាសំគាល់ពាក្យ ១ ប្រែក្រោយកិរិយាសំគាល់ពាក្យ ១ ប្រែព្រមគ្នានឹងកិរិយាសំគាល់ពាក្យ១ ។

ឧទាហរណ៍

ប្រែមុនកិរិយាសំគាល់ពាក្យ ឧទាហរណ៍ថា **សោ តស្សា បដិពទ្ធចិត្តោ ហត្ថិក្ខន្ធតោ បតនាការប្ប-ត្តោ វិយ ហុត្វា ខិប្បំ នគរំ បទក្ខិណំ កត្វា**

www.budinst.gov.kh www.elibraryofcambodia.org

អន្តេបុរំ បវិសិត្វា ឯកំ វិស្សាសិកំ អមច្ចំ អាហ

(ប្រែ) “សោ-រាជា ព្រះរាជា អង្គនោះ តស្សាបដិពទ្ធចិត្តោ មានព្រះហឫទ័យប្រតិព័ទ្ធហើយ ចំពោះស្រីនោះ ហត្ថិក្ខន្ធតោ បតនាការប្បត្តោ វិយ ហុត្វា(១) ជាអ្នកហាក់ដូចជាដល់ហើយនូវអាការៈ គឺការធ្លាក់ចុះ អំពីខ្នងនៃដំរី កត្វា ទ្រង់ធ្វើហើយ បទក្ខិណំ នូវប្រទក្សិណ នគរំ(២) នៃនគរ ខិប្បំ ដោយរហ័ស បវិសិត្វា ស្តេចចូលទៅហើយ អន្តេបុរំ កាន់ព្រះរាជវាំង អាហ ទ្រង់ត្រាស់ហើយ អមច្ចំ នូវអាមាត្យ វិស្សាសិកំ អ្នកស្និទ្ធស្នាល ឯកំ ម្នាក់”(ធ.ក.៣ ទំព័រ១៦៩) ។

ប្រែក្រោយកិរិយាសំគាល់ពាក្យ, *ទើបមានកិរិយាដែល*

---

១ ហត្ថិក្ខន្ធតោ អបាទានៈក្នុង បតន, បតនាការប្បត្តោ ឧបមាវិកតិកត្តា ក្នុងហុត្វា, វិយ-សព្ទ ឧបមាជោតកៈក្នុង បតនាការប្បត្តោ, ហុត្វា សមានកាលកិរិយាក្នុង កត្វា ។ ២ ទុតិយាវិភត្តិ ប្រែកាច់ជាឆដ្ឋីវិភត្តិ ហៅថា សាមញ្ញត្ថទុតិយា ។

www.budinst.gov.kh www.elibraryofcambodia.org

បទវិកតិកត្តា ត្រូវចូលនោះ ជាកិរិយាវិសេសនៈ ត្រូវតែប្រែបទឧបមាក្រោយកិរិយា ដូច **ពាលស្ស ហិ បាបំ អកុសលកម្មំ ករោន្តស្ស, តំ កម្មំ មធុ ឥវ មធុររសំ ឥវ ឥដ្ឋំ កន្តំ មនាបំ ឥវ (ហុត្វា) ឧបដ្ឋាតិ**

(ប្រែ) "ហិ ក៏ ពាលស្ស កាលមនុស្សពាល ករោន្តស្ស កាលធ្វើបាបំ នូវបាប បាបំ គឺថា អកុសលកម្មំ នូវ..., កម្មំ រីកម្មំ នោះ ឧបដ្ឋាតិ រមែងប្រាកដ មធុ ឥវ: មធុររសំ ឥវ: ឥដ្ឋំ កន្តំ មនាបំ ឥវ(ហុត្វា)(១) ជាធម្មជាតដូចជាទឹកឃ្មុំ គឺថា ជាអំពើដូចរសមានជាតិផ្អែម គឺថា ជាកិច្ចដូចជាគួរប្រាថ្នា គួរចង់បាន គួរពេញចិត្ត" (ធ.ក. ៣ ទំព័រ ២៣៥) ។

១ មធុក្តី មធុររសំក្តី ឥដ្ឋំ កន្តំ មនាបំក្តី វិកតិកត្តាក្នុង ហុត្វា ។ បើមិនបញ្ចូល ហុត្វា ទេ ជាឧបមាវិសេសនៈរបស់ កម្មំ ។ មធុ វិវរណៈក្នុង មធុររសំ។ វិវរណីយៈរបស់ មធុ, មធុររសំ វិវរណៈក្នុង ឥដ្ឋំ កន្តំ មនាបំ។ វិវរណីយៈរបស់ មធុររសំ, ឥវ សព្វទាំង ៣ ឧបមាជោតកៈក្នុងមធុ ក្នុងមធុររសំក្នុង ឥដ្ឋំ កន្តំ មនាបំ, ហុត្វា កិរិយាវិសេសនៈក្នុង ឧបដ្ឋាតិ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រែព្រមគ្នានឹងកិរិយាសម្គាល់ពាក្យ ដូចមានឧទាហរណ៍ថា **យថា មរីចិ ទូរេ បិតានំ រូបគតំ វិយ គយ្ហូបគា វិយ ហោតិ** (ប្រែ) „មរីចិ រីថ្ងៃបណ្ដើរ កូន ទូរេ បិតានំ រូបគតំ វិយ គយ្ហុបគា វិយ ហោតិ ជាធម្មជាតហាក់ដូចជាដល់ហើយ នូវភាពជារបស់មានរូបជាធម្មជាតហាក់ដូចជាចូលដល់នូវភាព គឺបុគ្គលគប្បីកាន់យកបានដល់បុគ្គល១. អ្នកឈរហើយ ក្នុងទីឆ្ងាយ យថា យ៉ាងណាមិញ ” (ធ.ក ៣ ទំព័រ ៦) ។

ប្រយោគឧបមា ជាពាក្យពេញចិត្ត ជាពាក្យនិរុត្តិ ដែលបានសំដែងមកនេះឯង មិនទាន់អស់ទេ, ដែលនិយាយមកនេះសម្រាប់ជាផ្លូវគំនិត នៃអ្នកសិក្សាប៉ុណ្ណោះ ។ ហេតុនោះ អ្នកសិក្សាបើជួបវិធីប្រែក្រៅពីនេះ ចូរនាំមកធៀបគ្នាមើល បើបែបណាល្អជាង ចូរកាន់យកបែបនោះ ទុកជាគតិចុះ ។

x

x x

www.budinst.gov.kh www.elibraryofcambodia.org

១៣- ប្រយោគបការៈ និង កិរិយាវិសេសនៈ

ប្រយោគទាំង ២ នេះ សំគាល់ដោយនិបាត ៣ សព្ទ គឺ យថា, តថា និងឯវ ។ វិធីរៀនប្រយោគទាំងពីរនេះឯង ដូចគ្នានឹងប្រយោគឧបមា-ឧបមេយ្យ ដែលជាពាក្យពេញទីដែរ តែសេចក្ដីផ្សេងគ្នា គឺ សេចក្ដីខាងប្រយោគឧបមា ជារឿងដែលលោកនាំមកប្រៀបធៀបដើម្បីធ្វើសេចក្ដីខាងប្រយោគឧបមេយ្យឲ្យអណ្ដែតច្បាស់ឡើង, ឯសេចក្ដីក្នុងប្រយោគបការៈ និងកិរិយាវិសេសនៈនេះ ខាងប្រយោគយថាជាសេចក្ដីប្រាប់ប្រការ, ប្រាប់ឧបាយ, ប្រាប់អាការ, ប្រាប់លំនាំ, ប្រាប់ដំណើរ, ឲ្យតម្រួយ ដល់ប្រយោគ តថា, ឯវ ។

> ប្រយោគបការៈ នឹង ប្រយោគកិរិយាវិសេសនៈកំណត់ដោយនិបាត៣សព្ទ គឺយថា, តថា និង ឯវ ជាប្រយោគគួរប្រែខ្លួលទើបសេចក្ដីក្ដីច្បាស់ល្អ ។ វិធីប្រែខ្លួលនោះ គប្បីប្រែប្រយោគ តថា មុន បន្សល់ទុកតែ តថា-សព្ទ;

www.budinst.gov.kh www.elibraryofcambodia.org

កាលប្រែអស់សេចក្តីខាងគថាហើយ ត្រូវយក យថា ព្រមទាំងបទដទៃមករួមគ្នាខាង គថា ប្រែចូលគ្នាតែម្តង ។

ប្រយោគបការៈ បើប្រែរួច ត្រូវប្រែថា“ ដោយប្រការដែល . . . ,ដោយឧបាយដែល . . ,ដោយអាការដែល . . . តាមដែល . . ” ។

ប្រយោគកិរិយាវិសេសនៈ បើប្រែរួច ត្រូវប្រែថា “យ៉ាងដែល ., តាមដែល . , ល្មមតែ . ..” ។

ប្រយោគបការៈ បើប្រែកាយ ត្រូវប្រែ យថា ថា“ដោយប្រការណា, ដោយឧបាយណា, ដោយអាការណា”, គថា ខាងឯង ត្រូវប្រែថា“ដោយប្រការនោះ. ដោយអា. ការនោះ”

ប្រយោគកិរិយាវិសេសនៈ បើប្រែកាយ ត្រូវប្រែ យថា ថា“យ៉ាងណា” គថា ឬឯង ប្រែថា “យ៉ាងនោះ” ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍

ប្រែជាបការៈ *ឧទាហរណ៍ថា* **អយំ ហិ អត្តា នាម ទុទ្ទមោ ។ តស្មា យថា(១) សោ សុទន្តោ ហោតិ តថា(២) ទមេតព្វោ** *(ប្រែ) "ហិ ពិត អយំ អត្តា នាម ឈ្មោះថាខ្លួនឯង ទុទ្ទមោ (ហោតិ) រមែងជាអត្តភាព ដែលបុគ្គលទូន្មានបានដោយលំបាក ។ តស្មា ព្រោះហេតុនោះ (បរេ បុគ្គលោ វី . . .ដទៃ បុគ្គលេន គឺ . . .) ទមេតព្វោ គប្បីទូន្មាន យថា សោ សុទន្តោ ហោតិ តថា ដោយឧបាយដែល ខ្លួននោះជាអត្តភាពដែលបុគ្គល ទូន្មានល្អ ហើយ"(ឥ.ក. ៦ ទំព័រ ១៦) ។* **យថា សោ សុរក្ខិតោ ហោតិ, ឯវន្តំ រក្ខេយ្យ** *(ប្រែ) "(បុគ្គលោ វី . .) រក្ខេយ្យ គប្បីរក្សា នូវខ្លួននោះ យថា សោ សុរក្ខិតោ ហោតិ ឯវំ ដោយអាការដែល ខ្លួននោះ ជាអត្តភាពដែលគេរក្សា*

---

១ យថា-សព្ទបការត្ថៈក្នុង ហោតិ ។ ២ តថា-សព្ទ បការត្ថៈក្នុង ទមេតព្វោ ។

www.budinst.gov.kh www.elibraryofcambodia.org

ទុកល្អហើយ (ធ.ក.៦ ទំព័រ៧) ។

ប្រែជាកិរិយាវិសេសនៈ ឧទាហរណ៍ថា **វិសាខា សស្សុរំ ពីជមានា ឋិតា(១)តំ ទិស្វា "សស្សុរស្ស អាចិក្ខិតុំ អយុត្តន្តិ យថា(២) សោ ថេរំ បស្សតិ ឯវំ(៣) អបគន្ត្វា អដ្ឋាសិ**(ប្រែ) "វិសាខា . . . សស្សុរំ ពីជមានា ឋិតា កាលឈរបក់នូវឪពុកក្មេក ទិស្វា ឃើញហើយ តំ ថេរំ នូវ . . (ចិន្តេត្វា គិតហើយ) សស្សុរស្ស អាចិក្ខិតុំអយុត្តំ ឥតិ ថាកិរិយាគឺអញប្រាប់ ដល់ឪពុកក្មេក មិនគួរឡើយ អបគន្ត្វា គេចចេញហើយ អដ្ឋាសិ បានឈរនៅហើយ យថា សោ ថេរំ បស្សតិ ឯវំ ឲ្យល្មមតែឪពុកក្មេកនោះ ឃើញនូវព្រះថេរៈ"(ធ.ក. ៣ទំព័រ ១០១) ។

ឧទាហរណ៍ដែលលើកមកពោលនេះ ប្រែចំខ្លួនហើយរួច

---

១ ពីជមានា និង ឋិតា វិសេសនៈរបស់ វិសាខា ។ ២ យថា-សព្ទកិរិយាវិសេសនៈក្នុង បស្សតិ ។ ៣ ឯវំ-សព្ទកិរិយាវិសេសនៈក្នុង អដ្ឋាសិ ។

www.budinst.gov.kh www.elibraryofcambodia.org

ផង, បើប្រែខ្លួលកែកាយ ត្រូវប្រែប្រយោគគតថា, ឯវិឲ្យទាល់តែអស់សេចក្តី ហើយបន្សល់ទុកតែ គតថា, ឯវិ ក្នុងទីបំផុតដើមប្រយោគ រួចទៅប្រែខាងប្រយោគយថា ឲ្យទាល់តែអស់សេចក្តី ហើយទើបប្រែយថា រួចប្រែ គតថា ឬ ឯវិ បន្ទាប់ពីយថានោះឯង ៗ អ្នកសិក្សាបាលីគប្បីមើលឧទាហរណ៍ខាងលើនេះ ហើយហាត់ប្រែតាមសេចក្តីពន្យល់ ក្នុងខាងលើនោះ ដោយខ្លួនឯងផងចុះ ។

*

*   *

១៤ បកិណ្ណកវិធី

ទីងសំដែងអំពីវិធីតិចសង្ខេក ក្នុងការប្រែភាសាបាលីជាវិធីកយវង ដូចតទៅនេះ៖

១_បើមានលេខក្នុង គឺសេចក្តីក្នុងវគ្គ ត្រូវគន់រកកិរិយាដែលចូលទីងវគ្គ សព្ទនោះ, បើមានហើយ តែមិនបាន

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីពេញទី គ្រប់ពេញ បែនេន ឬ ចិត្តនេនឬគឺ មនសិក-រិក្តា បទណាមួយមក តាមសមគួរដល់សេចក្ដីក្នុងទីនោះ ៗ ៗ

២–តុំ បច្ច័យ ចុះក្នុងអត្ថ ២ យ៉ាង គឺចុះក្នុងអត្ថបឋមាវិភត្តិ ហៅថា តុមត្ថកត្តា ១, ចុះក្នុងអត្ថចតុត្ថីវិភត្តិ ហៅថា តុមត្ថ-សម្បទាន ១ ។ តុមត្ថកត្តា ប្រែថា "កិរិយា..., ការ..., ដំណើរ..., សេចក្ដី..." ដូច **មយា តត្ថ គន្តុំ យុជ្ជតិ** «វិកិរិយា គឺគថាគតទៅ ក្នុងទីនោះ ទើបគួរ» ។ តុមត្ថ-សម្បទានប្រែថា «ដើម្បី...» បញ្ចូលពាក្យថា «បាន» ទៅទីបំផុតកិរិយាសព្ទដូច **កាតុំ** «ដើម្បីធ្វើបាន», **ញាតុំ** «ដើម្បីឲ្យបាន», **ខន្តុំ** «ដើម្បីអត់ទ្រាំបាន» ។ តែបើប្រែថា "ដើម្បី" បែរជានាំឲ្យស្លោកសេចក្ដីខ្ចូកដំឡែភាសា នោះមិនបាច់ប្រែថា "ដើម្បី..." ទេ ប្រែតែត្តុជាតុដែលបច្ច័យអាស្រ័យក៏បាន ដូច **សចេ អត្តានំ និច្ចលំ កាតុំ សក្ខិស្សសិ, ឯស បត្តោសិ និព្វានំ** (ប្រែ) «សចេ បើ ត្វំ អ្នក អត្តានំនូវខ្លួន

កាតុំ សក្កិស្សសិ មិនអាច ធ្វើ នូវខ្លួនមិនឲ្យកំរើកបាន ឯសោ ត្វំ អ្នកខ្ទុះ និព្វានបត្តោ អសិ ជាបុគ្គលដល់ហើយនូវព្រះនិព្វាន" ។ **សចេ ឯវរូបោ កាតុំ សក្ខិស្សសិ, ឥមំ បដិបទំ បូរយមានោ ឥទានិ អប្បមត្តោសិ, ឯសោ និព្វានប្បត្តោ នាម** (វែប្រ) "សចេ បើ ត្វំ អ្នក ឯវរូបោ កាតុំ សក្កិស្សសិ មិនអាច ជា បុគ្គលមានសភាព យ៉ាងនេះបាន, ត្វំ អ្នក បូរយមានោ កាលបំពេញ បដិបទំ នូវបដិបទា ឥមំ នេះ ឥទានិ អប្បមត្តោ អសិ រមែងជាអ្នក មិនប្រមាទហើយ ក្នុងកាលឥឡូវនេះ; ឯសោ ត្វំ អ្នកខ្ទុះ និព្វានប្បត្តោ នាម ឈ្មោះថាដល់ហើយ នូវព្រះនិព្វាន" ។ ព្រោះតុំបច្ច័យជាគុមត្តសម្បូតានេះ លោកគ្រាន់តែចុះមកកំ-ផរធាតុ ដើម្បីកុំឲ្យធាតុទៅតាមភាពដើមជា ករ សក្កិស្សសិ, គូសក្កិស្សសិ ប៉ុណ្ណោះ ។ កាលបើប្រែ ត្រូវគានគិរិយាដែលប្រកប តុំ បច្ច័យនោះ រួបបូលនឹងបទគិរិយាប្រចាំប្រយោគ

www.budinst.gov.kh www.elibraryofcambodia.org

ហើយប្រែរួបតែម្ដង, ដូចឧទាហរណ៍ខាងលើនេះ ត្រូវប្រែថា សចេ បេ ត្វំ រី ..អត្តានំ ឧបច្ចលំ កាតុំ សក្ខិស្សសិ .. នឹងអាច ធ្វើ នូវខ្លួនមិនឲ្យកំរើកបាន", សចេ បេ ត្វំ រី .. ឯងរួចបាកកាតុំ សក្ខិស្សសិ "នឹងអាច ជា បុគ្គលមានសភាពយ៉ាងនេះបាន" ។ បើសម្ពន្ធត្រូវសម្ពន្ធជាតុមត្ថសម្បទាន ចូលក្នុងកិរិយាដែល កានរួចចូលទៅនោះ ៗ ។

៣– នាមនាមប្រកបឆដ្ឋីវិភត្តិ ចូលនឹងបទនាមកិតក: ដែលចុះបច្ច័យ ៣ គឺ ណ្វុ, តុ, យុ ត្រូវប្រែកាច់ជាទុតិយាវិភត្តិ ។ ណ្វុ ដូច **ទានស្ស ទាយកោ** "ជនអ្នកឲ្យ នូវទាន" ។ តុ ដូច **សុខស្ស ទាតា** "ជនអ្នកឲ្យនូវសេចក្ដីសុខ" ។ យុ ដូច **សព្វបាបស្ស អករណំ** "ការមិនធ្វើ នូវបាបទាំងពួង" ។ នេះនិយាយតាមវិធីដែលលោកកំណត់ទុកមក ។ តែដូនកាល នាមកិតក:ដែលប្រកបបច្ច័យដទៃអំពីបច្ច័យ ៣ នេះ បើក្នុងធាតុដែលសម្រេចមកជាសាធន:

www.budinst.gov.kh www.elibraryofcambodia.org

នោះ ជាសកម្មធាតុ ក៏មានអំណាចបង្គាប់បទធម្មីវិភត្តិ ឲ្យចុះក្នុងអត្ថទុតិយា បានតែមានតិច ដូច **បុត្តទារស្ស**(១) **សង្គហោ** "ការសង្គ្រោះនូវកូននិងប្រពន្ធ" នេះ អ បច្ច័យ: **អភូតស្ស ភាណោ** "ការពោលនូវពាក្យមិនពិត" នេះ ណ-បច្ច័យ, **ឈានស្ស ឈាយី** "ជនអ្នកមានកិរិយាបាននូវឈានជាប្រក្រតី" នេះណី-បច្ច័យ ជាដើម ។

៦– បទការិតកម្ម ក្នុងប្រយោគជាហេតុកត្តាវាចកៈ លោកប្រកបវិភត្តិ ៣ គឺ ទុតិយា, តតិយា, ឆដ្ឋី ៈ នាវេលាប្រែ ត្រូវប្រែថា "ញុំាង" គ្រប់ទាំង ៣ វិភត្តិ ដូចឧទាហរណ៍ថា **បុរិសោ បុរិសំ កម្មំ ការេតិ ។ បុរិសោ បុរិសេន កម្មំ ការេតិ ។ បុរិសោ បុរិសស្ស កម្មំ ការេតិ** "បុរស ញុំាងបុរស ឲ្យធ្វើនូវការងារ" ។

៧– បទនាមនាមដែលចូលនឹងនិបាត ៦ សព្ទ គឺ **ធិរា**

១– បុត្តទារស្ស ឆដ្ឋីកម្មៈក្នុង សង្គហោ ។

www.budinst.gov.kh www.elibraryofcambodia.org

អញ្ញត្រ(១) *លោកប្រកបវិភត្តិ ៣ គឺ ទុតិយា, តតិយា បញ្ចមី នៅវេលាប្រែ ត្រូវប្រែថា "ចាក" ដូច* **វិនា សទ្ធម្មំ, វិនា សទ្ធម្មេន, វិនា សទ្ធម្មា; អញ្ញត្រ សទ្ធម្មំ, អញ្ញត្រ សទ្ធម្មេន, អញ្ញត្រ សទ្ធម្មា** *"វៀរហើយ ចាកព្រះសទ្ធម្ម"* ។

២- នាមនាមដែលឥតវិញ្ញាណដូចស្រុក, និគម, ជនបទ នគរ ជាដើម ក្នុងភាសាបាលី លោកប្រើជានាមមានវិញ្ញាណបានខ្លះ ដូច **សកលនគរំ សង្ខុភិ** *"អ្នកនគរទាំងមូល ក្ដាក់ផ្អើលហើយ"* **នគរំ វទតិ** *"អ្នកនគរនិយាយគ្នា"* **គាមោ អាគតោ** *"អ្នកស្រុក មកហើយ"* **គាមោ**

១- និបាតទាំង ២ នេះ មានគតិ ២ យ៉ាងគឺ បើចូលនឹងកិរិយា ហៅថា កិរិយាវិសេសនៈ, បើចូលនឹងនាម ហៅថា នាមវិសេសនៈដូច ន ហិ តំ វិនា អញ្ញំ អត្ថិ "មែនពិត ទីពឹងដទៃ វៀរ តែព្រះរតនត្រ័យនោះចេញ មិនមានឡើយ" នេះវិនា ចូលនឹង អញ្ញំ ដែលជាបទនាម ។ "មែនពិត ទីពឹងដទៃ មិនមានឡើយ វៀរតែព្រះរតនត្រ័យនោះចេញ" នេះ វិនា ចូលនឹង អត្ថិ ដែលជាកិរិយា ។

www.budinst.gov.kh www.elibraryofcambodia.org

សុរត្តោ "អ្នកស្រុក ដេកលក់ហើយ" បុរិស្ស ឯសា ទាថា "កំពានុះ របស់អ្នកក្រុង" រាជា គេរិញ្ញារបេសិ ព្រះរាជា ញ៉ាំងអ្នកស្គរ ឲ្យត្រាច់ទៅហើយ" ។

៧– មត្ត.សព្ទ បើរួមចូលជាបទសមាសនឹងសំខ្យាសព្ទ ត្រូវប្រែថា "ប្រមាណ" ដូច សដ្ឋីមត្តា ភិក្ខូ "ភិក្ខុ. មានប្រមាណ ៦០" , បើចូលនឹងសព្ទដទៃមិនមែនសំខ្យា ត្រូវប្រែថា "មាត្រាថា, ប៉ុន, ប៉ប៉ុន, គ្រាន់តែ, ត្រឹមតែ, សព្វបើ" ដូច ឧទកមត្តំ (១) "សព្វបើទឹក" ទាលត្តមត្តោបិ ឱកាសោ នត្ថិ "ទីទំនេរ សូម្បីប៉ប៉ុនចុងនៃរោមកន្ទុយ មិនមាន" ។

៨– បើក្នុងប្រយោគមុខមាន កិញ្ចាបិ ត្រូវប្រែ កិញ្ចាបិ

១– មត្ត-សព្ទដែលប្រែបែបនេះ គឺប្រែយកសេចក្ដីតាមភាសាខ្មែរ, បើប្រែតាមរូបសព្ទថា"ប្រមាណ" . បើរួមជាសមាស ច្រើនជាឆដ្ឋីពហុព្វីហិ, ដូចបទនេះ ប្រែថា "(ហេតុ) មានទឹកជាប្រមាណ" វិគ្គហៈថា ឧទកំ មត្តំ យស្ស តំ)ឧទកមត្តំ (ការណំ) ។

www.budinst.gov.kh www.elibraryofcambodia.org

ថា «ក៏ពិតមែនហើយ» ក្នុងប្រយោគក្រោយតែងមាន **បាន**, បើមិនមានទេ ក៏ត្រូវបំពេញចូលមកដោយខ្លួនឯង ហើយត្រូវប្រែថា "**បាន** ទុកជាដូច្នោះ" ។

៩_ អថ និបាត បើនៅដើមប្រយោគ ប្រែថា «លំដាប់នោះ "ឬ" គ្រានោះ» ហើយប្រែមុនបទប្រធាន; បើមាន កស្មា ផង, អថ នោះ ប្រែមុនក៏បាន; បើមាននៅក្នុងសេចក្តីនៃលេខក្នុង ត្រូវប្រែថា «អថ នាកាលហេតុយ៉ាងនេះ (សេន្តកាលមាន)» ។

១០_ កិរិយាសព្ទដែលប្រកបដោយ តព្វ.អនីយ-បច្ច័យ និង សក្កា ប្រែជាកត្តុវាចកៈមិនបានទេ ត្រូវប្រែជា កម្មវាចកៈ ឬ ភាវវាចកៈ ។

១១- ក្នុងប្រយោគ យ,ត បើប្រយោគខាង យ មានបិ ត្រូវប្រែប្រយោគ យ មុន បើមិនមានទេ ស្រេចតែចិត្តប្រែចុះ ។

១២- ប្រយោគ យ,ត សំនួនបាលីច្រើនតែរៀងប្រយោគ

www.budinst.gov.kh www.elibraryofcambodia.org

ក ទុកខាងមុខនៃប្រយោគ យ ជាដើម, ត្រូវប្រែប្រយោគយ មុន, តែប្រយោគ ក នោះ ដោយហេតុមិនទៀងគួរសព្ទតាមទុក ទេ នៅវេលាប្រែ ត្រូវនាំមកប្រកបខ្លួនឯង ដូច **អត្ថានន្ទ គន្ធជាតំ, យស្ស អនុវាតំបិ គន្ធោ គច្ឆតិ** (ប្រែ) ''អានន្ទ ម្នាលអានន្ទ គន្ធោ ក្លិន យស្ស គន្ធជាតស្ស នៃ គន្ធជាតណា គច្ឆតិ ផ្សាយទៅ អនុវាតំបិ កាន់ទិសបណ្ដោយ នៃ ខ្យល់ក៏បាន, គន្ធជាតំ គន្ធជាត (តំ នោះ) អត្ថិ មាន'' ។

១៣– បើបទវិកតិកត្ដា នៅមុខកិរិយា ១ នោះប្រាប់ កាលអ្វី ត្រូវលើកយកកាលនោះ មកប្រែនាំមុខបទវិកតិកត្ដា ដូច **អយំ មហេសក្ខាយ ទេវតាយ** <u>**បរិគ្គហិតោ ភវិស្សតិ**</u> (ប្រែ) ''អយំ-នេះ វនប្បតិ ឈើជាម្ចាស់នៃព្រៃ នេះ មហេសក្ខាយ ទេវតា បរិគ្គហិតោ ភវិស្សតិ នឹងជាឈើ គឺទេវតា អ្នកមានសក្ដាធំ រក្សាហើយ'' ។

១៤– បទវិសេសនៈក្ដី វិកតិកត្ដាក្ដី បើមានវិសេសនៈ ឬ

www.budinst.gov.kh www.elibraryofcambodia.org

សញ្ញាវិសេសនៈមួយជាន់ទៀត ត្រូវមានរូប ដូច **អម្ហាកំ សត្ថា សុមេធោ នាម ព្រាហ្មណកុមារោ ហោតិ** ក្នុងទីនេះ សុមេធោ ជាសញ្ញាវិសេសនៈ របស់ព្រាហ្មណ-កុមារោ ៗ ជាវិកតិកត្តាក្នុង ហោតិ, ត្រូវមានរូបថា "សត្ថា រ.. សុមេធោ នាម ព្រាហ្មណកុមារោ ហោតិ កើតជាព្រាហ្មណ-កុមារ ឈ្មោះសុមេធ"

១៥– កិរិយាមិនមែនអព្យយៈ នៅជិតកិរិយាថា "មាន, កើត, ជា" ត្រូវយកជាវិកតិកត្តា ចូលក្នុងកិរិយានោះ ដូច **ឯតំ ករោន្តោ និព្វានំ បត្តោ នាម ភវិស្សសិ**(ប្រែ) "ត្វំ អ្នក ករោន្តោ កាលធ្វើ ឯតំ យ៉ាងនេះ និព្វានំ បត្តោ នាម ភវិស្សសិ នឹងឈ្មោះថាជាអ្នកដល់ហើយ នូវព្រះនិព្វាន" ៗ

១៦– នាមសព្ទណា ប្រើជាបទគុណនៃនាមនាម, នាមសព្ទនោះជាលិង្គអ្វី ក៏នៅជាលិង្គនោះ ពុំបានផ្លាស់លិង្គទៅតាមលិង្គនៃនាមនាមជាបទប្រធានទេ ដូចពាក្យថា **ពុទ្ធោ បមុខំ**

www.budinst.gov.kh www.elibraryofcambodia.org

ហោតិ "ព្រះពុទ្ធព្រះអង្គជាប្រមុខ" ។ **ពុទ្ធោ មេ សរណំ**
វរំ "ព្រះពុទ្ធ ជាទីពឹង ដ៏ប្រសើរ របស់ខ្ញុំ" ។

១៧–កិរិយាសព្ទប្រកប ត្វាទិ-បច្ច័យ បើជានាមវិសេ-សនៈ ឬកិរិយាវិសេសនៈ ត្រូវប្រែទទេៗ គឺប្រែតែតួធាតុមិនប្រែថា "ហើយ" ដូច **ឋបេត្វា ទ្វេ អគ្គសាវកេ អវសេ-សា អរហត្តំ បាបុណឹសុ** "អវសេសា ភិក្ខុដ៏សេសទ. ឋបេត្វា លើកទុក អគ្គសាវកេ នូវអគ្គសាវកទ. ទ្វេ ២ រូប បាបុណឹសុ ដល់ហើយ អរហត្តំ នូវព្រះអរហត្ត" ។ បើជាបុព្វកាលឬសមានកាលវិញ, ត្រូវទាញកាលនៃកិរិយាអាខ្យាតដែលប្រកប បញ្ចមី, សត្តមី, ភវិស្សន្តិវិភត្តិឬ កាលាតិបត្តិវិភត្តិទៅទាំមុខផង លុះប្រែអស់យៈបុព្វកាលឬ សមានកាលហើយទើបប្រែកិរិយាអាខ្យាតតែត្រឹមតួធាតុ ឬបញ្ចូលពាក្យថា "ទើបរួច" ទាំមុខធាតុ ដូច **ឧបាសក សីសច្ឆេទនំ តាវ មេ សិថិលំ កត្វា ឥមំ គោញ្ចិ ឱលោកេហិ**

www.budinst.gov.kh www.elibraryofcambodia.org

(ប្រែ) ‹‹ ឧបាសក ម្នាលឧបាសក កុំ អ្នក ស៊ីសិរវេបធំ ការ មេ ស៊ិបិល់ កត្តា ជម្ម ពោញ៉ ៗ លោកេហ៊ ចូរធ្វើនូវចំណាំត្រង់ ក្បាលនៃគាត្ថាឲ្យចូរសិន ហើយមើលនូវសត្វក្រៀលនេះ›› ។

១៨ ក៏សព្ទ ដែលជាប់នឹងលេខក្នុង បើប្រែជាមួយនឹង លេខក្នុង មិនសូវបានសេចក្តីល្អទេ ឲ្យលើកមកប្រែជាមួយនឹង អតិ សព្ទវិញ ដូច **សត្ថា ធីតរ គេ មយ្ហំ អត្ថោ អត្ថិ នា នត្ថិ នាតិ អនត្ថោ ។បេ។ គាថមាហ** ។ ប្រយោគ នេះត្រូវទាញ ក៏-សព្ទ ទៅទុកក្រោយអតិវិញ ដូចប្រែថា ‹‹សត្ថារ៍ . . . អត្ថា មិនពោលហើយ ធីតរ គេ មយ្ហំ អត្ថោ អត្ថិ អតិក៏ ថាសេចក្តីត្រូវការនៃគាថាគត ដោយធីតារបស់អ្នក មាន ដូចនេះឬ ធីតរ គេ មយ្ហំ អត្ថោ នត្ថិ អតិ ក៏ ឬថា សេចក្តី ត្រូវការនៃគាថាគតដោយធីតារបស់អ្នក មិនមាន ។បេ។ គាថា ក្រាស់ហើយ គាថ់ នូវគាថា ។

១៩– មា និបាត នៅក្រោយនៃ អតិ-សព្ទ ជិតៗ នឹងបុទ

www.budinst.gov.kh www.elibraryofcambodia.org

កិរិយា មានអំណាចឲ្យទាញ ឥតិ ក្ដីមុខនោះ ទៅភ្ជាប់នឹងសព្ទដទៃវិញបាន ដូច **អានន្ទ ឥមិនា មាលាការេន អប្បមត្តកំ កម្មំ កតន្តិ អហ សល្លក្ខេសិ** (វេ) „អានន្ទ ម្នាល . . . តូវ . . . មា សល្លក្ខេសិ កុំកំណត់ព្រមឡើយ កម្មំ នូវកម្ម ឥមិនា មាលាការេន កតំ ដែលមាលាការនេះធ្វើហើយ អប្បមត្តកំ ឥតិ ថាមានប្រមាណតិច„ ។ សូម្បីក្នុងទីដទៃ ៗ បើមានន័យដូចគ្នានេះ ក៏អ្នកសិក្សាចូរទាញបែបនេះជាបទដ្ឋាន ក្នុងការប្រែលោកប្រយោគចុះ ។

២០ បទកិរិយាវិភត្តិដែលចូលនឹងភូ ធាតុ លោកច្រើនប្រកបឆដ្ឋីវិភត្តិជំនួសវិញ, ដល់វេលាប្រែត្រូវប្រែថា „ដោយ„ ប្រាប់សម្ពន្ធថា ករណៈ ដូច **បូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ** „ធីរោ អ្នកប្រាជ្ញ អាចិនំ កាលសន្សំ (បុញ្ញំ នូវបុណ្យ) ថោកំ ថោកំបិ សូម្បីបន្តិចបន្តិច ៗ បូរតិ គង់ពេញ បុញ្ញស្ស ដោយបុណ្យ„ ។

www.budinst.gov.kh www.elibraryofcambodia.org

៦១– នាមនាមប្រកបឆដ្ឋីវិភត្តិ ដែលចូលនឹងសុ. ធាតុ មិនមានឧត្តកម្មក្នុងចន្លោះទេ ត្រូវប្រែថា "អំពី, ពាក" ប្រាប់សម្ពន្ធថា អបាទានៈ ដូច **ពុទ្ធស្ស (១) សវនន្តេ ជាត-ក្ខេន** «ដោយអត្ថថាកើតហើយ ក្នុងទីបំផុត នៃការស្តាប់ អំពីព្រះពុទ្ធ» ។

៦២– ទេវតាមាន ២ ពួក គឺ សម្មតិទេវតា ១ ឧបបត្តិ-ទេវតា ១ ។ ទាំងពីរពួកនេះ ក្នុងគម្ពីរលោកប្រើ ទេវ-សព្ទ តែម្យ៉ាង អ្នកប្រែត្រូវមានការកំណត់ប្រែឲ្យត្រឹមត្រូវ គឺបើទេវ-សព្ទក្នុងទីណា សំគាល់យកស្តេចផែនដី, ក្នុងទីនោះឯង ត្រូវប្រែថា "សម្មតិទេព", តែបើសំគាល់យកទេវតា ដូចសក្ក-ទេវរាជជាដើម ត្រូវប្រែថា "ឧបបត្តិទេព" ។

៦៣– ហិ និបាតសព្ទ បើមាន តស្មា នៅក្នុងប្រយោគក្រោយ ត្រូវប្រែថា "ព្រោះថា", តែបើមិនប្រែដូច្នោះទេ

១– អបាទានត្ថឆដ្ឋី ក្នុង សវន ។

ត្រូវប្រែទទួលគ្នាថា "ហិ ព្រោះហេតុណា តស្មា ព្រោះហេតុនោះ" ។

២៤— ប្រយោគ យថា, ឯវំ, បើប្រយោគ ឯវំ មាន ចិ ឬ សោចិ ត្រូវប្រែប្រយោគ យថា មុន, បើមិនមានទេ តាមតែប្រែចុះ; បើប្រយោគ យថា មាន ចិ ប្រយោគ ឯវំ ក៏មាន បិ នឹងប្រែទទួលគ្នាក៏បាន ។

២៥— កិមង្គំ បន ឬ បគេវ, បើប្រយោគមុខ មាន បដិសេធ, ប្រយោគដែលមាន កិមង្គំ បន ឬ បគេវ ដែលនៅក្រោយ មិនត្រូវមានបដិសេធទេ; បើប្រយោគមុខ មិនមានបដិសេធ ទើបត្រូវមានវិញ, ឯកិរិយារបស់ប្រយោគក្រោយនោះ ត្រូវបញ្ចូលតាមប្រយោគមុខ ហើយប្រើភវិស្សន្តិវិភត្តិ ជាដើម ។

កិមង្គំ បន ឧទាហរណ៍ថា **តាត មហល្លកស្ស ហិ អត្តនោ ហត្ថបាទាបិ អនស្សវា ហោន្តិ,**

www.budinst.gov.kh www.elibraryofcambodia.org

ន ចសេ ចត្តន្តិ (នេះប្រយោគមុខ) **កិមត្ថំ បន ញាតកា** (នេះប្រយោគក្រោយ) (ប្រែ) "គាត ម្នាលប្អូន ហៃ មែនពិត មហល្លកស្ស អត្តនោ ហត្ថបាទាប៉ សូម្បីដៃផងនិងជើងទ. នៃខ្លួនរបស់បុគ្គលចាស់ អនស្សវា ហោន្តិ ជាអវយវៈមិនស្តាប់បង្គាប់ ន វត្តន្តិ មិនប្រព្រឹត្តទៅ វសេ ក្នុងអំណាចនៃខ្លួន; បន ចំណាន់ថៃ ញាតកា ដែលទ. ជាញាតិ (វត្តិស្សន្តិ នឹងប្រព្រឹត្តទៅ វសេ ក្នុងអំណាចនៃខ្លួន) កិមត្ថំ មានអ្វីជាហេតុ" ។

នេះប្រែ កិមត្ថំ បន ទុកក្នុងទីបំផុតនៃប្រយោគ, បើប្រែទុកក្នុងខាងមុខ ឲ្យប្រែមុន គឺកាលបើប្រែប្រយោគមុខអស់ហើយ ឲ្យលើក កិមត្ថំ បន ឡើងប្រែថា "កិមត្ថំ បន ក៏នឹងបាច់ពោលទៅថ្វី ញាតកា រី... វត្តិស្សន្តិ នឹង... វសេ ក្នុងអំណាច នៃខ្លួន" ។ ក្នុងទីដទៃខ្លះ មិនបាច់បញ្ចូលកិរិយា និង ន-បដិសេធ តាមប្រយោគមុខក៏បាន ដូច **កិមត្ថំ បន អត្តគាចស្ស** ត្រូវប្រែថា "បន ក៏ កិមត្ថំ នឹងបាច់ពោល

www.budinst.gov.kh www.elibraryofcambodia.org

ទៅថ្វី អត្តការស្ស ដល់អត្តភាព" ។

បគេវ ឧទាហរណ៍ថា **សាមណេរំ ហិ តស្មឹ កាលេ សិនេរុនា អវត្ថរន្តោបិ មារេតុំ សមត្ថោ នាម នត្ថិ** (នេះប្រយោគមុខ), **បគេវ អសិនា** (នេះប្រយោគក្រោយ) ។ ប្រែប្រយោគមុខ "ហិ គឺ (បុគ្គលណាវី..) សិនេរុនា អវត្ថរន្តោបិ សូម្បីកាលសង្កត់ ដោយភ្នំសិនេរុ សាមណេរំ តស្មឹ កាលេ មារេតុំ សមត្ថោ(១)នាម ជាអ្នកឈ្មោះថាអាច ដើម្បីញុំាងសាមណេរឲ្យស្លាប់ក្នុងកាលនោះ នត្ថិ មិនមាន" ។ ប្រែប្រយោគក្រោយ "បគេវ នឹងបាច់ពោលទៅថ្វី(បុគ្គលណាវី..)សាមណេរំ តស្មឹ កាលេ អសិនា មារេតុំ សមត្ថោ(២)នាម (ភវិស្សតិ) នឹងជាអ្នកឈ្មោះថាអាច ដើម្បីញុំាងសាមណេរឲ្យស្លាប់ ដោយដាវ ក្នុងកាលនោះបាន" ។

៤៦. ប្រយោគ២សង្កាត់, ប្រយោគមុខ ជាពាក្យសួរ,

---

១ សមត្ថោ វិកតិកត្តាក្នុង នត្ថិ ។ ២សមត្ថោ វិកតិកត្តាក្នុង ភវិស្សតិ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោគក្រោយជាពាក្យឆ្លើយ ដោយ តាម សត្ថុ, បើប្រ-យោគសួរ មិនមានបុច្ឆនត្ថនិបាត ដូច កឹ, អបិនុ, នុ ជាដើមទេ អ្នកប្រែត្រូវបញ្ចូល កឹ ត្រង់ទីបំផុតដើមប្រយោគ ឬបញ្ចូលពាក្យថា "ឬ,ឬទេ" រួមនឹងបទកិរិយាតែម្តង ក៏បាន ដូច **គន្តេ មយា គេលំ បចិត្វា បេសិតំ, នាសាយ នោ អាសិតន្តិ ។ អាម ឧបាសកាតិ ។**

ប្រែប្រយោគសួរៈ វេជ្ជោ វេទេយ្យ បុច្ឆិ សួរហើយ គន្តេ ។ល។ អាសិតំ ឥតិ ថា...ដូច្នេះ "គន្តេ បពិត្រព្រះថេរៈដ៏ចំរើន គេលំ រំប្រេង មយា គឺខ្ញុំ បចិត្វា ស្ងោហើយ បេសិតំ បញ្ជូនមកហើយ, នោ តើលោក អាសិតំ បន្តក់ហើយ នាសាយតាមច្រមុះ (កឹ ឬ)" ។

ប្រែប្រយោគឆ្លើយៈ ចក្ខុបាលោ រី... តាហ តបហើយ អាម ឧបាសក ឥតិ ថា "ចំរើនពរ ឧបាសក" ។

៦៧_តាមធម្មតាប្រយោគលក្ខណៈ បើមានច្រើន គប់

www.budinst.gov.kh www.elibraryofcambodia.org

តាំងពីពីរឡើងទៅ ត្រូវតែប្រែតួប្រធានរបស់ប្រយោគលក្ខ-ណៈក្រោយបំផុតជាមុន ហើយបន្សល់ទុក, ទៅប្រែប្រយោគមុខទៀតរហូតមកដូច **យថា ហិ ពហូសុ ឯកតោ គាម-ឃាតាទីនិ កម្មានិ ករោន្តេសុ, "កោ ឯតេសំ បុព្វង្គមោ ហោតិ ទុក្កេ, យោ តេសំ បច្ចយោ ហោតិ, យំ និស្សាយ តេ តំ កម្មំ ករោន្តិ, សោ ញាតោ វា មិត្តោ វា តេសំ បុព្វង្គមោ វុច្ចតិ, ឯវំ សម្បទមិទំ ទដ្ឋព្វំ** (ប្រែ)" ហិ ដូចជា (របៀប នា កាលពាក្យ) កោ ឯតេសំ បុព្វង្គមោ ឥតិ ថាអ្នកណាជាប្រធាននៃចោរៗ នុ៎ះ, ពហូសុ. ចោរេសុ នាកាលចោរៗ. ច្រើននាក់ ករោន្តេសុ កាល... កម្មានិ នូវ... គាមឃា-តាទីនិ មានការសម្លាប់នូវអ្នកស្រុកជាដើម ឯកតោ ក្នុងទីជាមួយគ្នា, (កេនចិ គឺអ្នកណា) វុត្ត ពោលហើយ យោ តោ-ករេ... តេសំ បច្ចយោ ហោតិ ជាបច្ច័យនៃចោរៗ. នោះ

www.budinst.gov.kh www.elibraryofcambodia.org

គេហោក រ៍.. និស្សាយ អាស្រ័យហើយ យំ.ហេតុ ខ្ញុំ.. ករេត្តិ រមែងធ្វើ កម្មំ ខ្ញុំ .. តំ នោះ; សោ.ហេតុ រ៍.. ទត្តា ក៏ ឈ្មោះទត្តកំ មិត្តា ក៏ ឈ្មោះមិត្តកំ (ជនេហិ គឺ...) វុច្ចតិ ពោល គេសំ បុព្វគ្គេ ឥតិ ថា រ៍ (ហេតុនេះ) ជាប្រធាន នៃហេតុ. នោះ យថា យ៉ាងណា សម្ពន្ធពាក្យឧបមេយ្យ ជាគ្រឿងញ៉ាំងអត្ថឲ្យដល់ព្រម តំ នេះ (បណ្ឌិតេន គឺ...) វេទិតព្វំ គប្បី... ឯវំ យ៉ាងនេះ,, ។

២៨-បទវិកតិកម្ម លោករៀងទុក នៅមុខកិរិយាប្រាប់ កម្មវាចកៈ នឹងប្រែឲ្យជាសញ្ញាវិសេសនៈ របស់បទប្រធានវិញ ក៏បាន ដូច **អមតំ វុច្ចតិ និព្វានំ** ។ ប្រែជាវិកតិកម្ម : «និព្វានំ រ៍.. កឥតោ គឺ ..វុច្ចតិ ត្រូវគេត្រាស់ អមតំឲ្យឈ្មោះ ជាអមតៈ» ។ ប្រែជាសញ្ញាវិសេសនៈ «និព្វានំ រ៍... កឥតោ គឺ.. វុច្ចតិ ... អមតំ ជាអមតៈ» ។

២៩- សំនួនភាសាបាលី ដែលជាពាក្យសួរ ដោយ

www.budinst.gov.kh www.elibraryofcambodia.org

កគម.សព្ទ ដូច កគមោ ឬ កគមានិ ជាដើម, ត្រូវស្រង់យកពាក្យក្នុងប្រយោគមុខ មកប្រកបប្រែឲ្យពេញ ដូច **គីណិមា-និ តន្តេ គន្ធជាតានិ ។ល។ កគមានិ គីណិ ។** (ប្រែ) ‹‹តន្តេ បពិត្រព្រះអង្គដ៏ចំរើន គន្ធជាតានិ រីគន្ធជាតទ. ឥមានិ នេះ គីណិញ ។ល។ គីណិ-គន្ធជាតានិ រីគន្ធជាតទ.ញ កគមានិ ដូចម្តេច? ។

៣០—វិធីប្រែប្រយោគកម្ម ដែលមានប្រយោគលក្ខណៈជ្រែកចូល ត្រូវប្រែបទប្រធាននិងបទអនភិហិតកត្តា នៃប្រ-យោគកម្មជាមុន ហើយបន្សល់កិរិយាទុក, ទៅប្រែប្រយោគដែលជ្រែកចូលនោះមកវិញ ដូច **ត្វំ មេ មាតរំ មតាយ, មាតា ទិយ; បិតរំ មតេ, បិតា ទិយ លទ្ធោ**(ប្រែ) ‹‹ ត្វំ អ្នក មេ គីខ្ញុំ មាតរំ នាកាលមាតា មតាយ ស្លាប់ហើយ លទ្ធោ បានហើយ មាតា វិយ ដូចជាមាតា; ត្វំ អ្នក មេ គីខ្ញុំ បិតរំ នាកាលបិតា មតេ ស្លាប់ហើយ លទ្ធោ

www.budinst.gov.kh www.elibraryofcambodia.org

បានហើយ បិតា វិយ (១) ដូចជាបិតា" ។

៣១– ច, វា, បិ ជាបទសមុច្ច័យត្ថ ជាពាក្យសមុច្ច័យត្ថ ដែលលោករៀនទុកតែមួយ តួ, កាលបើប្រែ ត្រូវបញ្ចូន ច ឬ វា, បិ នោះ ទៅរួមចូលនឹងបទសមុច្ច័យមួយ ៗ ឬពាក្យ-សមុច្ច័យមួយ ៗ នោះដូច **បញ្ច គេសដ្ឋានិ អដ្ឋ ច ឃានានិ** (ប្រែ) "បញ្ច កេសដ្ឋានិ ច គឺកេសដ្ឋទ. ៥ ផង អដ្ឋ ឃានានិ ច គឺទឹកបានទ. ៨ ផង" ។ **ខេត្តេ កត្តំ ហរន្តិយា ទារុបណ្ណាទីនំ វា អត្ថាយ អរញ្ញំ គច្ឆន្តិយា សោ តាយ សទ្ធឹយេវ គច្ឆតិ** (ប្រែ) "សោ សុនខោ គឺសុនខនោះ ខេត្តេ កត្តំ ហរន្តិយា វា ទារុបណ្ណាទីនំ អត្ថាយ អរញ្ញំ គច្ឆន្តិយា វា តាយ សទ្ធឹ គច្ឆតិ ឯវ តែងទៅ ជាមួយនឹងស្រីនោះ កាលនាំនូវបាយទៅកាន់ស្រែឬ

---

១ មាតា និង បិតា ឧបមាវិសេសនៈរបស់ ខ្ញុំ, វិយ-សព្ទ ឧបមាជោតកៈក្នុង មាតា ក្នុង បិតា ។

www.budinst.gov.kh www.elibraryofcambodia.org

ឬកាលទៅកាន់ព្រៃ ដើម្បីប្រយោជន៍ដល់វត្ថុ . មានឱស ទិនបន្ថែមជាដើម មិនស្ងួតទាន » ។

៣២- ប្រយោគដូច **យំ ឥច្ឆតិ, តំ ខាទេហិ។ យំ ឥច្ឆតិ, តំ ករោហិ ។ យំ ឥច្ឆតិ, តំ ទេហិ** ជាដើម ត្រូវលើកយកធាតុរបស់កិរិយាខាងក្រោយ មកប្រកប តុំ.បច្ច័យ ជាតុមត្ថសម្បទាន ចូលក្នុង ឥច្ឆតិ ជា **យំ (ខាទិតុំ) ឥច្ឆតិ តំ ខាទេហិ ។ យំ (កាតុំ) ឥច្ឆតិ តំ ករោហិ ។ យំ (ទាតុំ) ឥច្ឆតិ តំ ទេហិ។**

៣៣- អកម្មកិរិយា បើប្រើជាសកម្មកិរិយា, វេលាប្រែត្រូវរកពាក្យខ្មែរជាសកម្មកិរិយា ដែលបានសេចក្តីប៉ុនគ្នាមកប្រែ ដូច **ភាតិ** « រុងរឿង» បើប្រើជាសកម្មកិរិយា ប្រែថា «ឆ្លុះ, បំភ្លឺ», បើមិនមានពាក្យខ្មែរដែលជាសកម្មកិរិយាទេ ឲ្យបន្ថែម ពាក្យថា «រក, ទារ, ទុក» ជាដើម តពាក្យកិរិយានោះ ដូច **រោទតិ** «យំ», បើប្រើជាសកម្មកិរិយា ត្រូវប្រែថា «យំរក,

យំតារ» ២. **បុត្តំ** **រោទតិ** «យំរក នូវកូន», **ចន្ទំ**
រោទតិ «យំតារ នូវព្រះចន្ទ្រ» ។

៣៤_ បើចង់ធ្វើគុណសព្ទឲ្យជានាមសព្ទវិញ, នៅវេលាប្រែ ត្រូវបន្ថែម ការ-សព្ទ ដូច **ឧណ្ហាការំ** «នូវអាការគឺការៈជារបស់ក្ដៅ,, ។

៣៥ កិរិយាក្ដី នាមនាមក្ដី បើសេចក្ដីមិនទាន់ជាក់ប្រាកដទេ ក្នុងវេលាប្រែ ត្រូវបន្ថែមការៈមក ទើបលែងតែសេចក្ដីនោះជាក់ប្រាកដហើយ ដូច **សត្ថុ និសិន្នក្លាយ** «ដើម្បីប្រយោជន៍ដល់ការៈនៃព្រះសាស្ដាគង់ហើយ» នេះកិរិយា, **ភិក្ខុនោ សមណភាវេន** «ដោយអំណាចនៃការៈជាសមណៈរបស់ភិក្ខុ», នេះនាមនាម ។ ដែលបាននិយាយមកនេះ ចំពោះនាមដែលចូលជាសមាសហើយ, ចំណែកនាមដែលមិនចូលជាសមាស បើប្រែត្រឹមរូបសព្ទ មិនបានសេចក្ដីល្អទេ ក៏ឲ្យបញ្ចូល ការ-សព្ទ បានដែរ ដូច **គច**

www.budinst.gov.kh www.elibraryofcambodia.org

បិតុរថោ គច រថំ ន បាបុណិ (ប្រែ) "គេ បិតុរថោ រថនៃព្រះបិតា របស់ទ្រង់ ន បាបុណិ មិនដល់ហើយ រថំ នូវការៈជារថ គេ របស់ទ្រង់" ។

៣៦_សមយ.សព្ទ ប្រែបានច្រើនយ៉ាង តែក្នុងគម្ពីរ ធម្មបទដ្ឋកថា ច្រើនប្រែ ២ យ៉ាង គឺប្រែថា "កាល, សម័យ, ពេល, វេលា" ដូច **តេន ខោ បន សមយេន** "ក៏ក្នុងសម័យនោះឯង" ១, ប្រែថា "លទ្ធិ, អក្សរ" ដូច **សមយំ បរិគ្គណ្ហិត្វា** "រៀនហើយ នូវលទ្ធិ" ១ ។

១៥ - លក្ខណៈសព្ទមានឧបសគ្គ

សព្ទដែលប្រកបដោយឧបសគ្គ លោកបញ្ញត្តឲ្យប្រែ ៣ យ៉ាង គឺ ប្រែបំបែរធាតុ ១ ប្រែបណ្ដោយតាមធាតុ ១ ប្រែផ្សេងពីធាតុ គឺធ្វើធាតុឲ្យប្លែកចាកប្រក្រតី ១ ។

www.budinst.gov.kh www.elibraryofcambodia.org

អធិប្បាយ

ក) ប្រែបំបែរធាតុ ធាតុដើមយ៉ាងណាក៏ដោយ កាលលោកប្រកបឧបសគ្គចូលហើយ ទំនងប្រែតាមធាតុមិនបានជាជាប់ខាត ត្រូវប្រែបំបែរសេចក្ដីទៅតាមឧបសគ្គវិញ គឺប្រែឲ្យសេចក្ដីទំនាស់នឹងឧបសគ្គ ដូច **និព្វជ** ញែកសព្ទថា **និ** "ប្រាស" **ព្វជ** "ទាក់ស្រែះ, ស្អុកស្អាញ" ត្រូវប្រែថា "ស្ទាន, ស្រឡះ" ។ **និរាគោ** ញែកសព្ទថា **និ** "ប្រាស" **រាគ** "ជ្រលក់, ត្រេកអរ" ត្រូវប្រែថា "ការអស់តម្រេក" ឬ "ការគ្មានតម្រេក" ជាដើម ។

ខ) ប្រែបណ្ដោយតាមធាតុ ធាតុដើមយ៉ាងណា សូម្បីលោកប្រកបឧបសគ្គចូលហើយ ក៏ឲ្យប្រែតាមរូបធាតុនោះវិញ ។ ដែលលោកប្រកបឧបសគ្គ ពួកនេះចូលមកផង ដើម្បីធ្វើសេចក្ដីឲ្យច្បាស់លាស់ ឲ្យស្រស់ស្រាយឡើងបន្តិចតែប៉ុណ្ណោះ ដូច **បតិដ្ឋិតោ** ញែកសព្ទថា **បតិ** "ចំពោះ"

www.budinst.gov.kh www.elibraryofcambodia.org

បិត « ឈរ, បិតនៅ » ត្រូវប្រែថា «ឈរនៅចំពោះហើយ, ឈរស៊ប់ហើយ» បានសេចក្ដីត្រឹមតែ « ឈរ » ប៉ុណ្ណោះ ។ ឧបសគ្គពួកនេះសព្ទខ្លះមិនបាច់ប្រែក៏បាន សព្ទខ្លះត្រូវប្រែ, តែបើប្រែ ត្រូវប្រែឲ្យស៊ីសេចក្ដីនឹងធាតុ ដូច **បមោទោ** «សេចក្ដីស្រើនជ្រប់» ញែកសព្ទជា **ប** « ប្រការ» **មុទ** «ស្រើន» ។ **វិនាសោ** «សេចក្ដីខូចខាត» ញែកសព្ទជា **វិ** « ផ្សេងៗ » **នាស** « ខូចខាត » ; **អតិឧណ្ហោ** «ក្ដៅក្រៃពេក» ញែកសព្ទជា **អតិ** « ក្រៃពេក » **ឧណ្ហ** « ក្ដៅ » ជាដើម ។

គ) **ប្រែផ្សេងពីធាតុ** គឺធ្វើធាតុឲ្យប្លែកចាកប្រក្រតី, ធាតុដើមយ៉ាងណា កាលប្រកបឧបសគ្គចូលហើយ បើប្រែតាមលំនាំឧបសគ្គនិងធាតុនោះមិនបានទេ ត្រូវប្រែបង្វិលសេចក្ដីទៅផ្សេងវិញ ទើបបានសេចក្ដីល្អ, ព្រោះហេតុនោះឧបសគ្គបែបនេះទើបលំបាកនឹងប្រែជាទីបំផុតដូច **បរាភវោ**

www.budinst.gov.kh www.elibraryofcambodia.org

«សេចក្តីវិនាស» ញែកសព្ទជា **បរា** «ត្រឡប់» **ភវ** «មាន, កើត, ជា» ។ **អនុភវោ** «ការសោយ, ការរង» ញែកសព្ទជា **អនុ** «ជួប, តាម, បណ្តោយ, ខាងក្រោយ» **ភវ** «មាន, កើត, ជា» ។

*

* *

១៦_ វិធីរកតួកត្តាក្នុងគម្ពីរនានា

នឹងសំដែងអំពីវិធីរកតួកត្តា ក្នុងការប្រែភាសាបាលី ក្នុងគម្ពីរផ្សេង ៗ ដូចពោលតទៅនេះ ៖

បើជាបាលីប្រើ **ភគវន្តុ** ជាកត្តា; បើជាផ្លូវរៀន ប្រើ **ធម្មសង្គាហក** ជាកត្តា, បើក្នុងវិន័យ ប្រើ **ឧបាលិត្ថេរ** ជាកត្តា: បើក្នុងព្រះអភិធម្ម ប្រើ **អានន្ទត្ថេរ** ជាកត្តា, បើអដ្ឋកថា ឬ វណ្ណនា ប្រើ **អដ្ឋកថាចរិយ** ជាកត្តា. បើគម្ពីរមានរូបអ្នកសំដែង អ្នកណាសំដែង ត្រូវបញ្ចេញឈ្មោះអ្នកនោះ ដូចគម្ពីរមហានិទ្ទេសនិងបដិសម្ភិទា ប្រើ **សារីបុត្ត** ជាកត្តា;

www.budinst.gov.kh www.elibraryofcambodia.org

បើមិនដឹងជាអ្នកណាសំដែងទេជារឿងបរម្បរា ត្រូវប្រើ**បោរា-ណាចរិយ** ជាកត្តា ។ មួយទៀត បើប្រែ ឬមើលគម្ពីរណា ពាក្យដែលពោលក្នុងគម្ពីរនោះ ត្រូវប្រើ **មយា** ជាកត្តា ដូចពាក្យក្នុងអដ្ឋកថា នៃគម្ពីរធម្មបទជាដើម ។

●

១៧– គោលប្រែអដ្ឋកថា

អដ្ឋកថានៃគម្ពីរធម្មបទ មានវិធីប្រែច្រើនយ៉ាង ដែលជាហេតុឲ្យអ្នកសិក្សាដំបូងមិនងាយចូលចិត្តបានទេ ព្រោះហេតុដូច្នោះ ក្នុងទីនេះ នឹងដាក់វិធីប្រែអដ្ឋកថានោះ ៗ ទុកជាពួក ៗ ដើម្បីជាគ្រឿងកំណត់របស់អ្នកសិក្សាដំបូង ដូចតទៅនេះ៖

គោលប្រែពួកទី១(១)

ដែលសម្រាប់ប្រកបប្រែជាមួយនឹង ឥតិ-សព្ទ ដែលគាំងនៅក្នុងទីបំផុត នៃបទកៃកនិងបទគាំង ។

១– គោលប្រែពួកទី១ ទី២ ទី៣ ទី៤ អ្នកសិក្សាត្រូវខន្នែញឲ្យចាំរត់មាត់

១–**អត្ថោ** (អត្ថ) **ឥតិ . . . បទស្ស ឬ បទានំ . . . ឥតិ. . .**

ឧទាហរណ៍ដូច្នេះ **តត្ថ អប្បមាទរតោតិ : អប្ប-មាទេ ។ បេ ។ វីតិនាមេន្តោតិ អត្ថោ** (១)*(ប្រែ) «អត្ថ វែអត្ថ អប្បមាទេ ។ បេ ។ វីតិនាមេន្តោ ឥតិ ថា . . . ដូច្នេះ តត្ថ បទេសុ ជំនុំបទ. នោះ បទស្ស នៃបទ អប្បមាទរតោ ឥតិ ថា ... ដូច្នេះ,, (ធ.ក ២ ទំព័រ ១៨៩)* ។

២– **អត្ថោ** (សេចក្តី) **ឥតិ . . . បទស្ស ឬ បទានំ . . . ឥតិ.**

ឧទាហរណ៍ដូច្នេះ **បញ្ចគង្គោ ច ធុម្មង្គេតិ : បញ្ចគ-មុទ្ធនិដ្ឋិតោ ។ បេ ។ អកិច្ចេន អចេត្វតីតិ** *(ប្រែ) «អត្ថោ សេចក្តី បញ្ចគមុទ្ធនិដ្ឋិតោ;, ។បេ។ អកេតុតិ ឥតិ*

---

១ តត្ថ វិសេសនៈរបស់ បទេសុ ។ និទ្ធារណសត្តមីក្នុង បទស្ស. អប្បមាទរតោ សរូបនិទស្សនៈក្នុង ឥតិ ។ សព្វ សរូបនិទស្សនីយៈក្នុង បទស្ស ។ ឆដ្ឋីនិទ្ធារណីយៈរបស់ បទេសុ ហើយជាសាមីសម្ពន្ធៈក្នុង អត្ថោ. អប្បមាទេ ។បេ។ វីតិនាមេន្តោ សរូបនិទស្សនៈក្នុង ឥតិ ។ សព្វ សរូបនិទស្សនីយៈក្នុង អត្ថោ ។ លិង្គត្ថបឋមា ។

www.budinst.gov.kh www.elibraryofcambodia.org

ថា .. ដូច្នេះ បទទួយស្ស នៃប្រជុំនៃគាំរនៃបទ បញ្ចុះផ្ដោរ កុម្មរដ្ឋ ឥតិ ថា . . . ដូច្នេះ" (ធ.ក ២ ទំព័រ ១៥៧) ។

៣. អត្ថោ (សេចក្ដី) **ឥតិ. គាថាវចនស្ស.បណ្ឌិតេន វេទិតព្វោ.**

ឧទាហរណ៍ដូច្នេះ **គស្សត្ថោ យានិ កម្មានិ ។ បេ ។ បច្ឆាមុខគរណំ ទិយ អតិទុក្ករន្តិ** (១)

(ប្រែ) " អត្ថោ សេចក្ដី យានិ កម្មានិ ។បេ។ អតិទុក្ករំ ឥតិ ថា ...ដូច្នេះ គស្ស.គាថាវចនស្ស នៃពាក្យជាគាថានោះ បណ្ឌិតេន គឺបណ្ឌិត វេទិតព្វោគប្បីដឹង.,(ធ.ក ៦ ទំព័រ ៣២)។

៤– អត្ថោ (អត្ថាធិប្បាយ) . . . **ឥតិ**...**ក្នុង**... **ឥតិ** . . .

---

១ អត្ថោ វុត្តកម្មៈក្នុង វេទិតព្វោ ។ គិតបទ កម្មវាចកៈរបស់អត្ថោ, គស្ស វិសេសនៈរបស់ គាថាវចនស្ស ។ សាមីសម្ពន្ធៈក្នុង អត្ថោ. យានិ កម្មានិ ។ បេ ។ អតិទុក្ករំ សរូបនិទស្សនៈក្នុង ឥតិ។សព្ទសរូបនិទស្សនីយៈក្នុងអត្ថោ, បណ្ឌិតេនអនភិហិតកត្តាក្នុង វេទិតព្វោ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ដូច្នេះ **បរេ ចាតិៈ បុព្វេ មយា ។បេ។ មេធគា <u>សម្មន្តីតិ</u> អយមេត្ថ អត្ថោ**(១)*(ប្រែ)“ អត្ថោ គឺអត្ថាធិប្បាយ បុព្វេ មយា ។បេ។ មេធគា សម្មន្តិ ឥតិ ថា ... ដូច្នេះ ឯត្ថ គាថាយំ ក្នុងគាថានុ៎ះ បរេ ច ឥតិ ថា.. ដូច្នេះជាដើម អយំ នេះ បណ្ឌិតេន គឺបណ្ឌិត វេទិតព្វោ គប្បីដឹង” (ធ.ក. ១ ទំព័រ ៩៦)* ។

៥- អត្ថោ (អធិប្បាយ) **ឥតិ...**

ឧទាហរណ៍ដូច្នេះ **បសាទំ ជនេតិយេនាតិ <u>អត្ថោ</u>** *(ប្រែ “ អត្ថោ គឺអធិប្បាយ បសាទំ ជនេតិយេន ឥតិ ថា ... ដូច្នេះ” (ធ.ក. ៨ ទំព័រ ១០៥)*

១៖ អត្ថោ វុត្តកម្មៈក្នុង វេទិតព្វោ ។ គិតបទ កម្មវាចកៈរបស់អត្ថោ បរេ ច សរុបៈ ក្នុងឥតិ ។ សព្ទ អាខ្យាតៈក្នុង ឯត្ថ-គាថាយំ, បុព្វេ មយា ។បេ។ មេធគាសម្មន្តិ សរុបនិទស្សនៈក្នុង ឥតិ។សព្ទ សរុបនិទស្សនីយៈ ក្នុងអត្ថោ, អយំ វិសេសនៈរបស់ អត្ថោ, ឯត្ថវិសេសនៈរបស់ គាថាយំ។ អាធារៈក្នុង អត្ថោ, បណ្ឌិតេន អនភិហិតកត្តាក្នុង វេទិតព្វោ ។

www.budinst.gov.kh www.elibraryofcambodia.org

៦-បទំ(បទ)ឥតិ..បណ្ឌិតេន..វេទិតព្វំ (មយា វុច្ចតេ)

ឧទាហរណ៍ដូច្នេះ **ធម្មាតិ ។ បេ ។** (ប្រែ) "បទំ គឺបទ ធម្ម ឥតិ ថា...ដូច្នេះ បណ្ឌិតេន គឺបណ្ឌិត វេទិតព្វំ គប្បីដឹង(ឬ មយា គឺខ្ញុំ វុច្ចតេ ឲ្យពោល)" ធ.ក.១ ទំព័រ ៣១ ។

គោលប្រែពួកទី ២

បែបសម្រាប់ប្រែកបប្រែឲ្យសព្វ ដែលចុះសត្តមីវិភត្តិ ហើយតាំងនៅតែមួយបទ ឬក៏តាំងនៅក្រោយនៃបទតាំង តែទីបំផុតនៃបទកែ មិនមានឥតិ-សព្ទដូចន័យក្នុងគោលប្រែពួកទី១ទេ ។

១-អត្ថោ(សេចក្តី) ក្នុង... បណ្ឌិតេន... វេទិតព្វោ...

ឧទាហរណ៍ដូច្នេះ **ទុតិយគាថាយមិ**(ប្រែ) " អត្ថោ គឺសេចក្តី ទុតិយគាថាយំ សូម្បីក្នុង... បណ្ឌិតេន គឺ... វេទិតព្វោ គប្បី ..." ។ ន័យនេះ ឲ្យប្រែ ទិដ្ឋយោ ជំនួស អត្ថោ ឬប្រែ មយា វុច្ចតេ ជំនួស បណ្ឌិតេន វេទិតព្វោ ក៏បាន ពីប្រែដូចគ្នា (ធ.ក.៤ ទំព័រ២១) ។

www.budinst.gov.kh www.elibraryofcambodia.org

២– វិនិច្ឆយោ (វិនិច្ឆ័យ) ក្នុង... ឥតិ ... បណ្ឌិតេន...
វេទិតព្វោ...

ឧទាហរណ៍ដូច្នេះ ធនំ ធនញ្ជានិ ឯត្ថ(១) មហន្តា រុក្ខា ធនំ នាម (ប្រែ) "វិនិច្ឆយោ វិនិច្ឆ័យ ឯត្ថ-បទទ្វយេ ក្នុងប្រជុំនៃពីរនៃបទនុ៎ះ ធនំ ធនញ្ញ ឥតិ ថា . . . ដូច្នេះ បណ្ឌិតេន គឺ . . . វេទិតព្វោ គប្បី." (ធ.ក ៧ ទំព័រ១០៤)

៣– វិគ្គហោ (វិគ្រោះ) ក្នុង ... ឥតិ ... បណ្ឌិតេន . . .
វេទិតព្វោ...

ឧទាហរណ៍ដូច្នេះ ធីរោ ច សុខសំវាសោតិ ឯត្ថ សុខោ សំវាសោ ឯតេនាតិ សុខសំវាសោ(ប្រែ)

---

១ វិនិច្ឆយោ វុត្តកម្មៈក្នុង វេទិតព្វោ ។ កិតបទ កម្មវាចកៈរបស់ វិនិច្ឆយោ.ធនំ ធនញ្ញ សរូបនិទស្សនៈក្នុងឥតិ ។ សព្វស រូបនិទស្សនីយៈ ក្នុងឯត្ថ_បទទ្វយេ, ឯត្ថ វិសេសនៈរបស់ បទទ្វយេ ។ អាធារៈក្នុង វិនិច្ឆ-យោ, បណ្ឌិតេន អនភិហិតកត្តា ក្នុង វេទិតព្វោ ។

www.budinst.gov.kh www.elibraryofcambodia.org

«វិគ្គហោ វិគ្រោះ ឯគ្គ បទទ្វយ ក្នុងប្រជុំនៃពាក្យនៃបទទុំះ ពីរក ខ សុខសំពសោ អតិ ថា...ដូច្នេះ បណ្ឌិតគេ គឺ... វេទិតព្វោតព្វ...» (ធ.ក ៦ ទំព័រ ២០០) ។

គោលប្រែពួកទី ៣

បែបសម្រាប់ប្រែ អតិ-សព្ទ ជាសញ្ញាជាតកៈភ្ជាប់នឹងបទតាំង «**ឈ្មោះថា**» មានឧទាហរណ៍ ដូច្នេះ **អច្ចន្តទុស្សី-ល្យន្តិ ឯកន្តទុស្សីលភាវោ**(១)(ប្រែ)» ឯកន្តទុស្សីល-ភាវោ (២) វិការៈនៃបុគ្គលអ្នកឥតសីលដោយចំណែកមួយ អច្ចន្តទុស្សីល្យំ អតិ ឈ្មោះថា ភាពនៃបុគ្គលអ្នកទ្រុស្តសីលដោយចំណែកមួយ» (ធ.ក ៦ ទំព័រ ៦៩) ។

---

១ អច្ចន្តទុស្សីល្យំ សរុប.ក្នុង ឥតិ ។ សព្ទ សញ្ញាជាតកៈក្នុង ឯកន្តទុស្សីលភាវោ ។ លិង្គត្ថបឋមា ។ ២ ទុ-សព្ទ ក្នុងទីនេះ ប្រែថា « ឥត.គ្មាន,មិនមាន., មានន័យដូច និ. សព្ទ ឧ. ទុស្សីលោ « អ្នកឥតសីល., ទុប្បញ្ញោ, ទុម្មេធោ « អ្នកឥតប្រាជ្ញា » ព្រោះបទទាំងនេះ ក្នុងអដ្ឋកថា កែថា និស្សីលោ, និប្បញ្ញោ-និម្មេធោ ។

www.budinst.gov.kh www.elibraryofcambodia.org

គោលប្រែពួកទី ៤

បែបសម្រាប់ប្រកបប្រែ ទីនិបាតនាម, គុណ, កិរិយា, កិរិយានាម, កិរិយាគុណ ដែលលោករៀងគ្នា តាំងសេច-ក្តីសោក ក៏ប្រើប្រាស់គ្នា គឺជាវេវចនៈនឹងគ្នា ។

១– ប្រែមុនបទកែ "គឺថា" មានឧទាហរណ៍ដូច្នេះ

បាបំ ទុម្មេធំ : និប្បញ្ញំ បុគ្គលំ ចតូសុ អបាយេសុ អភិមត្ថតិ : វិទ្ធំសេតិ (១) (ប្រែ) "បាប រំពាប អភិមត្ថតិ រមែងញាំញី អភិមត្ថតិ គឺថា វិទ្ធំសេតិ ។ រមែងកំចាត់ បុគ្គលំ នូវបុគ្គល ទុម្មេធំ អ្នកឥតប្រាជ្ញា ទុម្មេធំ គឺថា និប្បញ្ញំ ។ អ្នកមានប្រាជ្ញាមិនមាន" (ធ.ក ៦ ទំព័រ ២៨) ។

២– ប្រែក្រោយបទកែ " **ឈ្មោះថា, ឲ្យឈ្មោះថា**

---

១ បាបំ សយកត្តាក្នុង អភិមត្ថតិ វិទ្ធំសេតិ, អភិមត្ថតិ វិវរណៈក្នុងវិទ្ធំសេតិ។ វិវរណីយៈរបស់អភិមត្ថតិ, អភិមត្ថតិ ក្តី វិទ្ធំសេតិ ក្តី អាខ្យាតបទកត្តុវាចកៈ របស់បាបំ. ទុម្មេធំ វិវរណៈក្នុង និប្បញ្ញំ ។ វិវរណីយៈរបស់ទុម្មេធំ, ទុម្មេធំ ក្តី និប្បញ្ញំក្តី វិសេសនៈរបស់ បុគ្គលំ។អវុត្តកម្មៈក្នុង អភិមត្ថតិ វិទ្ធំសេតិ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ដូច្នេះ **យន្តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ឯវរូបេន វីរិយេន អន្តរា អនោសក្កិត្វា និច្ចំ បវត្តេន ឧឡារេន បរក្កមេន សមន្នាគតា**(១) (វិប្រ) ..(ជនា វិជនេ.)

---

១ ជនា សយកត្តាក្នុង សមន្នាគតា ។ កិតបទ កត្តុវាចកៈរបស់ ជនា, យន្តំ ។ បេ ។ សណ្ឋានំ ភវិស្សតិ សរុបនិទស្សនៈក្នុងឥតិ ។ សព្ទ សរុបនិទស្សនីយៈក្នុង វីរិយេន, ឯវរូបេន វិសេសនៈរបស់ វីរិយេន ។ ករណៈក្នុង សមន្នាគតា: អន្តរា-សព្ទ អាធារៈក្នុងអនោសក្កិត្វា។ ហេតុកាលកិរិយាក្នុង បវត្តេនៈ និច្ចំ កិរិយាវិសេសនៈក្នុងបវត្តេន ។ ក្តី ឧឡារេន ក្តីវិសេសនៈរបស់ បរក្កមេន ។ ករណៈក្នុងសមន្នាគតា ។ (លេខក្នុង) យន្តំ អភិមុខីករណត្ថ-វិសេសនៈរបស់ កិច្ចំ ។ វុត្តកម្មៈក្នុង បត្តព្វំ ។ កិតបទ កម្មវាចកៈរបស់ កិច្ចំ. បុរិសត្ថាមេនក្តី បុរិសវីរិយេនក្តី បុរិសបរក្កមេនក្តី ករណៈក្នុង បត្តព្វំ, ន-សព្ទ បដិសេធៈក្នុង សណ្ឋានំ, តំ វិសេសនៈរបស់ កិច្ចំ ។ អវុត្តកម្មៈក្នុងអបាបុណិត្វា ។ បុព្វកាលកិរិយាក្នុងសណ្ឋានំ, វីរិយស្សឆដ្ឋីកម្មៈ ក្នុង សណ្ឋានំ ។ សយកត្តា ក្នុង ភវិស្សតិ ។

www.budinst.gov.kh www.elibraryofcambodia.org

សមន្នាគតា ប្រកបព្រមហើយ វីរិយេន ដោយសេចក្ដីព្យា-
យាម ឯវរូបេន មានសភាព យ៉ាងនេះ យន្តំ ។ល។ សណ្ឋានំ
ភវិស្សតិ ឥតិ ថា ... ដូច្នេះ, បរក្កមេន ឈ្មោះថា ដោយ
សេចក្ដីប្រឹងប្រែង ទឡ្ហេន ដ៏មុឹងម៉ាត់ បវត្តេន ដែលប្រ
ព្រឹត្តទៅហើយ និច្ចំ ជានិច្ច អនោសក្កិត្វា ព្រោះមិនបន្ធូរ
អត្តក ក្នុងពាក់កណ្ដាល ។ (លេខក្នុង) យន្តំ បុរិសត្ថាមេន
បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ នតំ អបាបុណិត្វា វីរិ-
យស្សសណ្ឋានំ រីកិរិយាមិនទាន់លុះ នូវ រីកិច្ចណា ដែល
បុគ្គលគប្បីលុះបាន ដោយកម្លាំងចិត្តរបស់បុរស ដោយ
សេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់
បុរស កិច្ចនោះ (មុខ)ទេ នឹងមិនបញ្ឈប់ នូវសេចក្ដីព្យាយាម
ភវិស្សតិ នឹងមាន" (ធ.ក. ២ ទំព័រ ១១៨) ។

១៨- វិធីសង្កេតគោលប្រែអដ្ឋកថា

អ្នកសិក្សា ចូរសង្កេតគោលប្រែអដ្ឋកថា ដែលពោលមក

www.budinst.gov.kh www.elibraryofcambodia.org

ហើយនោះ តាមវិធីសង្កេត ដូចតទៅនេះ ៖

សង្កេតគោលប្រែពួកទី ១

១—អដ្ឋកថាណា ដែលព្រះអដ្ឋកថាចារ្យ លើកយកបទក្នុងគាថាមកតាំង ត្រឹមតែ ១ បទក្តី ២ បទក្តី ច្រើនបទក្តី តាំងជាបាទក្តី តែសេចក្តីដែលកែចេញទៅ មិនពិស្តារទេ លោកតែងឲ្យល្មមសមគួរដល់បទ ឬបាទនៃគាថានោះប៉ុណ្ណោះៈ **អត្ថោ** ដែលយកទៅប្រើក្នុងអដ្ឋកថានោះ គប្បីប្រែថា "**អត្ថ**" ។ កាលនឹងប្រែបទតាំង, បើបទតាំងនោះមួយបទ ប្រើ **បទស្ស**, ពីរបទ ប្រើ **បទទ្វយស្ស**, តាំងពី ៣ បទឡើងទៅ ដែលមិនទាន់ពេញជាបាទគាថា ប្រើ **បទានំ**, បើពេញមួយបាទគាថា ប្រើ **គាថាបាទស្ស**, បើ ២ បាទ ប្រើ **គាថាបាទទ្វយស្ស** ។

២—អដ្ឋកថាណា មានប្រយោគចុណ្ណ នៅខាងមុខរបស់

www.budinst.gov.kh www.elibraryofcambodia.org

បទតាំង, បទតាំងនោះឯង ក៏ជាប្រយោគវិសជ្ជនារបស់ប្រ-
យោគបុច្ឆា, ហើយនៅមានចែកបញ្ចេញទៅទៀត ដើម្បីពង្រីក
សេចក្តីរបស់វិសជ្ជនានោះឲ្យច្បាស់លាស់, **អត្ថោ** ដែលយក
ទៅប្រើក្នុងអដ្ឋកថានោះ គប្បីប្រែថា "**សេចក្តី**" ។ ឧទា-
ហរណ៍ដូច្នេះ **យថា កឹ ។ ចក្កំវ វហតោ បទន្តិៈ ធុរេ
យុត្តស្ស ធុរំ វហតោ ពលិវទ្ទស្ស បទំ ចក្កំ វិយ**
(ប្រែ) "បុច្ឆា រីបុច្ឆា យថា កឹ ឥតិ ថា ... ដូច្នេះ ចក្កំ រីចក្ក
អន្វេតិ វិលទៅតាម តំ បុគ្គលំ នូវបុគ្គលនោះ យថា កឹ
ដូចជាអ្វី? ។ វិសជ្ជនា រីវិសជ្ជនា ចក្កំវ វហតោ បទំ ឥតិ
ថា ... ដូច្នេះ, ចក្កំ វហតោ បទំ (អនុគច្ឆន្តំ) ឥវ ដូចជា
រីចក្រ (កាលវិលតាម) នូវស្នាមជើង (នៃគោពលិព័ទ្ធ)
កាលនាំទៅ (នូវទឹម)" ។ (គតិនេះនៅចាំបែកសេចក្តីរបស់
វិសជ្ជនា) "អត្ថោ រីសេចក្តី ធុរេ យុត្តស្ស ។ បេ ។ ចក្កំ
វិយ ឥតិ ថា ... ដូច្នេះ ... គាថាបាទស្ស នៃបាទ

www.budinst.gov.kh www.elibraryofcambodia.org

នៃគាថា បក្កំ វេហគោ បចំ អតិ ថា... ដូចខ្ទះ, ធុរេ យុត្តស្ស ។ បេ ។ (អនុគច្ឆតិ) បក្កំ វិយ ដូចជាចក្រ (កាលវិលទៅតាម) នូវស្នាមជើង នៃគោពលិវ័ទ្ទ ដែលគេទឹមហើយក្នុងនឹម កាលនាំទៅ នូវនឹម" ។

នេះបំបែកសេចក្ដីរបស់ប្រយោគវិសជ្ជនា ដែលជាបទពាក់, បទពាក់នោះ ត្រូវចូលពីរលើក: លើកដំបូង ចូលនឹងប្រយោគវិសជ្ជនា, លើកទី ២ ចូលនឹងបទ អត្ថា ដែលបំបែកសេចក្ដីនៃវិសជ្ជនា (ធ,ក, ១ ទំព័រ ៣៤) ។

៣- អដ្ឋកថាណា លោកមិនមានបំណងនឹងដែកសព្ទឬដែកសេចក្ដីនៃរឿងដទៃទេ លោកប្រាថ្នានឹងដែកទៅតាមសេចក្ដីរបស់គាថាដែលមានប៉ុណ្ណោះ បើទុកជានិយាយដល់ពាក្យដទៃខ្លះក៏ជាពាក្យដែលជាប់ទាក់ទងគ្នានឹងសេចក្ដីរបស់គាថា បើមិននាំមកនិយាយផងទេ សេចក្ដីក៏មិនភ្លឺច្បាស់, អដ្ឋកថានោះលោករៀន**ពស្សន្តោ** ទុកក្នុងខាងដើម ដើម្បីជាគ្រឿង

www.budinst.gov.kh www.elibraryofcambodia.org

សង្កេតនៃគាថាសង្ខេបនេះ, **អត្ថោ** ដែលជាបទនឹង **ពស្ស** នោះ គប្បីប្រែថា «**សេចក្តី**» ដូចទី២ដែរ ផ្សេងគ្នាតែទីនេះប្រែជាកម្ម-វាចកៈគឺត្រូវបញ្ចូល បណ្ឌិតេន.. វេទិតព្វោ ... ឬមយាវុត្តេ ជំនួសបណ្ឌិតេន វេទិតព្វោ ក៏បាន, បើមិនបញ្ចូល បណ្ឌិតេន វេទិតព្វោ ឬ មយា វុត្តេ ណាមួយទេ ទុកជាខុសអំពីគោល ដែលលោកនិយមប្រើ. ចូរមើលឧទាហរណ៍ ក្នុងទី ៣ នៃ គោលប្រែពួកទី ១ នោះចុះ ។

៤—អដ្ឋកថាណា លោកលើកយកបទនៃគាថាមកតាំងមួយបទ១ឬច្រើនបទឬក៏តាំងជាបាទគាថា ហើយតែបញ្ចេញទៅរៀងរហូតចប់គាថាមួយ ៗ កាលចប់គាថាមួយហើយ ក៏ផ្តើមអធិប្បាយសេចក្តីរបស់គាថានោះ ថែមមួយលើកទៀត ដើម្បីធ្វើសេចក្តីឲ្យប្រាកដច្បាស់ឡើងជាដើម, **អត្ថោ** ដែលយកទៅប្រើ ក្នុងអដ្ឋកថានោះគប្បីប្រែថា «**អត្ថាធិប្បាយ**» ។ តែវិធីប្រែ

www.budinst.gov.kh www.elibraryofcambodia.org

បទតាំង មិនបានប្រើបទ, បានបុគាថា សព្វ ប្រកបឆដ្ឋីវិភត្តិ ដូចន័យទី ១.២.៣ ទេ ត្រូវប្រកបសត្តមីវិភត្តិវិញ ចូរមើលឧទាហរណ៍ក្នុងទី ៤ នៃគោលប្រពួកទី១ ។ មួយទៀត ត្រូវបញ្ចូល បណ្ឌិតេន វេទិតព្វោ ឬ មយា វុត្តេ ដូចពោលហើយក្នុងទី៣ ។

៥_ អដ្ឋកថាណា លោកតាំងបទកែមកច្រើនហើយ ប៉ុន្តែមានបទខ្លះ ឬសេចក្ដីក្នុងសន្លឹកខ្លះដែលកែមកហើយនោះនៅមានសេចក្ដីខ្លះខាតឬសេចក្ដីនៅកំបាំងជ្រាលជ្រៅ លោកក៏ប្រើអធិប្បាយចំពោះបទឬសេចក្ដីនៃសន្លឹកនោះថែមទៀត; **អត្ថោ** ដែលយកទៅប្រើក្នុងអដ្ឋកថានោះ គប្បីប្រែថា «**អធិប្បាយ**» ន័យនេះ មិនមានបទតាំងឡើយ ។ ឯបទឬសន្លឹកដែលអធិ-ប្បាយនោះប្រហែលៗ គ្នានឹងបទឬសន្លឹកដែលកែ ហេតុនោះ អ្នករៀនត្រូវសង្កេតឲ្យចូនគំនិត ទើបដឹងថាជាអធិប្បាយឬកែ ។ ឧទាហរណ៍ដូច្នេះ **សារម្ភោ តេ ន ទិដ្ឋិគតិកៈ ឯទំសន្តេ**

www.budinst.gov.kh www.elibraryofcambodia.org

បន តេ "ត្វំ ទុស្សីលោតិ "តុម្ហេ ទុស្សីលាតិ ឯវមាទិកោ ឧត្តរិករណវាចាលក្ខណោ សារម្ភោបិ ន វិជ្ជតិ, ន ភវិស្សតិយេវាតិ អត្ថោ (ប្រែ) "អត្ថោ ថែអត្ថ ឯវំ សេចក្តី។បេ។ ន វិជ្ជតិ" (ឥតិ) ថា . . . ដូច្នេះ គាថាបាទស្រៃ. . . . សារម្ភោ តេ ន វិជ្ជតិ ឥតិ ថា.. ដូច្នេះ, បទ ក៏ ឯវំ-ការណេ នាកាលហេតុយ៉ាងនេះសេចក្តីកាលមាន សារម្ភោ សូម្បី (ក៏ខ:) ប្រព្រឹត្តទៅមួយអន្លើ ដោយការប្រណាំងប្រជែង ឧត្តរិករណវាចាលក្ខណោ មានវាចាជាគ្រឿងធ្វើឲ្យក្រៃលែង ជាលក្ខណ: ត្វំ ។បេ។ ឯវមាទិកោ មានយ៉ាងនេះជាដើម ថា (ភិក្ខុទាំងឡាយ បានពោលហើយ) ថាអ្នកទ្រុស្តសីល (ចំណែកអ្នកពោល) ថាអ្នកទាំងឡាយក៏ទ្រុស្តសីល ន វិជ្ជតិ មិនមែនមាន តេ ដល់អ្នក, អត្ថោ ថែអដ-ប្បាយ "ន ភវិស្សតិយេវ ឥតិ ថា ... ដូច្នេះ, (តេ) ន ភវិស្សតិ ឯវ មិនមែនមាន (ដល់អ្នក) ឡើយ" (ធ.ក. ៥ទំព័រ៨៣) ។

២–បទ បុរេសេចក្ដី ក្នុងសង្កាត់នៃអដ្ឋកថា ដែលលោកពណ៌នាច្រើនៗទៅ មិនមានដើមអត្ថ តែសេចក្ដីដែលពណ៌នាទៅនោះ ក្នុងទីបំផុត គឺសរុបចុះក្នុងបទនោះឯង, កាលបើយ៉ាងនេះ បទតាំង ត្រូវប្រើ បទ បណ្ឌិតេន វេទិតព្វំ (ឬមយា វុច្ចតេ) ឧទាហរណ៍ដូច្នេះ **និគ្គយ្ហវាទីន្តិ ឯកច្ចោ ហិ ។បេ។ អយំ និគ្គយ្ហវាទី នាម សេយ្យថាបិ សម្មាសម្ពុទ្ធោ** (ប្រែ) ៖ បទ ថែម និគ្គយ្ហវាទី គត់ថា ... ដូច្នេះ បណ្ឌិតេន គឺ ... វេទិតព្វំ គប្បី ... (ឬមយា គឺ ... វុច្ចតេ នឹងពោល), ហិ ក៏ ឯកច្ចោ–គាថាយោ គាថាខ្លះៗទៅ អយំ–គាថាយោ គាថានេះ និគ្គយ្ហវាទីនាម ឈ្មោះថា អ្នកមានកិរិយាពោលសង្កត់សង្កិនជាប្រក្រតី សេយ្យ-ថាបិ សម្មាសម្ពុទ្ធោ ដូចជាព្រះសម្មាសម្ពុទ្ធ»(ធ.ក.៤ទំព័រ២)។

សង្កេតគោលប្រែពួកទី២

១–គាថាមានច្រើន កប់ត្រឹម ២គាថា ជាដើមឡើង

www.budinst.gov.kh www.elibraryofcambodia.org

ទៅ, ក្នុងគាថាដើម លោកតែយកដោយលំដាប់ហូតដល់ចប់. កាលទឹងតែគាថាតទៅ លោករៀន **ទុតិយគាថាយ** ទុកក្នុងខាងដើម, ឬមានគាថា ទី៣ ទី៤ ទៀត លោករៀន **តតិយគាថាយ ឬ ចតុត្ថគាថាយ** ទុកក្នុងខាងដើមទៀត, បើមិនរៀនទុកទេ លោកក៏តែតទៅហូតដល់ចប់ ។ បើលោករៀនទុក កាលទឹងប្រែ ត្រូវបញ្ចូល អត្ថា “សេចក្តី” បណ្តុំគេទ វេទិតព្វោ (ឬ មយា វុច្ចតេ ក៏បាន) ។ ឧទាហរណ៍មានហើយ ក្នុង ខទី ១ នៃគោលប្រែពួកទី ២ ។

២_ សេចក្តីនៃគាថាខ្លះ នៅកំបិទកំបាំង ដូចបទថា **ឱកមោកតឧព្ភតោ** ដែលប្រែថា “លើកឡើងហើយ ចាកអាល័យគឺទឹក” ពាក្យថា “ចាកអាល័យគឺទឹក” ប្រែចេញអំពីបទ **ឱកមោកតោ** តែបទនេះ កាលបើញែកចេញក៏ជា ២ សព្ទ គឺ **ឱក+ឱក** ប្រែថា “ទឹក+ទឹក” ដូចគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ហេតុដូចម្តេច លោកទើបសំគាល់យកសព្ទ១ថា ទឹក,សព្ទ១ ថា អាល័យ ? តើសំគាល់សេចក្តីផ្សេងគ្នាយ៉ាងណា? ដំណើរនេះ មកពីអដ្ឋកថាចារ្យវិនិច្ឆ័យ នូវសេចក្តីនោះ ឲ្យក្តីគ្រប់ ទៀតឧទាហរណ៍ដូច្នេះ **ឱកមោកតឧព្ភតោតិ "ឱកបុ-ណ្ណេហិ ចីវរេហីតិ ឯត្ថ ឧទកំ ឱកំ, " ឱកំ បហាយ អនិកេតសារីតិ ឯត្ថ អាលយោ, ឥធ ឧភយំបិ លព្ភតិ** (ប្រែ) "វិនិច្ឆយោ វិនិច្ឆ័យ ឥធ បទេ ក្នុងបទនេះ ឱកមោកតឧព្ភតោ ឥតិ ថា ... ដូច្នេះ បណ្ឌិតេន គឺ ... វេទិតព្វោ គប្បី ... (ឬ មយា ខ្ញុំគេ)។ ឧទកំ ទឹក ឱកំ ឈ្មោះថា ឱកៈ ឯត្ថ-បរយោគេ (ឬ ឧទា-ហរណ៍) ក្នុង... ឱកបុណ្ណេហិ ចីវរេហិ(១)ឥតិ ថា,:, ដូច្នេះ

---

១ ត្រូវបញ្ចូលដូច្នេះ គិត្តិ... បាបេយ្យកា អ្នកនៅក្នុងដែន ឈ្មោះ បាបេយ្យកៈ ចីវរេហិ មានចីវរទ. ឱកបុណ្ណេហិ ទទឹកហើយដោយទឹក អាគច្ឆិសុ មកហើយ សាវត្ថី កាន់ក្រុងសាវត្ថី គតវន្តំ ទស្សនត្ថាយ ដើម្បីប្រយោជន៍ដល់ការគាល់នូវព្រះមានព្រះភាគ ។

អាលយោ ក៏អាល័យ ឱកំ ឈ្មោះថា ឱក: ឯត្ថ-បយោគ (ឬ ឧទាហរណ៍) ក្នុង ... ឱកំ បហាយ អនិកេតសារី(១) ផង ថា . . . ដូច្នេះ, ឧកយំច-អាលយោ ឱកំ ក៏អាល័យមិនទីក ទាំងពីរ បណ្ឌិតគេ គឺ . . . លក្ខតិ រមែងបាន ផង ‹‹ឱក-មោកតឧក្កតោ›› ផង បទ ក្នុងបទថា ឱកមោកតឧក្កតោ នេះ›› (ធ.ក. ២ ទំព័រ ១៩៧) ។

៣–អដ្ឋកថាណា លោកបានកែដោយរូបវិគ្រោះ, អដ្ឋ-កថានោះ គប្បីប្រើ **វិគ្គហោ** ដែលប្រែថា ‹‹**វិគ្រោះ**››, ទាំងបញ្ជូល បណ្ឌិតគេ វេទិតព្វោ ឬ មយា វុត្តេ ក៏បានឧទា-ហរណ៍ដូច្នេះ **ឱហារិនន្តិ: អាកឌ្ឍិត្វា ចតូសុ អបា–យេសុ បាតនតោ អវហរតិ : ហេដ្ឋា ហរតីតិ ឱហារិនំ** (ប្រែ) ‹‹វិគ្គហោ វិគ្រោះ (ឯត្ថ បទ ក្នុងបទនេះ)

---

១ ត្រូវបញ្ចូលដូច្នេះ មុនិ ... បហាយ លះបង់ហើយ ឱកំ នូវអាល័យ អនិកេតសារី (ហោតិ) រមែងជាអ្នកមិនមានទីនៅត្រាច់ទៅដោយប្រក្រតី ។

www.budinst.gov.kh www.elibraryofcambodia.org

ឧហារិនំ ឥតិ ថា...ដូច្នេះបណ្ឌិតេន គឺ...វេទិតព្វោ គប្បី..(យំ កិលេសពន្ធនំ រីចំណងគឺកិលេសណា)អវហរតិ នាំចុះ អវហ-រតិ គឺថា ហេដ្ឋា ហរតិ, ហរតិ នាំទៅ ហេដ្ឋា ក្នុងខាងក្រោម អាកឌ្ឍិត្វា ចតូសុ អបាយេសុ បាតេនតោ ព្រោះជាគ្រឿងទាញទំលាក់ទៅក្នុងអបាយទាំងឡាយបួន ឥតិ ព្រោះហេតុនោះ (តំ កិលេសពន្ធនំ រីចំណង គឺកិលេសនោះ) ឧហារិនំ ឈ្មោះថានាំទៅក្នុងខាងក្រោម» (ធ.ក. ៨ ទំព័រ ២៨) ។

សង្កេតគោលប្រែពួក ទី ៣

អដ្ឋកថាណា លោកលើកយកបទប្រធានមកតាំង តែចំពោះតែបទប្រធានមួយប៉ុណ្ណោះ, អដ្ឋកថានោះ មិនត្រូវតាំង អត្ថ ត្រូវប្រែតែម្តង, ឥតិ ដែលនៅខាងក្រោយបទតាំងនោះ ត្រូវប្រែថា «**ឈ្មោះថា**» ឧទាហរណ៍ដូច្នេះ **ធម្មាតិ: វេទនាទយោ តយោ ខន្ធា** (ប្រែ) «ខន្ធា រីខន្ធទាំងឡាយ តយោ បី វេទនាទយោ មានវេទនាជាដើម ធម្មា

ឥតិ ឈ្មោះថា ធម៌" (ធ.ក ១ ទំព័រ៥០) ។ សូម្បីវិសេសនៈរបស់បទប្រធានខ្លះ មិនបាច់តាំងអត្ថ ប្រែតាមទំនងនេះក៏បាន ខ្លះដូច **កតបុញ្ញោតិ នានប្បការស្ស បុញ្ញស្ស កត្តា** ប្រែ "កត្តា បុគ្គលអ្នកធ្វើ បុញ្ញស្ស នូវបុណ្យ នានប្ប-ការស្ស មានប្រការផ្សេងៗ កតបុញ្ញោ ឥតិ ឈ្មោះថា អ្នកមានបុណ្យធ្វើហើយ" (ធ.ក. ១ ទំព័រ ១៩៤)។ បើប្រែសិនជាអដ្ឋកថាកែតួប្រធានចេញទៅ មិនចំពោះតែតួប្រធានមួយទេ, ក្នុងទីដូច្នោះ ទើបត្រូវតាំងអត្ថ ។

សង្កេតគោលប្រែពួកទី ៤

១_ប្រែមុនបទកែ "គឺថា" បានដល់បទទៃ គឺបទដែលយោងសេចក្ដីជ្រាលជ្រៅ ឲ្យអណ្ដែតកក់ឡើងៗ ការណ៍ដែលនឹងប្រែទៃនោះ មានន័យដូចអធិប្បាយតទៅនេះ៖

ក) អដ្ឋកថា ដែលលោកលើកបទ ក្នុងគាថាមកវៀនទុកខាងមុខនៃបទកែ ដែលមានសេចក្ដីជ្រះៗ គ្នាតាំងមានវចនៈ

www.budinst.gov.kh www.elibraryofcambodia.org

វិភត្តិ ស្មើគ្នានឹងបទដែលមានក្នុងគាថានោះ, អ្នកប្រែត្រូវប្រែខែបទមុខនោះ ទៅរកបទខាងក្រោយ ដូចជា **សោភតិ : វិរោចតិ** ។ សោភតិ ជាសព្ទដែលលោកលើកមកពីគាថា, វិរោចតិ មិនមានក្នុងគាថាទេ ជាសព្ទខែមកអំពី សោភតិ ដល់វេលាប្រែ ត្រូវប្រែថា សោភតិ រមែងល្អ សោភតិ គឺថា វិរោចតិ ១ រមែងរុងរឿង ។

២) បើបទខែនោះ ជាកិរិយាផ្សេងវាចកៈគ្នា, តួកម្មដែលរៀងទុកនៅខាងមុខនៃកិរិយានោះ ត្រូវទាញចូលមកប្រែគ្រប់កិរិយា ដែលផ្សេងវាចកៈគ្នានោះ ដូច **អត្តនា ច អត្តានំ ចោទយេ សារយេ** ។ ឯ ចោទយេ ជាកិរិយាកត្តុវាចកៈ, សារយេ ជាកិរិយាហេតុកត្តុវាចកៈ កាលបើប្រែ ត្រូវទាញយក អត្តានំ ចូលមកប្រែក្នុងកិរិយាទាំងពីរ ដូច្នេះ ៗ តើ រីអ្នក ចោទយេ ចូរដាស់តឿន អត្តានំ នូវខ្លួន អត្តានំ ចោទយេ គឺថា សារយេ, អត្តានំ ញ៉ាំងខ្លួន សារយេ ចូរឲ្យរលឹក អត្តនា

www.budinst.gov.kh www.elibraryofcambodia.org

ដោយខ្លួនឯង»(ធ.ក.៨ ទំព័រ១១៦) ។ តែបើកិរិយា ជាវាចកៈដូចគ្នា, តួកម្មត្រូវទាញមកប្រែនឹងកិរិយា ខាងក្រោយតែម្ដង ដូច **អត្តានំ សំយមេ គោបយេ** «ត្វំ អ្នក សំយម ចូរសង្រួម សំយម គឺថា គោបយ ។ ចូរឃុំគ្រង អត្តានំ នូវខ្លួន» (ធ.ក.៨ទំព័រ១១៧) ។

គ) វិធីប្រែទនេះ មានពាក្យសម្រាប់ហៅតាមវិធីសម្ពន្ធ គឺបទដែលត្រូវប្រែទ ហៅថា «វិវរណៈ», ឯបទដែលទទួល អំពីបទទៃមក ហៅថា«វិវរណីយៈ» ។ នឹងសម្ពន្ធឧទាហរណ៍ ខាងលើនេះ ទុកជាបែប ; ត្វំ សយកត្តាក្នុង បោធយ ហេតុ-កត្តាក្នុង សាវយ, បោធយ វិវរណៈក្នុងសាវយ ។វិវរណីយៈ របស់ បោធយ, បោធយ ការិតបទ កត្តុវាចកៈរបស់ ត្វំ សាវយ ការិតបទ ហេតុកត្តុវាចកៈរបស់ ត្វំ, អត្តនា ករណៈ ក្នុង បោធយ ក្នុង សាវយ, វិ.សព្វ អវធារណៈក្នុង អត្តនា អត្តានំ អវុត្តកម្មៈក្នុងបោធយ ការិតកម្មៈក្នុងសាវយ ។ នេះវាចកៈ

www.budinst.gov.kh www.elibraryofcambodia.org

ខុសគ្នា ៗ បើវាចកៈ ត្រូវគ្នាវិញ ត្រូវសម្ពន្ធមេគ្នាតែម្តង : ត្វំ សយកត្តាក្នុង សំយម គោបយ, សំយម វិវរណៈក្នុងគោបយៗ វិវរណីយៈ របស់ សំយម, សំយម ក្តី គោបយ ក្តីអាខ្យាតបទ កត្តុវាចកៈ របស់ ត្វំ, អត្តានំ អវុត្តកម្មៈក្នុង សំយម គោបយ ៗ

២– ប្រែក្រោយបទកែ «**ឈ្មោះថា ឲ្យឈ្មោះថា**» បានដល់ ប្រែដកហេតុ និង ប្រែកល់ហេតុ ៗ វិធីនេះ មានន័យដូចអធិប្បាយតទៅនេះ៖

ប្រែដកហេតុ, បទដែលមានក្នុងគាថា លោករៀងទុកក្នុងខាងក្រោយនៃបទកែ ដូច **ជនានំ ពាលានំ** ជាដើម: ពាលានំ មានក្នុងគាថាដែលហៅថាតួបាលី, ជនានំ មិនមានក្នុងគាថា ហៅថាបទកែ, បើប្រែ ជនានំ មុន, ពាលានំ ដែលប្រែក្រោយ ហៅថា ប្រែដកហេតុ, ត្រូវបន្ថែមពាក្យថា «ឈ្មោះថា» ដូចនេះ : **ជនានំ** នៃជនទាំងឡាយ **ពាលានំ** ឈ្មោះថានៃបុគ្គលពាលទាំងឡាយ ៗ បើប្រែនេះត្រឡប់មករក

www.budinst.gov.kh www.elibraryofcambodia.org

បទមុខវិញក៏បាន គឺត្រូវប្រែ ពាលានំ មុន រួចហើយនាំ ពាលានំ ចូលមករក ជនានំ ដូចនេះ : **ពាលានំ** នៃបុគ្គលពាលទ. ពាលានំ គឺជា **ជនានំ ៗ** នៃជនទ. ។

ឧទាហរណ៍ទៀត : **ចាតុម្មាសំ វស្សំ** ប្រែផកហេតុ **ចាតុម្មាសំ** អស់ប្រជុំនៃខែបួន **វស្សំ** ឈ្មោះថាអស់រដូវភ្លៀង ៗ ប្រែថា : **វស្សំ** អស់រដូវភ្លៀង វស្សំ គឺជា**ចាតុម្មាសំ ៗ** របស់ប្រជុំនៃខែបួន ។

មួយទៀត បទកិរិយាអាខ្យាត ដែលមានក្នុងគាថា កាលលោកកែ ច្រើនតែកែជាកិរិយាកិតកៈប្រកប អន្ត មាន-បច្ច័យ អ្នកសិក្សាចូរសង្កេតឲ្យល្អ, បើឃើញមានបទកិរិយា ខាងមុខ ប្រកប អន្ត ឬ មាន-បច្ច័យ ទាំងពីរនេះ បច្ច័យតួណាមួយ, ហើយបទកិរិយាខាងក្រោយ ជាកិរិយាអាខ្យាត ដែលលោកលើកមកអំពីគាថាពិត ៗ , បទកិរិយាខាងក្រោយនោះ ត្រូវប្រែផកហេតុថា "ឈ្មោះថា" ដូច **សោចិ បុរិមកុច្ចរិតា-**

www.budinst.gov.kh www.elibraryofcambodia.org

នុគតេន និព្វត្តំ ទុក្ខំ អនុគច្ឆមានោ បាបំ បស្សតិ (ប្រែ) “សោបិគេ្ហា រីឯបុគ្គលល្អនោះ អនុគមានោ កាល នៃ ទុក្ខំ នូវទុក្ខ និព្វត្តំ ដែលកើតហើយ បុរិមទុច្ចរិតានុគតេន ដោយអានុភាពនៃទុច្ចរិត មានក្នុងកាលមុន បស្សតិ ឈ្មោះថា ឃើញ បាបំ នូវបាប ។ **អថ ទិដ្ឋធម្មេ លាភសក្ការទិសុខំ សម្បរាយេ ច ទិព្វសម្បត្តិសុខំ អនុគច្ឆមានោ សោ ភទ្រោ ភទ្រានិយេវ បស្សតិ** (ប្រែ) “អថ ក្នុងកាលនោះ ភទ្រោ វិបុគ្គលល្អ សោ នោះ អនុគមានោ កាលទទួល ទិដ្ឋធម្មេ លាភសក្ការាទិសុខំ ច នូវសេចក្តីសុខមាននសេចក្តីសុខដែលកើតអំពីលាភនិងសក្ការៈជាដើមក្នុងបច្ចុប្បន្នក្តី សម្បរាយេ ទិព្វសម្បត្តិសុខំ ច នូវសេចក្តីសុខដែលកើតអំពីទិព្វសម្បត្តិក្នុងបរលោកក្តី បស្សតិ ឈ្មោះថាឃើញ ភទ្រានិ ឯវ នូវសេចក្តីចំរើនទ. មែនពិត» (ធ.ក.៥ ទំព័រ ២១) ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រែកល់ហេតុ អ្នកសិក្សាគប្បីកំណត់គោលយ៉ាងនេះ៖ បើបទនាម, គុណបទ ដែលលោកលើកអំពីគាថា មករៀងទុក នៅខាងក្រោយបទកែ, ឯបទកែនោះ លោកប្រែកបតតិយាវិភត្តិ ឬ បញ្ចមីវិភត្តិ ដែលត្រូវប្រែថា “ ព្រោះ ” ឬ “ហេតុ” ដើម្បីប្រាប់ហេតុផលរបស់បទ ដែលលើកអំពីគាថាមកនោះ, កាលបើព្រមដោយអត្ថនេះ បទដែលមានក្នុងគាថាត្រូវប្រែកល់ហេតុ ថា “ឈ្មោះថា” ដូច **ឧបដ្ឋិតស្សតិកាយ ហិ អប្បមត្តោ ឈាយន្តោ បុគ្គលោ** (ប្រែ) “ ហិ ក៏ បុគ្គលោ រីបុគ្គល ឈាយន្តោ កាលពិនិត្យ អប្បមត្តោ ឈ្មោះថាអ្នកមិនប្រមាទ ឧបដ្ឋិតស្សតិកាយ ព្រោះការៈ(នៃគាត់)ជាអ្នកមានស្មារតីតំកល់មាំហើយ» (ធ.ក. ២១ទំព័រ១៥៤) ។ **តិស្សន្នំ វា អដ្ឋន្នំ វា វិជ្ជានំ បញ្ចទសន្នញ្ច ចរណានំ សម្បត្តិយា សម្បន្នវិជ្ជាចរណា ឧបដ្ឋិតស្សតិកាយ បដិស្សតា ហុ-**

ត្វា ឥទំ អនប្បកំ វត្ថុកាមំ បជហិស្សថ

(ប្រែ) "តុម្ហេ អ្នកទាំងឡាយ តិស្សន្នំ ក៏ អដ្ឋន្នំ ក៏ វិជ្ជានំ ច បញ្ចទសន្នំ ចរណានំ ច សម្បត្តិយា សម្បន្នវិជ្ជាចរណា ឧបដ្ឋិតស្សតិកាយ បជិស្សតា ហុត្វា ឈ្មោះថាជាអ្នកមានវិជ្ជានិងចរណៈសម្រេចហើយ ព្រោះកិរិយាសម្រេចនូវវិជ្ជា ៣ ឬ ឬ ៨ ផង នូវចរណៈ ១៥ ផង ឈ្មោះថាជាអ្នកលើកចំពោះ ព្រោះការ:(នៃអ្នកទាំងឡាយ)ជាអ្នកមានស្មារតីតាំងកល់មាំហើយ បជហិស្សថ នឹងលះបង់ វត្ថុកាមំ នូវវត្ថុកាម អនប្បកំ មានប្រមាណមិនតិចទេ ឥទំ នេះ" (ធ.ក. ៤ទំព័រ ១២២) ។

វិធីប្រែជកៈហេតុ និងប្រែកល់ហេតុនេះ មិនមានពាក្យហៅដោយនូវសម្ពន្ធទេ ត្រូវហៅតាមសម្ពន្ធជម្មតា គឺ បើបទនាមនាម ហៅតាមអត្ថរបស់វិភត្តិនាម. បើគុណនាម ហៅថាវិសេសនៈ ឬ វិកតិកត្តា, បើជាកិរិយា ហៅថា អាខ្យាត-

www.budinst.gov.kh www.elibraryofcambodia.org

បទ ឬ គំតបទ ដូចបទដែលលើកមកជាឧទាហរណ៍នេះ គឺ ត្រង់បទថា អប្បមត្តោ ហៅថា វិសេសនៈរបស់ បុគ្គលោ, សម្បន្នវិជ្ជាចរណោ នឹង បជស្សតោ ហៅថា វិកតិកត្តាក្នុងហេតុ, បស្សតិ នឹង បជហិស្សថ ហៅថា អាខ្យាតបទ កត្តុវាចកៈ . . . ។

១៥_ វិធីប្រែអដ្ឋកថាពិសេស

វិធីនេះឯង ចំក្តីក្នុងការប្រែអដ្ឋកថាដែរ តែនិយាយចំ-ពោះត្រង់សេចក្តីពិសេសសល់ ដែលក្នុងវិធីគោលប្រែអដ្ឋ-កថា មិនបាននិយាយដល់ ។

១-បើយកនិបាតមកតាំង ហើយមានពាក្យថា **និបាតោ** នៅទីបំផុតរបស់បទនោះ, កាលនឹងប្រែ ត្រូវបំពេញពាក្យថាបទំ ឬ សទ្ទោ តភ្ជាប់នឹង ឥតិ ត្រង់ចុងនៃបទដែលលើកមកតាំង ហើយបំពេញ វត្តតិ ឥតិ និបាតោ ដូច **យាវទេវាតិ អវធិបរិច្ឆេទនត្ថេ និបាតោ** (ប្រែ) “បទំ ថា

(ឬ សទ្ទោ វែសទ្ទ) យាវទេវ អត្ថ ថា...ដូច្នេះ និបាតោ ជា និបាត វត្តតិ ប្រព្រឹត្តទៅ អវធិបរិច្ឆេទនត្ថេ ក្នុងអត្ថថាជា គ្រឿងកំណត់កាត់នូវខែត្រដែន,, (ធ.ភ. ៣ ទំព័រ ២៧០) ។

២–តាំងអត្ថរួចហើយ បើបទនៃកមាននិបាតសព្ទ, ប្រែនិបាតស្រេចហើយ ត្រូវប្រែតួប្រធាន. បើមិនមាននិបាតទេ ប្រែប៉ុនបទនៃកក៏បាន ។ មាននិបាត ដូច **អប្បមត្តា ន មីយន្តិ សតិយា សមន្នាគតា ហិ អប្បមត្តា** (ប្រែ) "ហិ ក៏ (ផង រី . . .) សមន្នាគតា ប្រកបព្រមហើយ សតិយា ដោយសតិ អប្បមត្តា ឈ្មោះថាមិនប្រមាទហើយ (ធ.ភ. ២ ទំព័រ ១១៦) ។ មិនមាននិបាត ដូច **សុចិកម្មស្សាតិ និទ្ទោសេហិ និរបរាធេហិ កាយកម្មាទីហិ សមន្នាគតស្ស** (ប្រែ) "សមន្នាគតស្ស អ្នកប្រកបព្រមហើយ កាយកម្មាទីហិ ដោយកម្ម. មានកាយកម្មជាដើម និទ្ទោសេហិ ដែលឥតទោស និទ្ទោសេហិ គឺថា

www.budinst.gov.kh www.elibraryofcambodia.org

ទិវេចកទេហិ ៗ ដែលឥតកំហុស» (ធ.ក ២ ទំព័រ១២៧) ។

៣—បើលោកលើកបទ ក្នុងគាថាមកតាំង, ក្នុងទីបំផុតនៃបទនៃ មានពាក្យថា **ឥទំ** ឬ **ឯតំ នាមំ** ឬក៏ **ឯតំ**.. **អធិវចនំ**, ក្នុងទីដូច្នេះ មិនត្រូវតាំងអត្ថ, ឥទំ ឬ ឯតំ ក្នុងបទនៃនោះ ត្រូវយោគ បទ ឬវចនំ ចូលមក ដូច **មុច្ឆន្តិ បញ្ញាយេតំ នាមំ** (ប្រែ) «ឯតំ-បទ នី... មុច្ឆន្តិ ឥតិ ថាក្បាលដូច្នេះ នាម ជាឈ្មោះ បញ្ញាយ នៃប្រាជ្ញា» (ធ.ក. ៣ ទំព័រ២៧០) ។ **បោសស្សាតិ ឥទម្បិ អបរេនាការេន សត្តាធិវចនមេវ** (ប្រែ) «ឥទំបិ-បទ គឺបទនេះ បោសស្ស ឥតិ ថា បោសស្ស ដូច្នេះ អបរេន អាការេន សត្តាធិវចនំ ឯវ ជាឈ្មោះរបស់សត្វ ដោយអាការដទៃមែនពិត (ធ.ក. ១ ទំព័រ ៤៩) ។

៤—អដ្ឋកថាណា លោកលើកបទក្នុងគាថាមកតាំងត្រឹមតែ១ បទឬ ២បទ, ដល់លោកកែចេញទៅ តែដោយតាំងបទដែលមិនបានលើកមកតាំងដូច **គន្ធ មូលេតិ (យស្ស**

www.budinst.gov.kh www.elibraryofcambodia.org

រុក្ខស្ស) ចតូសុ ទិសាសុ ។បេ។ និព្វត្តតិ យេនាតិ អង្គោ,អដ្ឋកថានេះ លោកលើកតែ **មូលេ** មួយបទមកតាំង, កាលបើដូច្នេះពីពិ-សព្ទ ដែលរៀនទុកក្នុងទីបំផុតបទតាំង ត្រូវប្រែជាកាឡត្ថៈថា "អគ្គោ ពីអគ្គ យស្ស រុក្ខស្ស ។ បេ ។ និព្វត្តតិ យេន ឥតិ ថា ... ដូច្នេះ គត្ថ បទេសុ ដំនុំបទតាំងឡាយនោះ (បទស្ស ខៃបទ) មូលេ ឥតិ . . . ថាដូច្នេះជាដើម (ជ.ក. ៨ ទំព័រ១៥) ។

៥–បើអដ្ឋកថាដែលលោករៀន **ឥមំ វុត្តំ ហោតិ** នៅខាងដើមនៃបទដែលលោកអធិប្បាយ ក្នុងវេលាប្រែបទថាឥទំនោះ ត្រូវយោគ អត្ថរូបំ "រូបនៃសេចក្តី" ឬ វចនំ "ពាក្យ" ដូចជា **ឥទំ វុត្តំ ហោតិ យថា មហន្តោ ។បេ។ បាបានិ បរិវជ្ជេយ្យាតិ** (ប្រែ) " ឥទំ អត្ថរូបំ រូបនៃសេចក្តីនេះ យថា មហន្តោ" ។ បេ ។ បរិវជ្ជេយ្យ ឥតិ ថា . . . ដូច្នេះ វុត្តំ ហោតិ ជាពាក្យអធិប្បាយ(គឺព្រះមានព្រះ

www.budinst.gov.kh www.elibraryofcambodia.org

កាត) ទ្រង់ត្រាស់ហើយ» (ធ.ក.៥ ទំព័រ ៣៣) ។

២០– វិធីប្រែប្រយោគបុច្ឆា
ប្រយោគ យថា កឹ

ប្រយោគនេះ មានវិធីប្រែ ៧ យ៉ាង គឺ

១– បុច្ឆា វីពាក្យសួរ យថា កឹ ឥតិ ថា ... ដូច្នេះ, កឹ-ការណំ វីហេតុដូចម្តេច យថា– គប្បការទិសទ្ទំ ជាឧទាហរ-ណ៍ជាគ្រឿងសំដែងចេញ ដោយប្រការណា នូវប្រការនោះៗ

២–បុច្ឆាវី ... យថា កឹ ឥតិ ថា ... ដូច្នេះ, យថា គាថា គឺថាទុច្ចរិតគាថា កំ បុគ្គលំ ទុក្ខមេត្តិ គប្បការទិ-ទសទ្ទំ វីឧទាហរណ៍ជាគ្រឿងសំដែងចេញ=វីទុក្ខកើតទៅតាម នូវបុគ្គលនោះ ព្រោះទុច្ចរិតមាន ៣ ប្រការនោះ ដោយប្រការណា=នូវប្រការនោះ គឺ ដូចអ្វី ។ (វិធីប្រែទាំង ២ បែបនេះ ប្រយោគក្រោយ ត្រូវមាន វិសជ្ជនា) ។

www.budinst.gov.kh www.elibraryofcambodia.org

៣–សត្ថា...បុច្ឆាយ នាកាលពាក្យសួរ យថា កឹ ឥតិ ថា...ដូច្នេះ សតិ កាលមាន គាហ ពោលហើយ ចក្កំ វេហគោ ចំ ឥតិ ថា...ដូច្នេះ អនុយោគំ បរិហារិតុំ ដើម្បីឆ្លើយតប នូវពាក្យជាគ្រឿងសាកសួរ ។

៤–សត្ថា...យថា កឹ ឥតិ ចោទនំ បរិហារិតុកាមោ មានបំណងដើម្បីដោះស្រាយ នូវពាក្យចោទន៍ថា...ដូច្នេះ គាហ ពោលហើយ ចក្កំ វេហគោ ចំ ឥតិ ថា...ដូច្នេះ ។

៥–សត្ថា...គាហ ពោលហើយ ចក្កំ វេហគោ ចំ ឥតិ ថា...ដូច្នេះ បរិហារិតុំ ដើម្បីដោះ ចោទនំ នូវ... យថា កឹ ឥតិ ថា...ដូច្នេះ ។

៦–សត្ថា...អភាសិ បានផ្ញើហើយ ឧបមំ នូវពាក្យឧបមា ចក្កំ វេហគោ ចំ ឥតិ ថា...ដូច្នេះ បរិហា-រិតុំ ដើម្បីការពារ ចោទនំ នូវ...យថា កឹ ឥតិ ថា.. ដូច្នេះ ។ (ពីទី ៣ ដល់ទី ៦ ប្រែ យថា កឹ ដូចទី ១-២) ។

www.budinst.gov.kh www.elibraryofcambodia.org

៧– ចូរមើលវិធីសង្កេតគោលប្រែអដ្ឋកថា ត្រង់ទី ២ នៃពួកទី ១ ។

(បាលីដែលមានដឹកបន្ទាត់ពីក្រោម គឺជាកន្លែងសម្រាប់បញ្ចូលតាមបទគាថា ដែលលោកលើកមកតាំងទុក នៅមុខប្រយោគ យថា កឹ ក្នុងទីតាំងពួង, ដល់វេលាប្រែ ត្រូវប្រែតាមលំនាំគាថានោះ ។) ។

តអំពីនេះទៅ ត្រូវបំបែកសេចក្តី របស់វិសជ្ជនានោះ,ត្រង់បទថា **ចក្កំវ វហតោ បទន្តិ ធុរេ យុត្តស្ស ។បេ។ ចក្កំ វិយ** ត្រូវប្រើ សព្ទ ដែលប្រែថា "សេចក្តី" គប្បីមើលក្នុងវិធីសង្កេតគោលប្រែអដ្ឋកថា ត្រង់ទី ២ នៃពួកទី ១ ។

ប្រយោគ យថា កឹ វិយ

យថា កឹ វិយាតិ ។ ផលមិច្ឆំវ វនស្មឹ វានរោតិ យថា រុក្ខផលំ ។បេ។ ធាវតិ (ធ.ក.៨ ទំព័រ ៩) ។

ប្រយោគនេះ វិធីប្រែដូចប្រយោគ យថា កឹ តាំងពីទី ២ ចុះមក

www.budinst.gov.kh www.elibraryofcambodia.org

ដែរ ប្លែកតែត្រង់បទដែលបញ្ចូលប៉ុណ្ណោះ ព្រោះបទដែលបញ្ចូលមកនោះ ត្រូវនិយមទៅតាមសេចក្តី ក្នុងទីនោះៗ ទាំងប្រែទុកជាគំរូ ដើម្បីធៀបនឹងប្រយោគ យថា កឹ ដូចតទៅនេះ៖

ពុច្ឆា វិពុច្ឆា យថា កឹ វិយ ឥតិ វា . . . ដូច្នេះ, យថា សោ កវេ កវេ បរិច្ចតេ គឺនិទស្សនំ ឧទាហរណ៍ជាគ្រឿងសំដែងចេញ ខូវ=បុគ្គលអ្នកលុះក្នុងតណ្ហានោះ រមែងស្ទុះទៅក្នុងភពទាំងពួង ដោយប្រការណា=ប្រការនោះ កឹ វិយ ដូចជាអ្វី ៗ វិសជ្ជនា ... ផលមិច្ឆំ កនេក ឥតិ វា ... ដូច្នេះ ។ នេះប្រែតាមបែប យថា កឹ ត្រង់ទី២, ចំណែកទី ៣-៤-៥-៦ អ្នករៀនចូរហាត់ប្រែដោយខ្លួនឯងផងចុះ ។

ប្រយោគ កឹ វិយ

កឹ និយាតិ ។ ឧសីរត្ថោ ច វីរណានិ យថា ឧសីរេន ។បេ។ ខនថាតិ អត្ថោ (ជ.ក. ៥ ទំព័រ ១១) ។ ប្រយោគនេះ វិធីប្រែខានពុច្ឆាបានឡើយ ដូចប្រ-

www.budinst.gov.kh www.elibraryofcambodia.org

យោគ យថា កឹ, ថ្វីកតែប្រែតួសព្ទ កឹ វិយ ព្រោះ កឹ វិយ នឹងប្រែប្រយោគ ការណ៍ ឬ កញ្ញការនិងសន្រ្ទំ មិនបានទេ, ត្រូវស្រង់យកប្រយោគខាងដើម នៃប្រយោគ កឹ វិយ មកប្រកបប្រែទើបបាន ។ នឹងប្រែតាមបែប យថា កឹ ត្រង់ទី ៧

ទុកជាទីសង្កេត៖

បុត្តា រ៉ . . . កឹ វិយ ឥតិ ថា . . . ដូចេ្នះ (ស្រង់យកប្រយោគមុខមកបំពេញប្រែ) ឥមិស្សា ឆទ្វារិកតណ្ហាយ អរហត្តមគ្គញាណេន មូលំ ខនថ " (វិសុទ.) ចូរដក នូវឬស នៃតណ្ហា ដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ នេះ ដោយអរហត្តមគ្គញាណ កឹ វិយ ដូចជាអ្វី" ។ វិសជ្ជនំ រ៉ . . . ឧសីរត្ថោ វីរណំ ឥតិ ថា . . ដូចេ្នះ ។

ប្រយោគ យថា កឹ ក្តី, យថា កឹ វិយ ក្តី, កឹ វិយ ក្តី (កឹទិសំ ក្តី) បើនឹងប្រែកាត់ឲ្យខ្លី មិនបាច់បញ្ចេញបញ្ចូលច្រើន ដូចវិធីខាងលើនេះក៏បាន តែត្រូវប្រែបែបនេះ៖

www.budinst.gov.kh www.elibraryofcambodia.org

បុច្ឆា រិ ... គឺ វៃយ ឥតិ ជាដូចជាអ្វី ។ វិសជ្ជនា វិវិ-សជ្ជនា ឧស័រក្តោរ វិរណា ឥតិ ជា... ដូច្នេះ ។

◎

◎ ◎

២១– វិធីតែងភាសាបាលី(១)

ការត្រឡប់ភាសាខ្មែរជាភាសាបាលី រមែងជាកិច្ចធ្វើឲ្យលំបាកចិត្ត នៃអ្នកសិក្សាដំបូងមិនមែនតិចឡើយ ព្រោះអ្នកដែលមិនសូវចូលចិត្តលក្ខណៈរបស់ប្រយោគ រមែងមិនទុកចិត្តថាការរៀន ប្រយោគបែបនេះ តើត្រូវឬខុស, តាំងជាភាសាដែលខ្លួនមិនសូវជំនាញផង ទើបធ្វើឲ្យគប់ប្រមល់ចិត្តៗ ព្រោះហេតុនោះ មុននឹងត្រឡប់ភាសាខ្មែរ ជាភាសាបាលី គប្បីពិនិត្យពិចារណា

១~ បានជាខ្ញុំយកវិធីនេះ មករៀបរៀងទុកក្នុងសៀវភៅនេះផង ដោយយល់ឃើញថា បើកុលបុត្រអ្នកសិក្សាបានចូលចិត្តវិធីតែងភាសាបាលីនេះហើយ ក៏នឹង វៃរកតែក្តីក្នុងវិធីប្រែគម្ពីរឡើងទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យមួយសព្ទ ៗ ហើយគប្បីរកសព្ទក្នុងភាសាបាលី មកធៀប
នឹងភាសាខ្មែរយើង បានដល់សព្ទអ្វី ជាលិង្គ វចនៈ វិភត្តិអ្វី
ហើយគប្បីប្រកបឲ្យត្រឹមត្រូវតាមលិង្គ វចនៈ វិភត្តិនោះៗ តាម
គោលរបស់វេយ្យាករណ៍ ដូចភាសាខ្មែរយើងថា **សិស្សទាំង
ឡាយ របស់អាចារ្យ** ។ គប្បីពិចារណាមើលចំពោះពាក្យ
ថា **សិស្ស** បានដល់សព្ទបាលីថា យ៉ាងណា, ពាក្យថា **របស់
អាចារ្យ** បានដល់សព្ទបាលីថា យ៉ាងណា, ទាំងពីរសព្ទនោះ
ជាលិង្គ, វចនៈ, វិភត្តិអ្វី ។ **សិស្ស** បានដល់សព្ទបាលីថា
សិស្ស ជាបុំលិង្គ មានពាក្យថា **ទាំងឡាយ** នៅផង ទើប
ដឹងបានថាជាពហុវចនៈ ទាំងជាបឋមាវិភត្តិ ព្រោះជាតួប្រ-
ធាន ។ កាលបើដឹងដូច្នេះហើយ ទើបប្រកប **សិស្ស**-សព្ទ
ឲ្យជាបឋមាវិភត្តិពហុវចនៈ សម្រេចរូបជា **សិស្សា** ។
ពាក្យថា **អាចារ្យ** បានដល់សព្ទបាលីថា **អាចរិយ** ជាបុំលិង្គ

www.budinst.gov.kh www.elibraryofcambodia.org

មិនមានពាក្យថា "ទាំងឡាយ" ទេ ទើបដឹងថាជា ឯកវចនៈ ជាឆដ្ឋីវិភត្តិព្រោះមានពាក្យថា **របស់** ដែលជាសំនៀងកាយ-គន់ប៉ាតរបស់ឆដ្ឋីវិភត្តិឯកវចនៈសម្រេចរូបជា **អាចរិយស្ស** តែវិធីដែលនឹងរៀនសព្វណា ទុកនៅទីណានោះ ចូរអ្នកសិក្សាពិចារណាមើលតាមវិធីដែលខ្ញុំជ្រើសរើសរួបរួមទុកដូចតទៅនេះ ៖

១ – វិធីរៀនភាសាបាលី មិនដូចរៀនភាសាខ្មែរទេ គឺប្រើរៀនត្រឡប់គ្នា ដូចពាក្យខ្មែរថា **សាវ័ក របស់ព្រះពុទ្ធ** ពាក្យបាលីត្រូវរៀនត្រឡប់ថា **ពុទ្ធស្ស សាវកោ របស់ ព្រះពុទ្ធ សាវ័ក** ដូច្នេះវិញ ។

២–គុណនាមរបស់នាមនាមណា ត្រូវមានលិង្គ,វចនៈ, វិភត្តិ ដូចលិង្គ, វចនៈ, វិភត្តិ របស់នាមនាមនោះ ទាំងត្រូវរៀនទុកនៅមុខនាមនាម ដូច **ឧច្ចោ** **រុក្ខោ** "ដើមឈើខ្ពស់,, **ឧច្ចេ** **រុក្ខេ** **សកុណា** " សត្វស្លាបទាំងឡាយ

www.budinst.gov.kh www.elibraryofcambodia.org

លើដើមឈើ ខ្ពស់» **កុសលា ធម្មា**« ធម៌ទ. ជាកុសល»។

៣–កិរិយាកិតក:ដែលមិនមែនអព្យយ: របស់នាមនាមណា ត្រូវមានលិង្គ, វចន:, វិភត្តិ ដូចលិង្គ. វចន:, វិភត្តិ របស់នាមនាមនោះ ដូចគ្នានឹងគុណនាម ដែលសំដែងមកហើយដែរ តែត្រូវរៀនទុកក្រោយនាមនាមដូច **បុត្តោ ជាតោ** «កូន កើតហើយ». **បិតា វុដ្ឋោ**«បិតា ក្រោកហើយ» ។

៤–**ឯក** សព្ទដែលជាសំខ្យា ជាឯកវចន:តែម្យ៉ាង, តាំងពី **ទ្វិ** ហូតដល់ **អដ្ឋារស** ជាពហុវចន:តែម្យ៉ាង, តាំងអំពី **ឯកូនវីសតិ** ដល់ **អដ្ឋនវុតិ** ជាឯកវចន: ឥត្ថីលិង្គតែម្យ៉ាង សូម្បីប្រើចូលនឹងសព្ទដែលជាពហុវចន: លិង្គឯទៀតក៏គង់នៅជាយ៉ាងនោះ មិនបានផ្លាស់លិង្គ, វចន:ទៅតាមនាមនាមនោះទេដូច **ឯកោ ជនោ**«ជន មួយនាក់»**ទ្វេ ជនា**«ជនទ. ពីរនាក់ «**បញ្ចត្តិំសាយ ជនានំ លាភោ ឧប្បន្នោ** «លាភ កើតហើយ ដល់ជនទ. ៣៥នាក់» ។

www.budinst.gov.kh www.elibraryofcambodia.org

៥–បុរិសសព្វនាម បឋមបុរិសៈ ប្រើជំនួសនាមនាមណា ត្រូវមានលិង្គ និង វចនៈ ដូចលិង្គ និង វចនៈ របស់នាមនាមនោះ, ចំណែកវិភត្តិនោះ ដូចគ្នាក៏បាន ផ្សេងគ្នាក៏បាន ដូច **ឯកោ ឧយ្យានេ រុក្ខោ, សោ វាតេន បហតោ, តស្ស បណ្ណានិ បតិតានិ** "ដើមឈើ ក្នុងសួន មួយដើម, វា គឺខ្យល់ បក់ខ្ទប់ហើយ, ស្លឹកទាំងឡាយរបស់វា ជ្រុះហើយ" ។

៦– **តេ, មេ, វោ, នោ** មជ្ឈិមបុរិសៈ និងឧត្តមបុរិសសព្វនាម ត្រូវតែមានបទខាងដើមនាំមុខ ទើបប្រើបានដូច **អាចរិយោ នោ** " អាចារ្យ របស់យើងទ· " **អយន្តេ បត្តោ** "នេះ បាត្រ របស់អ្នក" ។

៧–វិសេសនសព្វនាម របស់នាមនាមណា ត្រូវមានលិង្គ, វចនៈ, វិភត្តិ ដូចលិង្គ វចនៈ, វិភត្តិ របស់នាមនាមនោះ ដូច **យស្មឹ គគចតិ មយំ អភិប្បសន្នា,**

www.budinst.gov.kh www.elibraryofcambodia.org

តំ ភគវន្តំ សរណំ គតា “យើងខ្ញុំ ជ្រះថ្លាក្រៃពេក ហើយ ក្នុងព្រះមានព្រះភាគ អង្គណា,(យើងខ្ញុំ.) ដល់ហើយ នូវព្រះមានព្រះភាគ អង្គនោះ ជាទីពឹង” ។ វិសេសនសព្ទ-នាមនោះ បើមិននិយមតាមនាម គ្រាន់តែនិយមលិង្គនៃនាម-នាមប៉ុណ្ណោះ ហើយមិនបាច់រៀងតាមនាមទុកផងក៏បាន ដូច **យស្ស លាភោ ឧប្បន្នោ, តស្ស អលាភោ ឧប្បន្នោ** “លាភ កើតហើយ ដល់អ្នកណា, ការមិនមាន លាភ កើតហើយ ដល់អ្នកនោះ” ។

៨_ កិរិយាអាខ្យាត របស់នាមនាមក្តី របស់បុរិសសព្ទ-នាមក្តី ត្រូវតែមាន វចនៈ, វិភត្តិ និង បុរិសៈ ដូចវចនៈ, វិភត្តិ និង បុរិសៈ របស់នាមនាម ឬ របស់បុរិសសព្ទនាម នោះ ដូច **ជនោ យាតិ, ជនា យន្តិ; សោ យាតិ, តេ យន្តិ; ត្វំ យាសិ, តុម្ហេ យាថ; អហំ យាមិ, មយំ យាម** ។ កិរិយាអាខ្យាតនេះ

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវរៀងទុក ក្នុងទីបំផុតប្រយោគ ដូចគួយ៉ាងដែលសំដែងមក ហើយ. តែក្នុងទីខ្លះ រៀងទុកនៅមុខប្រយោគ ដូច **សុណាតុ មេ ភន្តេ សង្ឃោ** "បពិត្រលោកដ៏ចំរើន សូមព្រះសង្ឃស្តាប់ (នូវពាក្យ) របស់ខ្ញុំ" ។ វិធីប្រើមជ្ឈិមបុរិសៈ និងឧត្តមបុរិសៈ បើមិនសរសេរតួប្រធានទុកផងក៏បាន តែត្រូវប្រើកិរិយា ឲ្យបានត្រឹមត្រូវតាមវចនៈ និងបុរិសៈ ដូច **កតមស្មឹ អាវាសេ វស្សំ វសិ** "(អ្នក) នៅចាំវស្សា ក្នុងអាវាសណា", **ឧណ្ណាលោមារាមេ វស្សំ វសាមិ** "(ខ្ញុំ) នៅចាំវស្សា ក្នុងវត្តឧណ្ណាលោម" ។

៩_ គុណនាមដែលចូលនឹងកិរិយាថា "មាន, កើត, ជា" គឺបទវិកតិកត្តា ត្រូវរៀងទុកក្រោយនាមនាមដែលជាបទប្រធាន គឺនៅមុខកិរិយាថា "មាន, កើត, ជា" នោះ ដូច **សុគន្ធំ បុប្ផំ សព្វេសំ មនាបំ ហោតិ** "ផ្កាឈើ មានក្លិនក្រអូប ជាទីពេញចិត្ត របស់ជនទ. ទាំង

ពួន » ។ សូម្បីមិនរៀនកិរិយាទុកផង ក៏បាន ដូច **អត្តា ហិ អត្តនោ នាថោ** «ព្រោះថា ខ្លួនឯង ជាទីពឹង របស់ខ្លួន» (នេះមិនរៀន ហោតិ) ។

១០– នាមនាមប្រើជាគុណនាម ត្រូវមានវចនៈនិងវិភត្តិ ដូចនាមនាមដែលជាម្ចាស់របស់ តែលិង្គនោះ គង់នៅតាមទីសព្ទដើមជាលិង្គអ្វី ក៏នៅជាលិង្គនោះ ដូច **ពុទ្ធោ មេ សរណំ វរំ** «ព្រះពុទ្ធ ជាទីពឹង ដ៏ប្រសើរ របស់ខ្ញុំ» ។

១១– កិរិយាកិតកៈ ដែលមិនមែនជាអព្យយៈ បើមាន កិរិយាថា «មាន, កើត, ជា» នៅក្រោយ ចូលនឹង កិរិយាថា «មាន, កើត ជា» នោះ គាប់ប្រើកិរិយាអាខ្យាត ដែលមានន័យដូចគ្នា នឹងកិរិយាកិតកៈនោះ ក៏បានដូចនេះខ្លះ **សេដ្ឋិនោ លាភោ ឧប្បន្នោ ហោតិ** មានសេចក្តី ប៉ុនគ្នានឹង **សេដ្ឋិនោ លាភោ ឧប្បជ្ជតិ** «លាភ កើត ដល់សេដ្ឋី» ។

www.budinst.gov.kh www.elibraryofcambodia.org

១៦ – បើមានសេចក្តី(រឿង)ដទៃដែលជ្រែកចូលមកក្នុងចន្លោះនៃប្រយោគ, នាមនាមដែលជាប្រធាននៃសេចក្តីដែលជ្រែកនោះ ត្រូវប្រើឆដ្ឋីឬសត្តមីវិភត្តិ, កិរិយារបស់នាមនាមបទនោះ ត្រូវប្រើកិរិយាកិតក: ឲ្យមានលិង្គ, វចនៈ, វិភត្តិ ដូចលិង្គ, វចនៈ, វិភត្តិ របស់នាមនាមនោះ, ដែលជ្រែកចូលមកក្នុងទីណា ត្រូវរៀងទុកក្នុងទីនោះ ដូច **សុរិយេ អត្ថង្គតេ, ចន្ទោ ឧគ្គច្ឆតិ** “នាកាលព្រះអាទិត្យ អស្តង្គតហើយ, ព្រះចន្ទ្រ រះឡើង”. **ទារកស្ស រុទន្តស្ស, បិតា បព្វជិ** “នាកាលទារក កំពុងយំ, បិតា បួសហើយ” ។

១៧– ក្នុងសេចក្តីសង្កាត់មួយ បើមានកិរិយាជាប់គ្នាត ៗ មកដោយលំដាប់ជាច្រើន ត្រូវប្រើកិរិយាអាខ្យាតតែបទក្រោយ១បទ, បណ្តាកិរិយាខាងមុខ ប្រើកិរិយាកិតក:ដែលជាអព្យយៈខ្លះ មិនមែនជាអព្យយៈខ្លះ ទាំងអស់, តែដែលប្រើកិរិយាកិតក: ជាអព្យយៈនោះគឺកិរិយាដែលចុះ ត្វា-បច្ច័យ ច្រើន

www.budinst.gov.kh www.elibraryofcambodia.org

ជានិបច្ច័យដទៃ ដូច **សព្វេ សកុណា បុព្វណ្ហេ អត្តនោ កុលាវកា និក្ខមិត្វា សកលំ ទិវសំ ចរិត្វា សាយណ្ហេ បដិនិវត្តន្តិ** "សត្វស្លាបទ. ទាំងពួង ចេញ ហើយ ចាកសំបុក នៃខ្លួន ក្នុងវេលាព្រឹក ត្រាច់ទៅហើយ អស់ថ្ងៃទាំងអស់ ទើបត្រឡប់មកវិញ ក្នុងវេលាសៀល" ។

១៦ សព្ទដែលជាអព្យយៈ គឺនិបាតនិងបច្ច័យ មិនត្រូវ ប្រកបវិភត្តិយ៉ាងណាមួយទេ ត្រូវរៀងតាមរូបសព្ទដើម ដូច នេះ **សចេ បាបំ ន ករេយ្យាសិ, សុខំ លភិស្សសិ** "បើ (ឯង) មិនធ្វើ នូវបាប, (ឯង) នឹងបាន សុខ" ។

១៧— និបាតដើមសេចក្តី ច្រើនរៀងទុកជាសព្ទទី ២ ក្នុងសេចក្តីនោះ ដូច **កុហឹ បន ត្វំ វសសិ** "ចុះឯង នៅ ក្នុងទីណា" ។

១៨-កាលបទៈតាមសំនួនបាលីរៀងទុកជាទី២ក្នុងសេច-ក្តីនោះដូច **សង្ឃំ ភន្តេ ឧបសម្បទំ យាចាមិ** "បពិត្រ

www.budinst.gov.kh www.elibraryofcambodia.org

លោកដ៏ចំរើន (ខ្ញុំ) សូមសុំ នូវឧបសម្បទា នឹងព្រះសង្ឃ» ។ បើមានសព្ទនាម ឬនិបាត ត្រូវរៀងអាលបនៈ ទុកជាទី ៣ ខ្លះ ជាទី ៤ ខ្លះ ដូច **ធម្មំ ហិ វោ ភិក្ខវេ ទេសេស្សាមិ** «ម្នាលភិក្ខុទ. ក៏ តថាគត នឹងសំដែង នូវធម៌ ដល់អ្នកទ »។ **កុ-ហឹ បន ត្វំ អាវុសោ វស្សំ វុត្ថោ** «ម្នាលអ្នកមានអាយុ ចុះអ្នក នៅហើយ ចាំវស្សា ក្នុងទីណា» ។ តាមសំនួនអដ្ឋ-កថា រៀងអាលបនៈទុកខាងដើមខ្លះ ក្នុងទីបំផុតប្រយោគខ្លះ ដូច **ភន្តេ មា មំ នាសេថ** «បពិត្រលោកដ៏ចំរើនទ. (សូមលោកទ.) កុំ ញ៉ាំងខ្ញុំ ឲ្យវិនាស», **ឯវំ ករោហិ មហា-រាជ** «បពិត្រមហារាជ (សូមព្រះអង្គ) ទ្រង់ធ្វើ យ៉ាងនេះ» ។

១២. មា-សព្ទដែលប្រែថា «កុំ» ប្រើបានតែកិរិយា ដែលជាវិភត្តិបញ្ចមី និងអជ្ជតនី ប៉ុណ្ណោះ ប្រើជាមួយនឹងកិរិ-យាដែលជាវិភត្តិដទៃមិនបាន ដូច **មា មំ ភន្តេ នាសេថ** «បពិត្រលោកដ៏ចំរើន (សូមលោកទ.) កុំ ញ៉ាំងខ្ញុំ ឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

វិនាស ”. **មា ឯវំ ករិ** “(ឯង) កុំ ធ្វើ យ៉ាងនេះឡើយ” ។

១៨_ ក្នុងប្រយោគដែលជាពាក្យសួរ បើមាន កឹ-សព្ទ ឬសព្ទដែលផ្លាស់មកអំពី កឹ.សព្ទ ត្រូវរៀងសព្ទនោះទុកមុខ, បើមិនមានទេ ត្រូវរៀងកិរិយាទុកមុខ, **បន** ទុកទី២, តពីនោះប្រធាន ឬសព្ទដែលជាប់នឹងប្រធាន ដូច **កឹ តយា បព្វ-ជិតុំ ន វដ្ដតិ** “ កិរិយាគឺអ្នកបួស មិនគួរឬ ?;” **កច្ចិត្ថ បរិសុទ្ធា** “ (អ្នក)ជាបុគ្គលបរិសុទ្ធ ឬ ?”, **ទិយតិ បន គហបតិ កុលេ ទានំ**“នែគហបតី ចុះ ទាន ក្នុងត្រកូល គឺអ្នកនៅឲ្យ ឬ? ” ។

១៩_ សព្ទណាដែលជាកិរិយាវិសេសនៈ គឺសព្ទសំដែងលក្ខណៈរបស់កិរិយាឲ្យប្លែកចាកប្រក្រតី ប្រើទុតិយាវិភត្តិ ជាវិសេសនៈរបស់កិរិយាណា ត្រូវរៀងទុកនៅមុខកិរិយានោះ ឬមុខបទដទៃដែលជាប់ដោយកិរិយានោះ ដូច **ធម្មចារី សុខំ សេតិ** “អ្នកប្រព្រឹត្តធម៌រមែងដេកជាសុខ ”, **ទុក្ខំ**

www.budinst.gov.kh www.elibraryofcambodia.org

សេតិ បរាជិតោ "*បុគ្គលអ្នកចាញ់ រមែងដេក ជាទុក្ខ*" ។

២០– បើក្នុងប្រយោគមួយ មានសេចក្តីច្រឡូកច្រឡំគ្នា ច្រើនដូចអ្នកសំដែងនិទាន និយាយរឿង ហើយគាំងមនុស្ស ក្នុងនិទានដែលខ្លួននិយាយថា . មនុស្សនោះ និយាយយ៉ាង នេះ, មនុស្សនេះ និយាយយ៉ាងនោះ, ក្នុងទីបំផុតសេចក្តី មួយ ៗ ត្រូវចុះ ឥតិ.សព្ទខាន ដូច្នេះ ៖

ឯកស្មឹ សមយេ ភគវា រាជគហតោ និក្ខមិត្វា ឆ ទិសា នមស្សន្តំ សិង្គាលកំ មាណវំ ទិស្វា ''កិស្ស ត្វំ គហបតិបុត្ត ទិសា នមស្សសី' តិ បុច្ឆិ ។ តំ សុត្វា សិង្គាលកោ មាណវោ ''បិតា មេ ភន្តេ កាលំ ករោន្តោ ឯវំ អវោច ''ទិសា តាត នមស្សេយ្យាសី' តិ, សោ អហំ បិតុ វចនំ ករោន្តោ ទិសា នមស្សាមី' តិ អាហ។

''ក្នុងសម័យមួយ ព្រះមានព្រះភាគ ស្តេចចេញហើយ

www.budinst.gov.kh www.elibraryofcambodia.org

អំពីក្រុងរាជគ្រឹះ ទតឃើញហើយ នូវសិង្គាលកមាណព កំពុងថ្វាយបង្គំ នូវទិសទ.៦ ទើបត្រាស់សួរហើយថា «នែបុត្រនៃគហបតី អ្នកថ្វាយបង្គំ នូវទិសទាំងឡាយ ដើម្បីហេតុអ្វី» ។ សិង្គាលកមាណព ស្តាប់ហើយ នូវពាក្យនោះ ទើបទូលថា «បពិត្រព្រះអង្គដ៏ចំរើន បិតារបស់ខ្ញុំ កាលធ្វើ នូវកាល-កិរិយា បានផ្តាំហើយយ៉ាងនេះថា «នែកូន អ្នកគប្បីថ្វាយបង្គំ នូវទិសទ.» ខ្ញុំព្រះអង្គនោះ គប្បីធ្វើ តាមបណ្តាំ នៃបិតា ទើបថ្វាយបង្គំ នូវទិសទ.» ។

២១ នាមនាមដែលចេញពាកកិរិយា ដូច **ករណំ** «ការធ្វើ» **គមនំ** «ការទៅ» ជាដើម, មានកិរិយាខាងមុខបាន តែត្រូវជាកិរិយា ចុះត្វា-បច្ច័យ ឬបទតតិយាវិភត្តិ បើត្រូវការកត្តាគឺអ្នកធ្វើក៏បាន ដូច **បុញ្ញត្តិកានំ «អយំ នោ អត្ថោ»តិ** <u>**សល្លក្ខេត្វា បុញ្ញករណំ**</u> **ករោ** «ការកំណត់ថា «នេះ ជាប្រយោជន៍ របស់យើង.» ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើ នូវបុណ្យ ជាការ (របស់ជនខ.) អ្នកមានប្រយោជន៍ ដោយបុណ្យ ។

៦២. សត្តកម្ម ចូលនឹងនាម ដែលចេញចាកកិរិយានោះ ត្រូវប្រែឆដ្ឋីវិភត្តិ ជំនួសទុតិយាវិភត្តិ ដូច **បុញ្ញស្ស ករណំ** “ការធ្វើ នូវបុណ្យ ” **អរិយសច្ចានំ ទស្សនំ** “ ការឃើញ នូវអរិយសច្ច.” ។

៦៣. ប្រយោគភាសាបាលី តាមសំនួនក្នុងជាន់ក្រោយៗ ច្រើនកាត់សេចក្តីដែលសំ នឹងប្រយោគដើមៗចេញ បន្សល់ទុកតែពាក្យដែលមិនសំ ដូច **កុតោ អាគច្ឆសិ** “ (ឯង) មក អំពីណា”. **ជនបទតោ ភន្តេ** “អំពីជនបទ លោកដ៏ចំរើន” (កាត់ចោល **អាគច្ឆាមិ** “ខ្ញុំ មក”) ។

៦៤. ពាក្យរបស់អ្នកតូច និយាយទៅរកអ្នកធំ សូម្បីតែមួយនាក់ ត្រូវប្រើមជ្ឈិមបុរិសៈ ពហុវចនៈ ដូច **ខមថ មេ ភន្តេ** “បពិត្រលោកដ៏ចំរើន សូមអត់ទោស ដល់ខ្ញុំ” ។

www.budinst.gov.kh www.elibraryofcambodia.org

២៥ ករណបទៈ ក្នុងភាសាបាលី ក្នុងវេលានិយាយគ្នាច្រើន ប្រើញឹកញាប់ជាងភាសាខ្មែរ, ប្រយោគណាក្នុងភាសាខ្មែរមិនមានករណបទៈ, បើជាភាសាបាលី ត្រូវចុះក្នុងទីដែលគួរចុះៗ

២៦-កិរិយាដែលចុះត្វា បច្ច័យ ប្រើសំគាល់ហេតុក៏បានតែត្រូវបំណងយកតួប្រធាន ផ្សេងអំពីតួប្រធាន របស់កិរិយាភាព្យាក ដូច **សីហំ ទិស្វា ភយំ ឧបជ្ជតិ** "ការខ្លាចកើតឡើង ព្រោះឃើញ នូវរាជសីហ៍" ។

២៧. នាមនាមដែលជាឯកវចនៈច្រើនសព្ទ បើមានការរួមគ្នា ដូចបុរសស្ត្រីជាដើម ត្រូវប្រើ **ច**-សព្ទ កាន់កាប់សព្ទទាំងនោះ, គុណនាមក្តី កិរិយាក្តី របស់នាមនាមទាំងនោះ ប្រើជាពហុវចនៈដោយច្រើន ដូច **ទេសនាវសានេ កុមារោ ច កុមារិកា ច សោតាបន្នា**(១) **អហេសុំ** "ក្នុងកាលជាទីបប់នៃទេសនា កុមារផង កុមារីផង បានជាសោតា-

---

១ បទនេះជាឥត្ថីលិង្គ ពហុវចនៈ ព្រោះរៀងនៅជិតបទនាមជាឥត្ថីលិង្គ។

www.budinst.gov.kh www.elibraryofcambodia.org

បន្ទបុគ្គលហើយ» (អហេសុំ កុំសរសេរក៏បាន) ។

២៨–បើគុណនាម (វិកតិកត្តា) ជាប់ជាមួយនឹងកិរិយាថា «មាន, កើត, ជា» ច្រើនបទ, ត្រូវរៀងទុកនៅមុខកិរិយានោះតែបទមួយ ក្រៅពីនោះរៀងទុកក្រោយកិរិយា ដូច **តេន ខោ បន សមយេន វេសាលី សុភិក្ខា ហោតិ សុសស្សា សុលភបិណ្ឌា** "ក៏ក្នុងសម័យនោះឯង ក្រុងវេសាលី ជាក្រុងមានបាយ (គឺបុគ្គលរកបាន) ដោយងាយ មានសន្ទូងល្អ មានដុំបាយរកបានដោយងាយ» ។

២៩–គុណនាម ឬកិរិយារបស់នាម ដែលដឹងគ្នាបានដោយងាយ, នឹងសរសេរទុកតែគុណនាម ឬកិរិយាតែប៉ុណ្ណោះមិនបាច់សរសេរនាមផងក៏បាន ដូច **បុព្វេ ខោ កុមារ មនុស្សា ទីឃាយុកា** "ម្នាលរាជកុមារ មនុស្សទ. ក្នុងកាលពីដើម ជាអ្នកមានអាយុវែង» (នេះមិនសរសេរកិរិ. យា គឺ ហោន្តិ) ។ **សិស្សា អាចរិយំ ឧបសង្កមិត្វា**

www.budinst.gov.kh www.elibraryofcambodia.org

„ឥមំ បណ្ណំ វាចេហីតិ វុត្តេ, តំ វិវរិត្វា វាចេសិ
„សិស្សចូលទៅជិតហើយ នូវអាចារ្យ (នាកាលពាក្យ)ថា „(ឯង) ចូរអាន នូវសំបុត្រនេះ" (គឺអាចារ្យ) និយាយហើយ, បើក អាននូវសំបុត្រនោះ" (នេះមិនសរសេរតាមគី វចនេ អាចរិយេន) ។

៣០—កិរិយាអាខ្យាត ក្នុងផ្លូវនិទាន ប្រើតែ ២ វិភត្តិ គឺ វត្តមានា ១ អជ្ជត្តនី ១ តែប្រើអជ្ជត្តនីច្រើនជាង ដូច **តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ** „ក្នុងសម័យនោះ ព្រះមានព្រះភាគជាព្រះពុទ្ធ ស្តេចគង់នៅ លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ" ។ **អថខោ ភគវា ភិក្ខូ អាមន្តេសិ** „លំដាប់នោះ ឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅ នូវភិក្ខុ." ។

៣១—គុណនាមក្តី នាមនាមប្រើជាគុណនាមក្តី បើចូលនឹងកិរិយាថា „មាន, កើត, ជា" ដែលប្រកបដោយតុំ-បច្ច័យ ត្រូវប្រើបឋមាវិភត្តិខ្លះ តតិយាវិភត្តិខ្លះ ដូច **នាយំ**

ឃាតោ ហោតុំ អរហតិ „អ្នកនេះ មិនគួរ ជាមនុស្សឃាតកទេ", **បមត្តេន គមិតុំ ន វដ្ដតិ** „(បុគ្គលនេះ) មិនគួរ ជាមនុស្សប្រមាទទេ" ។

៣២–ការគន្លិតចូលសមាសនឹងសព្ទដទៃ បង់លុបបច្ច័យចេញក៏បាន ដូច **សត្ថុ និសិន្នត្ថាយ មជ្ឈេ អាសនំ បញ្ញាបេសិ** "(គេ) ក្រាលហើយ នូវអាសនៈក្នុងទីកណ្ដាល ដើម្បីប្រយោជន៍ ដល់ការៈ នៃព្រះសាស្ដាជាព្រះអង្គគង់ហើយ" (នេះលុប ត្ត-បច្ច័យ) ។

៣៣–ពាក្យនិយាយដោយសេចក្ដីគោរព ដែលគួរប្រើមជ្ឈិមបុរិសៈ, នឹងប្រើបឋមបុរិសៈ ឯកវចនៈវិញក៏បាន ដូច **សាធុ មេ ភន្តេ សង្ខិត្តេន ធម្មំ ទេសេតុ** „បពិត្រព្រះអង្គដ៏ចំរើន (សូមព្រះមានព្រះភាគ) ទ្រង់សំដែងនូវធម៌ ដល់ខ្ញុំព្រះអង្គ ដោយបំប្រួញ" ។

៣៤–បើក្នុងប្រយោគមួយ មាននាមនាមច្រើនបទ តែ

ផ្សេងលិង្គគ្នា, បើបទវិសេសនៈរៀងនៅជិតបទនាមនាមដែល ជាលិង្គណា ត្រូវប្រកបឲ្យជាលិង្គ នៃនាមនាមនោះដូច **គេសុ ឯកេកស្ស ឯកេកា សលាកយាគុ សលាកភត្តំ បក្ខិ-កភត្តំ សង្ឃភត្តំ ឧបោសថិកភត្តំ អាគន្តុកភត្តំ វស្សាវាសិកំ អហោសិ** «បបរគឺបុគ្គលគប្បីឲ្យដោយស្លាក, បាយគឺបុគ្គលគប្បីឲ្យ ដោយស្លាក, បាយគឺបុគ្គលគប្បីឲ្យក្នុងថ្ងៃបក្ខ, បាយគឺបុគ្គលគប្បីឲ្យដល់សង្ឃ, បាយគឺបុគ្គលគប្បីឲ្យក្នុងថ្ងៃជាទីរក្សាឧបោសថ, បាយគឺបុគ្គលគប្បីឲ្យដល់ភិក្ខុអ្នកជាអាគន្តុកៈ, សំពត់គឺបុគ្គលគប្បីឲ្យ ដល់ភិក្ខុអ្នកនៅចាំវស្សា មួយៗបានមានហើយ ផុំខុំបុត្រទាំងឡាយនោះដល់បុត្រម្នាក់ៗ» (នេះរៀងទុកនៅមុខនាមនាមជាឥត្ថីលិង្គ) ។ **មនុស្សលោកស្មឹ នា ហិ អបាយុប្បត្តិ នា សញ្ញា បមាទមូលការណេន** (**ហោតិ**) „ក៏ ការៈនៃបុគ្គលអ្នកមានចំណែកសាក្រក់ (មានគ្រោះសាក្រក់) ក្នុងមនុស្សឬ

www.budinst.gov.kh www.elibraryofcambodia.org

ឬការកើតឡើងក្នុងអបាយទាំងពួងមានសេចក្ដីប្រមាទជាមូលតែម្យ៉ាង» (នេះរៀងទុកនៅក្រោយនាមនាម ជាឥត្ថីលិង្គ) ។

វិធីរៀង ច, វា, បិ សមុច្ច័យ

៣៨_បទសមុច្ច័យក្ដី ពាក្យសមុច្ច័យក្ដី បើរៀងទុកឲ្យគ្រប់បទនាម ឬបទកិរិយា, ត្រូវរៀងទុកជាទីពីរ របស់បទនាម ឬបទកិរិយានោះៗ ដូច **តាត ខេត្តេ ច ឃរេ ច កិច្ចំ ត្វមេវ ករោសិ, តេន មយ្ហំ ចិត្តសុខំ នាម ន ហោតិ, អានេស្សាមិ តេ** «នែកូនប្រុស ឯងតែម្នាក់ឯង ធ្វើ ការងារ ក្នុងស្រែផង ក្នុងផ្ទះផង, ព្រោះហេតុនោះ ឈ្មោះថាសេចក្ដីស្រួលក្នុងចិត្ត នៃអញ មិនមានទេ (អញ) នឹងដណ្ដឹង (កូនគេ) មកឲ្យឯង» ។

៣៩_បើរៀងទុកតែមួយគត់ ត្រូវរៀងទុកជាទីពីរ របស់បទក្រោយ ឬពាក្យក្រោយ ដូច **គតិយមិទសេ បន ថេរោ តស្សា សមជ្ជនីសទ្ទំ សុត្វា, កាលច្ឆិ-**

ធម្មេហិ ច បរិជ្ជំ សរីរេកាសំ និស្វា, ទ្វារំ វិវរិត្វា "កោ ឯស សមណគីតិ បុច្ឆិ" ក៏ ក្នុងថ្ងៃទី ៣ ព្រះថេរៈ ឮ នូវសូរអំបោស នៃនាងលាជទេវធីតានោះផង ឃើញ នូវស្មើនៃសរីរៈ (របស់នាង) ដែលចូលទៅតាមចន្លោះនៃស្លឹកត្នោត(១)ទាំងឡាយផង ហើយបើក ទ្វារ ហើយសួរ ថា «អ្នកណា នុ៎ះ បោស» ។

៣៧—បើចំនាម មានគុណនាមផង ត្រូវរៀង **ច.វា, បិ** ទុកជាទីពីរ របស់គុណនាម នៃបទនាមនោះ ដូច **បញ្ច គេសញ្ញានិ, អដ្ឋ ច បានានិ** "កេសដ្ឋៈ១. ៥ ផង ទឹកបាន១. ៨ ផង" ។

វិធីប្រើកិរិយា

៣៧.បើកិរិយាជាប់គ្នាមកតាមលំដាប់, កិរិយាមុខ ត្រូវប្រើ ត្វា.បច្ច័យ ឯកិរិយាក្រោយ ត្រូវប្រើកិរិយាអាខ្យាត ដូច

១—ន័យខ្លះថា តាលច្ឆិទ្ទ ប្រែថា ប្រហោងនៃសោ។

www.budinst.gov.kh www.elibraryofcambodia.org

ឧបាសកោ អារាមំ គន្ត្វា ធម្មំ សុត្វា បដិនិវត្តិ “ឧបាសកទៅអារាម ហើយស្ដាប់ធម៌ រួចត្រឡប់មកវិញ” ។

៣៩–បើសំគាល់សេចក្ដីថា ធ្វើអំពើតាំងពីពីរយ៉ាងឡើងទៅក្ដី ធ្វើយ៉ាងណាមួយក្ដី ត្រូវប្រើកិរិយាស័ព្ទ គឺបើអាខ្យាតក៏អាខ្យាតដូចគ្នា បើកិតក:ក៏កិតក:ដូចគ្នា ដូច **ឧបាសកោ អារាមំ គន្ត្វា ទានញ្ច ទេតិ ធម្មញ្ច សុណាតិ** “ឧបាសកទៅអារាម ហើយឲ្យទានផង ស្ដាប់ធម៌ផង” ។ **ឧបាសកោអារាមំ គន្ត្វា ទានញ្ច ទត្វា ធម្មញ្ច សុត្វា បដិនិវត្តតិ** “ឧបាសកទៅអារាម ហើយឲ្យទានផង ស្ដាប់ធម៌ផង រួចត្រឡប់មកវិញ” ។ **ពាលោ រោទន្តោបិ បរិទេវន្តោបិ កាលកតំ ទដ្ឋុំ ន លភតិ** “បុគ្គលពាល កាលយំផង កាលខ្សឹកខ្សួលផង ក៏នៅតែមិនបាន ឃើញ (កូន) ដែលធ្វើមរណកាលទៅហើយឡើយ” ។

៤០–បើកិរិយាដែលធ្វើព្រមគ្នា គឺមានគោលសេចក្ដីថា

មួយគ្នា, កិរិយាក្នុង ត្រូវប្រើ អត្ត ឬ មាន-បច្ច័យ កិរិយាក្រៅ ត្រូវប្រើអាខ្យាត ឬ ក្តា បច្ច័យតាមគួរ ដូច **វាណិជោ ភណ្ឌំ វិក្កីណន្តោ**⁽¹⁾ **វិចរតិ** „ពាណិជ កំពុងត្រាច់ទៅលក់ទំនិញ” ឬ **វាណិជោ ភណ្ឌំ វិក្កីណន្តោ វិច-រិត្វា បដិនិវត្តិ** „ពាណិជ កាលត្រាច់ទៅ លក់ទំនិញ ហើយត្រឡប់មកវិញហើយ” ។

៤១— បើប្រើ សចេ ក្តី យ សព្ទ ត្រូវតែមានកិរិយា អាខ្យាត ឬកិរិយាកិតកៈប្រភេទ ត ឬ តព្វ-បច្ច័យ ជាដើមណាមួយ មកសូរគាត់កំណាត់សេចក្តីដូច **សចេ បុញ្ញំ ន ករិស្សតិ, សុខំ ន លភិស្សតិ** „បើ (គេ) នឹងមិនធ្វើបុណ្យទេ. (គេ) នឹងមិនបាន សេចក្តីសុខ” **យត្ថ មេត្តា បវត្តតិ, តត្ថ សុខំ បវត្តតិ** „មេត្តា ប្រព្រឹត្តទៅ ក្នុងបុគ្គលណា, សេចក្តីសុខ ក៏ប្រព្រឹត្តទៅ ក្នុងបុគ្គលនោះ”។

---

១ វិក្កីណន្តោ កិរិយាវិសេសនៈក្នុង វិចរតិ ។

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីបែបនេះ បើប្រាជ្ញានឹងធ្វើជាប្រយោគតែមួយវិញត្រូវកុំប្រើ សហេតុ យ.សព្ទ **បុញ្ញំ អករោន្តិ សុខំ ន លភិស្សតិ** „(ស្រី) កាលបើមិនធ្វើបុណ្យទេ នឹងមិនបាន សេចក្ដីសុខឡើយ" , **មេត្តាយ បវត្តាយ**, **សុខំ បវត្តតិ** " កាលបើមេត្តា ប្រព្រឹត្តទៅ, សេចក្ដីសុខទើបប្រព្រឹត្តទៅដែរ" ។

២២– សព្ទបាលីធៀបសព្ទសំស្ក្រឹត

សព្ទទាំងឡាយ ក្នុងភាសាបាលី និងក្នុងភាសាសំស្ក្រឹត តាមដែលបានសង្កេតឃើញថា អ្នកប្រាជ្ញបាលីរចនាឡើងអនុវត្តន៍ទៅតាមវិធីភាសាសំស្ក្រឹត ទើបភាសាទាំង ២ នេះស្រលិះបេះបិទនឹងគ្នា ប្រៀបដូចមនុស្សយើងដែលជាបងប្អូនជាប់លោហិតនឹងគ្នា ។ សូមអ្នកសិក្សាថ្មីមើលឧទាហរណ៍ដែលខ្ញុំលើកមកធៀបគ្នា ទុកជាបែបដោយសង្ខេប ៗ ដូច

www.budinst.gov.kh www.elibraryofcambodia.org

មានតទៅនេះ តែសូមមើលដោយគិតសង្កេត ប្រើគំនិតយ៉ាងខ្លាំង ថែមទាំងការតាមរកជួយពន្យល់ផងទៀត ទើបនឹងភ្លឺច្បាស់ទៅបាន ព្រោះឧទាហរណ៍នោះ ដែលជាប់ដោយបទសន្ធិទាំងមានអក្ខរៈប្រែប្រួលទៅផ្សេងៗ ខ្ញុំមិនបានកាត់បទ តែញែកដាច់ស្រឡះចេញពីគ្នាទេដោយឃើញថា បើធ្វើដូច្នោះ វិធីនេះនឹងលាតវែងពេកទើបបន្សល់ទុក ដើម្បីឲ្យអ្នកសិក្សាថ្មីហាត់ប្រើគំ-និតផងចុះ ។

ការយល់ក្នុងសព្ទបាលី និង សព្ទសំស្ក្រឹត ដែលខ្ញុំលើកមកជៀបគ្នានេះ ជាប្រយោជន៍ឲ្យស្គាល់បទសន្ធិ ដែលជាហេតុឲ្យភ្លឺក្នុងវិធីប្រែបាលីមកជាខ្មែរ បានមួយចំណែកដែរ ។

១-សំស្ក្រឹតជា ត-ការន្ត

	ក្នុងសំស្ក្រឹត	ក្នុងបាលី
ឧបសគ្គ	ឧត៑, សត៑	ឧ, ស
សព្វនាមនប៉ុ-	យត៑.តត៑.ឯតត៑	យំ. តំ, ឯតំ
សព្ទនិបាត	កិញ្ចិត៑, យាវត៑,តាវត៑	កិញ្ចិ, យាវ, តាវ

www.budinst.gov.kh www.elibraryofcambodia.org

សព្ទទាំងនេះ តាមវិធីក្នុងសំស្ក្រឹតថា៖ កាលបើមានស្រៈនៅខាងចុង ត្រូវផ្លាស់ ត ទីបំផុតសព្ទនោះជា ទ ។ ក្នុងទីដូច្នេះខាងភាសាបាលី លោកឲ្យចុះ ទ-អាគម ឬផ្លាស់និគ្គហិតជា ទ ដូចឧទាហរណ៍ថា **ឧទបាទិ ឧទាហរណំ, ឧទិក្ខតិ, សទត្ថោ, យទិទំ, តទេវ, ឯតទហោសិ, កិញ្ចិទេវ, យាវទេវ, តាវទេវ**(១) ជាដើម ។

បើមានព្យញ្ជនៈនៅខាងចុង, តាមវិធីសំស្ក្រឹតថា៖ បើព្យញ្ជនៈខាងចុងនោះរឹង (អឃោសៈ) ត្រូវទុក ត-ការខ្លួននោះឲ្យគង់រូបនៅជា ត ដដែល ដូច **ឧត្បាទះ, ឧត្សាហះ, សត្ការះ, សត្បុរុសះ**(២) ។ បើព្យញ្ជនៈខាងចុងនោះទន់ (ឃោសៈ) ត្រូវផ្លាស់ ត ការខ្លួននោះជា ទ ដូច **ឧទ្គតះ, ឧទ្ឃោសះ, ឧទ្ធមិះ, សទ្ធម៌ះ, សទ្ភាវះ** ។ បើ

---

១ កាត់បទតាមបាលី: ឧ+អបាទិ, ឧ+អាហរណំ, ឧ+ឥក្ខតិ, ។ល។

២ អក្សរត្ប ក្នុងរោងពុម្ពគ្មាន យើងបានយកអក្សរស ប្រើជំនួស

www.budinst.gov.kh www.elibraryofcambodia.org

ព្យញ្ជនៈខាងចុងនោះជា ន ឬ ម ត្រូវផ្លាស់ ត-ការន្តនោះជា ន ដូច **ឧន្នតមិ, ឧន្នាតិ**ៈ ជាដើម ។

ក្នុងទីដូច្នេះ ខាងភាសាបាលី លោកឲ្យតម្រួតព្យញ្ជនៈដែម ក្នុងទីដែលគួរតម្រួត ដូច **ឧប្បាទោ, ឧស្សាហោ, សក្ការោ, សប្បុរិសោ, ឧគ្គតោ, ឧន្នតំ, ឧម្មគ្គោ** ។ បើក្នុងទីណា មិនអាចតម្រួតព្យញ្ជនៈដែមមកបានទេ លោកឲ្យទីឃៈ ដូច **សម្មូហតិ, សារាគោ** ជាដើម ។

២– នាមសព្ទ ក្នុងសំស្ក្រឹតជា ស-ការន្ត
ក្នុងបាលីជា អ-ការន្ត

ស-ការន្តក្នុងទីនេះ លោកសំដៅយកមនោគណសព្ទគឺ **មនសិ, អយសិ, ចេតសិ, តបសិ, តមសិ, តេជសិ, បយសិ, យសសិ, វចសិ, វយសិ, ឧរសិ** ។

វិធីសំស្ក្រឹត, ស-ការន្តនេះ បើមានស្រះនៅខាងមុខ ត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ទុកជា ស ដដែល ដូច **មនសា, មនសិ, តាបសះ, ចេតសិកាះ** ។ បើមានព្យញ្ជនៈរឹង (អឃោសៈ) នៅខាងចុង ត្រូវទុក ស-ការន្តនោះ ឲ្យគង់រូបក៏បាន ឬ ផ្លាស់ជា វិសគ្គៈ (ះ) ក៏បាន ដូច **នមស្ការះ, នមះការះ**។ បើមានព្យញ្ជនៈទន់ (ឃោសៈ) នៅខាងចុងត្រូវផ្លាស់ ស-ការន្ត ព្រមទាំងស្រះ អ ទីបំផុតសព្ទនោះជា ឱ ដូច **អយោមយះ, មនោហរះ, សិរោរុហះ** ជាដើម ។

វិធីបាលី, បើមានស្រះ ដែលសម្រេចមកពីវិភត្តិ ឬ បច្ច័យនៅខាងចុង ត្រូវចុះ ស-កាគម ដូច **មនសា, មនសិ, តាបសោ, ចេតសិកា** ។ តែបើស្រះខាងចុងនោះ ជា បុព្វបទ គឺជាឧបសគ្គប្រើនាំមុខធាតុទេ លោកបែរជាហាមមិនឲ្យចុះ ស-កាគម ដូច **មនាយតនំ** ។

បើមានព្យញ្ជនៈទន់ក្ដី រឹងក្ដី (ឃោសៈ, អឃោសៈ) នៅខាងចុង ត្រូវផ្លាស់ស្រះ អ ទីបំផុតនៃមនោគណសព្ទជា ឱ

www.budinst.gov.kh www.elibraryofcambodia.org

ដូច **តបោធនំ, យសោគោតសមប្បិតោ, អយោគុឡំ, មនោមយា, តេជោគសិណំ, ចេតោបណិធិ, មនោសេដ្ឋា** ជាដើម ។

៣- ឧបសគ្គ ក្នុងសំស្រ្កឹតត្រង់ ទុស និស ក្នុងបាលីជា ទុ, និ

វិធីសំស្រ្កឹត, បើមានស្រះនៅខាងចុង ត្រូវផ្លាស់ ស ទីបំផុតនៃសព្ទនោះជា រ ដូច **ទុរាគ្ម:, ទុរត្តម, និរុបទ្រវ, និរាសង្ក** ។ បើមានព្យញ្ជនៈរឹង (អឃោសៈ) នៅខាងចុង ត្រូវទុក ស នោះ ឲ្យគង់រូបក៏បាន ផ្លាស់ជាវិសគ៌ៈ (ះ) ក៏បាន ដូច **ទុស្សហ:, ទុស្ចរិតម, ទុះប្រថ្ង:, និះកន្ទ:, និស្ចល:** ។ បើមានព្យញ្ជនៈទន់ (ឃោសៈ) នៅខាងចុង ត្រូវផ្លាស់ ស នោះជា រ ដូច **ទុគ៌ត:, ទុពិល:, និត៌យ:, និរ្វិត:** ។

វិធីបាលី, ទុ, និ បើមានស្រះនៅខាងចុង ឲ្យចុះ រ.

www.budinst.gov.kh www.elibraryofcambodia.org

តាម ដូច **ទុរក្ខាតោ**, **ទុរុត្តំ**, **និរុបទ្ទវោ**, **និរាសង្កោ** ។ បើមានព្យញ្ជនៈនៅខាងចុង អំណាច **ទុ**,**និ** ឲ្យគម្រួតព្យញ្ជនៈថែម លើព្យញ្ជនៈខាងចុងនោះ តាមគួរដល់ការប្រកប ដូច **ទុស្សហោ**, **ទុច្ចរិតំ**, **ទុព្បញ្ញោ**, **និក្កង្ខោ**, **និប្ផលោ**, **ទុគ្គតោ**, **ទុព្ពលោ**, **និព្ភយោ**, **និម្មិតោ** ។ បើកង់ទីណា គម្រួតព្យញ្ជនៈមិនបានទេ ពន្លាកឲ្យទីឃៈ ដូច **ទូហរំ**, **នីវរណំ**, **នីហារោ** ជាដើម ។

៤_ សព្ទក្នុងសំស្ក្រឹត ផ្ញើជើង ក្នុងបាលី គម្រួត

វិធីសំស្ក្រឹត.សព្ទជាព្យញ្ជនៈផ្ញើជើង ត្រូវទុកឲ្យនៅជាព្យញ្ជនៈផ្ញើជើងតាមរូបដើម ដូច **អនុប្រធានម៌**, **អនុគ្រហៈ**, **ប្រតិគ្រាហកៈ**, **ឧបស្តម្ភៈ**, **ឧបក្រមៈ**, **ឧបក្លេសៈ** **វិជ្ញាណម៌**, **វិស្តម្ភណម៌**, **សុខតិៈ**, **អក្សាន្តិ**,

www.budinst.gov.kh www.elibraryofcambodia.org

អញ្ញាណាមិ, ប្រមុខៈ, ស្កន្ធៈ, ហស្តិនិ, ស្ថានមិ ។

វិធីបាលី, សព្វណា ក្នុងសំស្រ្កឹតជាអក្សរផ្ទើដើម, សព្វនោះ ក្នុងភាសាបាលីលោកតម្រូត តាមគួរដល់ការប្រកប ដូច

អនុប្បជានំ, អនុគ្គហោ, បដិគ្គាហកោ, ឧបគ្គ-ហ្វោ, ឧបក្កមោ, ឧបក្កិលេសោ, ចិញ្ញាណំ, ចិក្ខម្ពណំ, សុព្វគោ. អក្ខន្តិ, អញ្ញាណំ ។

វិធីក្នុងបទសមាសវិញ ក៏មានន័យដូចគ្នានឹងវិធីទាំងពីរខាងលើនេះដែរ ឧទាហរណ៍ គឺទៅនេះ ៖–

សំស្រ្កឹត ៖ **ពុទ្ធ-ប្រមុខៈ, រូប-ស្កន្ធៈ, ហស្តិ-ស្កន្ធៈ ចេតិ- ស្ថានមិ ។**

បាលី ៖ **ពុទ្ធប្បមុខោ, រូបក្ខន្ធោ, ហត្ថិក្ខន្ធោ, ចេតិដ្ឋានំ ។**

៥– ឧបសគ្គ ក្នុងសំស្រ្កឹត ប្រតិ
ក្នុងបាលី បតិ

www.budinst.gov.kh www.elibraryofcambodia.org

វិធីបាលី, *បតិ.ឧបសគ្គ ពោះទៅជា បដិ ឬ បច្ច ក៏ដោយ ចុះ កាលបើប្រើជាបទមុខ នៃកិរិយា ឬនាមសព្ទ ជួនកាល លោកមិនតម្រួតព្យញ្ជនៈថែម ក៏មាន ដូចជា* **សុបដិបន្នោ, សំខារបច្ចយា, អបច្ចក្ខាយ** ។ *ជួនកាលលោកតម្រួត ក៏មាន ដូច* **អប្បដិរូបោ, សប្បដិឃោ** ។ *តាមដែលពោលមកនេះ ឃើញថាលោកបណ្ឌិតកំណត់ប្រើទាំងពីរន័យ ។ តែអធុនិកបណ្ឌិត បានចុះមតិជាឯកច្ឆន្ទថា ត្រូវតែតម្រួត ដើម្បីធ្វើឲ្យមានរបៀបត្រូវគ្នាជាបែបមួយ ឧ.* **ហេតុប្បច្ចយោ, អារម្មណប្បច្ចយោ** *លើកលែងតែនាមសព្ទខាងមុខជាទីឃៈពេញ ទើបមិនត្រូវតម្រួត ដូច* **អវិជ្ជាបច្ចយា, តណ្ហាបច្ចយា, វេទនាបច្ចយា** *ជាដើម* ។

៦-សព្ទខាងចុងមានអក្សរ ឆ នៅខាងដើម

វិធីបាលី, *សព្ទពីរសព្ទ ដែលរួមចូលគ្នាជាបទសមាសសព្ទក្រោយមានអក្សរ* **ឆ** *នៅខាងដើម សព្ទមុខតាមតែអក្សរអ្វីក៏*

www.budinst.gov.kh www.elibraryofcambodia.org

បាន, ក្នុងទីដូច្នេះ ត្រូវតម្រួតអក្សរ ច ថែម ដូច **សេតច្ឆត្តំ, សុច្ឆវិ, កុក្កុដច្ឆាបកោ, រុក្ខច្ឆាយា, បរិច្ឆេទោ, បទច្ឆេទោ** ជាដើម ។

វិធីក្នុងសំស្ក្រឹត ក៏មានន័យដូចគ្នា នឹងវិធីបាលីនេះដែរ ។

៣- សព្ទសំស្ក្រឹតមានអក្សរ ឫ, រេផៈ, ផ្ញើជើង ក្នុងភាសាបាលីគ្មានប្រើទេ

វិធីបាលី, សព្ទណា ក្នុងសំស្ក្រឹតមានអក្សរ ឫ, រេផៈ (រ.បាទ), ផ្ញើជើង ហើយមានទាំងអក្សរពួកទន្តជៈផង ដូច **ឫថវី, វ្ឫធះ, អធ៌ះ, ប្រថមះ, គ្រន្ថះ សំស្ថានម៑, ស្ថានម៑** ជាដើម សព្ទនោះ ក្នុងភាសាបាលី (គ្មានប្រើអក្សរ ឫ. រេផៈ ផ្ញើជើងទេ) លោកផ្លាស់អក្សរទន្តជៈ មកជាមុទ្ធជៈ វិញ ដូចជា **បឋវី, វុឌ្ឍោ, អឌ្ឍោ, បឋមោ, គណ្ឋោ, សណ្ឋានំ, ឋានំ** ។

តែចំពោះ **អដ្ឋិ** សព្ទ, ក្នុងភាសាបាលី ជួនកាលលោក

www.budinst.gov.kh www.elibraryofcambodia.org

ផ្លាស់ជាមុទ្ធជៈ ក៏មាន ដូច **អឌ្ឍកថា, បីឡ្យនឌ្ឍេន,** **អឌ្ឍិកត្វា, បឌ្ឍនា** ។ ចួនកាល ប្រើជាអក្សរទន្តជៈ តាមសំស្ក្រឹតក៏មាន ដូច **អន្ថោ, អត្ថំ** ។ ចំពោះសព្ទសំស្ក្រឹតពីរសព្ទ គឺ **ឧធិមិ មូធិមិ,** ក្នុងភាសាបាលី នៅប្រើជាអក្សរទន្តជៈ តាមសំស្ក្រឹត ជា **ឧទ្ធំ, មុទ្ធំ** ។

គ បច្ច័យក្នុងសំស្ក្រឹត ដែលចុះមុខធាតុមានអក្សរ ឬ ជាទីបំផុត ដូច **ក្យ, គ្យ, ហ្យ, ឃ្យ** ជាដើម ឧ. **ទុះក្យគមិ, រាជក្យតះ, អចហ្យគមិ, ឧធ្យគមិ** ។

ក្នុងភាសាបាលី ចួនកាល លោកផ្លាស់ គ.បច្ច័យជា ជ ក៏មាន **ទុក្ខជំ, រាជគជោ, អចហជំ, ឧទ្ធជំ, ទិចជោ** ។ ចួនកាល លោកទុកជា គ ដដែល តាមសំស្ក្រឹត ក៏មាន ដូច ជា **សុគតំ, អមតំ, សំខុគោ** ។

តែបើពោលដោយអំណាចធាតុវិញ, គ បច្ច័យនេះ ក្នុងវិធីបាលីប្រាប់ថា ៖ បើចុះនៅមុខធាតុ មាន រ ឬ ន ជាទី

www.budinst.gov.kh www.elibraryofcambodia.org

ចំណុច ទើបអាចឲ្យផ្លាស់ ត.បច្ច័យជា ជ បាន ដូច **ទុក្ខជំ**, **ហាជោ** ជាដើម ។

៨. សព្ទក្នុងសំស្ក្រឹតជាអក្សរ ស្ត ក្នុងភាសាបាលីជាអក្សរ ថ (ឬ ឋ)

វិធីបាលី, *សព្ទក្នុងភាសាសំស្ក្រឹតជាអក្សរ ស្ត ដូច* **សាស្តា**, **សស្ត្រមិ**, **សាស្ត្រមិ**, **ហស្តះ**, **ទស្តុ**, **អស្តិ**, **ស្តម្ភះ**, **ស្តូបះ**, **ស្តុតិ** ។ *ក្នុងភាសាបាលី ប្រើជាអក្សរ ជនិត ទន្តជៈ (ថ) ជា* **សត្ថា**, **សត្ថំ**, **ហត្ថោ**, **ទត្ថុ**, **អត្ថិ**, **ថម្ភោ**, **ថូបោ**, **ថុតិ** ។

ចំពោះសព្ទ ក្នុងសំស្ក្រឹត គឺ **អស្តង្គតះ**, **ប្រតិសំស្ការះ**, **ទិស្តារះ** *ក្នុងភាសាបាលី លោកប្រើអក្សរ ជនិត មុទ្ធជៈ (ឋ) ជា* **អដ្ឋង្គតោ**, **បដិសណ្ឋារោ**, **ទិដ្ឋារោ** ។

៩. អក្សរ ន ផ្លាស់ជា ណ

វិធីសំស្ក្រឹត, *កាលបើធាតុមានអក្សរ ឫ, រ, ស ហើយ*

www.budinst.gov.kh www.elibraryofcambodia.org

មានទាំងអក្សរ ន ដែលជាធាតុក្តី ដែលផ្លាស់មកអំពីកិត្តិ ឬ បច្ច័យក្តី, អក្សរ ន នោះ ត្រូវផ្លាស់ជា **ណ** វិញ ដូចជា **ប្រណាមៈ, បរិណាយកៈ, ប្រមាណាមិ, លក្ស-ណាមិ, ធុណាមិ, ថុណាមិ** ជាដើម ។

វិធីបាលី, ធាតុមានអក្សរ រ, (ហ) ជាទីបំផុត ត្រូវផ្លាស់ យុ បច្ច័យ ជា អន រួចផ្លាស់ ន នៃ អន នោះ ជា **ណ** ទៀត ដូច **ករណំ, ហរណំ, គហណំ, មរណំ** ជាដើម ។ តែចំពោះបទទាំងនេះ គឺ **បណាមោ, បមាណំ, លក្ខណំ, ឥណំ, តិណំ, តាណំ, ខណោ** ជាដើម ដែលផ្លាស់ ន នៃ អន ជា **ណ** ដែរ គឺលោកផ្លាស់អនុវត្តន៍ទៅតាមវិធីសំស្ក្រឹត ។

១០- សព្ទក្នុងសំស្ក្រឹតប្រកប ឥនិ - បច្ច័យ ក្នុងបាលីប្រកប ណ្យ, ណី - បច្ច័យ

សព្ទសំស្ក្រឹតប្រកប ឥនិ-បច្ច័យ, ដែលជាតទ្ធិត ដូច

www.budinst.gov.kh www.elibraryofcambodia.org

សេដ្ឋិនី, សិល្បិនី, ហស្តិនី, ដែលជាកិតកៈ ដូច យោធិនី, យោគិនី, ធេធិនី ។ ខាងភាសាបាលី ក្នុងតទ្ធិត ប្រកបឦ-បច្ច័យ ដូចជា **សេដ្ឋី, សិប្បី ហត្ថី,** ក្នុងកិតកៈ ប្រកប ណី·បច្ច័យ ដូចជា **យោធី, ហោគី. ធេធី** ។

សព្ទពួកនេះ បើរួមចូលជាបទសមាស ជាមួយនឹងសព្ទដទៃ ហើយតាំងនៅខាងមុខនៃសព្ទដទៃនោះ, ក្នុងសំស្រ្កឹត ត្រូវលុប ន ទុកតែ ឥ, ក្នុងភាសាបាលី ត្រូវរស្សៈ ឦ ជា ឥ តួយ៉ាង ដូច **សេដ្ឋិបុត្តោ; សិប្បកម្មំ, ហត្ថិឧន្តោ, យោធិ-ជេដ្ឋកោ· យោគិគណោ** ។ តែវិធីនេះមិនបានប្រើខ្លួទៅ ដល់សព្ទជា ឦ ការន្ត ឥត្ថីលិង្គទេ, ព្រោះនាមសព្ទជា អា, ឦ ឩ,-ការន្ត ឥត្ថីលិង្គ កាលរួមចូលជាបទសមាស ត្រូវទុកនៅជា អា, ឦ, ឩ ដដែល ដូច **បញ្ញាបាសាទោ, សទ្ធាធនំ, ឥត្ថីរតនំ, នទីតីរំ, វធូធនំ, សរព្វម្ពសិកា** ជាដើម ។

ចប់ ដោយសង្ខេប

www.budinst.gov.kh www.elibraryofcambodia.org

សុភាសិត

ស្មោចិញ្ចៀន វៀនជុះផុង ក្នុងវារី
នៅសល់ពី ទីទឹកស្មាន បានពីរធ្នាប់
ខ្យល់បក់បោក ខោកឥតស្រាក ងាករេជាប់
នៅមិនងាប់ ជាប់រហូត លូតឡើងបាន ។
ជនបណ្ឌិត ពិតពីរោះ ឈ្មោះឥតអាក់
មានឧបសគ្គ ស្អាក់រារាំង ទាំងប៉ុន្មាន
ប្រឹងរុករាន ឈានឥតខ្សោយ ដោយក្លាហាន
ត្រាតែប្រាណ បានរួចទុក្ខ សុខដូចស្មោ ។

ព្រះសោត - ឆាខ

www.budinst.gov.kh www.elibraryofcambodia.org